## អនុសាសន៍រួម លេខ ១

(សម័យប្រជុំលើកទី៥ ១៩៨៦)

របាយការណ៍ដំបូងបានស្នើឡើងតាមមាត្រា ទី១៨ នៃអនុសញ្ញា ដែលគួរតែមាននិយាយពីស្ថានភាពរហូតដល់ថ្ងៃស្នើឡើង ។ បន្ទាប់មក របាយការណ៍គួរតែស្នើឡើងរៀងរាល់បួនឆ្នាំ ក្រោយពី របាយការណ៍ដំបូង ។ របាយការណ៍ដំបូងអាចជំពាក់ និង គួរតែមានបញ្ជាក់ពីឧបសគ្គប្រឈមមុខ ក្នុងការអនុវត្ត អនុសញ្ញាឱ្យពេញលេញ និង វិធានការណ៍អនុមតិដើម្បីដោះស្រាយឧបសគ្គទាំងអស់ ។

## អនុសាសន៍រួម លេខ ២

(សម័យប្រជុំលើកទី៥ ១៩៨៧)

គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ចោលការរើសអើងប្រឆាំងនារីភេទ

ការបារម្ភក្នុងអារម្មណ៍ របស់គណកម្មាធិការដែលបានជួបនឹងការលំបាកលើការងារពិព្រោះថា របាយការណ៍ដំបូងរបស់រដ្ឋភាគីមួយចំនួន នៅក្រោមមាត្រា ១៨នៃ អនុសញ្ញា មិនបានឆ្លុះបញ្ចាំងគ្រប់គ្រាន់លើព័ត៌មានដែលរដ្ឋភាគីអាចធ្វើបានដោយយោងតាមការណែនាំ ។

សូមផ្តល់អនុសាសន៍ថា:

(ក) រដ្ឋភាគី ក្នុងការរៀបចំ របាយការណ៍ ក្រោមមាត្រា ១៨ នៃអនុសញ្ញា គួរតែធ្វើតាមការណែនាំទូទៅ ដែលបានអនុមតិ នៅខែសីហា ១៩៨៣ (CEDAW/C/7) ១ តាមទម្រង់ ខ្លឹមសារ និងចុះថ្ងៃខែរបាយការណ៍

(ខ) រដ្ឋភាគីគួរតែធ្វើតាមអនុសាសន៍រួមដែលអនុមតិក្នុងឆ្នាំ១៩៨៦ ដែលមានចែង: ២

"របាយការណ៍ដំបូងបានស្នើឡើងតាមមាត្រា ទី១៨ នៃអនុសញ្ញា ដែលគួរតែមាននិយាយពីស្ថានភាពរហូតដល់ថ្ងៃស្នើឡើង ។ បន្ទាប់មក របាយការណ៍គួរតែស្នើឡើងរៀងរាល់បួនឆ្នាំ ក្រោយពី របាយការណ៍ដំបូង ។ របាយការណ៍ដំបូងអាចជំពាក់ និង គួរតែមានបញ្ជាក់ពីឧបសគ្គប្រឈមមុខ ក្នុងការអនុវត្ត អនុសញ្ញាឱ្យពេញលេញ និង វិធានការណ៍អនុមតិដើម្បីដោះស្រាយឧបសគ្គទាំងអស់". ៣

(គ) ព័ត៌មានបន្ថែម លើរបាយការន៍រដ្ឋភាគី គួរតែបានបញ្ជូនទៅ អគ្គលេខាធិការ បីខែមុនយ៉ាងតិចមុនថ្ងៃកំណត់ការជជែករបាយការណ៍ ។

# អនុសាសន៍រួម លេខ ៣

(សម័យប្រជុំលើកទី៦ ១៩៨៧)

គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ចោលការរើសអើងប្រឆាំងនារីភេទ
សូមធ្វើការកត់សម្គាល់ដែរថា គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ចោលការរើសអើងប្រឆាំងនារីភេទ បាន ពិចារណាលើរបាយការណ៍ ៣៤ ដែលទទួលបានពីរដ្ឋភាគី តាំង ពីឆ្នាំ ១៩៨៣ ។

ការកត់សម្គាល់ជាពិសេស ថ្វីបើរបាយការណ៍បានមកពីរដ្ឋភាគីជាមួយ នឹងកម្រិតអភិវឌ្ឍន៍ផ្សេងគ្នាក៏ដោយ គេបាន បង្ហាញលក្ខណៈពិសេសទៅតាមកម្រិត ដែលមានក្នុងផ្នត់គំនិតទស្សនៈរបស់ស្ត្រី ក្នុងកត្តាសេដ្ឋកិច្ច សង្គមកិច្ច ដែលចងចាំនូវការរើសអើងដោយ ផ្អែកលើភេទ និងរារាំង ការអនុវត្តមាត្រា ៥នៃអនុសញ្ញា ។

សូមជម្រុញដល់គ្រប់រដ្ឋភាគីទាំងអស់ សុំទទួលយកការអប់រំ និង កម្មវិធីព័ត៌មានសាធារណៈ ជាមួយនឹងការជួយ លុបបំបាត់បុរេនិច្ឆ័យ នឹង ការអនុវត្តបច្ចុប្បន្នដែលរារាំង កាតអនុវត្តពេញលេញលើគោលការណ៍សមភាពស្ត្រី ក្នុងសង្គម

# អនុសាសន៍រួម លេខ ៤

(សម័យប្រជុំលើកទី៦ ១៩៨៧)

គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ចោលការរើសអើងប្រឆាំងនារីភេទ
សូមពិនិត្យលើរបាយការណ៍ដែលបានមកពីរដ្ឋភាគី ក្នុងវគ្គនេះ ។
សូមសម្តែងកង្វល់ដែលទាក់ទងនឹងសារៈប្រយោជន៍ ដែលបានកើតឡើងពីការរក្សាទុកដែលជាវិធីដែលនឹងចុះ សម្រុង ទៅនឹងគោលបំណង និង គោលដៅរបស់អនុសញ្ញា ។

ស្វាគមន៍ចំពោះការធ្វើសេចក្តីសម្រេចរបស់រដ្ឋភាគិ ដែលពិចារណា លើការបម្រុងទុក ទៅការប្រជុំលើកក្រោយនៅ ញូយ៉ក ឆ្នាំ ១៩៨៨ និង ដែលបញ្ចប់ការស្នើសុំ ដែលគ្រប់រដ្ឋភាគី បានពិចារនាសារឡើងវិញ លើការបម្រុងទុកជា មួយនឹងទស្សនៈដើម្បីការដកចេញរបស់គេ ។

# វិធានការពិសេសបណ្តោះអាសន្ន ០៤/០៣/៨៨

CEDAW **អនុសាសន៍រួម ៥** A/៤៣/៣៨

អនុសាសន៍រួមលេខ៥

វិធានការពិសេសបណ្តោះអាសន្ន

(សម័យប្រជុំលើកទី៦ ១៩៩៨)

គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ចោលការរើសអើងប្រឆាំងនារីភេទ

សូមធ្វើការកត់សំគាល់ចំពោះរបាយការណ៍ ការកត់សំគាល់នូវការណែនាំដំបូង និងការឆ្លើយតបដោយរដ្ឋភាគី ដែល បានលាតត្រដាងឱ្យឃើញថា ទទ្ទឹមនឹងមានការរីកចំរើនដែលសំរេចបានគួរឱ្យចាប់អារម្មណ៍ចំពោះការលុបបំបាត់ចោល ឬការកែតំរូវច្បាប់នៃការរើសអើង ក៏នៅមានតំរូវការសំរាប់ធ្វើការចាត់វិធានកការអនុវត្តឱ្យបានពេញលេញនូវអនុសញ្ញាដោយធ្វើការណែនាំវិធានការដើម្បីជំរុញភាពស្មើសិទ្ធិពិតប្រាកដ រវាងបុរស និងស្ត្រី ។

ដោយរំលឹកដល់មាត្រាទី៤ កថាខ័ណ្ឌ១ នៃអនុសញ្ញា

សូមផ្តល់អនុសាសន៍ថា រដ្ឋភាគីត្រូវប្រើនូវវិធានការពិសេសបណ្តោះអាសន្នច្រើនថែមទៀត ដូចជាការធ្វើសកម្មភាព វិជ្ជមាន ការប្រព្រឹត្តិដែលជាទីពេញចិត្ត ឬប្រព័ន្ធកូតាដើម្បីធ្វើការអភិវឌ្ឍន៍ដល់ការធ្វើសមាហរណកម្មនារីភេទចូលទៅក្នុង វិស័យអប់រំ សេដ្ឋកិច្ច នយោបាយ និងការធ្វើការងារ ។

** មាននៅក្នុងឯកសារ A/43/38 ។

# អនុសាសន៍រួម ទី៦

(សម័យប្រជុំលើកទី៧ ១៩៨៨)

ប្រសិទ្ធិភាព នៃយន្តការជាតិ និង ការផ្សព្វផ្សាយ

គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ចោលការរើសអើងប្រឆាំងនារីភេទ

បានពិចារណាលើ របាយការណ៍រដ្ឋភាគី នៃអនុសញ្ញា

ស្តីពីការលុបបំបាត់ចោលរាល់ទម្រង់នៃការរើសអើងលើនារីភេទ កត់សម្គាល់ ចំពោះដំណោះស្រាយ

របស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ចុះ លេខ 42/60 ថ្ងៃទី ៣០ វិច្ឆិកា ១៩៨៧ ។

ផ្តល់អនុសាសន៍ ដល់រដ្ឋភាគី

១- រៀបចំ នឹង/ឬពង្រឹងប្រសិទ្ធិភាពយន្តការជាតិ ស្ថាប័ន និងនិតិវិធី ចំពោះគ្រប់កម្រិតរដ្ឋាភិបាល និង ធនធានគ្រប់គ្រាន់ ការប្តេជ្ញាចិត្ត និងអំណាច ដើម្បីៈ

(ក) ផ្តល់យោបល់លើ ឥទ្ធិពល ដល់ស្ត្រី នៅគ្រប់ គោលនយោបាយរដ្ឋ

(ខ) តាមដានពិនិត្យ ស្ថានភាពការយល់ដឹងរបស់ស្ត្រី

(គ) ជួយរៀបចំនូវគោលនយោបាយ ថ្មីៗ និង មាន ប្រសិទ្ធិភាពក្នុងការអនុវត្តយុទ្ធសាស្ត្រ និង វិធានការណ៍ ដើម្បីលុបបំបាត់ការរើសអើង ។

២- រើសជំហានដ៏សមស្រប ដើម្បីធានា ការផ្សព្វផ្សាយ អនុសញ្ញា របាយការណ៍រដ្ឋភាគី ក្រោមមាត្រា ១៨ និង របាយការណ៍របស់គណកម្មាធិការ តាមភាសា ដែលត្រូវនឹងរដ្ឋភាគី

៣- ស្វែងរកជំនួយពីអគ្គលេខាធិការ និង នាយកដ្ឋាន ព័ត៌មានសាធារណៈ ក្នុងការផ្តល់ការបកប្រែអនុសញ្ញា និង របាយការណ៍គណកម្មាធិការ

៤- ដាក់បញ្ចូលរបាយការណ៍ដំបូង និង សមយ័កាល ដើម្បីធ្វើសកម្មភាពតាមអនុសាសន៍ ។

# អនុសាសន៍រួម ទី៧

(សម័យប្រជុំលើកទី៧ ១៩៨៨)

ធនធាន

<u>គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងប្រឆាំងនារីភេទ</u>

<u>ដោយកត់សំគាល់ថា</u> សេចក្តីសម្រេចសមាជលេខ ៤០/១០៨ ជាពិសេស លេខ ៤២/៦០ កត្ថាខណ្ឌ័ទី ១៤ ដែលអញ្ជើញគណៈកម្មាធិការ និង រដ្ឋភាគីអោយពិចារណាអំពីសំណួរ ស្តីពីការរៀបចំកិច្ចប្រជុំរបស់គណៈកម្មាធិការនៅវីយែនណា នាពេលខាងមុខ

ដោយប្រកាន់ខ្ជាប់នូវសេចក្តីសំរេចលេខ ៤២/១០៥ និងពិសេសតាមកត្ថាខណ្ឌ័លេខ ១១ ដែលស្នើរអោយអគ្គលេខាធិការ ពង្រឹងកិច្ចសហប្រត្តិបត្តិការណ៏រវាងមជ្ឈមណ្ឌលសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ និងមជ្ឈមណ្ឌលអភិវឌ្ឍសង្គម និង កិច្ចការមនុស្សធម៌របស់លេខាធិការដ្ឋាន លើការអនុវត្តន៍សន្ធិសញ្ញាសិទ្ធិមនុស្ស និង ស្ថាប័នបំរើអោយអនុសញ្ញា

សូមផ្តល់អនុសាសន៍ទៅរដ្ឋភាគីៈ

១- ថា រដ្ឋភាគីបន្តរគាំទ្រសំណើរពង្រឹងកិច្ចសម្របសម្រួល រវាងមជ្ឈមណ្ឌលសិទ្ធិមនុស្សនៅសេណែវ និង មជ្ឈ មណ្ឌលអភិវឌ្ឍន៏សង្គម និងកិច្ចការមនុស្សធម៌នៅវីយែនណា ក្នុងការបំរើអោយគណៈកម្មាធិការ

២- ថារដ្ឋភាគី គាំទ្រសំណើរដែលថាគណៈកម្មាធិការ នឹងជួបប្រជុំនៅទីក្រុងញូយក និង វីយែនណា

៣- ថារដ្ឋភាគីចាត់ជំហានចាំបាច់ និង សមស្របដើម្បីធានាថាធមានធនធាននិង សេវាកម្មគ្រប់គ្រាន់ជូនដល់គណៈកម្មាធិការដើម្បីជួយដល់ដំណើរការរបស់គណៈកម្មាធិការតាមការតំរូវរបស់អនុសញ្ញានិង ជាពិសេសធានាថាមានបុគ្គលិកបំរើការពេញម៉ោងសំរាប់ជួយគណៈកម្មាធិការក្នុងការរៀបចំកិច្ចប្រជុំ និងជួយក្នុងពេលដំណើរការកិច្ចប្រជុំ ។

៤- ថារដ្ឋភាគីធានាថារបាយការណ៏ និងសំភារៈបន្ថែមនានា ត្រូវផ្ញើរជូនទៅលេខាធិការដ្ឋាន តាមពេលកំណត់ដែលនឹងត្រូវបកប្រែជាភាសាផ្លូវការរបស់អង្គការសហប្រជាជាតិអោយទាន់ពេលចែកចាយ និងគណៈកម្មាធិការត្រួតពិនិត្យ ។

# ការអនុវត្តន៍មាត្រានី៨របស់អនុសញ្ញា ០៧/០៣/៨៨

CEDAW **អនុសាសន៍រួមលេខ៨** A/៤៣/៣៨

យោបល់រួមលេខ៨

ការអនុវត្តន៏មាត្រា៨នៃអនុសញ្ញា

(សម័យប្រជុំលើកទី៧ ១៩៨៨)

## គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ចោលការរើសអើងប្រឆាំងនារីភេទ

ដោយពិចារណាលើ របាយការណ៍របស់រដ្ឋភាគីដែលបានដាក់យោងតាមមាត្រា១៨នៃអនុសញ្ញា។

សូមផ្តល់អនុសាសន៍ថា រដ្ឋភាគីត្រូវធ្វើការចាត់វិធានការដោយផ្ទាល់ថែមទៀតដែលយោងតាមមាត្រ៤នៃ អនុសញ្ញា ដើម្បីធានាដល់ការអនុវត្តន៏ឱ្យបានពេញលេញនូវមាត្រា៨នៃអនុសញ្ញានិងដើម្បីធានាចំពោះនារីភេទអំពីលក្ខខ័ណ្ឌស្មើភាពជា មួយបុរសនិងមិនមានប្រកាន់នូវឱកាសដើម្បីធ្វើជាតំណាងឱ្យរដ្ឋាភិបាលរបស់គេនៅថ្នាក់អន្តរ ជាតិ ព្រមជាមួយការចូលរួមនៅក្នុងការងារអង្គការអន្តរជាតិនានា ផងដែរ។

* មាននៅក្នុងឯកសារ **A/43/38**

# ទិន្នន័យស្ថិតិអំពីស្ថានភាពនារីភេទ ០៣/០៣/៨៩

CEDAW **អនុសាសន៍រួមលេខ៩** A/**៤៤/៣៨**

យោបល់រួមលេខ៩

ទិន្នន័យស្ថិតិស្តីពីស្ថានភាពនារីភេទ

(សម័យប្រជុំទីលើក៨ ១៩៨៩)

**គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ចោលការរើសអើងប្រឆាំងនារីភេទ**

ដោយពិចារណាលើ

ពតិមានស្ថិតិដែលចាំបាច់យ៉ាងខ្លាំងដើម្បីឱ្យយល់បានពីស្ថានភាពរបស់នារីភេទនៅក្នុងរដ្ឋ ភាគី នីមួយ១ របស់អនុសញ្ញា។

ដោយសង្កេតឃើញថា

ភាគីរដ្ឋជាច្រើនដែលបានដាក់នូវរបាយការណ៍របស់គេឱ្យគណៈកម្មាធិការធ្វើការពិចារ ណា ដោយមិនបានផ្តល់នូវជាស្ថិតិមកជាមួយឡើយ។

សូមផ្តល់អនុសាសន៍ថាចំពោះតួរលេខនិងភាគរយដាច់ខាតទាំងពីរនេះ រដ្ឋភាគីគួរតែខិតខំធ្វើការឱ្យអស់ពីលទ្ធភាព ដើម្បីធានាថាសេវាស្ថិតិជាតិរបស់ខ្លួនដែលទទួលខុសត្រូវធ្វើការរៀបចំផែនការ ជំរឿនទូទាំងប្រទេស និងការ ធ្វើការស្ទង់មតិផ្នែកសង្គម សេដ្ឋកិច្ចដទៃទៀតត្រូវធ្វើការបង្កើតរូបមន្តជាសំនួរតាមបែបវិធីមួយដែលទិន្នន័យត្រូវបាន គេគិតយោងដោយ ប្រមូលយោលតាមភេទ ធ្វើដូចនេះអ្នកប្រើប្រាស់ដែលចាប់អារម្មណ៍អាចទទួលយក ពតិមាននេះ បានយ៉ាងងាយអំពីស្ថានភាពនារីភេទ ទៅលើផ្នែកជាក់លាក់ណាមួយដែលពួកគេចាប់អារម្មណ៍។

* មាននៅក្នុងឯកសារ **A/44/38**

# អនុសាសន៍រួម ទី១០

(សម័យប្រជុំលើកទី៨ ១៩៨៩)

ខួបលើកទី ១០ នៃការចាប់កំណើតអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ

គណៈកម្មាធិការទទួលបន្ទុកលុបបំបាត់ការរើសអើងប្រឆាំងនារីភេទ

- ដោយយល់ឃើញថាថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៨៩ ជាសក្ខីថ្ងៃចាប់កំណើត អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ

- ដោយយល់ឃើញផងដែរថា រយៈពេល១០ឆ្នាំកន្លងមកនេះ បានបង្ហាញថា អនុសញ្ញាគឺជាឧករណ៍ច្បាប់មួយក្នុងចំណោមឧករណ៍ច្បាប់ដែលមានប្រសិទ្ធភាពបំផុតទាំងឡាយ ដែលអង្គការសហប្រជាជាតិបានបង្កើត ដើម្បីលើកកំពស់សមភាពភេទក្នុងបណ្តាសង្គមជារដ្ឋភាគីរបស់ខ្លួន

- រំលឹកឡើងវិញពី អនុសាសន៍រួមទី ៦ (នៅសម័យប្រជុំលើកទី ៧ ឆ្នាំ ១៩៨៨) ស្តីពីយន្តការនិងការផ្សព្វផ្សាយជាតិដោយប្រសិទ្ធិភាព

នៅក្នុងឱកាសបុណ្យខួបលើកទី១០នៃការចាប់កំណើតអនុសញ្ញា សូមផ្តល់អនុសាសន៍ថារដ្ឋភាគីគួរតែពិចារណា:

១- អនុវត្តកម្មវិធីទាំងឡាយរួមមាន សន្និសិទ្ធ និងសិក្ខាសាលាដើម្បីផ្សព្វផ្សាយអនុសញ្ញាស្តីពី ការលុបបំបាត់រាល់ទំរង់ នៃការរើសអើងប្រឆាំងនឹងស្ត្រី ជាភាសាប្រើប្រាស់ជាផ្លូវការ និង ផ្តល់ព័ត៌ មានពីអនុសញ្ញានៅក្នុងប្រទេសរបស់ខ្លួនរៀងៗខ្លួន។

២-អញ្ជើញអោយអង្គការជាតិដើម្បីស្ត្រី អោយចូលសហប្រត្តិបត្តិការក្នុងយុទ្ធនាការផ្សព្វផ្សាយនានាដែលពាក់ពន្ធ័នឹងអនុសញ្ញា និង ការអនុវត្តអនុសញ្ញា ហើយជំរុញអោយបណ្តាអង្គការមិនមែនរដ្ឋាភិបាលថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ធ្វើការផ្សព្វផ្សាយពីអនុសញ្ញា និង ការអនុវត្ត

៣- ជំរុញអោយមានវិធានការណ៍ធានានូវការអនុវត្តអោយបានពេញលេញនូវគោលការណ៍របស់អនុសញ្ញា ហើយជាពិសេស ក្នុងមាត្រា ៨ ដែលចែងពីការចូលរួមរបស់ស្ត្រីនៅគ្រប់លំដាប់សកម្មភាពទាំងអស់របស់អង្គការសហប្រជាជាតិ និង ប្រពន្ធ័អង្គការសហប្រជាជាតិ។

៤- សូមអោយអគ្គលេខាធិការធ្វើវិធីរំលឹកបុណ្យខួបនៃការចាប់កំណើតអនុសញ្ញា ដោយមានការបោះពុម្ពផ្សាយ និងផ្សព្វផ្សាយ ឯកសារផ្សព្វផ្សាយ និង សម្ភារៈផ្សេងៗទៀតស្តីពីអនុសញ្ញា និងការអនុវត្ត ជាភាសាដែលប្រើប្រាស់ជាផ្លូវការទាំងអស់របស់អង្គការសហប្រជាជាតិ រៀបចំភាពយន្តឯកសារអំពីអនុសញ្ញា និងផ្តល់ធនធានចាំបាច់នានាដល់ផ្នែកគាំទ្រភាពរីកចំរើនរបស់ស្ត្រី មជ្ឈមណ្ឌលដើម្បីការអភិវឌ្ឍន៍សង្គម និងកិច្ចការសប្បុរសធម៌នៃការិយាល័យអង្គការសហប្រជាជាតិ នៅទីក្រុងវីយែនណា ដើម្បីរៀបចំធ្វើការវិភាគលើព័ត៌មានផ្តល់ជូនដោយភាគីរដ្ឋ ដែលអនុញ្ញាតិដល់ដាក់ព័ត៌មានថ្មី និងចេញផ្សាយរបាយការណ៍របស់គណៈកម្មាធិការ។

( A/CONF.116/13) បោះពុម្ពលើកដំបូងសំរាប់សន្និសិទ្ធិពិភពលោកប្រារព្ធនៅណៃរូប៊ី ឆ្នាំ ១៩៨៥ ដើម្បីពិនិត្យឡើងវិញ និង កោតសរសើរ ដល់ស្នាដៃសំរេចបានរបស់អង្គការសហប្រជាជាតិទសវត្សន៍ សំរាប់ស្ត្រីៈ សមភាព ការអភិវឌ្ឍ និង សន្តិភាព។

# អនុសាសន៍រួម ទី១១

(សម័យប្រជុំលើកទី៨ ១៩៨៩)

សេវាប្រឹក្សាយោបល់បច្ចេកទេស ក្នុងកាតព្វកិច្ចរាយការណ៍

គណៈកម្មាធិការស្តីពីការលុបបំបាត់ការរើសរើសប្រឆាំងនឹងស្ត្រី

ដោយប្រកាន់ខ្ជាប់ថា មានរដ្ឋចំនួន ៩៦ គិតត្រឹមថ្ងៃទី ៣ ខែ មិនា ឆ្នាំ ១៩៨៩ បានផ្តល់បច្ចាប់ន័លើអនុសញ្ញា លុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងស្ត្រី

ដោយយោងលើហេតុថា ត្រឹមថ្ងៃកំណត់នេះ បានទទួលរបាយការណ៍ដំបូងចំនួន ៦០ និងរបាយការណ៍សាម យិកចំនួន ១៩

ដោយសំគាល់ឃើញថា មានរបាយការណ៍សាមយិក៣៦ និងរបាយការណ៍ដំបូងចំនួន៣៦ ផុតកំណត់ត្រឹមថ្ងៃទី ៣ ខែ មិនា មិនទាន់ទទួលបាន

ដោយស្វាគមន៏សំណើររបស់មហាសន្និបាទលេខ ៤៣/១១៥ កត្តាខណ្ឌ័លេខ ៩ ដែលថាអគ្គលេខាធិការ គួរតែរៀបចំវគ្គបណ្តុះបណ្តាលបន្តទៀតសំរាប់ប្រទេសដែលជួបប្រទះការលំបាកធ្ងន់ធ្ងរ ក្នុងការបំពេញកាតួកិច្ច ធ្វើរបាយណ៍ទៅតាមឧបករណ៏ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ជាមួយនឹងធនធានដែលមាន និងទៅតាមអទិភាព របស់កម្មវិធីសេវាកម្មប្រឹក្សាយោបល់

សូមផ្តល់អនុសាសន៏ទៅរដ្ឋភាគីថា រដ្ឋភាគីគួរតែជំរុញ គាំទ្រ និង សហប្រត្តិបត្តិការជាមួយនឹងគំរោងផ្តល់សេ វាកម្មប្រឹក្សាយោបល់បច្ចេកទេស រួមមានវគ្គសិក្ខាសាលាផងដែរ ដើម្បីជាជំនួយដល់រដ្ឋភាគីទៅតាមការស្នើ សុំ ក្នុងការបំពេញកាតួកិច្ចធ្វើរបាយការណ៍ តាមមាត្រា ១៨របស់អនុសញ្ញា ។

# អំពើហិង្សាប្រឆាំងនារីភេទ ០៦/០៣/៨៩

## CEDAW **អនុសាសន៍រួម ១២**

យោបល់រួមលេខ១២

អំពើហិង្សាប្រឆាំងនារីភេទ

(សម័យប្រជុំលើកទី៨ ១៩៨៩)

***<u>គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ចោលការរើសអើងប្រឆាំងនារីភេទ</u>***

<u>ដោយសំរេចថា</u>មាត្រា ២,៥,១១,១២ និង ១៦នៃអនុសញ្ញាតំរូវឱ្យរដ្ឋភាគីធ្វើសកម្មភាពការពារនារីភេទមិនឱ្យរងនូវអំពើហិង្សាបែបណាមួយកើតឡើងនៅក្នុងរង្វង់គ្រួសារ នៅកន្លែងធ្វើការ ឬនៅទីណាៗផ្សេងទៀតនៃជីវិតរស់ នៅ។

<u>ដោយគិតគូ</u> លើដំណោះស្រាយក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម ១៩៨៨/២៧។

<u>សូមផ្តល់អនុសាសន៍</u> ចំពោះរដ្ឋភាគីថាគួរធ្វើការដាក់បញ្ចូលក្នុងរបាយការណ៍តាមពេលកំណត់របស់ខ្លួនមកគណៈកម្មា ធិការនូវពត៌មានស្តីពីៈ

១. នីតិបញ្ញត្តិដែលមានជាធរមានដើម្បីការពារនារីភេទឱ្យរួចផុតពីឧប្បត្តិហេតុគ្រប់ប្រភេទនៃអំពើហិង្សាទាំង អស់នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ (រួមមានអំពើហិង្សាផ្លូវភេទ ការបំពាននៅក្នុងគ្រួសារ ការយាយីផ្លូវភេទនៅកន្លែង ធ្វើការងារ ។ល។) ។

២. វិធានការនានាដែលបានអនុម័តដើម្បីលុបបំបាត់អំពើហិង្សានេះ។

៣. សេវាគាំទ្រដែលមានចំពោះនារីភេទដែលរងគ្រោះដោយសារការរំលោភបំពាន ឬការបំពារ។

៤. ទិន្នន័យស្ថិតិអំពីឧប្បត្តិហេតុនៃអំពើហិង្សាគ្រប់ប្រភេទប្រឆាំងនារីភេទ និងទិន្នន័យស្តីពីនារីភេទដែលជាជន រងគ្រោះដោយសារអំពើហិង្សា។

# ការផ្តល់កំរៃស្មើគ្នាចំពោះការងារដែលមានតំលៃប៉ុនគ្នា ០៧/០៣/៨៩

# យោបល់រួម CEDAW ១៣ A/៤៤/៣៨

យោបល់រួមលេខ១៣- ការផ្តល់កំរៃស្មើចំពោះការងារដែលមានតំលៃប៉ុនគ្នា ( សម័យប្រជុំលើកទី៨ ១៩៨៩)

គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ចោលការរើសអើងប្រឆាំងនារីភេទ

ដោយរំលឹកឡើងវិញដល់

អនុសញ្ញាលេខ១០០អង្គការការងារអន្តរជាតិស្តីពីការទទួលកំរៃស្មើគ្នាចំពោះអ្នក ធ្វើការបុរស និង នារី សំរាប់ការងារដែលមានតំលៃប៉ុនគ្នាវាត្រូវបានគេធ្វើសច្ចានុម័តដោយសម្លេងភាគច្រើនលើសលុប នៃរដ្ឋភាគីរបស់អនុសញ្ញាស្តីពីការលុបចោលរាល់ទម្រង់ ការរើសអើងប្រឆាំងនារីភេទ ។

ដោយរំលឹកឡើងវិញដល់ផងដែរ

ដែលខ្លួនបានធ្វើការពិចារណាលើរបាយការណ៍តាមពេលកំនត់លើកដំបូង៥១

និងរបាយការណ៍តាមពេលកំនត់លើកទី២ ចំនួន៥ របស់រដ្ឋភាគីចាប់តាំងពីឆ្នាំ១៩៨៣ ។

ដោយពិចារណាថា ទោះបីជារដ្ឋភាគីបង្ហាញថានៅមានកិច្ចការសេសសល់ជាច្រើនទៀតត្រូវធ្វើដើម្បី ធានាដល់ការអនុវត្តន៏គោលការណ៏នោះជាក់ស្តែង ទោះបីគោលការណ៏នៃការបង់ថ្លៃស្មើគ្នាចំពោះការងារដែលមានតំលៃប៉ុនគ្នាត្រូវបានគេទទួលយកក្នុងការធ្វើ នីតិកម្មនៃបណ្តារប្រទេសជាច្រើនក៏ដោយ ត្រូវធ្វើការជំនះលើការចែកភេទនៅ ក្នុងទីផ្សារការងារ ។

សូមផ្តល់អនុសាសន៍

ចំពោះរដ្ឋភាគីរបស់អនុសញ្ញាស្តីពីការលុបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រឆាំង នារីភេទថាៈ

១.ដើម្បីអនុវត្តនូវអនុសញ្ញាស្តីពីការលុបបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទឱ្យបានពេញ លេញនោះ រដ្ឋភាគីទាំងនោះដែលមិនទាន់បានធ្វើសច្ចានុម័តលើអនុសញ្ញាលេខ១០០ របស់អង្គការការងារអន្តរជាតិនៅ ឡើយគួរត្រូវធ្វើវាឡើង ។

២. គេគួរតែពិចារណាលើការសិក្សា ការអភិវឌ្ឍន៏ និងការអនុម័តនៃប្រព័ន្ធវាយតំលៃការងារ ដោយផ្អែកលើ លក្ខណៈសម្បត្តិអព្យាក្រិតផ្នែកភេទ ដែលជួយសំរួលដល់ការប្រៀបធៀបនៃតំលៃការងារទាំងនោះដែលមានលក្ខណៈ ខុសគ្នាដែលស្ត្រីមានភាពលុបលើនាពេលបច្ចុប្បន្ន ដោយបច្ចុប្បន្នការងារទាំងនោះបុរសមានភាពលុបលើ គេគួរដាក់ បញ្ចូលនូវលទ្ធផលដែលសំរេចបាននៅក្នុងរបាយការណ៏ជូនមកគណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ចោលការរើសអើងប្រឆាំងនារីភេទ ។

២. គេគួរធ្វើការគាំទ្រដល់ការបង្កើតនូវយន្តការត្រួតពិនិត្យ និងជំរុញការខិតខំប្រឹងប្រែង របស់រដ្ឋភាគីចំពោះកិច្ចព្រមព្រៀងរួមគ្នាតាមដែលអាចអនុវត្តទៅបានថាតើគេត្រូវអនុវត្តនៅទីណា ដើម្បីធានាដល់ការអនុវត្តន៏គោល ការណ៏នៃការបង់ថ្លៃស្មើគ្នាចំពោះការងារដែលមានតំលៃប៉ុនគ្នា ។

# អនុសាសន៍ទី ១៤ (កិច្ចប្រជុំទី ៩ ឆ្នាំ ១៩៩០)

## ការកាត់ស្បែកស្ត្រី

គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ការរើសអើងប្រឆាំងនារីភេទ

- ដោយមានការព្រួយបារម្ភអំពីការបន្តអនុវត្តន៏ការកាត់ស្បែកស្ត្រី និង ការអនុវត្តន៏បែបប្រពៃណីផ្សេងទៀត ដែលអាចប៉ះពាល់ដល់សុខភាពស្ត្រី
- ដោយសំគាល់ដោយការពេញចិត្ត ថានៅពេលដែលការអនុវត្តន៏បែបនេះនៅតែបន្តមាន រដ្ឋ អង្គការជាតិ ដើម្បីស្ត្រី អង្គការមិនមែនរដ្ឋាភិបាល និង ស្ថាប័នប្រពន្ធ័អង្គការសហប្រជាជាតិ ដូចជា អង្គការសុខភាពពិភព លោក និង អង្គការសហប្រជាតិដើម្បីកុមារ ក៏ដូចជា កម្មាធិការសិទ្ធិមនុស្ស និង អនុកម្មាធិការទប់ស្កាត់ការ រើសអើង និង ការពារជនជាតិភាគតិច ទោះបីនៅតែជាប់គាំងជាមួយនឹងបញ្ហានេះ ប៉ុន្តែទទួលស្គាល់ជាពិសេស ថាការអនុវត្តប្រពៃណីដូចជាការកាត់ស្បែកស្ត្រីបែបនេះ មានឥទ្ធិពលយ៉ាងធ្ងន់ធ្ងរលើសុខភាព និង ផលលំបាក ផ្សេងៗ ទៀតទៅលើស្ត្រី និងកុមារ
- ដោយកត់សំគាល់ដោយពេញចិត្តផងដែរលើការសិក្សារបស់អ្នករាយការណ៏ពិសេស លើការអនុវត្តប្រពៃណី ដែលប៉ះពាល់ដល់សុខភាពស្ត្រី និង កុមារ និង ការសិក្សារបស់ក្រុមការងារពិសេសលើការអនុវត្តប្រពៃណី
- ដោយទទួលស្គាល់ថា ស្ត្រីកំពុងចាត់វិធានការណ៏ដោយខ្លួនឯង ដើម្បីកំណត់ និង ប្រយុទ្ធប្រឆាំងនឹង ការអនុវត្តទាំងឡាយណាដែលធ្វើអោយប៉ះពាល់ដល់សុខភាព និង សុខមាលភាពរបស់ស្ត្រី និងកុមារ
- ដោយយល់ស្របថា វិធានការណ៏ចាំបាច់កំពុងតែអនុវត្តន៏ដោយស្ត្រី និង ក្រុមពាក់ពន្ធ័ទាំងអស់ ត្រូវមានការ គាំទ្រ និង លើកទឹកចិត្តពីសំណាក់រដ្ឋាភិបាល
- ដោយព្រួយបារម្ភជាអនេកថា សម្ពាធវប្បធមិ ប្រពៃណី និង សេដ្ឋកិច្ចនៅតែបន្តមាន ដែលហេតុជំនួយដល់ វត្តមាននៃការបន្តការអនុវត្តន៏ប្រកបដោយគ្រោះថ្នាក់ទាំងឡាយ ដូចជាការកាត់ស្បែកស្ត្រីនេះជាដើម

សូមផ្តល់អនុសាសន៏ថា រដ្ឋភាគីៈ

a). ចាត់វិធានការណ៏ សមស្រប និង ប្រកបដោយប្រសិទ្ធិភាព ដើម្បីលប់បំបាត់ការអនុវត្តកាត់ស្បែកស្ត្រី។ វិធានការណ៏ទាំងនេះអាចរួមមានៈ

I). ការប្រមូល និងការផ្សព្វផ្សាយតាមមហាវិទ្យាល័យ សមាគមវេជ្ជសាស្ត្រ ឬគិលានុបដ្ឋាយិកា អង្គការស្ត្រីៗ នានា និងបណ្ដាលស្ថាប័នទិន្នន័យមូលដ្ឋានស្ដីពីការអនុវត្តប្រពៃណីទាំងនេះ ។

II). គាំទ្រដល់អង្គការស្ត្រីដែលធ្វើការដើម្បីលប់បំបាត់ការអនុវត្តការកាត់ស្បែកស្ត្រី និង ការអនុវត្តផ្សេងៗ ទៀតដែលផ្ដល់ប៉ះពាល់មិនល្អដល់ស្ត្រី ទាំងនៅថ្នាក់ជាតិ និង ថ្នាក់មូលដ្ឋាន

III). លើកទឹកចិត្តអ្នកនយោបាយ អ្នកជំនាញការ អ្នកដឹកនាំសាសនា និងសហគមគ្រប់ជាន់ថ្នាក់ មានសារព័ត៌មាន និងក្រុមសិល្បៈ អោយធ្វើកិច្ចសហការរួមគ្នាបញ្ចេញអនុភាពលើកការកែប្រែឥរិយាបថ ដើម្បីឈានទៅលប់បំបាត់ការអនុវត្តកាត់ស្បែកស្ត្រីនេះ

IV). បង្កើតកម្មវិធីអប់រំ និងបណ្ដុះបណ្ដាល និងសិក្ខាសាលាសមស្រប ផ្អែកលើមូលដ្ឋានស្រាវជ្រាវលើបញ្ហាបង្កមកពីការអនុវត្តកាត់ស្បែកស្ត្រីនេះ ។

b). បញ្ចូលយុទ្ធសាស្ត្រសមស្របនានា ទៅក្នុងគោលនយោបាយសុខភាពជាតិ ឆ្ពោះទៅលប់បំបាត់ការអនុវត្តកាត់ស្បែកស្ត្រីក្នុងការគាំពារសុខភាពសាធារណៈ ។ យុទ្ធសាស្ត្រទាំងនោះអាចរួមមាន ការទទួលខុសត្រូវពិសេសរបស់បុគ្គលិកសុខាភិបាល (រួមមានឆ្មបបុរាណផងដែរ) ក្នុងការបកស្រាយពន្យល់ពីផលប៉ះពាល់នៃការអនុវតកាត់ស្បែកស្ត្រីនេះ ។

c)- សុំជំនួយ ព័ត៌មាន និង យោបល់ពីអង្គការនានាក្នុងប្រពន្ធ័អង្គការសហប្រជាជាតិ អោយគាំទ្រ និង ជួយដល់កិច្ចប្រឹងប្រែងដែលមាន ដើម្បីលប់បំបាត់ការអនុវត្តប្រពៃណីប្រកបដោយគ្រោះថ្នាក់ទាំងនោះ ។

d). តាមមាត្រា ១០ និង ១២នៃ អនុសញ្ញាស្ដីពីការលប់បំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងស្ត្រី ចូររាយការណ៍ពីព័ត៌មានស្ដីពីការចាត់វិធានការណ៍លប់បំបាត់ការអនុវវត្តកាត់ស្បែកស្ត្រីនេះ ។

# ការជៀសវាងការរើសអើងប្រឆាំងនារីភេទនៅក្នុងយុទ្ធសាស្ត្រជាតិដើម្បីទប់ស្កាត់ នូវរោគសញ្ញាដែល ធ្វើឱ្យចុះខ្សោយការស៊ាំមេរោគ(អេដស៍): ០៣/០២/៩០

## អនុសាសន៍រួម ១៥ A/៤៥/៣៨

អនុសាសន៍រួមលេខ ១៥

ការជៀសវាងការរើសអើងប្រឆាំងនារីភេទនៅក្នុងយុទ្ធសាស្ត្រជាតិដើម្បីទប់ស្កាត់ និងគ្រប់គ្រងនូវរោគសញ្ញាដែលធ្វើឱ្យចុះខ្សោយ ប្រព័ន្ធ ស៊ាំមេរោគ(អេដស៍)(សម័យប្រជុំលើកទី៩ ១៩៩០)

**គណៈកម្មាធិការទទួលបន្ទុកការរើសអើងប្រឆាំងនារីភេទ**

ដោយមានការពិចារណា នូវពត៌មានដែលធ្វើឱ្យមានការយកចិត្តទុកដាក់ទៅលើផលជាសក្តានុពលទាំងរោគឆ្លង រោគសញ្ញាធ្វើឱ្យចុះខ្សោយប្រព័ន្ធស៊ាំមេរោគពាសពេញពិភពលោក(អេដស៍)និងយុទ្ធសាស្ត្រគ្រប់គ្រងវាលើការអនុវត្តន៍សិទ្ធិនារី។

ដោយគិតគូរដល់ របាយការណ៍និងឯកសារដែលបានរៀបចំដោយអង្គការសុខភាពពិភពលោក ជាមួយនិងអង្គការសហប្រជាជាតិ អង្គភាពនិងស្ថាប័នរបស់អង្គការសហប្រជាជាតិ ដែលទាក់ទងដល់វីរុសដែលធ្វើឱ្យចុះខ្សោយប្រព័ន្ធការពារមេរោគខ្លួនមនុស្ស(HIV) ជាពិសេសការកត់សំគាល់ដោយ អគ្គលេខាធិការរបស់គណៈកម្មការទទួលបន្ទុកលើស្ថានភាពនារីភេទអំពីផលនៃមេរោគអេដស៍ដែលវិវត្តមកលើនារី និងឯកសារចុងក្រោយនៃការពិគ្រោះអន្តរជាតិស្តី អំពីអេដស៍ និងសិទ្ធិមនុស្ស ដែលរៀបចំឡើងនៅក្រុងសឺណែវពីថ្ងៃទី២៦ ដល់២៨កក្កដា ១៩៨៩។

ដោយកត់សំគាល់ថា សេចក្តីសំរេចនៃសមាជអង្គការសុខភាពពិភពលោក WHA៤១.២៤ អំពីការជៀសវាងការរើសអើងចំពោះអ្នកដែលផ្ទុកវីរុសហ៊ីវ និងអ្នកកើតអេដស៍នៅថ្ងៃទី១៣ ឧសភា ១៩៨៨ សេចក្តីសំរេច១៩៨៩/១១របស់ស្នងការផ្នែកសិទ្ធិមនុស្សអំពីការ មិនរើសអើងនៅក្នុងវិស័យសុខភាព នៅថ្ងៃទី២ មិនា ១៩៨៩ និងជាពិសេសសេចក្តីប្រកាសនៅក្រុងបារីសអំពីនារី កុមារ និងអេដស៍ នៅថ្ងៃទី៣០ វិច្ឆកា ១៩៨៩។

ដោយកត់សំគាល់ថា អង្គការសុខភាពពិភពលោកបានប្រកាសថារឿងសំខាន់នៅទិវាអេដស៍ពិភពលោកនៅថ្ងៃទី១ ធ្នូ១៩៨៩គឺ "នារី និងអេដស៍"។

សូមធ្វើការផ្តល់អនុសាសន៍ដូចតទៅ:

ក. រដ្ឋភាគីត្រូវបង្កើនល្បឿនការខិតខំប្រឹងប្រែងក្នុងការផ្សព្វផ្សាយពត៌មានដើម្បីបង្កើនការយល់ដឹងទូទៅនៃគ្រោះថ្នាក់ការឆ្លងវីរុសហ៊ីវនិងជំងឺអេដស៍ ជាពិសេសទៅលើនារី និងកុមារ និងផលវិបាករបស់វាទៅលើពួកគេ។

ខ. កម្មវិធីប្រយុទ្ធជំងឺអេដស៍គួរផ្តល់ការយកចិត្តទុកដាក់ពិសេសចំពោះសិទ្ធិ និងតំរូវការរបស់នារី និងកុមារ និងកត្តាផ្សេងៗទៀត ដែលទាក់ទងដល់តួនាទីបន្តពូជរបស់នារី និងតួនាទីបន្ទាប់បន្សំនៅក្នុងសង្គមខ្លះដែលធ្វើឱ្យពួកគេមានគ្រោះថ្នាក់ជាពិសេសការឆ្លងវីរុសហ៊ីវ ។

គ.រដ្ឋភាគីត្រូវធានាដល់ការចូលរួមសកម្មរបស់នារីនៅក្នុងការថែទាំបឋម និងចាត់វិធានការជំរុញតួនាទីពួកគេឱ្យទៅជាអ្នកផ្តល់ការថែទាំ អ្នកធ្វើការផ្នែកសុខភាព និងអ្នកអប់រំ នៅក្នុងការទប់ស្កាត់នៃការឆ្លងវីរុសហ៊ីវ ។

ឃ. រដ្ឋភាគីទាំងអស់ត្រូវដាក់មកនូវរបាយការណ៍របស់ខ្លួនតាមមាត្រា១២របស់អនុសញ្ញានូវពត៌មានចំពោះផលវិបាកនៃជំងឺអេដស៍លើស្ថានភាព នារីភេទ និងវិធានការដែលបានចាត់ឡើងដើម្បីបំពេញដល់តំរូវការផ្នែកម្ហូបអាហាររបស់នារីទាំង នោះដែលបានឆ្លង និងធ្វើការទប់ស្កាត់នូវការរើសអើងជាក់លាក់ប្រឆាំងនារីអំពីរោគអេដស៍ ។

# អ្នកធ្វើការនារីដែលមិនបានទទួលប្រាក់កម្រៃនៅក្នុងសហគ្រាស គ្រួសារនៅតាមជនបទនិងទីក្រុង

## O២/O១/៩១

## CEDAW អនុសាសន៍រួម ១៦ A/៤៦/៣៨

អនុសាសន៍រួមលេខ ១៦

អ្នកធ្វើការនារីដែលមិនបានទទួលប្រាក់កំរៃនៅក្នុងសហគ្រាសគ្រួសារតាមជនបទនិងទីក្រុង

(សម័យប្រជុំលើកទី១០ ១៩៩០)

**គណៈកម្មាធិការទទួលបន្ទុកការរើសអើងប្រឆាំងនារីភេទ**

ដោយចងចាំមាត្រា២ (c) និង ១១ (c), (d) និង (e) របស់អនុសញ្ញាស្តីពីការលុបបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទនិងអនុសាសន៍រួមលេខ៩ (សម័យប្រជុំលើកទី៨ ១៩៨៩) អំពីទិន្នន័យស្ថិតិចំពោះស្ថានភាពនារីភេទ។

ដោយគិតគូពិចារណាថា ចំនួនភាគរយខ្ពស់របស់នារីនៅក្នុងរដ្ឋភាគីដែលធ្វើការមិនបានទទួលប្រាក់កំរៃ មិនមានការធានាសង្គម និងប្រាក់ឧបត្ថម្ភសង្គមនៅក្នុងសហគ្រាសដែលជាធម្មតាកាន់កាប់ដោយសមាជិក គ្រួសារភេទប្រុស។

ដោយកត់សំគាល់ថា របាយការណ៍ដែលដាក់មកគណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ចោលការ រើសអើងប្រឆាំងនារីភេទជាទូទៅមិនសំដៅទៅលើបញ្ហាអ្នកធ្វើការនារីដែលមិនបានទទួលប្រាក់កំរៃនៃ សហគ្រាសគ្រួសារប៉ុណ្ណោះទេ។

ដោយញ្ជាក់ថា ការងារដែលមិនបានទទួលប្រាក់កំរៃបាននាំឲ្យមាននូវទម្រង់ការធ្វើអាជីវកម្មលើនារីភេទ ដែលវាផ្ទុយទៅនឹងអនុសញ្ញា។

សូមផ្តល់អនុសាសន៍ចំពោះរដ្ឋភាគីថា:

ក.ត្រូវដាក់បញ្ចូលនៅក្នុងរបាយការណ៍របស់ខ្លួនមកគណៈកម្មាធិការនូវពត៌មានស្តីពីស្ថានភាពច្បាប់ និងស្ថានភាព សង្គមនៃស្ត្រី ដែលមិនបានទទួលប្រាក់កំរៃធ្វើការនៅក្នុងសហគ្រាសគ្រួសារ។

ខ.សូមប្រមូលនូវទិន្នន័យស្ថិតិអំពីនារីដែលធ្វើការមិនមានប្រាក់កំរៃ ការធានាសង្គម និងប្រាក់ឧបត្ថម្ភសង្គម នៅក្នុងសហគ្រាសដែលកាន់កាប់ដោយសមាជិកគ្រួសារ ហើយសូមដាក់នូវទិន្នន័យទាំងនេះនៅក្នុងរបាយការណ៍មកគណៈកម្មាធិការ។

គ.ត្រូវចាត់វិធានការចាំបាច់ដើម្បីធានាការផ្តល់កំរៃ ការធានាសង្គម និងប្រាក់ឧបត្ថម្ភសង្គម សំរាប់នារីដែលធ្វើការមិនបានទទួលប្រាក់កំរៃនៅក្នុងសហគ្រាសកាន់កាប់ដោយសមាជិកគ្រួសារ ។

# ការវាស់ស្ទង់
# និងការកំរិតបរិមាណនៃសកម្មភាពនារីនៅក្នុងគ្រួសារដែលមិនបានទទួលការបង់ថ្លៃក្នុង
# និងការទទួលស្គាល់នៅក្នុងផលិតផលជាតិ: ០៣/០១/៩១

## CEDAW អនុសាសន៍រួមលេខ ១៧ A/៤៦/៣៨

**អនុសាសន៍រួមលេខ ១៧**

**ការវាស់ស្ទង់ និងការកំរិតបរិមាណនៃសកម្មភាពនារីនៅក្នុងគ្រួសារដែលមិនបានទទួលការបង់ថ្លៃ**

**និងការទទួលស្គាល់របស់ពួកគេនៅក្នុង ផលិតផលជាតិ**

**(សម័យប្រជុំលើកទី១០ ១៩៩១)**

**គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ចោលនៃការរើសអើងប្រឆាំងនារីភេទ**

ដោយចាំថា មាត្រា១១នៃអនុសញ្ញាអំពីការលុបបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ។

ដោយរំលឹកដល់ កថាខ័ណ្ឌទី១២០នៃយុទ្ធសាស្រ្តសំលឹងទៅមុខនៅណាយរ៉ូប៊ីចំពោះការអភិវឌ្ឍន៍ស្រ្តី។

ដោយបញ្ជាក់ថា ការវាស់និងការកំរិតបរិមាណនៃសកម្មភាពនារីនៅក្នុងគ្រួសារដែលមិនបានទទួលការបង់ថ្លៃ ដែលពួកគាត់បានចូលរួមធ្វើការអភិវឌ្ឍន៍នៅក្នុងប្រទេសនីមួយៗនឹងជួយបង្ហាញឱ្យឃើញនូវតួនាទីសេដ្ឋកិច្ចពិតរបស់នារី។

ដោយជឿជាក់ថា ការវាស់ និងការកំរិតបរិមាណផ្តល់ជាមូលដ្ឋានមួយសំរាប់ការធ្វើរូបមន្តនូវគោលនយោបាយបន្ថែមទៀតដែលទាក់ទងដល់ការអភិវឌ្ឍន៍នារីភេទ។

ដោយកត់សំគាល់ថា ការពិគ្រោះពិភាក្សានៃគណៈកម្មការស្ថិតិនៅឯការប្រជុំលើកទី២១របស់ខ្លួន អំពីការពិនិត្យឡើងវិញលើប្រព័ន្ធ គណនេយ្យជាតិ និងការអភិវឌ្ឍន៍ស្ថិតិនារីនាពេលបច្ចុប្បន្ន។

សូមធ្វើការផ្តល់អនុសាសន៍ដល់រដ្ឋភាគីថា:

ក.ផ្តល់ការលើកទឹកចិត្ត និងគាំទ្រដល់ការស្រាវជ្រាវ ព្រមជាមួយនិងការសិក្សាពិសោធន៍ដើម្បីធ្វើការវាស់ស្ទង់វាយតំលៃទៅលើ សកម្មភាពនារីនៅក្នុងគ្រួសារដែលមិនបានទទួលការបង់ថ្លៃ ឧទាហរណ៍ ការធ្វើការស្ទង់មតិប្រើពេលវេលាជាផ្នែកមួយនៃកម្មវិធីនៃការវាស់ស្ទង់ គ្រួសារនៅទូទាំងប្រទេសរបស់ខ្លួន និងដោយធ្វើការប្រមូលស្ថិតិដោយចែកចេញតាមភេទនៃពេលវេលាដែលបានចំណាយទៅលើគ្រួសារ និងទីផ្សារការងារទាំងពីរនេះ។

ខ. ដោយយោងទៅលើបទបញ្ញត្តិនៃអនុសញ្ញាស្តីពីការលុបបំបាត់ចោលរាល់ទម្រង់ នៃការរើសអើងប្រឆាំងនារីភេទជាមួយយុទ្ធសាស្ត្រសំលឹងទៅមុខនៅក្រុងណាយរ៉ូប៊ីចំពោះការអភិវឌ្ឍន៍នារី រដ្ឋត្រូវចាត់វិធានការដើម្បីធ្វើការកំនត់បរិមាណ និងដាក់បញ្ចូលនូវនូវសកម្ម ភាពនារីនៅក្នុងគ្រួសារដែលមិនបានទទួលការបង់ ថ្លៃនៅក្នុងផលិតផលជាតិ ។

គ. សូមធ្វើការដាក់របាយការណ៍ដែលត្រូវផ្ញើមកតាមមាត្រា១៨នៃអនុសញ្ញា នូវពតិមានអំពីការស្រាវជ្រាវ និងការសិក្សា ពិសោធន៍ដែលធ្វើឡើងដើម្បីវាស់ស្ទង់ និងវាយតំលៃចំពោះសកម្មភាពនារីនៅក្នុងគ្រួសារដែលមិនបានទទួលការបង់ថ្លៃក៏ដូចជាការរីកចំរើន ដែលបានធ្វើនៅក្នុងសារជីវកម្មនៃសកម្មភាពនារីនៅក្នុងគ្រួសារដែលមិនបានទទួលការបង់ថ្លៃនៅក្នុងគណនីជាតិ ។

# នារីពិការ : ០៤/០១/៩១

# CEDAW អនុសាសន៍រួម លេខ ១៨ A/៤៦/៣៨

**អនុសាសន៍រួមលេខ១៨**

**នារីពិការ**

**(សម័យប្រជុំលើកទី១០)**

គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ចោលការរើសអើងប្រឆាំងនារីភេទ

ដោយគិតគូរពិចារណា ជាពិសេសលើមាត្រាទី៣ នៃអនុសញ្ញាស្តីពីការលុបបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រឆាំងនារី ភេទ។

ដោយពិចារណា ទៅលើរបាយការណ៍តាមពេលកំនត់នៃរដ្ឋភាគីជាង៦០ ហើយបានជ្រាបថា ប្រទេសទាំងនោះបានផ្តល់នូវពត៌មាន មិនគ្រប់គ្រាន់អំពីនារីពិការ។

ដោយព្រួយបារម្ភ ចំពោះស្ថានភាពនារីពិការដែលទទួលរងនូវការរើសអើងទ្វេរដង ដែលជាប់ទាក់ទងដល់ក៏រិតជីវភាពរស់នៅជាពិសេសរបស់ពួកគេ។

ដោយរំលឹកឡើងវិញ នូវកថាខ័ណ្ឌលេខ២៩៦នៃយុទ្ធសាស្រ្តសំលឹងទៅមុខនៅក្រុងណាយរ៉ូប៊ីចំពោះការអភិវឌ្ឍន៏នារី ដែលនារីពិការ ត្រូវបានគេចាត់ទុកជាក្រុមងាយរងគ្រោះថ្នាក់ស្ថិតនៅក្រោម **"តំបន់ដែលមានការព្រួយបារម្ភជាពិសេស"**។

ដោយបញ្ជាក់ការគាំទ្ររបស់ខ្លួន ចំពោះកម្មវិធីសកម្មភាពពិភពលោកគិតគូរចំពោះជនពិការ។

សូមផ្តល់អនុសាសន៏ដល់ រដ្ឋភាគីសូមផ្តល់នូវពត៌មានអំពីនារីពិការនៅក្នុងរបាយការណ៏តាមកាលកំនត់របស់ខ្លួន និងវិធានការដែលខ្លួនចាត់ធ្វើឡើងដើម្បីដោះស្រាយនូវស្ថានភាពជាក់លាក់របស់គេ រួមទាំងវិធានការពិសេសដើម្បីធានាថាពួកគេអាចទទួលបានការអប់រំ និង ការងារដោយស្មើភាព ទទួលបានសេវាសុខភាព និងការធានាសង្គម និងដើម្បីធានាថាពួកគេបានចូលរួមគ្រប់វិស័យនៃជីវិតសង្គម និងវប្ប ធម៌។

# អនុសាសន៍រួមលេខ១៩

## អំពើហិង្សាប្រឆាំងនារីភេទ

## (សម័យប្រជុំលើកទី១១- ១៩៩២)

ប្រវត្តិកាល

១.អំពើហិង្សាលើភេទគឺជាទម្រង់នៃការរើសអើងដែលមានការរារាំងយ៉ាងខ្លាំងដល់សមត្ថភាពនារីមិនឱ្យចូលរួមអនុវត្តនូវសិទ្ធិនិងសេរីភាពផ្អែកលើមូលដ្ឋានសិទ្ធិ ស្មើភាពគ្នា ជាមួយបុរស ។

២. នៅឆ្នាំ១៩៨៩គណៈកម្មាធិការបានផ្តល់អនុសាសន៍ថា រដ្ឋគួរដាក់បញ្ចូលនូវ នៅក្នុងរបាយការណ៍របស់ខ្លួននូវពត៌មានស្តីពីអំពើហិង្សា និងពីវិធានការដែលធ្វើការណែនាំដើម្បីធ្វើការដោះស្រាយបញ្ហានេះ (យោបល់រួមលេខ១២ សម័យប្រជុំលើកទី៨) ។

៣. នៅសម័យប្រជុំទី១០របស់ខ្លួននៅឆ្នាំ១៩៩១ វាត្រូវបានគេសំរេចធ្វើការកំណត់ ផ្នែកនៃសម័យប្រជុំលើកទី១១ចំពោះការពិភាក្សានិង សិក្សាលើមាត្រា៦ព្រមជាមួយ មាត្រាផ្សេងៗទៀត របស់អនុសញ្ញាដែល ទាក់ទងអំពើហិង្សាចំពោះនារីភេទការយាយីផ្លូវភេទ និងការធ្វើអាជីវកម្មលើនារីភេទ។ វាត្រូវបានគេជ្រើស រើសយកមកប្រើនៅក្នុងសន្និសីទ ពិភពលោក១៩៩៣ស្តីពីសិទ្ធិមនុស្សដែលបានរៀបចំការប្រជុំដោយសមាជ ទូទៅតាមសេចក្តី សំរេច ៤៥/១៥៥ នៅថ្ងៃទី១៨ ធ្នូ ១៩៩០ ។

៤. គណៈកម្មាធិការបានធ្វើការសន្និដ្ឋានថា មិនមែនគ្រប់របាយការណ៍ របស់រដ្ឋភាគីបានឆ្លុះបញ្ចាំងគ្រប់គ្រាន់នូវការទាក់ទងយ៉ាងជិតស្និទ្ធ រវាងការរើសអើងប្រឆាំងនារីភេទ អំពើហិង្សារវាងភេទ ជាមួយនឹងការរំលោភលើសិទ្ធិមនុស្សនិង សេរីភាពជាមូលដ្ឋាន។ ការអនុវត្តន៍អនុសញ្ញាដ៏ពេញលេញគឺតំរូវឱ្យរដ្ឋធ្វើការចាត់វិធានការប្រកបដោយវិជ្ជមានដើម្បីលុបបំបាត់ចោលរាល់ទម្រង់នៃអំពើហិង្សាប្រឆាំងនារីភេទ។

៥. គណៈកម្មាធិការបានធ្វើការស្នើដល់រដ្ឋភាគីធ្វើការត្រួតពិនិត្យច្បាប់ និងគោលនយោបាយ របស់គេ ឡើងវិញហើយធ្វើរបាយការណ៍ស្ថិតក្រោមអនុសញ្ញា គេគួរធ្វើការគោរពទៅតាមយោបល់នៃគណៈកម្មាធិការ អំពីអំពើហិង្សា រវាងភេទដូច ខាងក្រោមនេះ ។

អនុសាសន៍រួម

៦. នៅក្នុងមាត្រា១របស់អនុសញ្ញា បានកំនត់និយមន័យការរើសអើងប្រឆាំងនារីភេទ។ និយមន័យ នៃ ការរើសអើងគឺរាប់ បញ្ចូលទាំងអំពើហិង្សាយេនឌ័រ គឺថា ហិង្សាដែលដឹកនាំឱ្យមានការប្រឆាំងនារីភេទ ពីព្រោះ នាងជានារី ឬក៏ធ្វើឱ្យ ប៉ះពាល់ដល់នារី ដោយមិនមាន លក្ខណៈសមាមាត្រ ។

វាក៏រាប់បញ្ចូលទាំង សកម្មភាព ដែលធ្វើឱ្យមាន របួសស្លាកស្នាម ដល់រាងកាយ ផ្លូវចិត្ត ឬគ្រោះថ្នាក់ផ្លូវភេទ ឬក៏ការឈឺចាប់ ការគំរាមកំហែង ដោយសកម្មភាពបែបនោះ ការបង្ខិតបង្ខំ ការដកហូតសេរីភាពផ្សេងទៀត។ អំពើហិង្សាយេនឌ័រអាចនាំឱ្យ មានការបំពានបទបញ្ញត្តិជាក់លាក់របស់ អនុសញ្ញាដោយមិនគិតន័យ ថាបទបញ្ញត្តិទាំងនោះលើកឡើងតែអំពី អំពើហិង្សា ពិតប្រាកដនោះឡើយ ។

៧. អំពើហិង្សាវាងភេទដែលធ្វើឱ្យខូចឬនាំឱ្យមានការទុកជាមោឃៈ នូវការចូលរួមអនុវត្ត ដោយនារី នូវសិទ្ធិមនុស្សនិងសិទ្ធិសេរីភាពក្រោមច្បាប់អន្តរជាតិទូទៅ ឬតាមអនុសញ្ញាស្តីពីសិទ្ធិមនុស្ស វាគឺជាការរើសអើងដែលឋិតនៅក្នុងអត្ថន័យមាត្រាទី១របស់អនុសញ្ញា ។ សិទ្ធិនិងសេរីភាពទាំងនេះរួមមានៈ

ក. សិទ្ធិរស់រានមានជីវិត។

ខ. សិទ្ធិរួចផុតពីការធ្វើទារុណកម្មឬអំពើឃោរឃៅព្រៃផ្សៃ អមនុស្សធម៌ ឬការប្រព្រឹត្តិបន្ថោក បន្ទាប និងការដាក់ទណ្ឌកម្ម ។

គ. សិទ្ធិមានការការពារស្មើគ្នាដោយយោងទៅតាមបទដ្ឋានមនុស្សធម៌នៅពេលមានជំលោះ ប្រដាប់អាវុធអន្តរជាតិឬផ្ទៃក្នុង ។

ឃ. សិទ្ធិទទួលបាននូវសេរីភាពនិងសន្តិសុខបុគ្គល ។

ង. សិទ្ធិទទួលបានការការពារដោយសមភាពចំពោះមុខច្បាប់ ។

ច. សិទ្ធិស្មើភាពគ្នានៅក្នុងគ្រួសារ ។

ឆ. សិទ្ធិទទួលបានកំរិតសុខមាលភាពតាមបទដ្ឋានកំរិតខ្ពស់តាមដែលអាច ធ្វើបានទាំងផ្នែក រាងកាយ ហើយនិងសតិស្មារតី។

ជ. សិទ្ធិទទួលបានលក្ខខ័ណ្ឌការងារដែលមានអំណោយផលនិង យុត្តិធម៌ដែលខ្លួនពេញចិត្ត។

៨. អនុសញ្ញាអនុវត្តចំពោះអំពើហិង្សាដែលប្រព្រឹត្តដោយអាជ្ញាធរសាធារណៈ។ អំពើហិង្សាបែបហ្នឹងអាចធ្វើឱ្យមានការខូចខាតដល់កាតព្វកិច្ចរបស់រដ្ឋតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិជាទូទៅ និង តាមអនុសញ្ញាផ្សេងទៀត បន្ថែមពីនេះទៀត វាធ្វើឱ្យខូចដល់អនុសញ្ញាតែម្តង។

៩. តែទោះបីជាយ៉ាងនេះក៏ដោយ វាក៏បានសង្កត់ធ្ងន់ទៅលើការរើសអើង ស្ថិតនៅក្រោមអនុសញ្ញាមិនទាន់ បានកំរិតចំពោះសកម្មភាព ដោយ ឬតំណាងរដ្ឋាភិបាល (សូមមើលមាត្រាទី២(e) ២(f) និង៥)។ ឧទាហរណ៍ តាមមាត្រាទី២(e) អនុសញ្ញាបានអំពាវនាវឱ្យរដ្ឋភាគី ធ្វើការចាត់វិធានការទាំងអស់ឱ្យ បានសមស្របដើម្បីបំបាត់ចោលការ រើសអើងប្រឆាំងនារីភេទ ដោយជនណាម្នាក់ អង្គភាព ឬ ដោយសហគ្រាសណាមួយ។ ស្ថិតក្រោមច្បាប់អន្តរជាតិជាទូទៅនិង កតិកាសញ្ញាសិទ្ធិមនុស្សដ៏ជាក់លាក់ រដ្ឋអាចធ្វើការទទួល

ខុសត្រូវផងដែរចំពោះសកម្មភាពឯកជន ប្រសិនជាគេមិនបានធ្វើប្រកបដោយភាពវៃឆ្លាត ចំពោះការទប់ស្កាត់ការរំលោភសិទ្ធិ ឬ ក៏ធ្វើការស៊ើបអង្កេតដើម្បីដាក់ទ័ណ្ឌកម្ម ដល់សកម្មភាពហិង្សា ហើយនិងផ្តល់ការសងជម្ងឺចិត្ត។

យោបល់រួមអំពីមាត្រាជាក់លាក់របស់អនុសញ្ញា

មាត្រា២ និង ៣

១០.មាត្រា២និង៣បានបង្កើតនូវកាតព្វកិច្ចយ៉ាងទូលំទូលាយមួយដើម្បីលុបបំបាត់ចោលនៅក្នុងរាល់ ទម្រង់នៃការរើសអើងទាំងអស់របស់ខ្លួនចំពោះកាតព្វកិច្ចជាក់លាក់តាមមាត្រា ៥-១៦។

មាត្រាទី២ ច,៥ និង ១០ គ

១១. ឥរិយាបទតាមទំនៀមទំលាប់ដែលនារីត្រូវបានគេចាត់ទុកជាអ្នកបន្ទាប់ពីបុរស ឬចាត់ទុកតាមតួនាទីចាស់គំរិលដែលបានរក្សាទុកនូវការប្រតិបត្តិ ពាសពេញពាក់ព័ន្ធដល់អំពើហិង្សាឬការបង្ខិតបង្ខំ ដូចជា ហិង្សានិងរំលោភបំពានក្នុងគ្រួសារ ការរៀបការដោយបង្ខំ ការបំផ្លាញ ការវាយប្រហារដោយអាស៊ីត និងការកាត់ស្បែកអង្គជាតិនារីភេទជាដើម។ ការលំអៀង និងការប្រតិបត្តិបែបហ្នឹងវាអាចធ្វើការកែតម្រូវហិង្សារវាង ភេទឱ្យទៅជាទម្រង់មួយនៃការការពារនិងការគ្រប់គ្រងនារីភេទ។ ផលនៃអំពើហិង្សាបែបណាមួយទៅលើភាព សុចរិតផ្លូវកាយនិងផ្លូវចិត្តរបស់នារីគឺជាការដកចេញនៃការចូលរួមស្មើភាពគ្នា ការអនុវត្តន៍ ការយល់ដឹងនៃសិទ្ធិ មនុស្សនិងសេរីភាពជាមូលដ្ឋាន។ ខណៈដែលយោបល់នេះលើកឡើងនូវអំពើហិង្សាជាក់ស្តែងឬហិង្សាគំរាមកំហែងជាចំបងដែលស្ថិតនៅក្រោមវិបាកនៃទំរង់អំពើហិង្សារវាងភេទទាំងនេះជួយរក្សាឱ្យនារីភេទស្ថិតនៅមានតួនាទីបន្ទាប់ធ្វើការចូលរួមនៅក្នុងនយោបាយកម្រិតទាប និងចូលរួមការអប់រំកម្រិតទាប ជំនាញ ព្រមជាមួយនិង ការឱកាសចូលរួមការងារផ្សេងៗ។

១២. ឥរិយាបទទាំងនេះក៏បានចូលរួមផងដែរដើម្បីធ្វើការផ្សព្វផ្សាយរឿងអាសអាភាស និងការតាំងពិពណ៌និងការចូលរួមនូវការធ្វើអាជីវកម្មពាណិជ្ជកម្មលើនារីភេទធ្វើជាឧបករណ៍ផ្លូវភេទ ជាជាងឯកត្តជន។ នេះក្លាយទៅជាការចូលរួមហិង្សារវាងភេទ។

មាត្រាទី៦

១៣. រដ្ឋភាគីត្រូវបានតំរូវដោយមាត្រា៦ ដើម្បីធ្វើការចាត់វិធានការបង្ក្រាបរាល់ទម្រង់នៃការជួញដូរ

នារីនិងការធ្វើអាជីវកម្មនៃពេស្យាកម្មនារី ។

១៤. ភាពក្រីក្រនិងភាពគ្មានការងារធ្វើ បង្កើនឱកាសដល់ការជួញដូរនារី។ បន្ថែមពីលើនេះទៅទៀត វាបង្កើតនូវទម្រង់ការជួញដូរដែលមាន ទម្រង់ថ្មីនៃការធ្វើអាជីវកម្មផ្លូវភេទ ដូចជាទេសចរណ៍ភេទ ការជ្រើសរើសធ្វើការងារក្នុងផ្ទះមកពីប្រទេសកំពុងអភិវឌ្ឍន៍ទៅធ្វើការនៅប្រទេសជឿនលឿន មានការរៀបចំអាពាហ៍ពិពាហ៍រវាងនារីមកពីប្រទេសកំពុងអភិវឌ្ឍន៍ជាមួយនិងជាតិសាសន៍បរទេសនានា។ ការអនុវត្តន៍ បែបនេះវាមិនសមស្របទៅនិងការចូលរួមអនុវត្តសិទ្ធិស្មើភាពគ្នាដោយនារីទេ និង មិនសមស្របទៅនឹងសិទ្ធិកិត្យានុភាពរបស់ពួកគេឡើយ។ គេដាក់នារីឱ្យស្ថិតនៅកន្លែងគ្រោះថ្នាក់នៃអំពើហិង្សា និងការបំពានជាពិសេស ។

១៥. ភាពក្រីក្រនិងការអត់ការងារធ្វើបង្ខំឱ្យនារីជាច្រើន រួមទាំងស្រីក្មេងៗចូលទៅ ក្នុងពេស្យាកម្ម។ ស្រីពេស្យាទទួលរងគ្រោះនូវ អំពើហិង្សាជាពិសេសពីព្រោះតែស្ថានភាពរបស់ពួកគេ ដែលមិនមានលក្ខណៈ ស្របច្បាប់ ហើយនាំឱ្យគេមើលស្រាលដល់ពួកគេ។ ពួកគេត្រូវការការការពារស្មើភាពចំពោះមុខច្បាប់ ប្រឆាំង ការរំលោភ និងប្រឆាំងរាល់ទម្រង់ហិង្សាផ្សេងៗ។

១៦ សង្គ្រាម ជំលោះប្រដាប់អាវុធ និងការកាន់កាប់ទឹកដី ជារឿយៗនាំទៅរកការកើនឡើងនូវពេស្យាកម្ម ការជួញដូរនារី និងការរំលោភបំពានផ្លូវភេទនារី ដែលតម្រូវឱ្យមានវិធានការការការពារ និងវិធានការដាក់ទណ្ឌ កម្មជាក់លាក់។

មាត្រាទី១១

១៧. ភាពស្មើគ្នានៅក្នុងការងារទទួលការចុះខ្សោយយ៉ាងខ្លាំងនៅពេលនារីស្ថិតនៅក្រោមអំពើហិង្សា ជាក់លាក់រវាងភេទ ដូចជា ការយាយីផ្លូវភេទនៅកន្លែងធ្វើការងារ ។

១៨. ការយាយីខាងផ្លូវភេទរួមបញ្ចូលទាំងដូចជាអាកប្បកិរិយាមិនស្វាគមន៍តាមលក្ខណៈភេទ ជាការទាក់ទងផ្លូវកាយនិងការរុលទៅមុខ ការកត់សំគាល់ពណ៌សម្បុរផ្លូវភេទ ការបង្ហាញរូបអាសអាភាស និងការទាមទារផ្លូវភេទ មិនថាជាពាក្យពេចន៍ឬក៏សកម្មភាពឡើយ។ គឺការ ប្រព្រឹត្តិបែបនេះអាចធ្វើឱ្យអាម៉ាស់ និងអាច ធ្វើឱ្យមាននូវបញ្ហាសុវត្ថិភាព និងសុខភាព វាជាការរើសអើងនៅពេលនារីមានមូលដ្ឋានត្រឹមត្រូវដោយជឿ ថាការជំទាស់របស់នាងអាចមានគុណវិបត្តិដល់ការទាក់ទងជាមួយការងាររបស់នាង រួមទាំងការជ្រើសរើសការ ងារ ឬការតំឡើងឋានៈ ឬក៏វាធ្វើឱ្យកើតមាននៅអរិភាពនៅក្នុងបរិស្ថានការងារ។

មាត្រាទី១២

១៩. រដ្ឋភាគីបានត្រូវតំរូវដោយមាត្រា១២ ឱ្យចាត់វិធានការដើម្បីធានានូវការទទួលការថែទាំសុខភាពឱ្យបានស្មើៗគ្នា។ អំពើហិង្សាប្រឆាំងនារីភេទបានធ្វើឱ្យមានគ្រោះថ្នាក់ដល់សុខភាព និងជីវិតរបស់ពួកគេ។

២០. នៅក្នុងរដ្ឋខ្លះមានការប្រតិបត្តិតាមទំនៀមទំលាប់ដែលរក្សាទុកនូវយ៉ាងខ្ជាប់ខ្ជួនតាមវប្បធម៌ និង ប្រពៃណីដែលមានផលប៉ះពាល់គ្រោះថ្នាក់ដល់នារី និងកុមារ។ ការប្រតិបត្តិទាំងនេះរួមបញ្ចូលនូវការដាក់កម្រិត ការតមចំណីអាហារដល់នារីមានផ្ទៃពោះ ការពេញចិត្តសំរាប់កុមារភេទប្រុស និងការកាត់អង្គជាតិភេទស្រី ឬក៏ការវះកាត់អង្គជាតិណាមួយ។

<u>មាត្រា ១៤</u>

២១.

នារីនៅតាមជនបទស្ថិតនៅក្នុងគ្រោះថ្នាក់ដោយសារអំពើហិង្សាយេនឌ័រពីព្រោះឥរិយាបទតាម ទំនៀមទំលាប់ប្រពៃណី ចំពោះតួនាទីនារីនៅក្រោមបង្គាប់ស្ថិតនៅមាននៅក្នុងសហគមន៍ជនបទជាច្រើន។ ក្មេងស្រីមកពីសហគមន៍ជនបទស្ថិតក្នុងអំពើហិង្សា និងការធ្វើអាជីវកម្មផ្លូវភេទជាពិសេស នៅពេលពួកអ្នកទាំងនោះចេញពីសហគមន៍ជនបទមកស្វែងរកការងារធ្វើនៅទីក្រុង។

<u>មាត្រាទី១៦(និងមាត្រាទី៥)</u>

២២. ការរារាំងដោយចាំបាច់ ឬការពន្លួតកូនដោយការជំទាស់បំណង វាធ្វើឱ្យប៉ះពាល់ដល់ សុខភាពផ្លូវកាយ និងផ្លូវចិត្ត និងរំលោភ ដល់សិទ្ធិនារីចំពោះការសំរេចចិត្តអំពីចំនួនកូន និងការពន្យាកំនើតកូន ។

២៣. ហិង្សាគ្រួសា វាជាទម្រង់មួយក្នុងចំណោមទម្រង់ប្រកបដោយកលល្បិចបំផុត នៃអំពើហិង្សាប្រឆាំងនារីភេទ។ ជាទូទៅវាកើតមាននៅក្នុងគ្រប់សង្គម។ នៅក្នុងទំនាក់ទំនងគ្រួសារ នារីគ្រប់អាយុស្ថិតនៅ ក្រោមអំពើហិង្សាគ្រប់ប្រភេទ រួមទាំងការវាយតប់ ការចាប់រំលោភ និងទម្រង់ផ្សេងៗនៃការរំលោភផ្លូវភេទឯទៀត ទម្រង់អំពើហិង្សាផ្លូវចិត្ត និងទំរង់ហិង្សាផ្សេងៗទៀត ដែលបានរក្សាទុកដោយឥរិយាបទតាមទំនៀមទំលាប់។ការខ្វះខាតនូវឯករាជ្យសេដ្ឋកិច្ចបានបង្ខំឱ្យនារីជាច្រើនស្ថិតនៅក្នុងការជាប់ទាក់ទងហិង្សា។ ការបដិសេធដល់ការទទួលខុសត្រូវគ្រួសារដោយបុរសអាចជាទម្រង់នៃអំពើហិង្សា និងទម្រង់នៃការបង្ខិតបង្ខំ។ ទម្រង់នៃអំពើហិង្សាទាំងនេះធ្វើឱ្យមានគ្រោះថ្នាក់ដល់សុខភាពផ្លូវចិត្ត និងធ្វើឱ្យខូចដល់សមត្ថភាពរបស់ពួកគេ ដើម្បីចូលរួមនៅក្នុងជីវិតគ្រួសារ និងជីវិតជាសាធារណៈផ្អែកលើសិទ្ធិស្មើភាព។

អនុសាសន៍ជាក់លាក់

២៤. នៅក្នុងពន្លឺនៃយោបល់ទាំងនេះ គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ចោលការរើសអើង ប្រឆាំងនារីភេទសូមធ្វើការផ្តល់អនុសាសន៍ថា ៈ

ក. រដ្ឋភាគី គួធ្វើការចាត់វិធានការឱ្យបានសមស្រប និងមានប្រសិទ្ធិភាពដើម្បីជំនះរាល់ទម្រង់នៃអំពើហិង្សាយេនឌរ មិនថាវាជាលក្ខណៈសាធារណៈ ឬក៏ជាលក្ខណៈឯកជនឡើយ ។

ខ. រដ្ឋភាគីគួធ្វើការធានាថាច្បាប់ដែលប្រឆាំងអំពើហិង្សាគ្រួសារ និង ការបំពាន ការចាប់រំលោភ ការរំលោភផ្លូវភេទ និងអំពើហិង្សាយេនឌរ ដទៃទៀតត្រូវផ្តល់ការការពារឱ្យបានគ្រប់គ្រាន់ចំពោះនារី គ្រប់រូប ហើយគោរពដល់ភាពសុចរិតនិងកិត្យានុភាពរបស់ពួកគេ ។ សេវាការពារ និងសេវាឧបត្ថម្ភសមស្របគួរត្រូវផ្តល់ឱ្យដល់ជនរងគ្រោះ។ ការបណ្តុះបណ្តាលមន្ត្រីតុលាការ មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីសាធារណៈផ្សេងៗទៀតទទួលបន្ទុកការគ្រោះថ្នាក់ខាងភេទគឺវាមានការចាំបាច់សំរាប់ការអនុវត្តឱ្យបានប្រសិទ្ធិភាពនៃអនុសញ្ញា។

គ. រដ្ឋភាគីគួរធ្វើការជំរុញដល់ការចងក្រងស្ថិតិ និងការស្រាវជ្រាវអំពីវិសាលភាពបុព្វហេតុ និង

ផលប៉ះពាល់នៃអំពើហិង្សា និង ទៅលើប្រសិទ្ធិភាពនៃវិធានការដើម្បីទប់ស្កាត់ និងដោះស្រាយអំពើហិង្សា។

ឃ. ត្រូវចាត់វិធានការប្រកបដោយប្រសិទ្ធិភាព ដើម្បីធានាថាប្រព័ន្ធផ្សព្វផ្សាយត្រូវគោរព និង ជម្រុញការគោរពចំពោះនារីភេទ ។

ង. នៅក្នុងរបាយការណ៍របស់ខ្លួនរដ្ឋភាគីគួរបង្ហាញនូវលក្ខណៈ និងវិសាលភាពនៃឥរិយាបថ ទំនៀមទំលាប់ និងការប្រតិបត្តិដែលរក្សានូវអំពើហិង្សាប្រឆាំងនារីភេទ និងរាល់ប្រភេទហិង្សាផ្សេងៗ ដែលបង្ក

ឡើង ។គេគួររាយការណ៍ពីវិធានការដែលខ្លួនបានធ្វើក្នុងការរៀបចំដើម្បីជំនះអំពើហិង្សានិងផលនៃវិធានការទាំងនោះ។

ច. រដ្ឋត្រូវចាត់វិធានការឱ្យមានប្រសិទ្ធិភាព ដើម្បីជំនះនូវឥរិយាបថ និង ការប្រតិបត្តិទាំងនេះ។ រដ្ឋគួរធ្វើការណែនាំនូវកម្មវិធីអប់រំ និងកម្មវិធីពតិមានសាធារណៈដើម្បីជួយលុបបំបាត់ការរើសអើងដែលធ្វើឱ្យមានការរារាំងដល់សិទ្ធិស្មើភាពនារីភេទ ( អនុសាសន៍លេខ ៣ ១៩៨៧) ។

ជ. វិធានការទប់ស្កាត់ និង ការដាក់ទ័ណ្ឌកម្មជាក់លាក់ គឺជាការចាំបាច់ដើម្បីជំនះដល់ការជួញដូរ និងការធ្វើអាជីវកម្មផ្លូវភេទ។

ឈ. នៅក្នុងរបាយការណ៍របស់ខ្លួនរដ្ឋភាគីត្រូវធ្វើការពិពណ៌នាពីវិសាលភាពនៃរាល់បញ្ហាទាំងនេះហើយនិងវិធានការនានា រួមទាំងបទបញ្ញត្តិព្រហ្មទ័ណ្ឌវិធានការទប់ស្កាត់ និងវិធានការស្តារឡើងវិញ

ដែលគេត្រូវចាត់ធ្វើវាឡើងដើម្បីការពារនារីដែលជាប់ទាក់ទងទៅក្នុងពេស្យាកម្ម ឬស្ថិតនៅក្រោមការជួញដូរ និងទម្រង់ផ្សេងៗទៀតនៃការធ្វើអាជីវកម្មផ្លូវភេទ។ ប្រសិទ្ធិភាពនៃវិធានការទាំងនេះគួរត្រូវគេធ្វើការពិពណ៌នាផងដែរ។

៣. គេគួរផ្តល់ជូននូវនីតិវិធីបណ្តឹង និងការព្យាបាលប្រកបដោយប្រសិទ្ធិភាព រួមទាំងការសងជំងឺចិត្តផងដែរ។

ដ. រដ្ឋភាគី គួរដាក់បញ្ចូលក្នុងរបាយការណ៍របស់ខ្លួន នូវពត៌មានអំពីការយាយីលើផ្នែកភេទ ឬក៏វិធានការដើម្បីការពារនារីកុំឱ្យទទួលនូវការយាយីផ្នែកផ្លូវភេទ និងរួចផុតរាល់ទំរង់ផ្សេងទៀតនៃអំពើហិង្សាដោយបង្ខំនៅកន្លែងធ្វើការងារ។

ឋ. រដ្ឋភាគីគួរបង្កើត ឬផ្តល់នូវការគាំទ្រសេវាសំរាប់ជនរងគ្រោះដោយអំពើហិង្សាគ្រួសារ ការចាប់រំលោភ ការរំលោភផ្លូវភេទ និងរាល់ទំរង់នៃអំពើហិង្សាយេនឌ័រ រួមទាំងទីជម្រក ជាពិសេសបណ្តុះបណ្តាលអ្នកធ្វើការខាងសុខភាព ការធ្វើឱ្យមាននីតិសម្បទា និងការពិគ្រោះយោបល់។

ឌ. រដ្ឋភាគី គួរចាត់វិធានការដើម្បីជំនះការប្រតិបត្តិបែបនេះ និង គួរធ្វើការគិតគូរដល់អនុសាសន៍របស់គណៈកម្មាធិការស្តីពីការកាត់អង្គជាតិនារីភេទ(អនុសាសន៍លេខ១៤)នៅក្នុងការធ្វើរបាយការណ៍អំពីបញ្ហា សុខភាព។

ឍ. រដ្ឋភាគីត្រូវធានាដល់វិធានការដែលបានចាត់ឡើង ដើម្បីទប់ស្កាត់ការបង្ខិតបង្ខំចំពោះបណ្តុះជីវិតនិង ការបន្តពូជ ហើយត្រូវធានាថានារីមិនត្រូវបានគេបង្ខំឱ្យស្វែងរកនូវនីតិវិធីវេជ្ជសាស្ត្រដែលមិនមានសុវត្ថិភាព ដូចជាការពន្លូតកូនខុសច្បាប់ ដោយមិនមានសេវាសមស្រប គ្រប់គ្រាន់ដើម្បីធ្វើការគ្រប់គ្រងឱ្យនៅមានជីវិត។

ណ. នៅក្នុងរបាយការណ៍របស់ខ្លួន រដ្ឋភាគីគួរបញ្ជាក់នូវវិសាលភាពនៃបញ្ហាទាំងនេះ ហើយគួរបង្ហាញ នូវវិធានការដែលត្រូវបានគេចាត់ធ្វើឡើង និងប្រសិទ្ធិភាពរបស់វា។

ត. រដ្ឋភាគី គួរធានាសេវាសំរាប់ជនរងគ្រោះដោយសារអំពើហិង្សា អាចទទួលបានដល់នារីរស់នៅជនបទ ហើយជាពិសេសកន្លែងណា ដែលត្រូវការសេវាចាំបាច់ គឺគេត្រូវធ្វើការផ្តល់ជូនចំពោះសហគមន៍ដែលនៅឯកោទាំងនោះ។

ថ. វិធានការ ដើម្បីការពារពួកគេឱ្យចាកផុតពីអំពើហិង្សា គួរដាក់បញ្ចូលនូវការបណ្តុះបណ្តាលនិងឱកាសការងារ ព្រមជាមួយនិងការត្រួតពិនិត្យនៃលក្ខខ័ណ្ឌការងារនៃអ្នកធ្វើការនៅក្នុងផ្ទះ។

ទ. រដ្ឋភាគីត្រូវរាយការណ៍ អំពីគ្រោះថ្នាក់ចំពោះនារីនៅជនបទ រាយការណ៍នូវវិសាលភាព និង

លក្ខណៈអំពើហិង្សា ការបំពានដែលនារីស្ថិតជាកម្មវត្ថុនៃអំពើទាំងនោះ តំរូវការការគាំទ្រ ហើយសេវានានាព្រមជាមួយសេវាដទៃទៀត និង ប្រសិទ្ធិភាពនៃវិធានការដើម្បីជំនះអំពើហិង្សា ។

ធ. វិធានការដែលចាំបាច់ដើម្បីធ្វើការជំនះនូវអំពើហិង្សាគ្រួសាររួមមានៈ

១. ការដាក់ទ័ណ្ឌកម្មជនល្មើសចាំបាច់និង ការរកដំណោះស្រាយរដ្ឋប្បវេណីនៅក្នុងករណីហិង្សាក្នុងគ្រួសារ ។

២. ធ្វើនីតិកម្ម ដើម្បីលុបបំបាត់ចោលការការពារនៃកិត្តិយសចំពោះការរំលោភបំពាន ឬឃាតកម្ម លើសមាជិកគ្រួសារនារី ។

៣. សេវាដើម្បីធានាសុវត្ថិភាព និង សន្តិសុខរបស់ជនរងគ្រោះ នៃគ្រួសារដែលទទួលរងដោយសារ អំពើហិង្សា រួមទាំងទីជម្រក ការពិគ្រោះ និងកម្មវិធីធ្វើនីតិសម្បទា ។

៤. កម្មវិធីនីតិសម្បទាដល់ជនប្រព្រឹត្តិបទឧក្រិដ្ឋក្នុងគ្រួសារ ។

៥. សេវាគាំទ្រដល់គ្រួសារដែលមានស្ថានការ ឬការរំលោភផ្លូវភេទដែលបានកើតឡើង ។

ន. រដ្ឋភាគីគួរធ្វើរបាយការណ៍អំពីវិសាលភាពនៃអំពើហិង្សាក្នុងគ្រួសារ និងការរំលោភផ្លូវភេទព្រមជាមួយវិធានការទប់ស្កាត់វិធានការដាក់ទ័ណ្ឌកម្មនិងវិធានការដំណោះស្រាយដែលបានចាត់ធ្វើឡើង ។

ប. រដ្ឋភាគីគួរចាត់នូវវិធានការច្បាប់ទាំងអស់ និងវិធានការផ្សេងៗដែលចាំបាច់ដើម្បីផ្តល់នូវការការពារ ប្រកបដោយប្រសិទ្ធិភាពប្រឆាំងនូវអំពើហិង្សាយេនឌ័រ រួមទាំង

១. វិធានការច្បាប់ប្រកបដោយប្រសិទ្ធិភាព រួមទាំងបទបញ្ញត្តិដាក់ទ័ណ្ឌកម្ម ពហុទ័ណ្ឌដំណោះសាយរដ្ឋប្បវេណីនិងបទបញ្ញត្តិសងជម្ងឺចិត្តដើម្បីការពារនារីភេទប្រឆាំងរាល់ទម្រង់នៃអំពើហិង្សាទាំងអស់រួមទាំងអំពើហិង្សានិងការបំពាននៅក្នុងគ្រួសារ ការរំលោភផ្លូវភេទ និងការយាយីផ្លូវភេទ នៅកន្លែងធ្វើការងារ ។

២. វិធានការទប់ស្កាត់ រួមទាំងពត៌មានសាធារណៈនិង កម្មវិធីអប់រំដើម្បីផ្លាស់ប្តូរឥរិយាបថចំពោះតួនាទី និង ស្ថានភាពរបស់បុរសនិងនារី ។

៣. វិធានការការការពារ រួមមាន ទីជម្រក ការពិគ្រោះ ការធ្វើនីតិសម្បទា និងសេវាគាំទ្រចំពោះនារីដែលជាជនរងគ្រោះដោយអំពើហិង្សា ឬអ្នកដែលស្ថិតនៅក្នុងគ្រោះថ្នាក់នៃអំពើហិង្សា ។

ផ. រដ្ឋភាគីគួររាយការណ៍អំពីរាល់ទំរង់ទាំងអស់នៃអំពើហិង្សាយេនឌរ ហើយនិងគួរដាក់បញ្ចូលរបាយការណ៍នោះនូវរាល់ទិន្នន័យដែលមានស្រាប់ទាំងអស់អំពីឧប្បត្តិហេតុនៃទម្រង់ហិង្សា នីមួយៗ និងអំពីផល ប៉ះពាល់ នៃអំពើហិង្សាបែបនោះទៅលើនារី ដែលជាជនរងគ្រោះ ។

៣. របាយការណ៍នៃ រដ្ឋភាគីទាំងនោះត្រូវដាក់ បញ្ចូលនូវពត៌មានស្តី ពីវិធានការច្បាប់ វិធានការទប់ស្កាត់និងវិធានការការពារដែលត្រូវបានគេចាត់ធ្វើឡើងដើម្បីជំនះលើអំពើហិង្សា ប្រឆាំងនារីភេទ និងអំពី ប្រសិទ្ធិភាពនៃវិធានការទាំងនោះ ។

## អនុសាសន៍រួម ទី ២០ (សម័យប្រជុំលើក ទី ១១ ១៩៩២)

ការបំរុងទុកចំពោះអនុសញ្ញា

១- គណៈកម្មាធិការ រំលឹកឡើងវិញពីសេចក្តីសំរេចកិច្ចប្រជុំលើកទី ៤របស់រដ្ឋភាគី ស្តីពីការបំរុងទុកចំពោះអនុសញ្ញា យោងតាមមាត្រាទី ២៨.២ ដែលបានបញ្ចូលក្នុងអនុសាសន៍រួម ទី ៤ របស់គណៈកម្មាធិការ ។

២- ពាក់ពន្ធ័នឹងការរៀបចំសំរាប់សន្និសិទ្ធពិភពលោកស្តីពី សិទ្ធិមនុស្សនៅឆ្នាំ ១៩៩៣ គណៈកម្មាធិការសូមផ្តល់អនុសាសន៍ថា រដ្ឋភាគីគួរតែៈ

a). លើកជាសំនួរស្តីពី បញ្ហាសុពលភាព និងប្រសិទ្ធិភាពច្បាប់នៃការបំរុងទុកចំពោះអនុសញ្ញា ទៅក្នុងបរិបទបំរុងទុកចំពោះសន្និសញ្ញាសិទ្ធិមនុស្សផ្សេងៗទៀត ។

b). ពិចារណាឡើងវិញ ពីការបំរុងទុកនេះ តាមរយៈទស្សនៈពង្រឹងការអនុវត្តន៍សន្និសញ្ញាសិទ្ធិមនុស្សទាំងអស់

c). ពិចារណាណែនាំនិតិវិធីលើការបំរុងទុកចំពោះអនុសញ្ញា ដោយធ្វើការប្រៀបធៀបទៅនឹងសន្និសញ្ញាសិទ្ធិមនុស្សផ្សេងទៀត ។

# អនុសាសន៍ទូទៅទី២១
# សិទ្ធិស្មើភាពនៅក្នុងអាពាហ៍ពិពាហ៍ និងទំនាក់ទំនងគ្រួសារ

(សម័យប្រជុំលើកទី១៣)

១. អនុសញ្ញាស្តីពីការលុបបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី (សេចក្តីសម្រេច មហាសន្និបាត ៣៤/១៨០ ឧបសម្ព័ន្ធ) បានបញ្ជាក់អំពីសារៈសំខាន់នៃសិទ្ធិមនុស្សចំពោះស្ត្រី និងបុរស នៅក្នុង សង្គម និងនៅក្នុងគ្រួសារ ។ អនុសញ្ញានេះ គឺជាអនុសញ្ញាដែលមានសារៈសំខាន់មួយ ក្នុងចំណោមសន្ធិសញ្ញា អន្តរជាតិនានា ដែលទាក់ទងទៅនឹងសិទ្ធិមនុស្ស ។

២. អនុសញ្ញា និងសេចក្តីប្រកាសផ្សេងៗទៀត ក៏បានផ្តល់សារៈសំខាន់យ៉ាងខ្លាំងទៅលើគ្រួសារ និង ស្ថានភាពរបស់នារីនៅក្នុងគ្រួសារ ។ អនុសញ្ញា និងសេចក្តីប្រកាសទាំងនោះ រួមមានសេចក្តីប្រកាសជាសកលនៃ សិទ្ធិមនុស្ស (សេចក្តីសំរេចអង្គមហាសន្និបាត ២១៧/១ទីង កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិស៊ីវិល និងសិទ្ធិ នយោបាយ (សេចក្តីសម្រេច ២២០០/១យយីង ឧបសម្ព័ន្ធ) អនុសញ្ញាស្តីពីសញ្ជាតិនារីដែលរៀបការ (សេចក្តី សម្រេច១០៤០ ១យីង ឧបសម្ព័ន្ធ) អនុសញ្ញាអំពីការព្រមព្រៀងចំពោះអាពាហ៍ពិពាហ៍អាយុអប្បបរិមារៀប អាពាហ៍ពិពាហ៍ និងការចុះលិខិតអាពាហ៍ពិពាហ៍ (សេចក្តីសំរេច១៧៦៣/១យ្យីង ឧបសម្ព័ន្ធ) និង អនុសាសន៍នានា (សេចក្តីសម្រេច២០១៨ ១យយង និងយុទ្ធសាស្ត្រសម្លឹងទៅមុខនៅដើម្បីអភិវឌ្ឍន៍នារី ក្រុង ណាយរ៉ូប៊ី ។

៣. អនុសញ្ញាស្តីពីការលុបបំបាត់ចោលរាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី បានបញ្ជាក់ឡើងវិញ អំពីសិទ្ធិដែលមិនអាចដកហូតបានរបស់នារី ហើយដែលត្រូវបានគេដាក់បញ្ចូលជាស្រេចនៅក្នុងអនុសញ្ញា និង សេចក្តីប្រកាសដូចដែលបានលើកឡើងខាងលើ ប៉ុន្តែអនុសញ្ញានេះក៏បានចូលស៊ីជម្រៅថែមទៀត ដោយទទួល ស្គាល់អំពីសារៈសំខាន់នៃវប្បធម៌ និងប្រពៃណី ថាមានឥទ្ធិពលទៅលើការគិតគូរ និងចរិកលក្ខណៈរបស់បុរស និងនារី និងឧបសគ្គនៃវប្បធម៌ និងប្រពៃណី ទៅលើស្ត្រី ក្នុងការអនុវត្តន៍សិទ្ធិជាមូលដ្ឋានរបស់ខ្លួន ។

ប្រវត្តិកាល

៤. មហាសន្និបាតបានជ្រើសរើសយកឆ្នាំ១៩៩៤ ជាឆ្នាំអន្តរជាតិនៃគ្រួសារ តាមរយៈសេចក្តីសម្រេច លេខ ៤៤/៨២ ។ គណៈកម្មាធិការបានឆ្លៀតយកឱកាសនេះ ដើម្បីបញ្ជាក់អំពីសារៈសំខាន់នៃការអនុវត្តន៍សិទ្ធិ ជាមូលដ្ឋានរបស់នារីនៅក្នុងគ្រួសារ ជាវិធានការមួយក្នុងចំណោមវិធានការទាំងឡាយដែលនឹងផ្តល់ការគាំទ្រ និងលើកទឹកចិត្តដល់ថ្នាក់ជាតិ ក្នុងការរៀបចំពិធីអបអរសាទ ។

៥. គណៈកម្មាធិការ បានជ្រើសរើស ឆ្នាំនេះជាឆ្នាំនៃគ្រួសារអន្តរជាតិ ដោយធ្វើការវិភាគលើមាត្រា ចំនួន៣ នៅក្នុងអនុសញ្ញាដែលមានសារៈសំខាន់ជាពិសេសសំរាប់ស្ថានភាពនារី នៅក្នុងគ្រួសារ :

មាត្រា៩

១. រដ្ឋភាគីត្រូវផ្តល់ឱ្យនារីមានសិទ្ធិស្មើភាពគ្នាជាមួយបុរសចំពោះការទទួលយក ការផ្លាស់ប្តូរឬការរក្សាទុកនូវសញ្ជាតិរបស់ខ្លួន។ ជាពិសេស រដ្ឋភាគីត្រូវធានាថាការរៀបការជាមួយជនបរទេស ឬក៏ផ្លាស់ប្តូរសញ្ជាតិតាមស្វាមីនៅពេលរៀបការ នឹងពុំអាចធ្វើការផ្លាស់ប្តូរសញ្ជាតិភរិយាបានដោយស្វ័យប្រវត្តិឡើយ ហើយនឹងពុំអាចធ្វើឱ្យនាងជាមនុស្សដែលមានប្រទេសជាតិ ឬក៏ជំរុញឱ្យនាងទៅតាមសញ្ជាតិរបស់ស្វាមីនោះឡើយ។

២. រដ្ឋភាគីត្រូវផ្តល់ឱ្យនារីមានសិទ្ធិស្មើភាពគ្នាជាមួយបុរស នៅពេលត្រូវសំរេចដាក់សញ្ជាតិដល់កូនរបស់គេ។

យោបល់

៦. សញ្ជាតិ គឺមានសារៈសំខាន់ណាស់ចំពោះការចូលរួមនៅក្នុងសង្គមប្រកបដោយភាពពេញលេញ។ ជាទូទៅ រដ្ឋត្រូវផ្តល់សញ្ជាតិឱ្យអ្នកទាំងឡាយណាដែលបានកើតនៅក្នុងប្រទេសរបស់ខ្លួន។ សញ្ជាតិអាចត្រូវបានគេផ្តល់ជូនទៅតាមហេតុផលនៃការរស់នៅ ឬអាចផ្តល់ឱ្យតាមហេតុផលមនុស្សធម៌ដូចជាជនគ្មានប្រទេសជា ដើម។ បើសិនជាគ្មានសញ្ជាតិ ឬពុំមែនជាប្រជាពលរដ្ឋនោះទេ នារីមិនមានសិទ្ធិធ្វើការបោះឆ្នោត ឬឈរឈ្មោះសម្រាប់មុខតំណែងសាធារណណាមួយបានទេហើយនឹងអាចត្រូវគេធ្វើការបដិសេធមិនឱ្យទទួលបានផលប្រយោជន៍ពីការចូលរួមក្នុងវិស័យសាធារណៈ និងការជ្រើសរើសការតាំងទីលំនៅទៀតផង។ នារីពេញវ័យត្រូវមានលទ្ធភាពក្នុងការផ្លាស់ប្តូរសញ្ជាតិ និងសញ្ជាតិរបស់គាត់ ពុំត្រូវបានគេដកតាមទំនើងចិត្ត ដោយសារតែការរៀបអាពាហ៍ពិពាហ៍ ឬការលុបចោលអាពាហ៍ពិពាហ៍ ឬមកពីមូលហេតុស្វាមី ឬក៏ឪពុករបស់គេប្តូរសញ្ជាតិនោះទេ។

មាត្រា១៥

១. រដ្ឋភាគីត្រូវផ្តល់ឱ្យនារីនូវសិទ្ធិស្មើភាពជាមួយបុរសនៅចំពោះមុខច្បាប់។

២. ក្នុងបញ្ហារដ្ឋប្បវេណីរដ្ឋភាគី ត្រូវផ្តល់ឱ្យនារីនូវសមត្ថភាពខាងច្បាប់ឱ្យដូចគ្នាទៅនឹងបុរស និងផ្តល់ឱកាសស្មើគ្នាដើម្បីអោយស្ត្រីអាចប្រើនូវសមត្ថភាពនោះ។ ជាពិសេសរដ្ឋភាគីត្រូវផ្តល់ឱ្យនារីនូវសិទ្ធិស្មើគ្នាចំពោះការសំរេចនៃកិច្ចសន្យា និងដើម្បីគ្រប់គ្រងនូវទ្រព្យសម្បត្តិ

ហើយនិងផ្តល់នូវភាពស្មើៗគ្នា នៅក្នុងគ្រប់ដំណាក់កាលនៃនីតិវិធីនៅក្នុងតុលាការក៏ដូច ជាសាលាក្តី ។

៣. រដ្ឋភាគីត្រូវយល់ព្រមថារាល់កិច្ចសន្យា និងលិខិតុបករណ៍ឯកជនដទៃទៀតដែលជា ឧបសគ្គ ដល់សមត្ថភាពផ្នែកច្បាប់របស់នារី នឹងត្រូវចាត់ទុកជាមោឃៈ ។

៤. រដ្ឋភាគីត្រូវផ្តល់ឱ្យបុរស និងនារីមានសិទ្ធិស្មើភាពគ្នា នៅក្នុងច្បាប់ទាំងឡាយណាដែល ទាក់ទងទៅដល់ការដើរហើររបស់មនុស្ស និងសេរីភាពការជ្រើសរើសការតាំងទីលំនៅ និងលំនៅ ដ្ឋាន ។

យោបល់

៧. នៅពេលស្ត្រីម្នាក់មិនអាចចុះកិច្ចសន្យាបាន ឬគ្មានឱកាសទទួលបានឥណទានហិរញ្ញវត្ថុ ឬក៏អាច ទទួលបាន ប៉ុន្តែទាល់តែមានការព្រមព្រៀង ឬការធានាពីស្វាមី ឬសាច់ញាតិខាងស្វាមីរបស់នាង នេះគឺមាន ន័យថាស្ត្រីត្រូវបានគេបដិសេធនូវភាពស្វ័យភាពតាមផ្លូវច្បាប់ ។ ឧបសគ្គទាំងនោះ គឺរួមទាំងឧបសគ្គរារាំងទាំង ឡាយណាដែលរារាំងស្ត្រីមិនឱ្យកាន់កាប់ទ្រព្យសម្បត្តិកម្មសិទ្ធិផ្ទាល់ខ្លួន មិនឱ្យស្ត្រីអាចធ្វើការគ្រប់គ្រងអាជីវ-កម្មផ្ទាល់ខ្លួននាងស្របតាមលក្ខណៈច្បាប់ ឬរារាំងស្ត្រីមិនឱ្យចុះនូវក្នុងទម្រង់បែបបទណាមួយ តាមផ្លូវច្បាប់នៃ កិច្ចសន្យា ។ ឧបសគ្គទាំងនេះ នឹងរារាំងយ៉ាងធ្ងន់ធ្ងរ ដល់សមត្ថភាពរបស់ស្ត្រី ក្នុងការប្រកបការងារសំរាប់ខ្លួន ផ្ទាល់ និងសម្រាប់អ្នកដែលនៅក្រោយការគ្រប់គ្រងរបស់ស្ត្រី ។

៨. នៅក្នុងប្រទេសមួយចំនួន ច្បាប់បានដាក់កំរិតទៅលើសិទ្ធិរបស់នារីក្នុងការធ្វើបណ្តឹងវិវាទ ឬសិទ្ធិ របស់ស្ត្រីនៅមានកំរិតដោយសារតែខ្វះ ឱកាសទទួលបានប្រឹក្សាយោបល់ផ្នែកច្បាប់ និងដោយសារតែខ្វះលទ្ធ-ភាពក្នុងការស្វែងរកដំណោះស្រាយពីតុលាការ ។ ម្យ៉ាងទៀតស្ត្រីពុំទទួលបានការគោរព ឬការអោយទំងន់ដូច បុរស នៅពេលដែលស្ត្រីត្រូវធ្វើជាសាក្សី ឬជាភ័ស្តុតាងដូចបុរសដែរនោះ ។ ច្បាប់ ឬក៏ទំនៀមទំលាប់បែបនោះ បានកំរិតទៅលើសិទ្ធិរបស់ស្ត្រី ក្នុងការស្វែងរកប្រកបដោយប្រសិទ្ធិភាព ឬទទួលបាននូវភាគចំណែកស្មើគ្នានៃ ទ្រព្យសម្បត្តិ និងកាត់បន្ថយសមត្ថភាពរបស់ស្ត្រី ជាសមាជិកឯករាជ្យ មានការទទួលខុសត្រូវ និងជាសមាជិក ដែលមានតំលៃនៅក្នុងសហគមន៍របស់ស្ត្រី ។ នៅពេលប្រទេសកំនត់សមត្ថភាពផ្លូវច្បាប់របស់ស្ត្រី តាមរយៈ ច្បាប់របស់ប្រទេសនោះ ឬក៏អនុញ្ញាតអោយឯកត្តជន ឬស្ថាប័ន កំរិតសមត្ថភាពរបស់ស្ត្រី គឺមានន័យថា ប្រទេសនោះ កំពុងបដិសេធសិទ្ធិស្មើភាពរបស់ស្ត្រី ជាមួយនឹងបុរស ហើយក៏កំពុងដាក់កំរិតលើសមត្ថភាព របស់ស្ត្រី ក្នុងការប្រកបការងារសំរាប់ខ្លួនផ្ទាល់ និងសំរាប់អ្នកដែលនៅក្រោយការគ្រប់គ្រងរបស់ស្ត្រី ។

៩. លំនៅដ្ឋាន គឺជាពាក្យផ្លូវច្បាប់នៅក្នុងច្បាប់សាមញ្ញរបស់ប្រទេស ដែលសំដៅទៅលើប្រទេសដែល មនុស្សនោះមានបំណងតាំងទីលំនៅ និងសំដៅដល់យុត្តាធិការរបស់ប្រទេសដែលស្ត្រី នឹងដាក់ពាក្យសុំ ។ លំនៅ

ដ្ឋានរបស់កូន គឺដាក់តាមឪពុកម្ដាយរបស់កូន ប៉ុន្តែនៅពេលពេញវ័យ លំនៅដ្ឋានរបស់ជនណាម្នាក់ គឺជាប្រទេសដែលមនុស្សនោះ រស់នៅជាធម្មតា និងជាប្រទេសដែលគាត់មានបំណងចង់រស់នៅជាអចិន្ត្រៃយ៍។ ដូចក្នុងករណីសញ្ជាតិដែរ ការត្រួតពិនិត្យមើលលើរបាយការណ៍រដ្ឋភាគី បានបង្ហាញឱ្យឃើញថា ជានិច្ចកាលស្ត្រីមិនត្រូវបានគេអនុញ្ញាតតាមច្បាប់ ក្នុងការជ្រើសរើសការតាំងទីលំនៅផ្ទាល់ខ្លួនរបស់នាងឡើយ។ ការតាំងទីលំនៅក៏ដូចជាសញ្ជាតិដែរ គួរតែអាចផ្លាស់ប្ដូរបានតាមបំណងរបស់ស្ត្រីពេញវ័យ ដោយមិនគិតពីស្ថានភាពប្ដីប្រពន្ធរបស់នាងទេ។ ការរឹតត្បិតណាមួយទៅលើសិទ្ធិនារីចំពោះការជ្រើសរើសការតាំងទីលំនៅ ផ្អែកលើមូលដ្ឋានដូចគ្នានឹងបុរស គឺអាចជាឧបសគ្គដល់ស្ត្រីក្នុងការងារពាក់ព័ន្ធនឹងតុលាការ នៅក្នុងប្រទេសដែលនាងរស់នៅ ឬអាចជាឧបសគ្គរារាំងមិនឱ្យស្ត្រីអាចចូលទៅប្រទេស និងចាកចេញពីប្រទេស ដោយសេរី និងទៅតាមសិទ្ធិរបស់ខ្លួន។

១០. នារីជាអន្តោប្រវេសន្ត៍ ដែលរស់នៅ និងធ្វើការបណ្ដោះអាសន្ននៅក្នុងប្រទេសមួយទៀត គួរត្រូវបានគេផ្ដល់នូវសិទ្ធិស្មើគ្នានិងបុរស ក្នុងការអនុញ្ញាតឱ្យប្ដី ដៃគូរ និងកូនចៅ មករស់នៅជាមួយពួកគេ។

## មាត្រា១៦

១. រដ្ឋភាគី នឹងប្រកាន់យកគ្រប់វិធានការណ៍សមស្របទាំងអស់ ដើម្បីបំបាត់ការរើសអើងប្រឆាំងនារីភេទនៅក្នុងគ្រប់វិស័យដែលទាក់ទិនទៅនឹងអាពាហ៍ពិពាហ៍ និងទំនាក់ទំនងគ្រួសារនិងជាពិសេស ដោយឈរលើមូលដ្ឋានសមភាពរវាងបុរសនិងនារី និងធានានូវៈ

ក. សិទ្ធិដូចគ្នាក្នុងអាពាហ៍ពិពាហ៍។

ខ. សិទ្ធិដូចគ្នាក្នុងសេរីភាពជ្រើសរើសគូស្រករ និងរៀបអាពាហ៍ពិពាហ៍ដោយការស្ម័គ្រចិត្តទាំង ស្រុង និងដោយគ្មានការបង្ខិតបង្ខំ។

គ. សិទ្ធិ និងការទទួលខុសត្រូវដូចគ្នា នៅក្នុងចំណងអាពាហ៍ពិពាហ៍ និងការរំលាយកិច្ចអាពាហ៍ពិពាហ៍នេះ។

ឃ. សិទ្ធិនិងការទទួលខុសត្រូវដូចគ្នា នៅក្នុងតួនាទីជាឪពុកម្ដាយនៅគ្រប់វិស័យដែលទាក់ទិនទៅនឹងកូនចៅខ្លួន ដោយមិនគិតពីស្ថានភាពអាពាហ៍ពិពាហ៍។ នៅក្នុងគ្រប់ករណីទាំងអស់ ផលប្រយោជន៍កូនចៅត្រូវស្ថិតនៅជាបញ្ហាចំបង ។

ង. សិទ្ធិដូចគ្នាក្នុងការសំរេចដោយគ្មានការបង្ខិតបង្ខំនៅក្នុងស្មារតីទទួលខុសត្រូវនូវចំនួនកូន និងចន្លោះពេលដែលត្រូវមានកូន ហើយនិងការទទួលបាននូវពត៌មានការអប់រំ និងមធ្យោបាយនានាដែលអាចឱ្យនារីប្រើប្រាស់បាននូវសិទ្ធិទាំងឡាយនេះ។

ច. សិទ្ធិនិងការទទួលខុសត្រូវដូចគ្នានៅក្នុងការថែទាំទទួលបន្ទុកធ្វើអាណាព្យាបាល និងការទទួលចិញ្ចឹមកូនអ្នកដទៃ ឬក៏ ក្នុងទំរង់ច្បាប់ដូចគ្នានេះ បើសិនជាគោលគំនិតទាំងនេះមាននៅក្នុងបញ្ញត្តិច្បាប់ប្រទេសជាតិហើយ ។ នៅគ្រប់ករណីទាំងអស់ផល ប្រយោជន៍របស់កូនចៅស្ថិតនៅជាចំបង ។

ឆ. សិទ្ធិជាបុគ្គលដូចគ្នាក្នុងតួនាទីជាប្តីនិងប្រពន្ធ រួមបញ្ចូលទាំងការជ្រើសរើសនាមត្រកូល វិជ្ជាជីវៈនិងមុខរបរផងដែរ ។

ជ. សិទ្ធិដូចគ្នារវាងប្តី និងប្រពន្ធ ក្នុងការកាន់កាប់ ការទទួលបាន ការចាត់ចែង ការគ្រប់គ្រង ការទទួលផល និងការប្រើប្រាស់កម្មសិទ្ធិ ទោះជាដោយមិនគិតថ្លៃ ឬគិតថ្លៃក្តី ។

**២.** ការភ្ជាប់ពាក្យ និងការរៀបអាពាហ៍ពិពាហ៍បុត្រធីតា ពុំត្រូវមានឥទ្ធិពលផ្នែកផ្លូវច្បាប់មកប៉ះពាល់នោះឡើយ ហើយត្រូវចាត់គ្រប់វិធានការចាំបាច់ រួមបញ្ចូលទាំងបញ្ញត្តិច្បាប់ផង ដើម្បីកំណត់អំពីអប្បរមានៃ អាយុសំរាប់ការរៀបអាពាហ៍ពិពាហ៍ និងធ្វើការបង្ខំអោយមានការចុះបញ្ជីអាពាហ៍ពិពាហ៍ជាផ្លូវការ ។

## យោបល់

### <u>ជីវិតសាធារណៈ និងជីវិតឯកជន</u>

១១. តាមប្រវត្តិសាស្រ្ត សកម្មភាពមនុស្សនៅក្នុងជីវិតសាធារណៈ និងជីវិតឯកជនត្រូវបានគេមើលឃើញខុសៗគ្នា និងត្រូវបានគេធ្វើនិយតកម្ម ទៅតាមភាពខុសគ្នានោះ ។ នៅគ្រប់សង្គមទាំងអស់ និងជាយូរមកហើយ តួនាទីការងារជាប្រពៃណីរបស់នារី នៅក្នុងផ្នែកឯកជន ឬនៅក្នុងគ្រួសារ ត្រូវបានគេចាត់ទុកថាជាការងារថ្នាក់ទាប ។

១២. ដោយសារតែសកម្មភាពបែបនេះ ពុំមានតំលៃដល់ការរស់រានរបស់សង្គម ដូច្នេះហើយពុំមានការហេតុផលគាំទ្រ ដើម្បីអោយមានការអនុវត្តន៍ខុសប្លែកពីនេះ និងការកែប្រែច្បាប់ ឬប្រពៃណីទំនៀមទំលាប់ដែលមានការរើសអើងប្រឆាំងនឹងស្ត្រី ។ តាមរបាយការណ៍របស់រដ្ឋភាគី បង្ហាញអោយឃើញថានៅមានប្រទេសជាច្រើនដែលសិទ្ធិស្មើភាពតាមផ្លូវច្បាប់នៅមិនទាន់មាននៅឡើយ ។ ដោយហេតុនោះហើយស្ត្រី ត្រូវបានគេរារាំងមិនឱ្យទទួលបានធនធានស្មើគ្នា និងមិនទទួលបានតួនាទី និងឋានៈស្មើភាពនៅក្នុងគ្រួសារនិងក្នុងសង្គម ។ ទោះបីជាសិទ្ធិស្មើភាពតាមច្បាប់មានក៏ដោយ ក៏សង្គមខ្លះបានកំណត់តួនាទីខុសគ្នារវាងស្ត្រី និងបុរស ដែលតួនាទីរបស់ស្ត្រី ត្រូវបានគេចាត់ទុកជាតួនាទីទាបជាងតួនាទីរបស់បុរស ។ ក្នុងករណីនេះ គឺរំលោភទៅនឹងគោលការណ៍យុត្តិធម៌ និងសមភាពសំរាប់ប្រជាពលរដ្ឋទាំងអស់ ដែលមានចែងនៅក្នុងអនុសញ្ញា ជាពិសេសមាត្រា១៦ និងមាត្រា ២,៥ និង២៤ ។

**ទម្រង់ខុសគ្នានៃគ្រួសារ**

១៣. ទម្រង់ និងទស្សនៈស្តីពីគ្រួសារ អាចមានការខុសគ្នាពីរដ្ឋមួយទៅរដ្ឋមួយ និងសូម្បីតែនៅក្នុងតំបន់នានា នៅក្នុងប្រទេសតែមួយ ។ ទោះជាមានការប្រកាន់ទម្រង់បែបណាក៏ដោយ ប្រកាន់ប្រព័ន្ធច្បាប់ សាសនា ទំនៀមទំលាប់ ឬប្រពៃណីយបែបណាក៏ដោយ ប៉ុន្តែការប្រតិបត្តិទៅលើនារីនៅក្នុងគ្រួសារ ទៅតាម ផ្លូវច្បាប់ និងតាមលក្ខណៈឯកជន ត្រូវតែស្របតាមគោលការណ៍សិទ្ធិស្មើភាព និងគោលការណ៍យុត្តិធម៌សំរាប់ មនុស្សគ្រប់រូប ដូចចែងនៅក្នុងមាត្រា២ នៃអនុសញ្ញា ។

**អាពាហ៍ពិពាហ៍ពហុពន្ធ**

១៤. របាយការណ៍របស់រដ្ឋភាគីបានលាតត្រដាងឱ្យឃើញផងដែរថា ពហុពន្ធភាពត្រូវបានគេអនុវត្តនៅក្នុងប្រទេសមួយចំនួន ។ អាពាហ៍ពិពាហ៍ពហុពន្ធបានរំលោភដល់សិទ្ធិស្មើភាពរបស់នារី ជាមួយនឹងបុរស និង អាចធ្វើឱ្យមាននៅផលវិបាកផ្នែកផ្លូវចិត្ត និងហិរញ្ញវត្ថុធ្ងន់ធ្ងរដល់នាង និងអ្នកនៅក្រោមបន្ទុករបស់ស្ត្រី ដូច្នេះ ហើយអាពាហ៍ពិពាហ៍បែបនេះ ពុំគួរអោយកើតមាន និងត្រូវតែហាមឃាត់ ។ គណៈកម្មាធិការបានកត់សំគាល់ ឃើញថា រដ្ឋភាគីខ្លះដែលរដ្ឋធម្មនុញ្ញរបស់ខ្លួន បានធានានូវសិទ្ធិស្មើភាព ប៉ុន្តែបានអនុញ្ញាតឱ្យមានអាពាហ៍ពិពាហ៍ពហុពន្ធ ដោយគិតថានេះជាច្បាប់ផ្ទាល់ខ្លួន ឬជាទំនៀមទម្លាប់ ។ ករណីនេះបានរំលោភដល់សិទ្ធិរបស់ នារីនៅក្នុងរដ្ឋធម្មនុញ្ញ និងរំលោភដល់មាត្រាទី ៥ (ក) របស់អនុសញ្ញា ។

មាត្រា១៦ (១)(ក) និង (ខ)

១៥. នៅខណៈពេលប្រទេសជាច្រើនបានរាយការណ៍ថា រដ្ឋធម្មនុញ្ញ និងច្បាប់ជាតិស្របតាមអនុសញ្ញា ប៉ុន្តែទំនៀមទំលាប់ប្រពៃណី និងការខកខានមិនបានធ្វើការអនុវត្តន៍ច្បាប់ទាំងនេះ គឺមានន័យថារំលោភលើ អនុសញ្ញានេះ ។

១៦. សិទ្ធិនារីចំពោះការជ្រើសរើសគូរស្រករ និងការទទួលយកអាពាហ៍ពិពាហ៍ដោយសេរី គឺជាចំនុច សំខាន់សម្រាប់ជីវិតរបស់នាង ជាភាពថ្លៃថ្នូរ និងសមភាពជាមនុស្សជាតិ ។ ការពិនិត្យលើរបាយការណ៍របស់ រដ្ឋភាគី បានបង្ហាឱ្យឃើញថា នៅមានប្រទេសមួយចំនួនដែលផ្អែកលើទំនៀមទម្លាប់ ជំនឿសាសនា ឬទំនៀម ទម្លាប់របស់ក្រុមជនជាតិភាគតិច នៅតែអនុវត្តការរៀបការដោយបង្ខំ ឬក៏ឱ្យមានការរៀបការជាថ្មី ។ ប្រទេស ខ្លះទៀតបានអនុញ្ញាតិការរៀបការរបស់នារី ត្រូវគេរៀបចំឡើង ជាការទូទាត់សង ឬទៅតាមចំណង់ចិត្តរបស់ អ្នកណាម្នាក់ ហើយនៅក្នុងប្រទេសខ្លះទៀត ភាពក្រីក្ររបស់ស្ត្រី បានបង្ខំឱ្យស្ត្រី ត្រូវរៀបការជាមួយជន បរទេស

ដើម្បីធានានូវបញ្ហាហិរញ្ញវត្ថុ ។ នៅក្រោមការដាក់កំរិតសមស្រប ឧទាហរណ៍ដោយផ្អែកលើយុវវ័យ ភាពរបស់ស្ត្រី ឬដោយផ្អែកលើខ្សែលោហិតជាមួយដៃគូរបស់នាង សិទ្ធិរបស់នារីក្នុងការជ្រើសរើសពេលវេលា និងមនុស្សដែលនាងនឹងរៀបការជាមួយ ត្រូវតែទទួលបានការគោរព និងអនុវត្តនៅក្នុងច្បាប់ ។

មាត្រា១៦ (១) (គ)

១៧. ការពិនិត្យលើរបាយការណ៍រដ្ឋភាគីបានបង្ហាញឱ្យឃើញថា ប្រព័ន្ធច្បាប់របស់ប្រទេសជាច្រើនបានផ្តល់សិទ្ធិ និងការទទួលខុសត្រូវចំពោះដៃគូដែលបានរៀបការ ទៅតាមការអនុវត្តន៍ច្បាប់សាមញ្ញ ច្បាប់សាសនា ឬទំនៀមទម្លាប់ ជាជាងការអនុវត្តន៍តាមគោលកាណ៍ដែលមាននៅក្នុងអនុសញ្ញា ។ ការខុសគ្នានៅក្នុងច្បាប់ និងការអនុវត្តន៍ដែលទាក់ទិនទៅនឹងអាពាហ៍ពិពាហ៍ បានផ្តល់ផលវិបាកយ៉ាងធំធេងចំពោះនារី ដូចជាការដាក់កម្រិតលើសិទ្ធិរបស់ស្ត្រី ក្នុងការទទួលបានតួនាទី ស្ថានភាព និងការទទួលខុសត្រូវស្មើគ្នានៅក្នុងអាពាហ៍ពិពាហ៍ ។ លទ្ធផលនៃការកំរិតបែបនេះជារឿយៗ គឺការចាត់ទុកស្វាមី ជាមេគ្រួសារ និងជាមនុស្សសំខាន់ក្នុងការធ្វើការសម្រេច - ករណីនេះ គឺរំលោភលើបទបញ្ញត្តិរបស់អនុសញ្ញា ។

១៨. លើសពីនេះទៅទៀត ជាទូទៅស្ថានភាពជាក់ស្តែងនៃគ្រួសារ គឺពុំដូចអ្វីដែលច្បាប់ បានចែងនោះឡើយ ។ ស្ត្រីដែលរស់នៅក្នុងចំណងអាពាហ៍ពិពាហ៍ គួរតែទទួលបានភាពស្មើគ្នាជាមួយនិងបុរស ទាំងនៅក្នុងជីវិតគ្រួសារ និងនៅក្នុងការចែករំលែកប្រាក់ចំណូល និងទ្រព្យសម្បត្តិ ដូចដែលមានចែងនៅក្នុងច្បាប់ ។ ស្ត្រីគួរតែទទួលបាននូវសិទ្ធិ និងការទទួលខុសត្រូវស្មើគ្នាជាមួយបុរស ក្នុងការបីបាច់ថែទាំ និងការចិញ្ចឹមកូននៅក្នុង បន្ទុក ឬសមាជិកគ្រួសារ ។

មាត្រា១៦ (១) (ឃ) និង (ង)

១៩. ដូចមានចែងនៅក្នុងមាត្រា៥ (ខ) រដ្ឋភាគីភាគច្រើន បានទទួលស្គាល់នូវការចែករំលែកការទទួលខុសត្រូវរបស់មាតាបិតាចំពោះការថែទាំ ការការពារ និងថែរក្សាកូនចៅ ។ គោលការណ៍ដែលចែងថា "អត្ថប្រយោជន៍របស់កុមារ គឺត្រូវទទួលបាននូវការពិចារណាខ្ពស់" ត្រូវបានគេដាក់បញ្ចូលនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ (សេចក្តីសម្រេចលេខ ៤៤/២៥ ឧបសម្ព័ន្ធ នៅក្នុងមហាសន្និបាត) ហើយបច្ចុប្បនេះដូចជាត្រូវបានគេទទួលស្គាល់ជាសកលហើយ ។ តែទោះជាយ៉ាងនេះក៏ដោយ ប្រទេសមួយចំនួន មិនបានធ្វើការអង្កេតលើការអនុវត្តន៍ជាក់ស្តែង នៃគោលការណ៍ដែលផ្តល់ឱ្យមាតាបិតារបស់ កុមារនូវតួនាទីស្មើគ្នានោះទេ ជាពិសេសនៅពេលដែលឪពុកម្តាយមិនទាន់បានរៀបការ ។ កុមារដែលស្ថិតក្នុងស្ថានភាពបែបនេះ ជានិច្ចកាលមិនបានទទួលនូវ

ស្ថានភាពដូចអ្នកដែលបានកើតនៅក្នុងឪពុកម្តាយជាប្តីប្រពន្ធ ហើយកូនដែលមានម្តាយត្រូវបានប្តីលែងលះ ឬ រស់នៅបែកពីគ្នា នោះឪពុកភាគច្រើន ពុំបានចែករំលែកការទទួលខុសត្រូវក្នុងការថែទាំ ការការពារ និងការថែរក្សាកូនទេ។

២០. សិទ្ធិស្មើគ្នា និងការចែករំលែកការទទួលខុសត្រូវ ដែលមានចែងនៅក្នុងអនុសញ្ញា ត្រូវតែអនុវត្តនៅក្នុងច្បាប់ និងក្នុងករណីសមស្រប ត្រូវអនុវត្តតាមរយៈការអនុវត្តតាមផ្លូវច្បាប់នៃភាពជាអាណាព្យាបាល ការគោរពប្រតិបត្តិ ការទុកចិត្តគ្នាទៅវិញទៅមក និងការយកកូនមកចិញ្ចឹម។ រដ្ឋភាគី គួរធ្វើការធានា ដោយច្បាប់របស់ខ្លួនថា មាតាបិតាទាំងពីរត្រូវចែករំលែកសិទ្ធិ និងការទទួលខុសត្រូវចំពោះកូនរបស់គេ ស្មើៗគ្នា ដោយមិនគិតលើស្ថានភាពអាពាហ៍ពិពាហ៍របស់ពួកគេ និងដោយមិនគិតថាតើពួកគេរស់នៅជាមួយកូនរបស់ខ្លួនឬអត់។

មាត្រា១៦(១)(ច)

២១. ការទទួលខុសត្រូវដែលនារីត្រូវទទួល និងការចិញ្ចឹមបីបាច់កូន ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ស្ត្រីក្នុងការទទួលបានការអប់រំ ការងារ និងសកម្មភាពនានាដែលទាក់ទងទៅនឹងការអភិវឌ្ឍន៍ផ្ទាល់ខ្លួនរបស់ស្ត្រី។ ការទទួលខុសត្រូវទាំងនោះ ក៏បានដាក់បន្ថែមនូវបន្ទុកការងារអសមភាពទៅលើស្ត្រី។ ចំនួនកូន និងការពន្យារកំនើតកូន ក៏មានឥទ្ធិពលដូចគ្នាផងដែរ ទៅលើជីវិតរបស់ស្ត្រី ហើយក៏បានប៉ះពាល់ផងដែរ ដល់សុខភាពផ្លូវកាយ និងផ្លូវចិត្ត និងក៏ប៉ះពាល់ផងដែរដល់សុខភាពកូនរបស់គេ។ ដោយសារហេតុផលទាំងនេះ ស្ត្រីត្រូវមានសិទ្ធិក្នុងការសម្រេចចំនួនកូន និងការពន្យាកំណើតកូនរបស់ខ្លួន។

២២. របាយការណ៍ខ្លះបានលាតត្រដាងឱ្យឃើញនូវការអនុវត្តន៍ដោយបង្ខិតបង្ខំ ដែលបណ្តាលអោយមានគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរដល់ស្ត្រី ដូចជាការមានផ្ទៃពោះដោយបង្ខំ ការពន្លូតកូន ឬការធ្វើមិនអោយមានកូន។ ទោះបីជាការពិគ្រោះជាមួយប្តីប្រពន្ធ ឬដៃគូរគឺជាចំណុចល្អក្នុងការសំរេចចំនួនកូន ប៉ុន្តែសហព័ន្ធ ឪពុកម្តាយ ឬរដ្ឋាភិបាល ពុំគួរដាក់កំរិតចំពោះការសម្រេចនេះទេ។ ដើម្បីធ្វើការសំរេចចិត្តអោយបានសមស្របអំពីវិធានការប្រកបដោយសុវត្ថិភាព និងអំពីមធ្យោបាយពន្យារកំណើតដែលអាចទុកចិត្តបាន នារីត្រូវទទួលពត៌មានអំពីមធ្យោបាយពន្យារកំណើត និងការប្រើប្រាស់មធ្យោបាយទាំងនោះ និងទទួលបានការអប់រំផ្លូវភេទ ដែលបាន ធានា និងទទួលបានសេវាធ្វើផែនការគ្រួសារ ដូចដែលបានបញ្ជាក់នៅក្នុងមាត្រាទី ១០(ជ)របស់អនុសញ្ញា។

២៣.មានការយល់ស្របជាទូទៅថា នៅពេលដែលមានវិធានការសមស្របសម្រាប់ការបន្តពូជដោយស្ម័គ្រចិត្ត នោះនាំអោយមានការប្រសើរឡើងលើផ្នែកសុខភាព ការអភិវឌ្ឍន៍ និងសុខមាលភាពរបស់សមាជិកទាំងអស់នៅក្នុងគ្រួសារ។ ជាងនេះទៅទៀត សេវាទាំងនេះនឹងបង្កើនគុណភាពទូទៅនៃជីវិត និងបង្កើនសុខភាព

របស់ប្រជាជន ភាពទៀងទាត់នៃកំណើនប្រជាពលរដ្ឋ នឹងជួយថែរក្សាបរិស្ថាន និងជួយសម្រេចឱ្យបាននូវការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមប្រកបដោយចិរភាព។

មាត្រា១៦ (១) (ឆ)

២៤. គ្រួសារដែលមានស្ថេរភាព គឺជាគ្រួសារមួយដែលផ្អែកលើគោលការណ៍សមធម៌ យុត្តិធម៌ និងការផ្តល់សិទ្ធិបុគ្គលដល់សមាជិកនីមួយៗ។ ហេតុដូចនេះបុគ្គលនីមួយៗ ត្រូវមានសិទ្ធិក្នុងការជ្រើសរើសវិជ្ជាជីវៈ ឬការងារដែលសមទៅតាមសមត្ថភាព គុណសម្បត្តិ និងសមតាមបំណងប្រាថ្នារបស់ខ្លួន ដូចដែលបានបញ្ជាក់នៅក្នុងមាត្រា ១១ (ក) និង (គ) របស់អនុសញ្ញា។ លើសពីនេះទៅទៀត បុគ្គលនីមួយៗ គួរមានសិទ្ធិធ្វើ ការជ្រើសរើសនូវឈ្មោះរបស់គេ ដើម្បីរក្សានូវឯកត្តនាម នៅក្នុងសហគមន៍ និងភិនភាគខុសប្លែករបស់ខ្លួនពីអ្នក ដ៏ទៃ និងការបែងចែកមនុស្សឱ្យដាច់ចេញពីសមាជិកផ្សេងៗរបស់សង្គម។ ដូច្នេះ បើសិនជាច្បាប់ ឬទំនៀម ទំលាប់តម្រូវអោយស្ត្រីត្រូវផ្លាស់ប្តូរឈ្មោះរបស់នាង ដោយសារការរៀបអាពាហ៍ពិពាហ៍ ឬដោយសារការលុបចោលអាពាហ៍ពិពាហ៍ នោះមានន័យថាសិទ្ធិរបស់ស្ត្រី ក្នុងករណីនេះ គឺត្រូវគេបរិសេធ។

មាត្រា១៦ (១) (ជ)

២៥. សិទ្ធិផ្តល់នៅក្នុងមាត្រានេះ ដូចគ្នា និងជាការបន្ថែមទៅលើមាត្រា១៥(២) ដែលចែងអំពីកាតព្វកិច្ចរបស់រដ្ឋ ក្នុងការផ្តល់ដល់ស្ត្រីនូវសិទ្ធិស្មើគ្នាក្នុងការចុះកិច្ចសន្យា និងការគ្រប់គ្រងទ្រព្យសម្បត្តិ។

២៦. មាត្រា ១៥(១) ធានាចំពោះនារីនូវសិទ្ធិស្មើភាពគ្នាជាមួយបុរសនៅចំពោះមុខច្បាប់។ សិទ្ធិធ្វើជាម្ចាស់កម្មសិទ្ធិ ចាត់ចែង ចូលរួម និងចាត់ចែងទ្រព្យសម្បត្តិ គឺមានសារៈសំខាន់ចំពោះស្ត្រី ក្នុងការឈានទៅរកឯករាជ្យភាពផ្នែកហិរញ្ញវត្ថុ ហើយនៅក្នុងប្រទេសជាច្រើន សិទ្ធិនេះមានសារៈសំខាន់ចំពោះស្ត្រី ក្នុងការមានលទ្ធភាពធ្វើការរកស៊ីចិញ្ចឹមជីវិត និងការផ្តល់ផ្ទះសម្បែង និងអាហារឱ្យបានគ្រប់គ្រាន់សំរាប់ខ្លួននាងផ្ទាល់ និងសំរាប់គ្រួសាររបស់នាង។

២៧. នៅក្នុងប្រទេសដែលកំពុងអនុវត្តកម្មវិធីកំណែទម្រង់កសិកម្ម ឬការបែងចែកដីសារជាថ្មីនៅក្នុងចំណោមក្រុមប្រជាជនផ្សេងៗគ្នា សិទ្ធិរបស់ស្ត្រី ដោយពុំគិតពីស្ថានភាពអាពាហ៍ពិពាហ៍ ដើម្បីបែងចែកដីធ្លីអោយបានស្មើភាពជាមួយនឹងបុរស ប្រទេសទាំងនេះត្រូវធ្វើការអង្កេតលើកម្មវិធីនេះដោយយកចិត្តទុកដាក់។

២៨. នៅក្នុងប្រទេសភាគច្រើន ស្ត្រីមួយចំនួនធំ គឺនៅលីវ ឬលែងលះ ហើយស្ត្រីជាច្រើន មានការទទួលខុសត្រូវតែឯងចំពោះការចិញ្ចឹមបីបាច់គ្រួសារ។ ការរើសអើងណាមួយនៅក្នុងការបែងចែកទ្រព្យសម្បត្តិ

ដែលគិតថាបុរសតែម្នាក់ឯងជាអ្នកទទួលខុសត្រូវក្នុងការចិញ្ចឹមស្ត្រី និងកូនចៅនៅក្នុងគ្រួសាររបស់គាត់ និង ដែលគិតថា បុរសអាច ឬបុរសនឹងទទួលខុសត្រូវ ប្រកបដោយកិត្តិយស — ប៉ុន្តែពិតប្រាកដណាស់ដែលការយល់ឃើញទាំងនេះ គឺពុំមែនជាភាពជាក់ស្តែងនោះទេ ។ ផលវិបាក គឺថាបើច្បាប់ ឬទំនៀមទម្លាប់ ដែលបានផ្តល់សិទ្ធិឱ្យបុរសទទួលយកនូវភាគចំណែកទ្រព្យសម្បត្តិភាគច្រើន នៅពេលបញ្ចប់ចំណងអាពាហ៍ពិពាហ៍ ឬនៅពេលបញ្ចប់ទំនាក់ទំនងជាក់ស្តែង ឬការស្លាប់របស់សាច់ញាតិ គឺជាច្បាប់ ឬទំនៀមទម្លាប់ដែលមានការរើសអើង និងមានឥទ្ធិពលយ៉ាងធ្ងន់ធ្ងរ ទៅលើលទ្ធភាពជាក់ស្តែងរបស់ស្ត្រី ក្នុងការលែងលះស្វាមីរបស់នាង ដើម្បីចិញ្ចឹមបីបាច់ខ្លួនឯង ឬគ្រួសាររបស់នាង និងដើម្បីរស់នៅក្នុងកិត្យានុភាពជាបុគ្គលឯករាជ្យ ។

២៩. សិទ្ធិទាំងអស់នេះ គួរត្រូវបានគេធានា ដោយមិនគិតពីស្ថានភាពអាពាហ៍ពិពាហ៍របស់ស្ត្រីឡើយ ។

## <u>ទ្រព្យសម្បត្តិក្នុងចំណងអាពាហ៍ពិពាហ៍</u>

៣០. មានប្រទេសជាច្រើនដែលមិនទទួលស្គាល់នូវសិទ្ធិរបស់នារីដើម្បីធ្វើការកាន់កាប់ នូវភាគចំណែកទ្រព្យសម្បត្តិស្មើគ្នាជាមួយស្វាមីនៅក្នុងកំឡុងស្ថិតក្នុងចំណងអាពាហ៍ពិពាហ៍ ឬនៅក្នុងទំនាក់ទំនងជាក់ស្តែង និងនៅពេលដែលអាពាហ៍ពិពាហ៍ ឬទំនាក់ទំនងនោះបានបញ្ចប់ ។ ប្រទេសជាច្រើនបានទទួលស្គាល់ថា ច្បាប់និងទំនៀមទម្លាប់ បានក៏រិតលើសិទ្ធិរបស់ស្ត្រី ប៉ុន្តែជាក់ស្តែងនោះ បានដាក់ក៏រិតលើលទ្ធភាពរបស់នារី ក្នុងការអនុវត្តន៍សិទ្ធិរបស់ខ្លួន ។

៣១. ទោះបីជានៅពេលសិទ្ធិទាំងនេះ ត្រូវបានប្រគល់ឱ្យនារីមែន ហើយតុលាការជួយពង្រឹងសិទ្ធិទាំងនោះ ប៉ុន្តែនៅក្នុងកំឡុងពេលក្នុងចំណងអាពាហ៍ពិពាហ៍ ឬនៅពេលលែងលះ បុរសអាចនឹងគ្រប់គ្រងលើទ្រព្យសម្បត្តិ ដែលជាកម្មសិទ្ធិរបស់ស្ត្រី ។ នៅក្នុងរដ្ឋជាច្រើន រួមទាំងរដ្ឋដែលមានរបបទ្រព្យសម្បត្តិត្រូវគ្រប់គ្រងដោយសហគមន៍ក៏ដោយ ក៏ពុំមានច្បាប់ ដែលតម្រូវអោយមានការពិគ្រោះយោបល់ជាមួយស្ត្រី អំពីទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ភាគីទាំងពីរ នៅក្នុងកំឡុងពេលស្ថិតក្នុងចំណងអាពាហ៍ពិពាហ៍ ឬនៅក្នុងទំនាក់ទំនងជាក់ស្តែង នៅពេលដែលសម្បត្តិនោះត្រូវបានគេលក់ ឬបែងចែកទៅអោយអ្នកផ្សេង ។ ករណីនេះ ដាក់ក៏រិតលើលទ្ធភាពរបស់ស្ត្រី ក្នុងការគ្រប់គ្រង ការបែងចែកទ្រព្យសម្បត្តិ ឬប្រាក់ចំណូលដែលបានមកពីទ្រព្យ សម្បត្តិនោះ ។

៣២. នៅក្នុងប្រទេសខ្លះទៀត ការបែងចែកទ្រព្យសម្បត្តិប្តីប្រពន្ធ គឺសង្កត់ធ្ងន់ទៅលើការរួមវិភាគទានផ្នែកហិរញ្ញវត្ថុទៅលើទ្រព្យសម្បត្តិទាំងនោះ នៅក្នុងកំឡុងពេលស្ថិតក្នុងចំណងអាពាហ៍ពិពាហ៍ ប៉ុន្តែការរួមវិភាគទានផ្សេងៗទៀត ដូចជាការចិញ្ចឹមកូន ការថែទាំសាច់ញាតិចាស់ជរា និងការអនុវត្តន៍តួនាទីក្នុងគ្រួសារ គឺមានលក្ខណៈតិចតួច ។ ជារឿយៗ វិភាគទានរបស់ស្ត្រីបែបជាលក្ខណៈមិនមែនជាហិរញ្ញវត្ថុ បានផ្តល់លទ្ធភាព

ឱ្យស្វាមី ក្នុងការទៅរកប្រាក់ចំណូល និងធ្វើការបង្កើនទ្រព្យសម្បត្តិ ។ វិភាគទានហិរញ្ញវត្ថុ និងវិភាគទានមិនមែនជាហិរញ្ញវត្ថុ គួរតែទទួលបានទំងន់ស្មើៗគ្នា ។

៣៣. នៅក្នុងប្រទេសជាច្រើន ទ្រព្យសម្បត្តិដែលកើតមាននៅក្នុងទំនាក់ទំនងជាក់ស្តែង ពុំត្រូវទទួលបានការដោះស្រាយនៅក្នុងច្បាប់ ដូចគ្នានឹងទ្រព្យសម្បត្តិដែលមាននៅក្នុងចំណងអាពាហ៍ពិពាហ៍ឡើយ ។ ដូចគ្នានេះដែរ ប្រសិនជាទំនាក់ទំនងត្រូវបញ្ចប់ ស្ត្រីនឹងទទួលបានចំណែកតិចបំផុត បើប្រៀបធៀបទៅនឹងចំណែកដែលដៃគូរបស់ខ្លួនទទួលបាន ។ ដូច្នេះច្បាប់ស្តីពីទ្រព្យសម្បត្តិ និងទំនៀមទម្លាប់ ដែលប្រឆាំងនារីដែលរៀបការ ឬនារីដែលមិនបានរៀបការ និងមានកូន ឬមិនមានកូន  គួរតែកែប្រែ ឬពុំគួរនឹងអនុវត្តទេ ។

__**ការទទួលមរតក**__

៣៤. របាយការណ៍រដ្ឋភាគី គួរផ្តល់ពតិមានអំពីបទបញ្ញត្តិច្បាប់ ឬទំនៀមទំលាប់ ដែលទាក់ទិនទៅនិងការទទួលបានមរតក ព្រោះថាបញ្ហានេះប៉ះពាល់ដល់ស្ថានភាពនារី ដូចដែលបានចែងនៅក្នុងអនុសញ្ញា និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម លេខ៨៨៤ ឌ ១យយឃ្វីច ដែលក្រុមប្រឹក្សាបានផ្តល់អនុសាសន៍ថារដ្ឋត្រូវធានាថាបុរស និងនារីដែលមានទំនាក់ទំនងស្មើគ្នាទៅនឹងអ្នកស្លាប់ ត្រូវមានសិទ្ធិក្នុងការទទួលបាននូវចំណែកស្មើគ្នា នៅពេលបែងចែកអចលនវត្ថុ និងកិរិតឋានៈប៉ុនគ្នាតាមលំដាប់នៃការបន្តវេណ ។ បទបញ្ញត្តិនេះ ពុំទាន់ត្រូវបានអនុវត្តជាទូទៅនៅឡើយទេ ។

៣៥. មានប្រទេសជាច្រើន ដែលច្បាប់ និងការប្រតិបត្តិចំពោះការទទួលមរតក និងទ្រព្យសម្បត្តិ មានការរើសអើងយ៉ាងធ្ងន់ធ្ងរប្រឆាំងនឹងស្ត្រី ។ ដូច្នេះស្ត្រីអាចទទួលបានភាគចំណែកទ្រព្យសម្បត្តិរបស់ប្តី ឬទ្រព្យសម្បត្តិរបស់ឪពុកដែលស្លាប់ តិចជាងទ្រព្យសម្បត្តិដែលពោះម៉ាយ និងកូនប្រុសទទួលបាន ។ នៅមានករណីខ្លះសិទ្ធិរបស់ស្ត្រីត្រូវបានគេផ្តល់អោយ នៅមាកំរិត និងស្ថិតក្រោមការគ្រប់គ្រងរបស់គេ ហើយស្ត្រីទទួលបានប្រាក់ចំណូលត្រឹមតែពីទ្រព្យសម្បត្តិអ្នកស្លាប់ប៉ុណ្ណោះ ។ ជារឿយៗ សិទ្ធិរបស់ស្ត្រីមេម៉ាយ ពុំដូចទៅនឹង គោលការណ៍កម្មសិទ្ធិទ្រព្យសម្បត្តិស្មើភាព នៅក្នុងកំឡុងពេលក្នុងចំណងអាពាហ៍ពិពាហ៍ ។ បទបញ្ញត្តិបែបនេះរំលោភទៅលើអនុសញ្ញា ហើយគួរត្រូវលុបចោល ។

មាត្រា ១៦ (២)

៣៦. សេចក្តីប្រកាសក្រុងវីយែន ទ្វិនេនាច និងកម្មវិធីសកម្មភាព ដែលបានអនុម័តដោយសន្និសីទពិភពលោកស្តីអំពីសិទ្ធិមនុស្ស ប្រារព្ធធ្វើឡើងនៅក្រុងវីយែន កាលពីថ្ងៃទី១៤-២៥ ខែមិថុនា ឆ្នាំ១៩៩៣

បានអំពាវនាវអោយរដ្ឋភាគីទាំងឡាយ ត្រូវពិនិត្យឡើងវិញលើច្បាប់ និងបញ្ញត្តិដែលមានស្រាប់ និងធ្វើការលុបបំបាត់ចោលនូវទំនៀមទំលាប់ និងការអនុវត្តន៍ដែលរើសអើងប្រឆាំងនឹងស្ត្រី និងដែលធ្វើឱ្យមានគ្រោះថ្នាក់ដល់ក្មេងស្រី ។ មាត្រា ១៦(២) និងបទបញ្ញត្តិរបស់អនុសញ្ញាស្តីពីសិទ្ធិកុមារ បានហាមឃាត់រដ្ឋភាគីមិនឱ្យផ្តល់ការអនុញ្ញាត ឬផ្តល់សុពលភាពចំពោះអាពាហ៍ពិពាហ៍រវាងមនុស្សដែលមិនទាន់គ្រប់វ័យការ ។ នៅក្នុងបរិបទនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ "នៅក្រោមច្បាប់អនុវត្តន៍ចំពោះកុមារ កុមារមានន័យថាគ្រប់មនុស្សជាតិដែលមានអាយុក្រោម១៨ឆ្នាំ លើកលែងតែភាពពេញវ័យការអាចមកដល់មុនអាយុនេះ" ។ ថ្វីបើមាននូវនិយមន័យនេះ មែនហើយនឹងការចងចាំនៅនូវបទបញ្ញត្តិនៃសេចក្តីប្រកាសរបស់ក្រុងវីយែនក៏ដោយ គណៈកម្មាធិការបានធ្វើការពិចារណាថាអាយុអតិបរិមាសំរាប់រៀបការ គឺគួរតែអាយុ ១៨ឆ្នាំ សំរាប់ទាំងបុរស និងនារី ។ នៅពេលបុរសនិងនារីរៀបការ ពួកគេត្រូវទទួលបន្ទុកការខុសត្រូវយ៉ាងចម្បង ។ ដូច្នេះអាពាហ៍ពិពាហ៍មិនត្រូវអនុញ្ញាតឱ្យមុនពួកគេមានអាយុគ្រប់វ័យការ និងមានសមត្ថភាពធ្វើការនោះទេ ។ យោងតាមអង្គការសុខភាពពិភពលោកបានអោយដឹងថា នៅពេលដែលអនីតិជន ជាពិសេសក្មេងស្រីរៀបការហើយមានកូន សុខភាពរបស់គេអាចត្រូវទទួលផលប៉ះពាល់មិនល្អ ហើយការអប់រំរបស់ក្មេងស្រី នឹងត្រូវអាក់ខាន ។ ហេតុនេះស្វ័យភាពសេដ្ឋកិច្ចរបស់ក្មេងស្រី នឹងមានកំរិត ។

៣៧. នេះមិនត្រឹមតែមានផលប៉ះពាល់ដល់នារីទាំងនោះដោយផ្ទាល់ទេ ប៉ុន្តែថែមទាំងកំរិតដល់ការអភិវឌ្ឍន៍ជំនាញ ឯករាជ្យភាពទៀតផង និងកាត់បន្ថយដល់ការទទួលបានការងារ ដូច្នេះធ្វើឱ្យប៉ះពាល់ដល់ គ្រួសារ និងសហគមន៍របស់គេផងដែរ ។

៣៨. ប្រទេសមួយចំនួនបានកំណត់អាយុរៀបការខុសៗគ្នាចំពោះបុរស និងនារី ។ បទបញ្ញត្តិទាំងនេះបានសន្មត់ ដោយគ្មានលក្ខណៈត្រឹមត្រូវ ថានារីមានកំរិតការវិវត្តន៍បញ្ញាស្មារតីខុសពីបុរស ឬក៏ថាតំណាក់កាលនៃការវិវត្តន៍រាងកាយ និងបញ្ញាស្មារតីរបស់ស្ត្រី នៅពេលរៀបអាពាហ៍ពិពាហ៍រួច មិនសូវសំខាន់ទេ — បទបញ្ញត្តិទាំងនេះ គួរតែលុបចោល ។ នៅក្នុងប្រទេសខ្លះទៀត ការភ្ជាប់ពាក្យក្មេងស្រី ឬការរៀបចំដោយសមាជិកគ្រួសារជំនួសពួកគេ ត្រូវបានអនុញ្ញាត ។ វិធានការបែបនេះមិនត្រឹមតែរំលោភទៅលើអនុសញ្ញាប៉ុណ្ណោះទេ ថែមទាំងរំលោភដល់សិទ្ធិនារីចំពោះការជ្រើសរើសគូរស្រករដោយសេរីទៀតផង ។

៣៩. រដ្ឋភាគីគួរតំរូវឱ្យមានការចុះអ៊ីតាស៊ីវិលនៃអាពាហ៍ពិពាហ៍ផងដែរ មិនថាបានធ្វើការចុះកិច្ចសន្យាតាមបែបស៊ីវិលឬយោងតាមទំនៀមទម្លាប់ និងច្បាប់សាសនា ។ ហេតុនេះរដ្ឋអាចធ្វើការធានាដល់ការអនុវត្តន៍តាមអនុសញ្ញា និងបង្កើតឱ្យមានភាពស្មើគ្នារវាងដៃគូរទាំងពីរ កំនត់អាយុអប្បបរមា ហាមឃាត់ចំពោះ ទ្វេពន្ធភាព និងពហុពន្ធភាព និងធ្វើការការពារដល់សិទ្ធិកុមារ ។

## អនុសាសន៍

### អំពើហិង្សាប្រឆាំងនឹងស្ត្រី

៤០. ដោយការពិចារណាអំពីស្ថានភាពរបស់នារីនៅក្នុងជីវិតគ្រួសារ គណៈកម្មាធិការសង្កត់ធ្ងន់ទៅលើអនុសាសន៍ទូទៅលេខ១៩ (សម័យប្រជុំលើកទី១១) ដែលពាក់ពន្ធ័នឹងអំពីហិង្សាប្រឆាំងនឹងស្ត្រី ដែលអំពើហិង្សាប្រឆាំងនឹងស្ត្រី មានផលប៉ះពាល់យ៉ាងខ្លាំង ចំពោះលទ្ធភាពរបស់ស្ត្រី ក្នុងការទទួលបានសិទ្ធិ និងសេរីភាពផ្អែកលើមូលដ្ឋានស្មើភាពជាមួយបុរស ។ រដ្ឋភាគីត្រូវបានគេអំពាវនាវឱ្យអនុវត្តតាមអនុសាសន៍ទូទៅនេះ ដើម្បីធានាថាទាំងនៅក្នុងជីវិតសាធារណៈ និងជីវិតប្រចាំគ្រួសារ ស្ត្រីនឹងត្រូវរួចផុតពីអំពើហិង្សាយេនឌ័រ ដែលអំពើហិង្សានេះ បង្អាក់យ៉ាងធ្ងន់ធ្ងរ ដល់សិទ្ធិ និងសេរីភាពរបស់ស្ត្រី ជាឯកត្តជន ។

### ការបម្រុងទុក

៤១. គណៈកម្មាធិការបានកត់សំគាល់អំពីចំនួននៃរដ្ឋភាគី ដែលបានធ្វើការបម្រុងទុក ចំពោះមាត្រា១៦ ទាំងមូល ឬផ្នែកខ្លះៗនៃមាត្រា១៦ ជាពិសេសក៏បានធ្វើការកត់សំគាល់ចំពោះការបម្រុងទុកចំពោះមាត្រា២ផង ដែរ ដែលរដ្ឋភាគីទាំងនោះអះអាងថា ការអនុវត្តន៍តាមមាត្រានេះ អាចប្រឆាំងជាមួយនិងទស្សនៈរបស់គ្រួសារ ជាពិសេសលើជំនឿវប្បធម៌ ឬជំនឿសាសនា ឬលើស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេស ឬស្ថានភាពនយោបាយ ។

៤២. ភាគច្រើននៃប្រទេសទាំងនេះ ប្រកាន់ជំនឿលើរចនាសម្ព័ន្ធគ្រួសារបែបបិតាធិបតេយ្យ ដែលអោយតំលៃខ្ពស់ទៅលើឪពុក ស្វាមី ឬកូនប្រុស ។ នៅប្រទេសខ្លះដែលមានទស្សនៈអ្នកប្រកាន់និយម ឬទស្សនៈអ្នកជ្រុលនិយម ឬមានការលំបាកខាងសេដ្ឋកិច្ច ត្រូវបានជម្រុញឱ្យមានការវិលត្រឡប់មករកតម្លៃដើម និងប្រពៃណីចាស់ ដែលបានធ្វើឱ្យមានការយ៉ាប់យឺនកាន់តែខ្លាំងឡើងដល់ឋានៈរបស់នារីនៅក្នុងគ្រួសារ ។ នៅក្នុងប្រទេសដទៃទៀត ដែលត្រូវបានគេទទួលស្គាល់ថា សង្គមសម័យទំនើប គឺអាស្រ័យលើការរីកចំរើនសេដ្ឋកិច្ច និងភាពល្អប្រសើរជាទូទៅរបស់សហគមន៍ ក្នុងការពាក់ព័ន្ធជាមួយមនុស្សពេញវ័យទាំងអស់ដោយស្មើៗគ្នា ដោយមិនគិតពីយេនឌ័រ ដូច្នេះហើយនៅក្នុងប្រទេសទាំងនោះ ពុំមានការលើកទឹកចិត្តអោយមានពិសិដ្ឋកម្ម និងគំនិតប្រតិកិរិយា ឬជ្រុលនិយមទាំងនេះឡើយ ។

៤៣. ស្របតាមមាត្រា២,៣ និង២៤ ជាពិសេស គណៈកម្មាធិការតំរូវឱ្យរដ្ឋភាគីទាំងអស់ ធ្វើឱ្យមានការរីកចំរើនជាបណ្តើរៗ ទៅដល់ដំណាក់កាល ដែលប្រទេសនីមួយៗពេញចិត្តក្នុងការមិនជម្រុញអោយមានអសមភាពចំពោះស្ត្រី នៅក្នុងគ្រួសារ នោះប្រទេសនីមួយៗ នឹងដកយកចេញនូវការបម្រុងទុករបស់ខ្លួន ជាពិសេសចំពោះមាត្រា៩ ១៥ និង១៦ របស់អនុសញ្ញា ។

៤៤. រដ្ឋភាគីពុំគួរដាច់ខាត ក្នុងការជំរុញអោយមានសញ្ញាណណាមួយនៃអសមភាពរវាងស្ត្រី និង បុរស ដែលសញ្ញាណនេះ មាននៅក្នុងច្បាប់ ឬដោយច្បាប់សាសនា ឬច្បាប់ឯកជន ឬតាមទំនៀមទំលាប់ ហើយគួរតែអោយមានការរីកចំរើនរហូតដល់ដំណាក់កាលត្រូវដកចេញនូវការបម្រុងទុករបស់ខ្លួន ជាពិសេសមាត្រា១៦។

៤៥. ផ្អែកលើការត្រួតពិនិត្យរបាយការណ៍លើកដំបូង និងរបាយការណ៍តាមពេលកំណត់បន្តបន្ទាប់ គណៈកម្មាធិការបានកត់សំគាល់ឃើញថា រដ្ឋភាគីខ្លះដែលបានធ្វើសច្ចាប័ន ឬផ្តល់ការយល់ព្រម ដោយពុំមានការបម្រុងទុក ជាពិសេសទាក់ទងនឹងគ្រួសារ ពុំបានអនុវត្តតាមបទបញ្ញត្តិរបស់អនុសញ្ញាឡើយ ។

៤៦. ច្បាប់របស់រដ្ឋភាគីទាំងនោះ នៅតែមានវិធានការជាច្រើនដែលរើសអើងប្រឆាំងនឹងស្ត្រី ដោយផ្អែកលើបទដ្ឋាន ទំនៀមទម្លាប់ និងការអោយតម្លៃពីវប្បធម៌ និងសង្គម ។ ដោយសារស្ថានភាពជាក់លាក់របស់រដ្ឋភាគី ចំពោះមាត្រាទាំងនេះ រដ្ឋទាំងនេះបានធ្វើឱ្យមានការលំបាកដល់គណៈកម្មាធិការ ក្នុងការវាយតម្លៃ និងយល់ពីស្ថានភាពរបស់ស្ត្រី ។

៤៧. គណៈកម្មាធិការ ជាពិសេសផ្អែកលើមាត្រា១ និង២របស់អនុសញ្ញា បានធ្វើការស្នើរឡើង ថារដ្ឋភាគីទាំងនោះចាំបាច់ត្រូវធ្វើការខិតខំប្រឹងប្រែង ដើម្បីពិនិត្យស្ថានការណ៍ជាក់ស្តែងដែលទាក់ទិនទៅនិងបញ្ហា និងចាត់វិធានការដែលចាំបាច់ ចំពោះច្បាប់របស់ខ្លួន ដែលនៅមានបទបញ្ញត្តិខ្លះ រើសអើងប្រឆាំងនឹងស្ត្រី ។

**<u>របាយការណ៍</u>**

៤៨. ដោយមានការជួយជាយោបល់ ដូចដែលមាននៅក្នុងអនុសាសន៍ទូទៅនាពេលបច្ចុប្បន្ននេះ នៅក្នុងរបាយការណ៍ របស់គេរដ្ឋភាគីគួរ :

(ក). បង្ហាញនូវតំណាក់កាលដែលបានឈានទៅដល់នូវការវិវត្តន៍របស់ប្រទេស ដើម្បីលុបចោលរាល់ការបំរុងទុក ចំពោះអនុសញ្ញា ជាពិសេសការបម្រុងទុកចំពោះមាត្រា១៦។

(ខ). បង្ហាញថាតើច្បាប់របស់ខ្លួន ស្របទៅតាមគោលការណ៍នៃមាត្រា៩,១៥ និង១៦ និងថាតើកន្លែងណាដែលហាមឃាត់ការអនុវត្តន៍តាមច្បាប់ ឬអនុសញ្ញា ដោយហេតុផលនៃច្បាប់សាសនា ឬច្បាប់ឯកជន ឬទំនៀមទម្លាប់ ។

**<u>នីតិកម្ម</u>**

៤៩. បើសិនជាចាំបាច់ ក្នុងការអនុវត្តអោយស្របតាមអនុសញ្ញា និងជាពិសេសដើម្បីឱ្យស្របជាមួយ និងមាត្រា៩ ,១៥ និង១៦ រដ្ឋភាគីគួរធ្វើការអនុម័ត និងពង្រឹងការអនុវត្តន៍ច្បាប់ ។

## <u>ការជម្រុញឱ្យមានការអនុវត្តន៍តាមអនុសញ្ញា</u>

៥០. ដោយមានការជួយជាយោបល់ដែលមាននៅក្នុងអនុសាសន៍ទូទៅបច្ចុប្បន្ន និងតាមការតម្រូវដែលមាននៅក្នុងមាត្រា២, ៣ និង២៤ រដ្ឋភាគីគួរតែអនុវត្តវិធានការ ដែលនាំទៅរកការអនុវត្តន៍ពេញលេញ ស្របទៅតាមគោលការណ៍របស់អនុសញ្ញា ជាពិសេសនៅក្នុងប្រទេសដែលមានច្បាប់សាសនា ឬច្បាប់ឯកជន ឬក៏ទំនៀមទម្លាប់ ផ្ទុយពីគោលការណ៍ទាំងនោះ។

## អនុសាសន៍រួម ទី ២២ (សម័យប្រជុំលើកទី ១៤ ១៩៩៥)

ធ្វើវិសោធន៍កម្ម មាត្រាទី ១០ នៃអនុសញ្ញា
គណៈកម្មាធិការស្ដីពីការលប់បំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី
តាមសំណើររបស់រដ្ឋសភា ដោយយល់ឃើញថា រដ្ឋភាគីនៃអនុសញ្ញាលប់បំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងស្ត្រី នឹងជួបប្រជុំនៅឆ្នាំ ១៩៩៥ ដើម្បីពិចារណាធ្វើវិសោធន៍កម្ម មាត្រា ទី ២០ នៃអនុសញ្ញា

យោងតាមសេចក្ដីសំរេចកន្លងមក នៅកិច្ចប្រជុំលើកទី ១០ ដើម្បីធានានូវប្រសិទ្ធភាព ក្នុងការងាររបស់ខ្លួន និង ទប់ស្កាត់មិនអោយការសរសេររបាយការណ៍របស់រដ្ឋភាគីនៅសេសសល់

យោងថា អនុសញ្ញា គឺជាច្បាប់សិទ្ធមនុស្សអន្តរជាតិ ដែលបានធ្វើសត្យាបន័ដោយរដ្ឋភាគីជាច្រើនប្រទេស

ពិចារណាថា មាត្រាទាំងឡាយនៃអនុសញ្ញា លើកឡើងពីសិទ្ធិជាមូលដ្ឋានរបស់ស្ត្រី គ្រប់ទិដ្ឋភាពនៃជីវិតរស់នៅប្រចាំថ្ងៃ និងគ្រប់វិស័យក្នុងសង្គម និង រដ្ឋ

ដោយបារម្ភអំពីទំហំការងាររបស់គណៈកម្មាធិការ ដែលបណ្ដាលមកពីការកើនឡើងចំនួនប្រទេសធ្វើសត្យាប័នបន្ថែមពីលើការងារពិនិត្យរបាយការណ៍ ដែលនៅសេសសល់រង់ចាំការផ្ដល់យោបល់

ដោយបារម្ភអំពីគំលាតពេលវែង រវាងការផ្ញើររបាយការណ៍ និង ពត័មានដាក់បញ្ចូលរបស់រដ្ឋភាគី ដែលតំរូវអោយរដ្ឋភាគីត្រូវផ្ដល់ពត័មានថ្មីៗបន្ថែមលើរបាយការណ៍

ដោយប្រកាន់ខ្ជាប់ថា អនុសញ្ញាស្ដីពីការលប់បំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងស្ត្រី គឺជាសន្ធិសញ្ញាសិទ្ធិមនុស្សតែមួយគត់ ដែលមានពេលវេលាប្រជុំកំណត់ដោយអនុសញ្ញាខ្លួនឯង ហើយមានរយៈពេលប្រជុំខ្លីបំផុតក្នុងចំណោមអង្គសន្ធិសញ្ញាទាំងអស់ ដូចដែលបង្ហាញក្នុង ឧបសម្ពន្ធ II

ដោយសំគាល់ឃើញថា ពេលវេលានៃកិច្ចប្រជុំមានកំរិត ដូចដែលមានចែងក្នុងអនុសញ្ញា បានក្លាយជាឧបសគ្គដ៏ធ្ងន់ធ្ងរសំរាប់ការប្រព្រឹត្តណ៏ទៅនូវតួនាទីប្រកបដោយប្រសិទ្ធិភាពរបស់គណៈកម្មាធិការ ទៅតាមការកំនត់របស់អនុសញ្ញាៈ

១- សូមណែនាំថា រដ្ឋភាគីគួរពិចារណាធ្វើវិសោធនកម្មមាត្រាទី ២០នៃអនុសញ្ញា ទៅតាមពេលវេលាប្រជុំរបស់គណៈកម្មាធិការ ដើម្បីអនុញ្ញាតិអោយគណកម្មាធិការ ធ្វើការជួបប្រជុំជារៀងរាល់ឆ្នាំតាមពេលវេលាពីព្រោះ នេះជាការចាំបាច់សំរាប់ការប្រព្រឹត្តិណ៏ទៅនូវតួនាទីប្រកបដោយប្រសិទ្ធិភាព ដូចដែលកំណត់ដោយអនុសញ្ញា ដោយមិនមានការរារាំងជាក់លាក់ណាមួយ លើកលែងតែរដ្ឋសភាចែងកំណត់។

២- សូមណែនាំផងដែរថា ដោយរង់ចាំការបញ្ចប់នូវដំណើរការវិសោធនកម្ម រដ្ឋសភាអនុញ្ញាតិអោយគណៈកម្មាធិកាជួបដោយឡែក នៅឆ្នាំ ១៩៩៦ ចំពោះកិច្ចប្រជុំពីរ ហើយកិច្ចប្រជុំនីមួយៗមានរយៈពេល៣សប្តាហ៏និង មានរៀបចំកិច្ចប្រជុំមុនជាមួយក្រុមការងារ។

៣- សូមណែនាំបន្តថា កិច្ចប្រជុំរបស់រដ្ឋភាគីទទួលនូវការរាយការណ៏ដោយផ្ទាល់មាត់ពីប្រធានរបស់គណៈកម្មាធិការ អំពីផលលំបាកដែលគណៈកម្មាធិការជួបប្រទះក្នុងការបំពេញតួនាទីរបស់ខ្លួន។

៤- សូមណែនាំថា អគ្គាធិការ ផ្តល់ពត័មានដែលពាក់ពន្ធ័ទាំងអស់ស្តីពីទំហំការងាររបស់ គណៈកម្មាធិការ និងពត័មានប្រហាក់ប្រហែលមួយចំនួនពាក់ពន្ធ័នឹងអង្គសន្និសញ្ញសិទ្ធិមនុស្សផ្សេងៗទៀត នៅក្នុងកិច្ចប្រជុំរបស់ខ្លួន។

# អនុសាសន៍ទូទៅលេខ២៣
# ជីវិតនយោបាយ និងជីវិតសាធារណៈ
# (សម័យប្រជុំលើកទី១៦, ១៩៩៧)[១]

## មាត្រា៧ (នយោបាយ និងសាធារណៈ)

រដ្ឋភាគីត្រូវធ្វើការចាត់វិធានការទាំងអស់ឱ្យបានសមស្របដើម្បីធ្វើការលុបបំបាត់ចោលការរើសអើងប្រឆាំងនារីភេទនៅក្នុងជីវិតនយោបាយ និងជីវិតសាធារណៈរបស់ប្រទេសជាពិសេសគេត្រូវធ្វើការធានាដល់នារីអំពីលក្ខខ័ណ្ឌស្មើគ្នាជាមួយ បុរសគឺសិទ្ធិ :

(ក) ត្រូវធ្វើការបោះឆ្នោតរាល់ការជ្រើសតាំង និងការធ្វើប្រជាមតិសាធារណៈ និងត្រូវធ្វើការបោះឆ្នោតចំពោះស្ថាប័នដែលត្រូវ ជ្រើសតាំងជាសាធារណៈ ។

(ខ) ត្រូវធ្វើការចូលរួមនៅក្នុងការបង្កើតរូបមន្តនៃគោលនយោបាយរដ្ឋាភិបាល និងការអនុវត្តន៏នេះ ហើយត្រូវកាន់នូវមុខតំណែង សាធារណៈ ព្រមទាំងកាន់នូវមុខងារសាធារណៈទាំងអស់នៅគ្រប់លំដាប់ថ្នាក់របស់រដ្ឋាភិបាល ។

(គ) ត្រូវចូលរួមជាមួយអង្គការក្រៅរដ្ឋាភិបាល និងសមាគមន៏ដែលទាក់ទងជាមួយជីវិតនយោបាយ និងជីវិតសាធារណៈរបស់ ប្រទេស ។

## ប្រវត្តិកាល

១.អនុសញ្ញាអំពីការលុបបំបាត់ចោលរាល់ទម្រង់ការរើសអើងប្រឆាំងនារីភេទបានធ្វើការដាក់នូវសារៈសំខាន់ជាពិសេសទៅលើ ការចូលរួមរបស់នារីនៅក្នុងជីវិតសាធារណៈនៃប្រទេសរបស់គេ។ បុព្វកថារបស់អនុសញ្ញាបានធ្វើការបញ្ជាក់នៅក្នុងផ្នែក :

"ដោយរំលឹកឡើងថា ការរើសអើងប្រឆាំងនារីភេទបានរំលោភលើគោលការណ៏សិទ្ធិស្មើភាព និងរំលោភលើការគោរពចំពោះ កិត្យានុភាពមនុស្ស វាគឺជាឧបសគ្គចំពោះការចូលរួមរបស់នារី អំពីលក្ខខ័ណ្ឌស្មើគ្នាជាមួយបុរស នៅក្នុងជីវិតនយោបាយ សង្គម សេដ្ឋកិច្ច និងជីវិតវប្បធម៌ក្នុងរបស់ប្រទេសគេ ធ្វើឱ្យរាំងស្ទះដល់ការលូតលាស់ចំរុងចំរើនរបស់សង្គម និងគ្រួសារ ព្រមទាំងបង្កការលំបាកដល់ការ អភិវឌ្ឍន៏ឱ្យបាន ពេញលេញនៃសក្តានុពលភាពរបស់នារីនៅក្នុងការបំរើប្រទេសរបស់គេ និងការបំរើមនុស្សជាតិ" ។

---
[១] មាននៅក្នុងឯកសារ A/៤៧/៣៨។

២.អនុសញ្ញាបានធ្វើការបញ្ជាក់សារជាថ្មីឡើងវិញបន្ថែមទៀតនៅក្នុងបុព្វកថារបស់ខ្លួននូវសារៈសំខាន់នៃការចូលរួមរបស់នារីនៅ ក្នុងការធ្វើសេចក្តីសំរេចចិត្តដែលមានដូចតទៅនេះ :

"ដោយជឿជាក់ថា ការអភិវឌ្ឍន៍ឱ្យបានពេញលេញ និងគ្រប់គ្រាន់របស់ប្រទេសមួយជាសុខមាលភាពរបស់ពិភពលោក និងការ ធ្វើឱ្យមានសន្តិភាពដែលបានតំរូវឱ្យមានការចូលរួមរបស់នារីឱ្យបានជាអតិបរមាលើលក្ខខ័ណ្ឌស្មើគ្នាជាមួយបុរសនៅគ្រប់វិស័យ"។

៣. លើសពីនេះទៅទៀត នៅក្នុងមាត្រាទី១នៃអនុសញ្ញា ពាក្យថា "ការរើសអើងប្រឆាំងនារីភេទ" គឺត្រូវបានគេបកស្រាយនូវ អត្ថន័យ :

"ភាពខុសគ្នា ការមិនរាប់បញ្ចូល ឬការកំរិតណាមួយដែលធ្វើឡើងផ្អែកលើមូលដ្ឋានភេទដែលមានផល ឬមានបំណងធ្វើឱ្យខូច ឬ ធ្វើឱ្យទៅជាមោឃៈការទទួលស្គាល់ ការចូលរួម ឬការអនុវត្តន៍ដោយនារី មិនគិតពីស្ថានភាពប្តីប្រពន្ធ ផ្អែកលើមូលដ្ឋានភាពស្មើគ្នារវាង បុរស និងនារី អំពីសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាននៅក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌ ស៊ីវិល ឬក៏វិស័យនានាដទៃ ទៀត"។

៤.អនុសញ្ញា សេចក្តីប្រកាស និងការវិភាគដទៃទៀតបានដាក់សារៈសំខាន់យ៉ាងធំធេងទៅលើការចូលរួមរបស់នារីនៅក្នុងជីវិតសាធារណៈ និងបានកំនត់នូវក្របខ័ណ្ឌការងារតាមមាត្រដ្ឋានអន្តរជាតិអំពីភាពស្មើគ្នា។ ទាំងនេះរួមទាំងសេចក្តីប្រកាសជាសកលនៃសិទ្ធិ មនុស្ស[១] កតិការអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ[២] អនុសញ្ញាស្តីពីសិទ្ធិនយោបាយរបស់នារី[៣] សេចក្តីប្រកាសក្រុងវីយែន[៤] កថា ខ័ណ្ឌ១៣នៃសេចក្តីប្រកាសក្រុងប៉េកាំង និងកម្មវិធីនយោបាយសំរាប់អនុវត្ត[៥] យោបល់រួម៥ និង៨ស្ថិតនៅក្រោមអនុសញ្ញា[៦] យោបល់រួម ២៥ដែលបានអនុម័តដោយគណៈកម្មាធិការសិទ្ធិមនុស្ស[៧] អនុសាសន៍ដែលបានអនុម័តដោយក្រុមប្រឹក្សាសហគមន៍អឺរ៉ុបអំពីការចូលរួមមាន តុល្យភាពរបស់នារី និងបុរសនៅក្នុងដំណើរការធ្វើការសំរេចចិត្ត និង[៨] ស្ពងការសហគមន៍អឺរ៉ុប "ធ្វើយ៉ាងណាដើម្បីបង្កើតតុល្យភាពភេទនៅ ក្នុងការធ្វើការសំរេចចិត្តខាងនយោបាយ"។

៥.មាត្រាទី៧បង្គាប់ឱ្យរដ្ឋភាគីធ្វើការចាត់វាល់វិធានការទាំងអស់ឱ្យបានសមស្របដើម្បីលុបបំបាត់ចោលការរើសអើងប្រឆាំងនារីភេទនៅក្នុងជីវិតនយោបាយ និងជីវិតសាធារណៈ និងដើម្បីធានាថាពួកគេបានចូលរួមអនុវត្តនូវសិទ្ធិស្មើភាពគ្នាជាមួយបុរសនូវជីវិតនយោបាយ និងជីវិតសាធារណៈ។ កាតព្វកិច្ចបានបញ្ជាក់នៅក្នុងមាត្រាទី៧ឱ្យធ្វើការពង្រីកដល់គ្រប់តំបន់ទាំងអស់នៃជីវិតសាធារណៈ និង ជីវិតនយោបាយព្រមទាំងមិនត្រូវធ្វើការកំនត់ចំពោះតំបន់ទាំងនោះដែលមានបញ្ជាក់នៅក្នុងអនុកថាខ័ណ្ឌ(ក) (ខ)និង(គ)។ ជីវិតនយោបាយ និងជីវិតសាធារណៈរបស់ប្រទេសមួយគឺជាទស្សនាទានដ៏ទូលំទូលាយ។ នេះសំដៅទៅលើការអនុវត្តន៍អំណាចនយោបាយជាពិសេស ការអនុវត្តន៍លើអំណាចនីតិបញ្ញត្តិ អំណាចតុលាការ អំណាច

នីតិប្រតិបត្តិ និងអំណាចរដ្ឋបាល។ លក្ខខ័ណ្ឌវាគ្របដណ្តប់លើគ្រប់ចំនុចនៃ រដ្ឋបាលសាធារណៈ ការបង្កើត រូបមន្ត និងការអនុវត្តន៍នូវគោលនយោបាយក៏រិតថ្នាក់អន្តរជាតិ ថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់មូលដ្ឋាន។ ទស្សនាទាន បានដាក់បញ្ចូលនូវចំនុចសង្គមជាច្រើនផងដែរ រួមទាំងគណៈកម្មាធិការសាធារណៈ និងក្រុមប្រឹក្សាមូលដ្ឋាន ព្រមទាំង សកម្មភាពរបស់អង្គភាពនានា ដូចជាគណបក្សនយោបាយ សហជីព សមាគមន៏វិជ្ជាជីវ ឬសមាគមន៏ឧស្សាហកម្ម អង្គការស្រ្តី អង្គការដែល មានមូលដ្ឋានតាម សហគមន៏ និងអង្គការនានាដែលទាក់ទងជាមួយជីវិតនយោបាយ និងជីវិតសាធារណៈ។

៦. អនុសញ្ញាបានប្រមើលឃើញថា ដើម្បីធ្វើឱ្យមានប្រសិទ្ធិភាព គេត្រូវសំរេចឱ្យបាននូវសិទ្ធិស្មើភាពនៅក្នុងក្របខ័ណ្ឌប្រព័ន្ធនយោ បាយ ដែលពលរដ្ឋម្នាក់ៗត្រូវចូលរួមអនុវត្តសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោតនៅក្នុងការបោះឆ្នោតតាមពេលកំនត់ត្រឹមត្រូវ ដែលរៀបចំឡើងផ្អែកលើសិទ្ធិបោះឆ្នោតជាសកល និងការបោះឆ្នោតដោយសំងាត់ តាមលក្ខណៈដើម្បីធ្វើការធានាដល់ការបញ្ចេញនូវឆន្ទៈ ដោយសេរីនៃការបោះឆ្នោត ដូចដែលបានបញ្ជាក់ស្ថិតនៅលិខិតុបករណ៏សិទ្ធិមនុស្សអន្តរជាតិ ដូចជាមាត្រាទី២១នៃសេចក្តីប្រកាសជាសកល នៃសិទ្ធិមនុស្ស និងមាត្រាទី២៥នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិស៊ីវិល និងសិទ្ធិនយោបាយ។

៧.ការសង្កត់ធ្ងន់របស់អនុសញ្ញាស្តីពីសារៈសំខាន់ភាពស្មើគ្នានៃឱកាស និងការចូលរួមនៅក្នុងជីវិតសាធារណៈ និងការធ្វើការសំរេចចិត្តដែលបាននាំឱ្យគណៈកម្មាធិការធ្វើការត្រួតពិនិត្យមើលមាត្រាទី៧ និងដើម្បីស្នើឱ្យរដ្ឋភាគីធ្វើការត្រួតពិនិត្យនូវច្បាប់ និងគោលនយោបាយរបស់ខ្លួន និងនៅក្នុងការធ្វើសេចក្តីរាយការណ៏ស្ថិតនៅក្រោមអនុសញ្ញា គេត្រូវធ្វើការគិតគូរទៅលើយោបល់រួម និងអនុសាសន៏ដែលបានកំនត់ដូចខាងក្រោមនេះ :

## <u>យោបល់</u>

៨. ដែនសកម្មភាពមនុស្សជាសាធារណៈនិងឯកជនជានិច្ចកាលបានត្រូវគេធ្វើការពិចារណាខុសគ្នា ហើយវាត្រូវបានគេធ្វើនិយត កម្មស្របគ្នា។ ដោយមិនមានការខុសគ្នា នារីត្រូវបានគេប្រគល់ការងារព្រំដែនឯកជន ឬព្រំដែនក្នុងគ្រួសារ ដោយមានការទាក់ទងជាមួយ និងការបន្តពូជ និងការចិញ្ចឹមបីបាច់កូន ហើយគ្រប់សង្គមទាំងអស់សកម្មភាពទាំងនេះត្រូវបានគេចាត់ទុកក៏រិតទាប។ ផ្ទុយទៅវិញជីវិត សាធារណៈដែលត្រូវបានគេគោរព និងផ្តល់កិត្តិយស វាបានពង្រីកនូវក៏រិតសកម្មភាពយ៉ាងទូលំទូលាយខាងក្រៅដែនឯកជន និងដែនក្នុងគ្រួសារ។ តាមប្រវត្តិសាស្រ្តបុរសមានភាពលុបលើទាំងជីវិតសាធារណៈ និងបានប្រើអំណាចធ្វើការកំនត់ដាក់នារីនៅក្រោមបង្គាប់នៅក្នុង ដែនឯកជន។

៩. ទោះបីតួនាទីសំខាន់របស់នារីនៅក្នុងការធ្វើឱ្យមាននិរន្តភាពនៅក្នុងគ្រួសារ និងសង្គម ព្រមទាំងការរួមវិភាគទានការអភិវឌ្ឍន៏ ក៏ដោយ ពួកគេមិនត្រូវបានគេដាក់បញ្ចូលនៅក្នុងជីវិតនយោបាយ និងដំណើរការធ្វើការសំរេចចិត្ត ដែលទោះបីជាបានកំនត់នៅបែបផែន ជីវិតប្រចាំថ្ងៃ និងអនាគតរបស់សង្គមក៏ដោយ។ ជាពិសេសនៅពេលមានវិបត្តិ ការមិនរាប់បញ្ចូលនេះបានធ្វើឱ្យគេមិនឮសំលេងនារី និងធ្វើ ឱ្យមើលមិនឃើញនូវការរួមវិភាគទាន និងបទពិសោធន៏របស់គេ។

១០. នៅគ្រប់ប្រទេសទាំងអស់ កត្តាសំខាន់បំផុតដែលរារាំងលទ្ធភាពនារីមិនឱ្យចូលរួមនៅក្នុងជីវិតសាធារណៈ គឺជាក្របខ័ណ្ឌ តំលៃវប្បធមិ និងជំនឿសាសនា ខ្វះនៅសេវា និងការខកខានរបស់បុរសដើម្បីចូលរួមភារកិច្ចជាប់ទាក់ទងជាមួយអង្គភាពគ្រួសារ ព្រមជាមួយការថែទាំចិញ្ចឹមបីបាច់កូន។ នៅគ្រប់ប្រទេសទាំងអស់ប្រពៃណីយ វប្បធមិ និងជំនឿសាសនាបានដើរតួនាទីជាផ្នែកមួយនៅក្នុងការ កំនត់ចំពោះដែនសកម្មភាពឯកជន និងការមិនគិតបញ្ចូលនារីឱ្យចូលរួមសកម្មនៅក្នុងជីវិតសាធារណៈ។

១១. ការបន្ធូបន្ថយនូវបន្ទុកការងារនារីក្នុងគ្រួសារ គឺបានអនុញ្ញាតឱ្យគេជាប់ទាក់ទងនៅក្នុងជីវិតសហគមន៏របស់ពួកគេកាន់តែ ពេញលេញថែមទៀត។ ការពឹងផ្អែកសេដ្ឋកិច្ចរបស់នារីទៅលើបុរស ជារឿយៗបានរារាំងពួកគេមិនឱ្យធ្វើការសំរេចចិត្តដល់នយោបាយ សំខាន់ៗ និងមិនបានចូលរួមយ៉ាងសកម្មនៅក្នុងជីវិតសាធារណៈ។ បន្ទុការងារទ្វេរដង និងការពឹងអាស្រ័យសេដ្ឋកិច្ចរបស់គេរួមជាមួយ យូរម៉ោង ឬម៉ោងមិនផ្លាស់ប្តូរបានទាំងនៅការងារសាធារណៈ និងការងារនយោបាយ វាបានរារាំងនារីមិនឱ្យកាន់តែសកម្មឡើង។

១២. ការប្រកាន់នូវគំនិតចាស់គំរិល រួមទាំងការប្រព្រឹត្តដោយប្រព័ន្ធផ្សព្វផ្សាយផង បានកំរិតនារីនៅក្នុងជីវិតនយោបាយចំពោះ បញ្ហាដូចជាបរិស្ថាន កុមារ និងសុខភាព គេមិនរាប់បញ្ចូលពួកគេឱ្យមានការទទួលខុសត្រូវខាងការគ្រប់គ្រងហិរញ្ញវត្ថុ ថវិកា និងការសំរេចជំលោះទេ។ ការពាក់ព័ន្ធនារីនៅកំរិតទាបក្នុងវិជ្ជាជីវដែលអ្នកនយោបាយធ្វើការជ្រើសរើសនោះអាចបង្កើតជាឧបសគ្គមួយទៀត។ នៅក្នុងប្រទេសខ្លះដែលមានមេដឹកនាំនារីកាន់អំណាចនេះអាចបានមកពីឥទ្ធិពលរបស់ឪពុកស្វាមី ឬសាច់ញាតិប្រុស របស់គេច្រើនជាងការទទួល បានជ័យជំនះមកពីបោះឆ្នោតដោយការប្រើសិទ្ធិផ្ទាល់ខ្លួនគេ។

## ប្រព័ន្ធនយោបាយ

១៣. គោលការណ៍ស្មើភាពរវាងបុរស និងនារីបានត្រូវគេធ្វើការបញ្ជាក់អះអាងនៅក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់នៃប្រទេសភាគច្រើន និងនៅក្នុងលិខិតុបករណ៍អន្តរជាតិទាំងអស់។ តែទោះជាយ៉ាងណាក៏ដោយ នៅក្នុងរយៈពេល៥០ឆ្នាំចុងក្រោយនេះនារីមិនបានសំរេចភាព ស្មើគ្នា និងភាពមិនស្មើគ្នាត្រូវបាន គេដាក់បន្ថែម ដោយការចូលរួមនៅក៏រិតទាបនៅក្នុងជីវិតសាធារណៈ និងជីវិតនយោបាយ។ គោលនយោបាយនិងការសំរេចចិត្តធ្វើឡើងដោយបុរសតែឯងបានឆ្លុះបញ្ចាំងឱ្យឃើញត្រឹមតែផ្នែកនៃការជួបប្រទះ និងសក្តានុពលរបស់មនុស្សប៉ុណ្ណោះ។ អង្គភាពសង្គមដែលមានប្រសិទ្ធិភាព និងយុត្តិធម៌ទាមទារនូវការរាប់បញ្ចូល និងការចូលរួមនូវគ្រប់សមាជិកទាំងអស់។

១៤.មិនមានប្រព័ន្ធនយោបាយណាមួយប្រគល់ឱ្យទាំងសិទ្ធិចំពោះ និងអត្ថប្រយោជន៍ការចូលរួមពេញលេញ និងស្មើគ្នាទេ។ ទន្ទឹម នោះប្រព័ន្ធប្រជាធិតេយ្យបានធ្វើការលើកស្ទួយឱកាសរបស់នារីដើម្បីទាក់ទងនៅក្នុងជីវិតនយោបាយ ឧបសគ្គសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលពួកបន្តធ្វើការប្រឈរមុខបានកំនត់ដល់ការចូលរួមរបស់ពួកគេយ៉ាងខ្លាំង។ ទោះបីតាមប្រវត្តិសាស្រ្តប្រជាធិបតេយ្យដែលមានស្ថេរភាព បានខកខានដើម្បីធ្វើការដាក់បញ្ចូលឱ្យបានពេញលេញ និងស្មើគ្នានូវទស្សនៈ និងផលប្រយោជន៍របស់ប្រជាជនពាក់កណ្តាលជាភេទនារី។ សង្គមដែលមិនរាប់បញ្ចូលនារីនៅក្នុងជីវិតសាធារណៈ និងការធ្វើការសំរេចចិត្ត មិនអាចចាត់ទុកថាប្រជាធិបតេយ្យបានទេ។ ទស្សនាទាន ប្រជាធិតេយ្យនឹងមានអត្ថន័យពិតប្រាកដ និងប្រកបដោយថាមពលខ្លាំង ហើយបន្តនូវផលបាននៅពេលណាការធ្វើការសំរេចចិត្ត នយោបាយត្រូវបានចូលរួមដោយនារី និងបុរសព្រមទាំងធ្វើការគិតគូរដល់ផលប្រយោជន៍ទាំងពីរស្មើៗគ្នា។ ការត្រួតពិនិត្យលើរបាយការណ៍របស់រដ្ឋភាគីបានបង្ហាញថាកន្លែងណាដែលមានការចូលរួមរបស់នារីដោយពេញលេញ និងស្មើគ្នានៅក្នុងជីវិតសាធារណៈ និងការធ្វើការសំរេចចិត្ត នោះការអនុវត្តន៍នូវសិទ្ធិ និងគោរពតាមអនុសញ្ញាបានប្រសើរឡើងហើយ។

## <u>វិធានការពិសេសបណ្តោះអាសន្ន</u>

១៥. ទន្ទឹមការលុបចោលនូវរបាំងឧបសគ្គតាមលក្ខណៈច្បាប់គឺជាការចាំបាច់ តែវានៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ ការខកខានចំពោះការសំរេចឱ្យបាននូវការចូលរួមរបស់នារីឱ្យបានពេញលេញ និងស្មើគ្នា វាអាចជាអចេតនា និងអាចបណ្តាលមកការប្រតិបត្តិខុស របៀប និងនីតិវិធីដែលបានធ្វើការជំរុញបុរសដោយអចេតនា។ តាមមាត្រទី៤ អនុសញ្ញាបានជំរុញឱ្យមានការប្រើនូវវិធានការពិសេស បណ្តោះអាសន្នដើម្បីផ្តល់នូវផលពេញលេញដល់មាត្រាទី៧ និងទី៨។ នៅប្រទេសដែលបានធ្វើឱ្យជឿនលឿននូវយុទ្ធសាស្រ្តបណ្តោះ

អាសន្ន ប្រកបដោយប្រសិទ្ធិភាពក្នុងការប៉ុនប៉ងដើម្បីសំរេចឱ្យបាននូវភាពស្មើៗគ្នានៃការចូលរួម នោះវិធានការដែលមានកំរិតធំធេងត្រូវបានគេធ្វើ ការអនុវត្តន៍ហើយ រួមទាំងការជ្រើសរើសបុគ្គលិក ការជំនួយហិរញ្ញវត្ថុ ការបណ្តុះបណ្តាលបេក្ខនារី ការធ្វើវិសោធនកម្មនីតិវិធីបោះឆ្នោត អភិវឌ្ឍន៍យុទ្ធនាការដែលដឹកនាំឱ្យមានការចូលរួមស្មើគ្នា ការកំនត់នូវគោលបំណង កំនត់កូតា និងការកំនត់គោលដៅមួយចំនួនដល់នារី ដើម្បីការចាត់តាំងកាន់មុខតំណែងសាធារណៈដូចជាតុលាការ ឬក្រុមវិជ្ជាជីវៈដែលបានដើរតួមួយផ្នែកយ៉ាងសំខាន់នៅក្នុងជីវិតប្រចាំថ្ងៃនៃគ្រប់សង្គមទាំងអស់។ ការលុបបំបាត់ចោលឧបសគ្គជាផ្លូវការ និងការណែនាំបង្ហាញនូវវិធានការពិសេសបណ្តោះអាសន្នដើម្បីជំរុញឱ្យមានការចូលរួមស្មើគ្នាទាំងបុរស និងនារីនៅក្នុងជីវិតសាធារណៈនៃសង្គមរបស់គេ ដែលគឺជាការត្រូវការមុនយ៉ាងចំបងចំពោះភាពស្មើគ្នា ពិតប្រាកដនៅក្នុងជីវិតនយោបាយ។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីជំនះនូវសតវត្សនៃភាពលុបលើព្រំដែនសាធារណៈរបស់ភេទបុរស នារីត្រូវការផងដែរ នូវការលើកទឹកចិត្ត និងការគាំទ្រវាល់គ្រប់ផ្នែករបស់សង្គម ដើម្បីសំរេចបាននូវការចូលរួមពេញលេញ និងប្រកបដោយប្រសិទ្ធិភាព ការលើកទឹកចិត្តដែលត្រូវតែធ្វើការដឹកនាំដោយរដ្ឋភាគីរបស់អនុសញ្ញា ព្រមទាំងដោយគណៈបក្សនយោបាយ និងមន្ត្រី សាធារណៈផងដែរ។ រដ្ឋភាគីមានកាតព្វកិច្ចដើម្បីធ្វើការធានាថា វិធានការពិសេសបណ្តោះអាសន្នត្រូវគេធ្វើការរៀបចំយ៉ាងច្បាស់លាស់ ដើម្បីគាំទ្រដល់គោលការណ៍ភាពស្មើគ្នា និងហេតុនេះត្រូវធ្វើការគោរពតាមគោលការណ៍រដ្ឋធម្មនុញ្ញ ដែលបានធានាដល់ភាពស្មើគ្នានៃប្រជាពលរដ្ឋទាំងអស់។

## <u>ការបូកសរុបសង្ខេប</u>

១៦. បញ្ហាសំខាន់ ដែលបានសង្កត់ធ្ងន់ទៅលើកម្មវិធីនយោបាយអនុវត្តនៅក្រុងប៉េកាំង ៥ គឺជាគំលាតរវាងភាពត្រឹមត្រូវតាមច្បាប់ ជាមួយនិងពិតប្រាកដ ឬក៏ សិទ្ធិដែលប្រឆាំងនូវសច្ចភាព នៃការចូលរួមរបស់នារីនៅក្នុងនយោបាយ និងជីវិតសាធារណៈជាទូទៅ។ ការស្រាវជ្រាវបានបង្ហាញថា ប្រសិនបើការចូលរួមរបស់នារីឈានដល់៣០ ទៅ៣៥ភាគរយ (ជាទូទៅហៅពាក្យថា "មហាជនសំខាន់") វាមានឥទ្ធិពលពិតប្រាកដទៅលើរចនាបទនយោបាយ និងមាតិកានៃការសំរេចចិត្ត ហើយជីវិតនយោបាយ ត្រូវគេធ្វើឱ្យមានជីវិតរស់ឡើងវិញ។

១៧. ដើម្បីសំរេចនូវតំណាងដ៏ទូលំទូលាយនៅក្នុងជីវិតសាធារណៈ នារីត្រូវតែមានភាពស្មើគ្នាពេញលេញនៅក្នុងការអនុវត្តន៍ អំណាចនយោបាយ និងអំណាចសេដ្ឋកិច្ច ពួកគេត្រូវតែជាប់ពាក់ព័ន្ធយ៉ាងពេញលេញ និងប្រកបដោយភាពស្មើគ្នានៅការធ្វើការសំរេចចិត្ត នៅគ្រប់ជាន់ថ្នាក់ទាំងលើឆាកជាតិ និងអន្តរជាតិ។ ដូចនេះពួកគេអាចធ្វើការរួមវិភាគទានរបស់គេចំពោះគោលបំណងនៃភាពស្មើគ្នា គោលបំណងការអភិវឌ្ឍន៍

និងគោលបំណងការសំរេចសមិទ្ធផលសន្តិភាព។ ទស្សនៈវិស័យភេទគឺជាសារៈសំខាន់ប្រសិនបើគោលបំណងនេះឆ្លើយតប ហើយប្រសិនបើលទ្ធិប្រជាធិបតេយ្យពិតត្រូវបានគេធានា។ ចំពោះហេតុផលទាំងនេះ វាមានសារៈសំខាន់ចំពោះការជាប់ទាក់ទងនារី នៅក្នុងជីវិតសាធារណៈដើម្បីរកបាននូវផលប្រយោជន៍នៃការរួមវិភាគទានរបស់គេ ដើម្បីធានាដល់ប្រយោជន៍របស់គេត្រូវបានការការពារ និងដើម្បីបំពេញនូវការធានាថាការអនុវត្តន៍សិទ្ធិមនុស្សគឺធ្វើឡើងសំរាប់មនុស្សគ្រប់រូបដោយមិនគិតពីភេទឡើយ។ ការចូលរួមពេញលេញរបស់នារីគឺមានសារៈសំខាន់ចំពោះការប្រគល់អំណាចប៉ុណ្ណោះទេ វាថែមទាំងធ្វើឱ្យជឿនលឿនដល់សង្គមទាំងមូលទៀតផង។

## សិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត (មាត្រា៧ កថាខ័ណ្ឌ"ក")

១៨. អនុសញ្ញាបានបង្គាប់ឱ្យរដ្ឋភាគីនៅក្នុងរដ្ឋធម្មនុញ្ញ ឬនីតិកម្មធ្វើការចាត់វិធានការឱ្យបានសមស្របដើម្បីធានាថា នារីដែល ផ្អែកលើគោលការណ៍ស្មើភាពជាមួយបុរស គេត្រូវមានសិទ្ធិចូលរួមបោះឆ្នោតនៅរាល់ការធ្វើការបោះឆ្នោត និងការធ្វើប្រជាមតិទាំងអស់ ហើយនិងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត។ សិទ្ធិទាំងនេះត្រូវតែចូលរួមដោយស្របច្បាប់ និងត្រឹមត្រូវពិតប្រាកដ។

១៩. ការត្រួតពិនិត្យលើរបាយការណ៍រដ្ឋភាគីបានបង្ហាញថា ទន្ទឹមនិងមានស្ទើរតែរដ្ឋទាំងអស់បានអនុម័តនូវបទបញ្ញត្តិរដ្ឋធម្មនុញ្ញ ឬបទបញ្ញត្តិច្បាប់ផ្សេងៗដែលប្រគល់ឱ្យទាំងបុរស និងនារីនូវសិទ្ធិស្មើគ្នាដើម្បីធ្វើការបោះឆ្នោតនៅរាល់ការរៀបបោះឆ្នោត និងការធ្វើប្រជាមិតសាធារណៈនោះ នៅក្នុងប្រទេសជាច្រើននៅមាននារីបន្តធ្វើការឆ្លងកាត់នូវការលំបាកនៅក្នុងការអនុវត្តន៍សិទ្ធិនេះ។

២០. កត្តាដែលធ្វើឱ្យរាំងស្ទះនូវសិទ្ធិទាំងនេះមានដូចតទៅ:

ក. ជារឿយៗនារីទទួលបានពតិមានតិចជាងបុរសអំពីបេក្ខជន និងអំពីកម្មវិធីនយោបាយគណបក្ស ហើយនិងនីតិវិធីការ បោះឆ្នោត ជាពតិមានដែលរដ្ឋាភិបាល និងគណបក្សនយោបាយខកខានមិនបានផ្តល់ឱ្យ។ កត្តាសំខាន់ផ្សេងៗទៀតដែលហាមឃាត់ នារីមិនឱ្យអនុវត្តន៍នៃសិទ្ធិរបស់ខ្លួនឱ្យពេញលេញ និងស្មើភាពគ្នាចំពោះការបោះឆ្នោតរួមមាន អនក្ខរកម្ម ការខ្វះនូវការយល់ដឹងនិងការយល់របស់គេនៃប្រព័ន្ធនយោបាយ ឬអំពីឥទ្ធិពលដែលគំនិតផ្តួចផ្តើមនយោបាយ និងគោលនយោបាយនឹងមាននៅលើជីវិត របស់ពួកគេ។ ការមិនយល់ពីសិទ្ធិ មិនយល់ពីការទទួលខុសត្រូវនិងពីឱកាសសំរាប់ផ្លាស់ប្តូរដែលផ្តល់ដោយសិទ្ធិបោះឆ្នោត ហើយក៏ចង់សំដៅផងដែរថា នារីជានិច្ចកាលមិនបានចុះឈ្មោះបោះឆ្នោត។

ខ. បន្ទុកការងារទ្វេដងរបស់នារី ព្រមជាមួយការដាក់កំរិតហិរញ្ញវត្ថុ វានឹងកំនត់ដល់ពេលវេលារបស់នារី ឬកំរិតឱកាស ដើម្បីធ្វើតាមយុទ្ធនាការបោះឆ្នោត និងដើម្បីមានសេរីភាពពេញលេញចំពោះការអនុវត្តន៍សិទ្ធិបោះឆ្នោតរបស់គេ។

គ. នៅក្នុងប្រទេសជាច្រើន ប្រពៃណី និងភាពចាស់គំរិលរបស់សង្គម និងវប្បធម៌បានរាំងនារីមិនឱ្យបានធ្វើការប្រើ សិទ្ធិបោះឆ្នោតរបស់គេ។ បុរសជាច្រើនមានឥទ្ធិពល ឬគ្រប់គ្រងលើការបោះឆ្នោតរបស់នារីប្រើការបញ្ចុះបញ្ចូលឬដោយសកម្ម ភាពផ្ទាល់រួមទាំងធ្វើការបោះឆ្នោត ជំនួសឱ្យពួកគេ។ ការប្រតិបត្តិបែបណាមួយគួរគេត្រូវធ្វើការហាមឃាត់។

ឃ. កត្តាផ្សេងៗទៀតជាច្រើននៅក្នុងប្រទេសខ្លះបានរាំងស្ទះដល់ការពាក់ព័ន្ធរបស់នារីនៅក្នុងជីវិតសាធារណៈឬជីវិត នយោបាយនៃសហគមន៍របស់គេរួមទាំងការកំរិតលើសេរីភាពការដើរហើរ ឬកំរិតនូវសិទ្ធិចូលរួម ការយកឈ្នះលើតិរិយាបថអវិជ្ជ មានឆ្ពោះទៅរកការចូលរួម នយោបាយរបស់នារី បើពុំនោះសោតទេវានឹងខ្វះនៅជំនឿជឿជាក់លើបេក្ខនារី និងការគាំទ្របេក្ខនារី ដោយការបោះឆ្នោត។ បន្ថែមពីនេះទៅទៀត នារីខ្លះបានចាត់ទុកការពាក់ព័ន្ធនៅក្នុងនយោបាយជាការចូលរួមគួរឱ្យស្អប់ខ្ពើម និង គួឱ្យជៀសវាងនៅក្នុងយុទ្ធនាការនយោបាយ។

២១. កត្តាទាំងនេះយ៉ាងហោចណាស់បានធ្វើការពន្យល់ប្រតិមតិដោយផ្នែកដែលនារី ជាអ្នកតំណាងពាក់កណ្តាលនៃអ្នកបោះឆ្នោត ទាំងអស់មិនបានផ្សារភ្ជាប់នូវអំណាចនយោបាយរបស់គេ ឬមិនបានបង្កើតជាក្រុមដែលធ្វើការជំរុញនូវអត្ថប្រយោជន៍ ឬធ្វើការផ្លាស់ប្តូររដ្ឋា ភិបាល ឬធ្វើការលុបបំបាត់ចោលគោលនយោបាយរើសអើងរបស់គេ។

២២. ប្រព័ន្ធបោះឆ្នោត ការបែងចែកអស្សនៈនៅក្នុងសភា ការជ្រើសរើសតំបន់ ទាំងអស់នេះសុទ្ធតែជាឥទ្ធិពលដ៏មានសារៈសំខាន់ ទៅលើសមាមាត្រនារីដែលជាប់ឆ្នោតទៅរដ្ឋសភា។ គណបក្សនយោបាយត្រូវអោបនូវគោលការណ៍នៃឱកាសស្មើគ្នា និងលទ្ធិប្រជាធិប តេយ្យ និងត្រូវតែធ្វើការពុះពារដើម្បីឱ្យមានតុល្យភាពនូវចំនួនបេក្ខជន និងបេក្ខនារី។

២៣. ការចូលរួមអនុវត្តន៍នូវសិទ្ធិបោះឆ្នោតរបស់នារីមិនគួរត្រូវដាក់កំរិតឡើយ ឬលក្ខខ័ណ្ឌដែល មិនប្រើចំពោះបុរស ឬក៏ថាមាន ឥទ្ធិពលមិនសមាមាត្រទៅលើនារី។ ឧទាហរណ៍ ការកំរិតនូវសិទ្ធិបោះឆ្នោតចំពោះមនុស្សដែលមានកំរិតវប្បធម៌កំនត់ជាក់លាក់មួយ ដែល មានលក្ខណៈសម្បត្តិទ្រព្យសម្បត្តិអប្បបរមា ឬអ្នកដែលចេះអានចេះសរសេរគឺវាមិនទាន់សមស្របនៅឡើយទេ វាអាចរំលោភដល់ការ ធានាជាសកលនៃសិទ្ធិមនុស្ស។ ហើយវាទំនងជាមានឥទ្ធិពលមិនសមាមាត្រផងដែរទៅលើនារី ដោយហេតុថាវារំលោភទៅលើបទបញ្ញត្តិ របស់អនុសញ្ញា។

## សិទ្ធិចូលរួមនៅក្នុងការបង្កើតរូបមន្តគោលនយោបាយរដ្ឋាភិបាល (មាត្រា៧ កថាខ័ណ្ឌ"ខ")

២៤. ការចូលរួមរបស់នារីនៅក្នុងរដ្ឋាភិបាលនៅកំរិតគោលនយោបាយបានបន្តនៅកំរិតទាបនៅឡើយជាទូទៅ។ ទោះបីជាមាន ការវិវត្តន៍រីកចំរើនគួរឱ្យចាប់អារម្មណ៍ដែលបានធ្វើឡើង ហើយនិងនៅប្រទេសមួយចំនួនបានទទួលផលសំរេចក៏ដោយ ។

២៥. មាត្រាទី៧(ខ)ក៏បានតំរូវឱ្យរដ្ឋភាគីធ្វើការធានាផងដែរថា នារីមានសិទ្ធិចូលរួមពេញលេញ និងធ្វើជាតំណាងនៅក្នុងការ បង្កើតនូវគោលនយោបាយសាធារណៈនៅគ្រប់ផ្នែក និងគ្រប់លំដាប់ថ្នាក់។ នេះជួយសំរួលដល់ឥទ្ធិពលនៃបញ្ហាភេទ និងរួមវិភាគទាននូវ ទស្សនៈវិស័យភេទដល់ការតាក់តែងគោលនយោបាយសាធារណៈ។

២៦. រដ្ឋភាគីត្រូវមានការទទួលខុសត្រូវ នៅកន្លែងដែលខ្លួនគ្រប់គ្រង ទាំងធ្វើការតែងតាំងនារីនូវតួនាទីធ្វើការការសំរេចចិត្តថ្នាក់ ធំៗ ហើយជាការពិតណាស់ ត្រូវធ្វើការពិគ្រោះ និងចូលរួមនូវយោបល់ដំបូន្មានរបស់ក្រុមដែលជាតំណាងនៃទស្សនៈ និងផលប្រយោជន៍ របស់នារីយ៉ាងទូលំទូលាយ ។

២៧. រដ្ឋភាគីត្រូវមានកាតព្វកិច្ចបន្ថែមទៀតដើម្បីធានាថាឧបសគ្គចំពោះការចូលរួមពេញលេញរបស់នារីនៅក្នុងការបង្កើតគោល នយោបាយរដ្ឋាភិបាលត្រូវបានគេបង្ហាញឱ្យដឹង និងត្រូវបានគេជំនះ។ ឧបសគ្គទាំងនេះរួមទាំងការពេញចិត្តនៅពេលដែលនារីជានិមិត្តរូបត្រូវ បានគេធ្វើការតែងតាំង ហើយឥរិយាបថ ប្រពៃណីយ និងទំនាមទំលាប់ដែលរារាំងដល់ការចូលរួមរបស់នារី។ នៅពេលដែលនារីមិនធ្វើជា តំណាងថ្នាក់ខ្ពស់របស់រដ្ឋាភិបាល ឬមិនទាន់មានគ្រប់គ្រាន់ ឬមិនបានធ្វើការពិគ្រោះតែម្តង គោលនយោបាយរដ្ឋាបាលនោះនៅមិនទាន់ទូលំទូលាយ និងមានប្រសិទ្ធិភាពនៅឡើយទេ។

២៨. ទន្ទឹមនិងរដ្ឋភាគីជាទូទៅបានធ្វើការកាន់អំណាចតែងតាំងនារីកាន់នៅគណៈរដ្ឋមន្ត្រីថ្នាក់ខ្ពស់ និងតួនាទីរដ្ឋបាល គណបក្ស នយោបាយក៏ត្រូវមានការទទួលខុសត្រូវផងដែរដើម្បីធានាថានារីត្រូវបានគេរាប់បញ្ចូលនៅក្នុងបញ្ជីគណបក្សនិងត្រូវបានតែងតាំងសំរាប់ ការបោះឆ្នោតនៅកន្លែងដែលពួក គេអាចប្រហាក់ប្រហែលនឹងឈ្នះការបោះឆ្នោត។ រដ្ឋភាគីគួរធ្វើការពុះពារផងដែរដើម្បីធានាថានារីត្រូវ បានគេធ្វើការតែងតាំងកាន់នៅស្ថាប័នទីប្រឹក្សារដ្ឋាភិបាលផ្អែកលើមូលដ្ឋានស្មើគ្នាជាមួយបុរស ហើយស្ថាប័នទាំងនេះ ត្រូវធ្វើការគិតគួរឱ្យ បានសមស្របនូវទស្សនៈក្រុមរបស់នារីដែលធ្វើជាតំណាង។ វាជាការទទួលខុសត្រូវដ៏ចំបង របស់រដ្ឋាភិបាលចំពោះការលើកទឹកចិត្តនូវគំនិត ផ្តួចផ្តើមទាំងនេះដើម្បីដឹកនាំ និងចង្អុលបង្ហាញនូវទស្សនៈសាធារណៈព្រមទាំងធ្វើការផ្លាស់ប្តូរនូវឥរិយាបថដែលរើសអើងប្រឆាំងនារីភេទ ឬ រារាំងដល់ការពាក់ព័ន្ធរបស់នារីនៅក្នុងជីវិត នយោបាយ និងសាធារណៈ។

២៩. វិធានការដែលបានអនុម័តឡើងដោយរដ្ឋភាគីមួយចំនួនដើម្បីធានាដល់ការចូលរួមស្មើគ្នារបស់នារីនៅ ក្នុងមុខតំណែងគណៈ រដ្ឋមន្ត្រីជាន់ខ្ពស់ និងតំណែងរដ្ឋបាល ហើយនិងក៏ដូចជាធ្វើជាសមាជិកស្ថាប័នទីប្រឹក្សារដ្ឋាភិបាលរួមមានៈ ដោយហេតុនេះ ការអនុម័តច្បាប់ នៅពេលដែលអ្នកដែលត្រូវគេតែងតាំងដ៏មានសក្តានុពលមានគុណសម្បត្តិស្មើគ្នា ការពេញចិត្តជ្រើសរើសនឹងប្រគល់ឱ្យបេក្ខនារី ការអនុម័តច្បាប់ដែលថាមិនគិតពីភេទត្រូវកំនត់នូវសមាជិកនៃស្ថាប័នសាធារណៈតិចជាង៤០ភាគរយ កូតាសំរាប់សមាជិកនារីរបស់គណៈរដ្ឋមន្ត្រី ហើយនិងកូតាសំរាប់ការតែងតាំងចំពោះមុខតំណែងសាធារណៈ ធ្វើការពិគ្រោះជាមួយនិងអង្គការនារីដើម្បីធានាថានារីដែលមានលក្ខណៈ សម្បត្តិត្រូវបានគេតែងតាំងសំរាប់សមាជិកភាព នៅក្នុងស្ថាប័ន និងមុខតំណែងសាធារណៈហើយធ្វើការអភិវឌ្ឍន៍ និងថែទាំអ្នកចុះជា នារីភេទ ដើម្បីជួយសំរួលដល់ការឈរឈ្មោះរបស់នារីសំរាប់ការចាត់តាំងឱ្យកាន់នូវស្ថាប័ន និងមុខតំណែងសាធារណៈ ។ កន្លែងដែលសមាជិកត្រូវគេតែងតាំងឱ្យកាន់នូវស្ថាប័នទីប្រឹក្សាអាស្រ័យលើការឈរឈ្មោះរបស់អង្គការឯកជន រដ្ឋភាគីគួរធ្វើការលើកទឹកចិត្តដល់ អង្គការទាំងនេះដើម្បី ផ្តល់ឱ្យបេក្ខនារីដែលមានលក្ខណៈសម្បត្តិ និងសាកសមឈរឈ្មោះសំរាប់សមាជិកភាពនៅក្នុងស្ថាប័នទាំងនេះ ។

## សិទ្ធិកាន់មុខតំណែងសាធារណៈ និងប្រតិបត្តិនូវគ្រប់មុខងារសាធារណៈ (មាត្រា៧ កថាខ័ណ្ឌ"ខ")

៣០. ការពិនិត្យលើរបាយការណ៍របស់រដ្ឋភាគីបានបង្ហាញថានារីមិនត្រូវបានគេរាប់បញ្ចូលនៅក្នុងមុខតំណែងដែលមានឋានន្តរស័ក្តិ ខ្ពស់នៅក្នុងគណៈរដ្ឋមន្ត្រី សេវាស៊ីវិល ក្នុងរដ្ឋបាលសាធារណៈ នៅក្នុងប្រព័ន្ធតុលាការ និងប្រព័ន្ធយុត្តិធម៌ទេ។ នារីកម្រគេធ្វើការតែងតាំង ឱ្យកាន់មុខតំណែងជាន់ខ្ពស់ ឬមុខតំណែងដែលមានឥទ្ធិពលទាំងនេះណាស់ ហើយទន្ទឹមនោះដែរចំនួនពួកគេអាចកំពុងកើនឡើងនៅថ្នាក់ ទាប និងមុខតំណែងដែលជាប់ទាក់ទងជាមួយផ្ទះសម្បែង ឬគ្រួសារ ពួកគេរៀបចំបានត្រឹមតែភាគតិចតួចប៉ុណ្ណោះនៅក្នុងមុខតំណែងការធ្វើ ការសំរេចចិត្តដែលជាប់ទាក់ទងជាមួយនិងគោលនយោបាយសេដ្ឋកិច្ច ឬការអភិវឌ្ឍន៍ កិច្ចការនយោបាយ ការការពារ បេសកកម្មរក្សា សន្តិភាព ការសំរេចដោះស្រាយជំលោះ ឬការបកស្រាយរដ្ឋធម្មនុញ្ញ និងដំណើរការសំរេចចិត្ត។

៣១. ការត្រួតពិនិត្យលើរបាយការណ៍របស់រដ្ឋភាគីក៏បានបង្ហាញដែរថា ករណីយពិតប្រាកដខ្លះរដ្ឋមិនបានរាប់បញ្ចូលនារីចូលរួមនូវ ការអនុវត្តន៍វាជាអំណាច ការបំរើជាចៅក្រមនៅក្នុងសាលាក្តី សាសនា ឬសាលាក្តី តាមប្រពៃណីយដែលបានដាក់នូវយុត្តាធិការតាងនាមឱ្យ រដ្ឋ ឬមិនឱ្យមានការចូលរួមពេញលេញនូវក្នុងយោធា។ បទបញ្ញត្តិទាំងនេះរើសអើងប្រឆាំងនារី បដិសេធចំពោះអត្ថប្រយោជន៍សង្គមនៃការ ពាក់ព័ន្ធរបស់ពួកគេព្រមទាំងជំនាញនៅក្នុងផ្នែកជីវិតនៃសហគមន៍របស់ពួកគេ វាបានរំលោភទៅលើគោលការណ៍របស់អនុសញ្ញា។

## សិទ្ធិចូលរួមនៅក្នុងអង្គការក្រៅរដ្ឋាភិបាល អង្គការសាធារណៈ និងអង្គការចាត់តាំងនយោបាយ (មាត្រា៧ កថាខ័ណ្ឌ"គ")

៣២. ការត្រួតពិនិត្យមួយលើរបាយការណ៍របស់រដ្ឋភាគីបានបង្ហាញថា អំពីឱកាសតិចតួចនៅពេលដែលពតិមានស្តីពីគណបក្ស នយោបាយត្រូវបានគេធ្វើការផ្តល់ជូន នារីមានតំណាងតិចជាង ឬផ្តោតទៅលើតួនាទីណាដែលមានឥទ្ធិពលតិចជាងបុរស។ ជាគណបក្ស នយោបាយគឺជាយានមួយដ៏សំខាន់នៅក្នុង តួនាទីការធ្វើការសំរេចចិត្ត រដ្ឋាភិបាលគួរជំរុញគណបក្សនយោបាយឱ្យធ្វើការត្រួតពិនិត្យលើ វិសាលភាពដើម្បីឱ្យនារីបានចូលរួមពេញលេញ និងស្មើភាពនៅក្នុងសកម្មភាពរបស់គេ ហើយរដ្ឋាភិបាកលគួរបង្ហាញនូវហេតុផលរឿងនេះ ដែលនេះពុំមែនជារឿងក្តីទេ។ គណៈបក្សនយោបាយគេគួរជំរុញដើម្បីធ្វើ ការអនុម័តវិធានការប្រកបដោយប្រសិទ្ធិភាព រួមទាំងបទបញ្ញត្តិ ពតិមាន ធនធានហិរញ្ញវត្ថុ និងធនធានដទៃទៀតដើម្បីជំនះនូវឧបសគ្គចំពោះការចូលរួម និងការធ្វើជាតំណាងពេញលេញរបស់នារី ហើយ ត្រូវធានាថានារី

មានឱកាសស្មើគ្នានៅក្នុងការប្រតិបត្តិដើម្បីបំរើជាមន្ត្រីគណបក្ស និងត្រូវបានគេឱ្យឈរឈ្មោះជាបេក្ខនារីសំរាប់ការបោះ ឆ្នោត ។

៣៣. វិធានការដែលបានអនុម័តដោយគណបក្សនយោបាយរួមទាំងការដាក់ដោយឡែកចំពោះចំនួនតួនាទី ឬភាគរយអប្បបរមា ពិតប្រាកដនៅក្នុងស្ថាប័ននីតិប្រតិបត្តិ ត្រូវធានាថាមានតុល្យភាពរវាងចំនួនបេក្ខជន និងបេក្ខនារីដែលឈរឈ្មោះបោះឆ្នោត ហើយត្រូវធានា ថានារីមិនត្រូវបានគេចាត់តាំងឱ្យទៅកាន់មណ្ឌលបោះឆ្នោតដែលមិនសូវពេញចិត្តនោះទេ ឬទៅកាន់តួនាទីដែលមានសារៈប្រយោជន៍តិចតួចដាក់លើបញ្ជីគណបក្ស ។ រដ្ឋភាគីគួរត្រូវធ្វើការធានាថាវិធានការពិសេសបណ្តោះអាសន្នត្រូវបានគេអនុញ្ញាតិយ៉ាងជាក់លាក់ស្ថិតក្រោម នីតិកម្មប្រឆាំងការរើសអើង ឬការធានាភាពស្មើគ្នានានាតាមរដ្ឋធម្មនុញ្ញ ។

៣៤. អង្គការនានាដូចជាសហជីព និងគណបក្សនយោបាយមានកាតព្វកិច្ចធ្វើការបង្ហាញនូវការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះគោលការណ៍ភាពស្មើគ្នាផ្នែកភេទនៅក្នុងរដ្ឋធម្មនុញ្ញរបស់គេ នៅក្នុងការអនុវត្តន៍ច្បាប់ទាំងនោះ និងនៅក្នុងការតែងតាំងនូវសមាជិកភាពដោយមាន តំណាងតុល្យភេទនៅក្នុងគណៈកម្មាធិការប្រតិបត្តិ ដូចនេះស្ថាប័នទាំងនេះអាចទទួលផលប្រយោជន៍ពីការចូលរួមពេញលេញ និងស្មើភាពនៃគ្រប់ផ្នែករបស់សង្គម និងទទួលបានវិភាគទានដែលធ្វើឡើងដោយភេទទាំងពីរនេះ ។ អង្គការទាំងនេះក៏បានផ្តល់នូវមូលដ្ឋានបណ្តុះបណ្តាល ផងដែរសំរាប់នារីនៅក្នុងជំនាញនយោបាយ ការចូលរួម និងភាពជាអ្នកដឹកនាំ ក៏ដូចជាការធ្វើការនៅក្នុងអង្គការក្រៅរដ្ឋាភិបាល ។

## មាត្រា៨ (ភាវិតអន្តរជាតិ)

រដ្ឋភាគីត្រូវចាត់វិធានការទាំងអស់ឱ្យបានសមស្របដើម្បីធានាចំពោះនារី ស្តីអំពីលក្ខខ័ណ្ឌស្មើភាពជាមួយបុរសដោយមិនមានការរើសអើង ហើយនិងអំពីឱកាសដើម្បីធ្វើជាតំណាងឱ្យរដ្ឋាភិបាល របស់គេនៅថ្នាក់អន្តរជាតិ និងដើម្បីចូលរួមការងារនៅក្នុងអង្គការ អន្តរជាតិ ។

## <u>យោបល់</u>

៣៥. តាមមាត្រាទី៨ រដ្ឋាភិបាលត្រូវធ្វើការធានាដល់វត្តមាននារីនៅគ្រប់លំដាប់ថ្នាក់ទាំងអស់ និងគ្រប់វិស័យទាំងអស់នៃកិច្ចការ អន្តរជាតិ ។ នេះតំរូវឱ្យពួកគេត្រូវបានរាប់បញ្ចូលនៅក្នុងរឿងកិច្ចការសេដ្ឋកិច្ច និងយោធា នៅក្នុងទាំងដំណើរការទូតពហុភាគី និងឧបត្ថោ ភាគី និងនៅក្នុងប្រតិភូផ្លូវការ ទៅកាន់សន្និសីទអន្តរជាតិ និងសន្និសីទថ្នាក់តំបន់ ។

៣៦. តាមការត្រួតពិនិត្យលើរបាយការណ៍រដ្ឋភាគី វាបានបង្ហាញយ៉ាងច្បាស់ថានារីគឺមានតំណាងតិចជាងយ៉ាងខ្លាំងនៅក្នុងសេវា ការទូត និងការបរទេសនៃរដ្ឋាភិបាលភាគច្រើន ហើយជាពិសេសនៅថ្នាក់ខ្ពស់បំផុត។ នារីទំនងជាត្រូវបានគេចាត់តាំងឱ្យប្រចាំនៅស្ថានទូត ដែលមានសារៈសំខាន់តិចតួចចំពោះការទំនាក់ទំនងការបរទេសរបស់ប្រទេស និងករណីយខ្លះទៀតនារីត្រូវបានគេរើសអើងប្រឆាំងនៅក្នុង លក្ខខ័ណ្ឌនៃការតែងតាំងដោយក៏រិតភ្ជាប់ជាមួយនិងស្ថានភាពប្តីប្រពន្ធ។ ហើយនៅក្នុងតួយ៉ាងខ្លះទៀត អត្ថប្រយោជន៍ប្តីប្រពន្ធនិងគ្រួសារ បានយល់ព្រមទៅលើអ្នកការទូតបុរសដែលមិនមានសំរាប់នារីនៅក្នុងតំណែងដូចគ្នានេះ។ ឱកាសសំរាប់នារីដែលជាប់ទាក់ទងនៅក្នុងការងារ អន្តរជាតិជារឿយៗត្រូវបានគេបដិសេធដោយសារ ការសន្មតអំពីការទទួលខុសត្រូវនៅក្នុងគ្រួសារ រួមទាំងការថែទាំមើលអ្នកនៅក្នុងបន្ទុក គ្រួសារដែលនឹងរារាំងពួកមិនឱ្យទទួលនូវការតែងតាំងនេះ។

៣៧. បេសកកម្មអចិន្ត្រៃយ៍ប្រចាំអង្គការសហប្រជាជាតិជាច្រើន និងប្រចាំអង្គការអន្តរជាតិដទៃទៀតមិនមាននារីនៅក្នុង ចំណោមអ្នកការទូតរបស់ខ្លួនទេ ហើយមានតិចតួចនៅក៏រិតថ្នាក់ខ្ពស់។ ស្ថានភាពគឺស្រដៀងទៅ និងកិច្ចប្រជុំនិងសន្និសីទជំនាញដែលបង្កើត នូវគោលបំណងអន្តរជាតិ និងពិភពលោករបៀបវារៈ និងអាទិភាព។ ប្រព័ន្ធអង្គការសហប្រជាជាតិ និងរចនាសម្ព័ន្ធសេដ្ឋកិច្ច នយោបាយ និងយោធានៅថ្នាក់តំបន់បានក្លាយទៅជានិយោជកសាធារណៈអន្តរជាតិដ៏សំខាន់ តែនៅទីនេះនារីក៏ស្ថិតនៅ ចំនួនភាគតិចដែលបង្កើនទៅលើ តួនាទីថ្នាក់ទាបផងដែរ។

៣៨. មានឱកាសតិចតួចសំរាប់បុរស និងនារីអំពីលក្ខខ័ណ្ឌស្មើគ្នា ដើម្បីធ្វើជាតំណាងឱ្យរដ្ឋាភិបាលនៅថ្នាក់អន្តរជាតិ និងដើម្បីចូលរួមនៅក្នុងការងារអង្គការអន្តរជាតិ។ នេះជាលទ្ធផលរឿយៗនៃការអវត្តមាននូវលក្ខណៈសម្បត្តិមិនលំអៀង និងដំណើរការសំរាប់ការតែង តាំង និងតំឡើងឋានៈចំពោះតួនាទីដែលពាក់ព័ន្ធនិងប្រតិភូផ្លូវការ។

៣៩. សកលភាវូបនីយកម្មនៃពិភពលោកសហសម័យបានធ្វើឱ្យមានការគិតដាក់បញ្ចូលនារី និងការចូលរួមរបស់គេនៅក្នុងអង្គការ អន្តរជាតិ អំពីលក្ខខ័ណ្ឌស្មើភាពគ្នាជាមួយបុរស កាន់តែមានសារៈសំខាន់កើនឡើង។ ការធ្វើសមាហរណកម្មនៃទស្សនៈវិស័យភេទ និងសិទ្ធិមនុស្សរបស់នារីភេទដាក់នៅ ក្នុងរបៀបវារៈនៃស្ថាប័នអន្តរជាតិទាំងអស់គឺជាកាតព្វកិច្ចរដ្ឋាភិបាល។ ការសំរេចចិត្តសំខាន់ជាច្រើនអំពីបញ្ហាពិភពលោក ដូចជាដំណោះស្រាយធ្វើឱ្យមានសន្តិភាព និងដំណោះស្រាយទំនាស់ ការចំណាយយោធា និងការរំសាយអាវុធនុយក្លេអ៊ែរ ការអភិវឌ្ឍន៍និងបរិស្ថាន ជំនួយបរទេស និងការរៀបរចនាសម្ព័ន្ធសេដ្ឋកិច្ចបានត្រូវគេចាត់ធ្វើឡើងដោយមានការចូលរួមរបស់នារីនៅមានក៏រិត។ នេះគឺស្ថិតនៅក្នុងភាពផ្ទុយស្រឡះចំពោះការចូលរួម របស់គេនៅក្នុងវិស័យទាំងនេះនៅក៏រិតថ្នាក់ក្រៅរដ្ឋាភិបាល។

៤០. ការរាប់បញ្ចូលនៃមហាជននារីជាចាំបាច់នៅការចរចារអន្តរជាតិ សកម្មភាពបង្កើតសន្តិភាព រាល់លំដាប់ថ្នាក់ការទូត ការ សម្របសម្រួល ជំនួយមនុស្សធម៌ ការបង្រួបបង្រួមសង្គម ការចរចារសន្តិភាព និងប្រព័ន្ធយុត្តិធម៌ឧក្រិដ្ឋកម្មអន្តរជាតិនឹងពិតជាមានការប្រែ ប្រួលខុសប្លែក។ នៅក្នុងការលើក ឡើងអំពីទំនាស់ប្រដាប់អាវុធ ឬទំនាស់ផ្សេងៗ ទស្សនៈវិស័យផ្នែកភេទ និងការវិភាគគឺចាំបាច់ត្រូវយល់នូវផលដែលខុសប្លែកគ្នាអំពីនារី និងបុរស។[១០]

## អនុសាសន៍

## មាត្រា៧ និង៨

៤១. រដ្ឋភាគីត្រូវធានាថារដ្ឋធម្មនុញ្ញ និងនីតិកម្មរបស់ខ្លួនគោរពទៅតាមគោលការណ៍របស់អនុសញ្ញា ហើយជាពិសេសគោរពទៅ តាមមាត្រាទី៧ និងទី៨។

៤២. រដ្ឋភាគីដែលស្ថិតនៅក្រោមកាតព្វកិច្ចត្រូវធ្វើការចាត់វិធានការទាំងអស់ឱ្យបានសមស្រប រួមទាំងធ្វើការអនុម័តនៃការធ្វើ នីតិកម្មឱ្យបានសមស្របដែលគោរពទៅតាមរដ្ឋធម្មនុញ្ញរបស់ខ្លួន ដើម្បីធានាថាអង្គការដូចជាគណបក្សនយោបាយ និងសហជីព ដែល មិនឋិតនៅកាតព្វកិច្ចដោយផ្ទាល់ក្រោមអនុសញ្ញា មិនត្រូវរើសអើងប្រឆាំងនារីភេទ និងត្រូវគោរពទៅលើគោលការណ៍ដែលមានចែងនៅ ក្នុងមាត្រាទី៧ និងទី៨។

៤៣. រដ្ឋភាគីគួរធ្វើការបង្ហាញ និងត្រូវធ្វើការអនុវត្តន៍នូវវិធានការពិសេសបណ្តោះអាសន្នដើម្បីធានាឱ្យមានការធ្វើតំណាងរបស់ ស្មើគ្នានៅក្នុងគ្រប់វិស័យដែលបានធានាដោយមាត្រាទី៧ និងទី៨។

៤៤. រដ្ឋភាគីរដ្ឋភាគីគួរធ្វើការពន្យល់ហេតុផល និងផលចំពោះខរក្សាទុកណាមួយចំពោះមាត្រាទី៧ ឬទី៨ ហើយការបង្ហាញនៅ កន្លែងដែលរក្សាទុកឆ្លុះបញ្ចាំងពីឥរិយាបថតាមប្រពៃណីយ តាមទំនាមទំលាប់ ឬតាមគំនិតចាស់បូរាណចំពោះតួនាទីរបស់នារីនៅក្នុងសង្គម ក៏ដូចជាជំហានដែលចាត់វិធានការដោយ រដ្ឋភាគីដើម្បីធ្វើការផ្លាស់ប្តូរនៅឥរិយាបថទាំងនោះ។ រដ្ឋភាគីគួរធ្វើការរក្សានូវការចាំបាច់ចំពោះខ រក្សាទុកបែបណាមួយដែលវាស្ថិតនៅក្រោមការត្រួតពិនិត្យយ៉ាងជិតដិត និងដាក់នៅក្នុងរបាយការណ៍របស់ខ្លួនរួមទាំងកាលវិភាគ សំរាប់ដកចេញ។

## មាត្រា៧

៤៥. វិធានការដែលគួរគេធ្វើការបង្ហាញ អនុវត្ត និងត្រួតពិនិត្យឱ្យមានប្រសិទ្ធិរួមមាន មាត្រាទី៧ កថា ខ័ណ្ឌ(ក) ទាំងនោះរៀបចំ ដើម្បី :

(ក) សំរេចនូវតុល្យភាពរវាងនារី និងបុរសធ្វើការកាន់នូវមុខតំណែងដែលជាប់ឆ្នោតជាសាធារណៈ។

(ខ) ធានាថានារីយល់នូវសិទ្ធិបោះឆ្នោតរបស់គេ យល់នូវសារៈសំខាន់នៃសិទ្ធិនេះ និងរបៀបប្រើវា។

(គ) ធានាថាឧបសគ្គចំពោះភាពស្មើគ្នាត្រូវបានគេជំនះ រួមទាំងឧបសគ្គដែលកើតចេញពីអនក្ខរកម្ម ពីភាសា ពីភាព ក្រីក្រ និងឧបសគ្គការអនុវត្តន៍នូវសេរីភាពដើរហើររបស់នារី។

(ឃ) ជួយនារីឆ្លងកាត់នូវគុណវិបត្តិចំពោះការប្រើសិទ្ធិបោះឆ្នោតរបស់គេ និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត។

៤៦. តាមមាត្រាទី៧ កថាខ័ណ្ឌ(ខ) វិធានការបែបណាមួយត្រូវរួមមានវិធានការនោះរៀបចំឡើងដើម្បីធានា:

(ក) ភាពស្មើគ្នានៃការធ្វើជាតំណាងរបស់នារីនៅក្នុងការបង្កើតនូវរូបមន្តគោលនយោបាយរដ្ឋាភិបាល។

(ខ) ការចូលរួមរបស់នារីនៅក្នុងការប្រតិបត្តិនូវសិទ្ធិស្មើគ្នាចំពោះការកាន់មុខតំណែងសាធារណៈ។

(គ) ជ្រើសរើសដំណើរការសំដៅលើនារីដោយចំហរ និងដាក់នូវការអំពាវនាវ។

៤៧. តាមមាត្រាទី៧ កថាខ័ណ្ឌ(គ) វិធានការបែបណាមួយរួមមានវារៀបចំឡើងដើម្បី:

(ក) ធានាថានីតិកម្មប្រកបដោយប្រសិទ្ធិភាពត្រូវបានគេអនុម័តឡើងដើម្បីធ្វើការរារាំងដល់ការរើសអើងប្រឆាំងនារី ភេទ។

(ខ) លើកទឹកចិត្តដល់អង្គការក្រៅរដ្ឋាភិបាល សមាគមន៍សាធារណៈ និងសមាគន៍នយោបាយឱ្យអនុម័តនូវយុទ្ធសាស្ត្រ ដែលជំរុញដល់ការធ្វើជាតំណាង និងការចូលរួមរបស់នារីនៅក្នុងការងាររបស់គេ។

៤៨. នៅពេលធ្វើរបាយការណ៍តាមមាត្រាទី៧ រដ្ឋភាគីគួរ:

(ក) ធ្វើការពិពណ៌នានូវបទបញ្ញត្តិច្បាប់ដែលផ្តល់ផលចំពោះសិទ្ធិដែលមាននៅក្នុង មាត្រាទី៧។

(ខ) ត្រូវផ្តល់នូវចំនុចលំអិតនៃការកំរិតណាមួយចំពោះសិទ្ធិទាំងនោះ ថាតើកើតចេញមកពីបទ បញ្ញត្តិច្បាប់ ឬមកពីការ ប្រតិបត្តិតាមប្រពៃណីយ តាមសាសនា ឬតាមវប្បធម៌។

(គ) ពិពណ៌នានូវវិធានការដែលបានដាក់ និងរៀបចំឡើងដើម្បីជំនះឧបសគ្គចំពោះការប្រើនូវសិទ្ធិទាំងនោះ ។

(ឃ) ត្រូវដាក់រួមនូវទិន្នន័យស្ថិតិ ដោយមិនគិតពីភេទ បង្ហាញនូវភាគរយនារីដែលជាប់ទាក់ទងទៅ និងបុរសដែលបាន ប្រើនូវសិទ្ធិទាំងនោះ ។

(ង) ពិពណ៌នានូវប្រភេទការរៀបចំរូបមន្តបង្កើតគោលនយោបាយ រួមទាំងវាមានការជាប់ទាក់ទងកម្មវិធីអភិវឌ្ឍន៍ ដែលនារីបានចូលរួមជាមួយ ហើយក៏វិតនិងវិសាលភាពនៃការចូលរួមរបស់គេ ។

(ច) តាមមាត្រាទី៧ កថាខ័ណ្ឌ(គ) ធ្វើការពិពណ៌នានូវវិសាលភាពចំពោះនារីដែល បានចូលរួមនៅក្នុងអង្គការក្រៅរដ្ឋា ភិបាលនៅក្នុងប្រទេសរបស់ខ្លួន រួមទាំងនៅក្នុងអង្គការរបស់នារីផង ។

(ឆ) ធ្វើការវិភាគនូវវិសាលភាពចំពោះរដ្ឋភាគីធានាថាអង្គការទាំងនោះបានគេធ្វើការពិគ្រោះ និងឥទ្ធិពលនៃដំបូន្មាន របស់គេទៅលើគ្រប់ជាន់ថ្នាក់នៃការរៀបចំ និងការអនុវត្តន៍ គោលនយោបាយរដ្ឋាភិបាល ។

(ជ) ផ្តល់នូវពតិមានដែលទាក់ទិននិងធ្វើការវិភាគលើកត្តាដែលចូលរួម ចំពោះការមានតំណាងនារីតិចជាងជាសមាជិក និងជាមន្ត្រីគណបក្សនយោបាយ សហជីព អង្គភាពនិយោជក និងសមាគមន៍វិជ្ជាជីវៈ ។

## មាត្រា៨

៤៩. វិធានការដែលគេត្រូវបង្ហាញ អនុវត្ត និងធ្វើការត្រួតពិនិត្យដើម្បីឱ្យមានប្រសិទ្ធិភាព នោះរួមមានវិធានការដែលរៀបចំឡើង ដើម្បីធានាឱ្យមានតុល្យភាពខាងភេទឱ្យបានកាន់តែប្រសើរឡើងនៅក្នុងសមាជិកភាពនៃរាល់ស្ថាប័នអង្គការសហប្រជាជាតិទាំងអស់ រួមទាំងគណៈកម្មាធិការមហាសន្និបាត គណៈកម្មាធិការសេដ្ឋកិច្ច និងក្រុមប្រឹក្សាសង្គមសំខាន់ៗ និងស្ថាប័នជំនាញរួមមានស្ថាប័នសន្និសញ្ញា ចំពោះការចាត់តាំងប្រចាំក្រុមការងារឯករាជ្យ ឬប្រចាំប្រទេស ឬ អ្នកទំនាក់ទំនង។

៥០. នៅពេលធ្វើរបាយការណ៍តាមមាត្រាទី៨ រដ្ឋភាគីគួរៈ

(ក) ផ្តល់ស្ថិតិដោយមិនគិតពីភេទ បង្ហាញនូវភាគរយនៃចំនួននារីនៅក្នុងសេវាការបរទេសរបស់ខ្លួនឬនារីដែលជាប់ទាក់ ទងនៅក្នុងតំណាងអន្តរជាតិរបស់ខ្លួនជាទៀតទាត់ ឬនៅក្នុងការងារតំណាងឱ្យរដ្ឋរួមទាំងសមាជិកភាពនៅក្នុងប្រតិភូរដ្ឋាភិបាលប្រចាំនៅ សិន្និសីទអន្តរជាតិ និងការតែងតាំងសំរាប់ តួនាទីរក្សា សន្តិភាព ឬតួនាទីសំរេចដោះស្រាយជំលោះ និងជាតំណាងជាន់ខ្ពស់របស់គេនៅក្នុងផ្នែក ដែលពាក់ព័ន្ធ។

(ខ) ពិពណ៌នាពីការខិតខំប្រឹងប្រែងដើម្បីបង្កើតនូវលក្ខណៈសម្បត្តិមិនលំអៀង និងដំណើរការតែងតាំង និងការតំឡើង ឋានៈរបស់នារីចំពោះមុខងារដែលពាក់ព័ន្ធ និងធ្វើជាប្រតិភូជាផ្លូវការ។

(គ) ពិពណ៌នាវិធានការដែលបានចាត់ធ្វើឡើងដើម្បីធ្វើការផ្សព្វផ្សាយពត៌មាន ឱ្យបានទូលំទូលាយ អំពីការប្តេជ្ញាចិត្តជា អន្តរជាតិរបស់រដ្ឋាភិបាលដែលប៉ះពាល់ដល់នារី និងឯកសារជាផ្លូវការដែលចេញដោយវេទិកាពហុភាគី ជាពិសេសចំពោះទាំង ស្ថាប័នរដ្ឋាភិបាល និងក្រៅរដ្ឋាភិបាលដែលទទួលខុសត្រូវចំពោះការអភិវឌ្ឍន៍របស់នារី។

(ឃ) ផ្តល់នូវពត៌មានអំពីការរើសអើងប្រឆាំងនារីភេទដោយសារសកម្មភាពនយោបាយថាតើវាជាបុគ្គល ឬជាសមា ជិករបស់អង្គការនារី ឬអង្គការដទៃទៀត។

## សំគាល់:

១. សេចក្តីសំរេចមហាសន្និបាត ២១៧ A(III)

២. សេចក្តីសំរេចមហាសន្និបាត ២២០០ A(XXI) ឧបសម្ព័ន្ធ

៣. សេចក្តីសំរេចមហាសន្និបាត ៦៤០ (VII)

៤. របាយការណ៍របស់សន្និសីទពិភពលោកស្តីពីសិទ្ធិមនុស្ស នៅក្រុងវីយែន ថ្ងៃទី១៤-២៥មិថុនា ១៩៩៣

(A/CONF.157/24(ភាគ I) ជំពូក III)

៥. របាយការណ៍សន្និសីទពិភពលោកលើកទី៤ស្តីពីនារី នៅក្រុងប៉េកាំង ថ្ងៃទី៤-១៥ កញ្ញា ១៩៩៥ (A/CONF. 177/20 and Add.1) ជំពូក I សេចក្តីសំរេច ១ ឧបសម្ព័ន្ធ I

៦. សូមមើលរបាយការណ៍ផ្លូវការនៃអង្គមហាសន្និបាត សម័យប្រជុំលើកទី៤៣ សេចក្តីបន្ថែមលេខ ៣៨ (A/43/38) ជំពូក៥

៧. CCPR/21/21/Rev.1/Add.7, ថ្ងៃទី២៧ សីហា ១៩៩៦

៨. 96/694/EC,Brussels ថ្ងៃទី២ ធ្នូ ១៩៩៦

៩. ឯកសារគណៈកម្មាធិការអឺរ៉ុប V/1206/96-EN (ខែមិនា ១៩៩៦)

១០. សូមមើលកថាខ័ណ្ឌ

១៤១នៃកម្មវិធីនយោបាយសំរាប់អនុវត្តដែលអនុម័តដោយសន្និសីទពិភពលោកលើកទី៤ស្តីពីនារី ដែល បានប្រារព្ធឡើងនៅថ្ងៃ៤-១៥ ខែកញ្ញា ១៩៩៥នៅក្រុងប៉េកាំង (A/CONF.177/20 ជំពូក I សេចក្តីសំរេច ១ ឧបសម្ព័ន្ធ II)។ សូមមើលកថាខ័ណ្ឌ១៣៤ផងដែរ ដែលមានជាផ្នែក៧ៈ" ការប្រើប្រាស់ស្មើគ្នា និងការចូលរួមដោយពេញលេញរបស់នារី នៅក្នុងរចនាសម្ព័ន្ធអំណាច និងនៅក្នុងការពាក់ព័ន្ធពេញលេញនៅក្នុងរាល់ការខិតខំប្រឹងប្រែងទាំងអស់ដើម្បីទប់ស្កាត់ និងធ្វើការសំរេចដោះស្រាយជំលោះដែលមានសារៈសំខាន់ដើម្បីធ្វើការថែរក្សា និងជំរុញឱ្យមានសន្តិភាព និងសន្តិសុខ"។

# អនុសាសន៍ទូទៅលេខ ២៤
# នារី និងសុខភាព (មាត្រា១២)
## (សម័យប្រជុំលើក២០, ១៩៩៩ )[២]

១. គណៈកម្មាធិការទទួលបន្ទុកការលុបបំបាត់ចោលការរើសអើងប្រឆាំងនារីភេទ បញ្ជាក់ថា ការអាចចូលដល់ការថែទាំសុខភាព រួមទាំងការថែទាំសុខភាពបន្តពូជ គឺជាសិទ្ធិមូលដ្ឋានស្ថិតនៅក្រោម អនុសញ្ញាស្តីពីការលុបបំបាត់ចោលរាល់ ទម្រង់ការរើសអើងប្រឆាំងនារីភេទដែលបានសំរេចនៅសម័យ ប្រជុំលើកទី២០ តាមមាត្រា២០ ដើម្បីធ្វើការពន្យល់បកស្រាយ អនុសាសន៍រួមលើមាត្រា១២របស់អនុ សញ្ញា ។

## ប្រវត្តិកាល

២. ការគោរពរបស់រដ្ឋភាគីដោយយោងតាមមាត្រា១២នៃអនុសញ្ញាគឺមានសារៈសំខាន់ចំពោះ សុខភាព និងសុខមាលភាពរបស់នារី ។ វាតំរូវឱ្យរដ្ឋភាគីធ្វើការលុបបំបាត់ចោលការរើសអើងប្រឆាំងនារីភេទ ក្នុងការចូល ទៅរកសេវាថែទាំសុខភាពរបស់គេពេញខួបជីវិត ជាពិសេសនៅក្នុងផ្នែកការរៀបចំផែនការ បន្តពូជគ្រួសារ ការ មានផ្ទៃពោះ ការកំនត់ពេល វេលាកំនើត និងនៅក្នុងអំឡុងពេលក្រោយកើត ។ ការត្រួតពិនិត្យលើរបាយការណ៍ ដែលបានដាក់ដោយរដ្ឋភាគីយោងតាមមាត្រា១៨របស់អនុសញ្ញាបាន បង្ហាញថា សុខភាពរបស់នារីគឺជា បញ្ហា មួយដែលចាត់ទុកជាការទាក់ទងមួយដ៏សំខាន់នៅក្នុងការជំរុញ លើផ្នែកសុខភាព និងសុខមាលភាពរបស់នារី ។ ចំពោះអត្ថប្រយោជន៍របស់រដ្ឋភាគី ហើយអ្នកទាំងនោះជាអ្នក ដែលមានផលប្រយោជន៍ជាក់លាក់នៅក្នុងការ ជាប់ទាក់ទងជាមួយបញ្ហានៅជុំវិញសុខភាពរបស់នារី យោបល់រួមបច្ចុប្បន្នស្វែងរកការពន្យល់ពីការយល់ឃើញ របស់គណៈកម្មាធិការលើមាត្រា១២ និង ដើម្បីថ្លែង នូវវិធានការធ្វើការលុបបំបាត់ចោលការរើសអើង ដើម្បី ទទួលស្គាល់សិទ្ធិនារីឱ្យដល់កំរិតមាត្រដ្ឋាន សុខភាព ខ្ពស់បំផុត ។

៣. សន្និសីទពិភពលោករបស់អង្គការសហប្រជាជាតិនាពេលថ្មីៗនេះ បានធ្វើការពិចារណាលើគោល បំណងទាំងនេះ ។ នៅក្នុងការរៀបចំនូវយោបល់រួមនេះ គណៈកម្មាធិការបានធ្វើការគិតគូរដល់កម្មវិធីអនុវត្ត

[២] មាននៅក្នុងឯកសារ A/៥៤/៣៨ Rev1ជំពូក I

ស្តីពីសិទ្ធិមនុស្ស១៩៩៣ សន្និសីទអន្តរជាតិស្តីពីប្រជាជននិងការអភិវឌ្ឍន៍១៩៩៤ ព្រមជាមួយ និង សន្និសីទពិភព លោកលើកទី៤ អំពីនារី១៩៩៥ ។ គណៈកម្មាធិការបានកត់សំគាល់ឃើញនូវការងាររបស់អង្គការ សុខភាព ពិភពលោកមូលនិធិប្រជាជនសហប្រជាជាតិ និងស្ថាប័នអង្គការសហប្រជាជាតិផ្សេងៗទៀតផងដែរ ។ វាបានធ្វើការសហការជាមួយនិងអង្គការក្រៅរដ្ឋាភិបាលមួយចំនួនធំ ដែលមានអ្នកជំនាញ ពិសេសផ្នែកខាង សុខភាព នារីនៅក្នុងការរៀបចំអនុសាសន៍រួមនេះ ។

៤. គណៈកម្មាធិការបានកត់សំគាល់លើការគូសបញ្ជាក់ដែលលិខិតុបករណ៍អង្គការសហប្រជាជាតិបាន ដាក់ទៅលើសិទ្ធិចំពោះសុខភាពនិងលក្ខខ័ណ្ឌដែលផ្តល់នូវសុខភាពល្អ ត្រូវបានគេធ្វើឱ្យសំរេចជោគជ័យបាន ។ នៅក្នុងចំណោមលិខិតុបករណ៍បែបនោះគឺមានសេចក្តីប្រកាសជាសកល នៃសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងសិទ្ធិវប្បធម៌ កតិកាសញ្ញាអន្តរជាតិទៅលើសិទ្ធិស៊ីវិលនិងសិទ្ធិនយោបាយ អនុសញ្ញា ស្តីពីសិទ្ធិកុមារ និងអនុសញ្ញាស្តីពីការលុបចោលរាល់ទម្រង់នៃការរើសអើងជាតិសាសន៍ ។

៥. គណៈកម្មាធិការក៏សំដៅទៅលើយោបល់រួមពីមុនៗរបស់ខ្លួនផងដែរ ស្តីពីការកាត់ស្បែកអង្គជាតិ នារីភេទ វីរុសដែលធ្វើឱ្យចុះខ្សោយប្រព័ន្ធការពារមេរោគក្នុងខ្លួនមនុស្ស/រោគសញ្ញាដែលធ្វើឱ្យចុះខ្សោយ ប្រព័ន្ធការពារមេរោគដែលទទួលបាន(ហ៊ីវ/អេដស៍) ស្តីពីនារីពិការ អំពើហិង្សាប្រឆាំងនារីនិងភាពស្មើគ្នានៅ ក្នុងទំនាក់ទំនងគ្រួសារ ទាំងអស់នេះដែលសំដៅទៅលើបញ្ហាដែលដាក់បញ្ចូលដើម្បីឱ្យមាន ការអនុវត្តន៍ឱ្យបាន ពេញលេញចំពោះមាត្រា១២របស់អនុសញ្ញា ។

៦. ទន្ទឹមនិងភាពខុសគ្នាជីវរូបរវាងនារីនិងបុរសអាចនាំឱ្យមានការខុសគ្នានៅក្នុងស្ថានភាពសុខភាព មានកត្តាសង្គមជាច្រើន ដែលកំនត់ស្ថានភាពសុខភាពរបស់នារីនិងបុរស ហើយនិងអាចធ្វើឱ្យខុសគ្នានៅក្នុង ចំណោមនារីខ្លួនឯង ។ ចំពោះហេតុផលនេះ ការយកចិត្ត ទុកដាក់ជាពិសេសត្រូវគេផ្តល់ជូននូវសេចក្តីត្រូវការ សុខភាពនិងសិទ្ធិនារីដែលនៅក្នុងក្រុមដែលងាយរងគ្រោះថ្នាក់ និងគុណវិបត្តិដូចជា នារីផ្លាស់ទី នារីភៀសខ្លួន និងនារីផ្លាស់ទីក្នុងតំបន់ ក្មេងស្រី និងស្ត្រីវ័យចំណាស់ នារីនៅក្នុងបន នារីអន្តោគ្រាម និងនារីដែលពិការរាងកាយ ឬ ពិការផ្លូវប្រាជ្ញាស្មារតី ។

៧. គណៈកម្មាធិការបានកត់សំគាល់ឃើញថាការទទួលស្គាល់ពេញលេញសិទ្ធិចំពោះសុខភាពរបស់នារី ដែលគេអាចសំរេចបានលុះណាតែរដ្ឋភាគីធ្វើការបំពេញនូវកាតព្វកិច្ចខ្លួនដោយធ្វើការគោរព ការពារ និងការ ជំរុញនូវសិទ្ធិមនុស្សជាមូលដ្ឋានរបស់នារីចំពោះសុខមាល ភាពអាហាររូបត្ថម្ភពេញមួយអាយុកាល ដោយការ ផ្តល់ម្ហូបអាហារដែលមានសុវត្ថិភាពចិញ្ចឹមរាងកាយ ដែលធ្វើទៅតាមលក្ខខ័ណ្ឌក្នុងតំបន់នោះ ។ មកដល់ ចុងបញ្ចប់នេះ រដ្ឋភាគីគួរចាត់វិធានការដើម្បីជួយសំរួលផ្នែករូបវ័ន្ត និងសេដ្ឋកិច្ចឱ្យអាចឈានដល់ធនធានដែល

ប្រកបដោយផ្លែផ្កា ជាពិសេសនារីនៅជនបទ និងម្យ៉ាងទៀតដើម្បីធានាថាតំរូវការអាហាររូបត្ថម្ភពិសេសរបស់ នារីទាំងអស់នៅក្នុងយុត្តាធិការដែលឆ្លើយតប ។

មាត្រា១២

៨. មាត្រា១២មានខ្លឹមសារដូចតទៅនេះ :

"១. រដ្ឋជាភាគីទាំងឡាយ នឹងប្រកាន់យកនូវរាល់វិធានការណ៍សមស្របទាំងឡាយដើម្បីបំបាត់ការរើសអើងប្រឆាំងនារីភេទ នៅក្នុងវិស័យថែរក្សាសុខភាព ដើម្បីធានានូវការទទួលបាននូវសេវាសុខាភិបាល ដោយឈរលើមូលដ្ឋានសមភាពរវាងបុរសនិងនារីដោយរួម បញ្ចូលទាំងកិច្ចការដែលទាក់ទិនទៅនឹងផែនការ គ្រួសារថែមទៀតផង ។

២. ក្រៅពីបញ្ញត្តិដែលបានចែងនៅក្នុងកថាខណ្ឌ ១នៃមាត្រានេះ រដ្ឋជាភាគីទាំងឡាយធានានារីភេទនូវរាល់សេវាសមស្រប ទាំងឡាយដែលទាក់ទិនទៅនឹងការពរពោះ ការសំរាលកូនហើយ និងរយៈពេលក្រោយសំរាលកូន ផ្តល់សេវាទាំងឡាយដោយឥតគិតថ្លៃ បើសិនជាចាំបាច់ ក៏ដូចជាផ្តល់នូវម្ហូបអាហារសមស្របក្នុងរយៈពេលពរពោះ និងពេលបំបៅកូនផងដែរ ។"

រដ្ឋភាគីត្រូវបានគេជំរុញឱ្យធ្វើការលើកឡើងនូវបញ្ហានៃសុខភាពនារីពេញមួយអាយុកាលនារី ។ ដូច្នេះ គោលបំណងនៃយោបល់រួមបច្ចុប្បន្នគឺ "នារី" រួមទាំងក្មេងស្រី និងមនុស្សពេញវ័យ ។ យោបល់រួមនឹងធ្វើការកំនត់នូវការវិភាគនៃធាតុផ្សំសំខាន់ៗមាត្រាទី១២របស់ គណៈកម្មាធិការ ។

**<u>ធាតុផ្សំសំខាន់ៗ</u>**

## មាត្រា១២ (១)

៩. រដ្ឋភាគីត្រូវមានគោលជំហររឹងមាំដើម្បីធ្វើការរាយការណ៍អំពីបញ្ហាសុខភាពដែលសំខាន់បំផុតដែលធ្វើឱ្យប៉ះពាល់ដល់នារីនៅក្នុងប្រទេសនោះ ។ ដូចនេះ អាចផ្តល់លទ្ធភាពគណៈកម្មាធិការធ្វើការវាយតំលៃថាតើវិធានការដើម្បីលុបបំបាត់ចោលការរើសអើងប្រឆាំងនារីភេទនៅក្នុងផ្នែកថែទាំសុខភាពវាបានសមស្របដែរឬទេ រដ្ឋភាគីត្រូវតែធ្វើសេចក្តីរាយការណ៍អំពីការធ្វើនីតិកម្ម ការរៀបចំផែនការ និង គោលនយោបាយ

ផ្អែកសុខភាពរបស់ខ្លួនចំពោះនារី ដោយមានទិន្នន័យដែលអាចជឿបានដោយចែកចេញតាមភេទទៅលើឧបត្តិហេតុនិងភាពធ្ងន់ធ្ងរនៃជំងឺ និងលក្ខខ័ណ្ឌគ្រោះថ្នាក់ចំពោះសុខភាពនារី អាហាររូបត្ថម្ភ និងអំពីអ្វីដែលមានស្រាប់ព្រមទាំងប្រសិទ្ធិភាពតំលៃនៃវិធានការទប់ស្កាត់ និងវិធានការសំរាប់កែរោគ ។ របាយការណ៍ដាក់មកគណៈកម្មាធិការត្រូវតែបង្ហាញថា នីតិកម្ម ការរៀបចំផែនការ និងគោលនយោបាយផ្អែក សុខភាពត្រូវផ្អែកលើការស្រាវជ្រាវផ្អែកវិទ្យាសាស្ត្រ និងប្រកបដោយក្រមសីលធម៌ ហើយផ្អែកលើការវាយតំលៃនៃស្ថានភាពសុខភាព និងតំរូវការរបស់នារីនៅក្នុងប្រទេសព្រមទាំងធ្វើការគិតគូរទៅលើការខុសគ្នានូវក្រមសីលធម៌ ការខុសគ្នាតាមតំបន់ ឬសហគមន៍ ឬការប្រតិ បត្តិដោយផ្អែកលើសាសនា ប្រពៃណីយ ឬវប្បធម៌ ។

១០. រដ្ឋភាគីត្រូវបានគេលើកទឹកចិត្តឱ្យធ្វើការដាក់បញ្ចូលក្នុងរបាយការណ៍របស់ខ្លួននូវពត៌មានអំពីជំងឺលក្ខខ័ណ្ឌសុខភាព និងលក្ខខ័ណ្ឌ គ្រោះថ្នាក់ចំពោះសុខភាពដែលធ្វើឱ្យមានផលប៉ះពាល់ដល់នារី ឬក្រុមនារីជាក់លាក់ណាមួយដោយខុសពីបុរស និងពត៌មានផ្សេងៗអំពីការធ្វើអន្តរាគមន៍នៅក្នុងការគិតគូរនេះផងដែរ ។

១១. វិធានការដើម្បីលុបបំបាត់ចោលការរើសអើងប្រឆាំងនារីត្រូវបានគេចាត់ទុកថាវាមិនសមស្រប ប្រសិនបើប្រព័ន្ធថែទាំសុខភាពនេះខ្វះនៅសេវាសំរាប់ធ្វើការទប់ស្កាត់ ការពារ និងព្យាបាលនូវជំងឺជាក់លាក់ចំពោះនារី ។ វាជាការរើសអើងរបស់រដ្ឋភាគីចំពោះការមិន ផ្តល់ឱ្យត្រឹមត្រូវតាមច្បាប់ដើម្បីដំណើរការសេវាសុខភាពបន្តពូជជាក់លាក់ដល់នារី ។ ឧទាហរណ៍ ប្រសិនបើអ្នកផ្តល់សេវាសុខភាពមិនព្រមធ្វើការបំរើសេវាណាមួយផ្អែកតាមលើការជំទាស់ដោយសម្បជញ្ញៈ វិធានការគួរត្រូវគេបង្ហាញដើម្បីធានាថានារីនោះត្រូវបានគេប្តូអ្នកផ្តល់សេវាសុខភាពជំនួសដោយអ្នកថ្មីវិញបាន ។

១២. រដ្ឋភាគីគួរត្រូវធ្វើរបាយការណ៍អំពីការយល់ដឹងពីគោលនយោបាយ និងវិធានការយ៉ាងណាអំពីការថែទាំសុខភាពដែលគិតគូរ អំពីសិទ្ធិសុខភាពរបស់នារីតាមរយៈទស្សនៈវិស័យនៃតំរូវការ និងអត្ថប្រយោជន៍របស់នារីនិងថាតើវាត្រូវលើកឡើងពីលក្ខណៈ ពិសេសខុសប្លែកគ្នាយ៉ាងណា ព្រមទាំងកត្តាដែលខុស ប្លែកចំពោះការប្រៀបធៀបទៅនិងបុរស ដូចជាៈ

ក. កត្តាជីវរូបដែលខុសចំពោះនារីក្នុងការប្រៀបធៀបជាមួយបុរស ដូចជាខួបរដូវ មុខងារ បន្តពូជ និងដំណើរអស់រដូវ ។ ឧទាហរណ៍មួយទៀត គឺការគ្រោះថ្នាក់ធ្ងន់ធ្ងរនៃការធ្វើឱ្យទទួលរងជំងឺដែលឆ្លងតាមភេទដែលនារីប្រឈម ។

ខ. កត្តាសេដ្ឋកិច្ចសង្គមដែលខុសគ្នាចំពោះនារីទូទៅ និងក្រុមនារីខ្លះជាពិសេស ។ ឧទាហរណ៍ ការទំនាក់ទំនងអំណាច មិនស្មើគ្នារវាងបុរសនិងនារីនៅក្នុងផ្ទះ និងកន្លែងធ្វើការងារដែលអាចនឹងមានផលប៉ះពាល់ធ្វើឱ្យទៅជាអវិជ្ជមានដល់អាហាររូបត្ថម្ភ និងសុខភាពរបស់នារី ។ គេអាចធ្វើការបង្ហាញនូវទំរង់ខុសគ្នានៃអំពើហិង្សាដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់គេ ។ ក្មេងស្រី និង មនុស្សពេញវ័យ

ស្ត្រីជារឿយៗអាចមានគ្រោះថ្នាក់ចំពោះការបំពានលើផ្លូវភេទដោយបុរសចំណាស់ និងដោយសមាជិកគ្រួសារ ដែលបានដាក់ពួកគេឱ្យស្ថិតនៅគ្រោះថ្នាក់ផ្នែករាងកាយ និងចិត្តសាស្ត្រ ការបង្កឱ្យមានផ្ទៃពោះមិនតាមបំណង និងមានផ្ទៃពោះមុនពេលចង់បាន។ ប្រតិបត្តិតាមវប្បធម៌ ឬតាមប្រពៃណីយខ្លះដូចជាការវះកាត់អង្គជាតិនារីភេទដែលធ្វើដោយមានគ្រោះថ្នាក់ខ្លាំងដែលអាចបណ្តាលឱ្យស្លាប់ និងពិការ។

គ. កត្តាចិត្តសាស្ត្រដែលធ្វើឱ្យខុសគ្នារវាងនារីនិងបុរសរួមទាំងការមានវិបត្តិផ្លូវចិត្ត ជាទូទៅ និងការមានវិបត្តិផ្លូវចិត្ត ក្រោយពេលឆ្លងទន្លេជាពិសេសព្រមជាមួយនិងលក្ខខ័ណ្ឌចិត្តសាស្ត្រផ្សេងៗ ទៀតដូចជាលក្ខខ័ណ្ឌដែលនាំឱ្យការញ៉ាំខុសរបៀប តួយ៉ាងរោគបរិភោគអាហារមិនបាន និងរោគ ឃ្លានអាហារ។

ឃ. ទន្ទឹមនេះ ក៏នៅមានការខ្វះការគោរពចំពោះភាពសំងាត់របស់អ្នកជំងឺដែលនឹងនាំឱ្យមានផលប៉ះពាល់ដល់ទាំងបុរសនិងនារី វាអាចធ្វើឱ្យនារីញញើតខ្លាចចំពោះការស្វែងរកដំបូន្មាន និងការព្យាបាល ដោយហេតុនេះវាធ្វើឱ្យមានផលមិនល្អ ចំពោះសុខភាព និងសុខមាលភាពរបស់គេ។ ចំពោះហេតុផលនេះ នារីនឹងមិនសូវមានឆន្ទៈដើម្បីស្វែងការថែទាំវេជ្ជសាស្ត្រចំពោះជំងឺនៃផ្លូវអង្គជាតិ ចំពោះការធ្វើមិនឱ្យមានកូន ឬការពន្លូតកូនដោយមិនត្រឹមត្រូវ ហើយនៅក្នុងករណីយដែលគេមាន ការរងគ្រោះពីអំពើហិង្សាផ្លូវភេទ ឬហិង្សាលើរាងកាយ។

១៣. ភារកិច្ចរដ្ឋភាគីដើម្បីធ្វើការធានាចំពោះការទទួលសេវាសុខភាព ពត៌មាននិងការអប់រំ ដែលបង្ហាញពីកាតព្វកិច្ចចំពោះការ គោរព ការការពារ និងការបំពេញនូវសិទ្ធិការថែទាំសុខភាព របស់នារីដោយឈរលើភាពស្មើគ្នារវាងបុរសនិងនារី។ រដ្ឋភាគីត្រូវមានការ ទទួលខុសត្រូវដើម្បីធានាថានីតិកម្ម និងសកម្មភាពនីតិប្រតិបត្តិព្រមជាមួយនិងគោលនយោបាយគោរពតាមកាតព្វកិច្ចទាំងបីនេះ។ គេត្រូវ តែដាក់វាឱ្យនៅក្នុងប្រព័ន្ធដែលធានាដល់សកម្មភាពតុលាការប្រកបដោយប្រសិទ្ធិភាព។ ការខកខានមិនបានអនុវត្តតាមបែបនេះ នឹងកំនត់ថាជាការរំលោភលើមាត្រា១២។

១៤. កាតព្វកិច្ចចំពោះការគោរពសិទ្ធិ តំរូវឱ្យរដ្ឋភាគីធ្វើការរារាំងមិនឱ្យមានការរាំងស្ទះដល់សកម្មភាពដែលចាត់វិធានការដោយនារី នៅក្នុងការស្វែងរកនូវគោលបំណងថែទាំសុខភាពរបស់គេ។ រដ្ឋភាគីត្រូវធ្វើរបាយការណ៍អំពីរបៀបអ្នកផ្តល់សេវាថែទាំសុខភាពសាធារណៈ និងឯកជនឆ្លើយតបនូវភារកិច្ចរបស់គេចំពោះការគោរពដល់សិទ្ធិនារីក្នុងការទទួលនូវការថែទាំងសុខភាពយ៉ាងណា។ ឧទាហរណ៍ ភាគីរដ្ឋមិនត្រូវរឹតបន្តឹងចំពោះការចូលទៅរកសេវាសុខភាពរបស់នារី ឬទៅរកគ្លីនិចសុខភាពរបស់នារីដែលវាមានការផ្តល់នូវសេវាទាំងនោះដោយផ្អែកលើមូលដ្ឋាននារីដែលមិនមានការអនុញ្ញាតពីស្វាមី ពីដៃគូរ ពីឪពុកម្តាយ ឬពីអាជ្ញាធរសុខភាព

ដោយហេតុផលមកពីគេមិនបានរៀបការឡើយ[១] ឬមកពីគេជានារីភេទ ។ ការរារាំងផ្សេងៗទៀតចំពោះការស្វែងរកការថែទាំសុខភាពឱ្យបានសមស្របរបស់នារី រួមទាំងច្បាប់ដែលធ្វើឱ្យមានបទឧក្រិដ្ឋចំពោះតែនីតិវិធីវេជ្ជសាស្ត្រត្រូវដោយនារីដាក់ទ័ណ្ឌកម្មលើនារីដែលប្រព្រឹត្តិនៅនីតិវិធីទាំងនោះ ។

១៥. កាតព្វកិច្ចចំពោះការការពារសិទ្ធិដែលទាក់ទងទៅនិងសុខភាពនារីដែលតំរូវឱ្យរដ្ឋភាគី ភ្នាក់ងារនិងមន្ត្រីរបស់គេធ្វើការចាត់ វិធានការ និងដាក់ទ័ណ្ឌកម្មចំពោះការរំលោភលើសិទ្ធិដោយបុគ្គល និងអង្គការឯកជនណាមួយ ។ ពីព្រោះអំពើហិង្សារវាងភេទគឺជាបញ្ហាសុខភាពដ៏សំខាន់ចំពោះនារី រដ្ឋភាគីគួរធ្វើការ ធានាដល់:

ក. ការអនុម័ត និងការអនុវត្តន៏ច្បាប់ប្រកបដោយប្រសិទ្ធិភាព ហើយនិងការបង្កើតនូវគោលនយោបាយ រួមទាំងពិធីការ ការថែទាំសុខភាព និងនីតិវិធីមន្ទីរពេទ្យដើម្បីធ្វើការលើកឡើងអំពីអំពើហិង្សាប្រឆាំងនារី និងប្រឆាំងការបំពានលើផ្លូវភេទក្មេងស្រី ព្រមជាមួយបទបញ្ញត្តិនៃសេវាសុខភាពឱ្យបានសមស្រប ។

ខ. ការបណ្តុះបណ្តាលពីការងាយរងគ្រោះថ្នាក់នៃភេទវាផ្តល់លទ្ធភាពដល់អ្នកធ្វើការផ្នែកខាងថែទាំសុខភាពដើម្បីធ្វើការស្វែងរកការរៀបចំចាត់ចែងនូវផលវិបាកនៃអំពើហិង្សារវាងភេទ ។

គ. នីតិវិធីសមស្រប និងប្រកបដោយការការពារចំពោះការធ្វើសវនាការបណ្តឹងនិងការដាក់ទ័ណ្ឌកម្មសមស្របទៅលើ កំហុសវិជ្ជាជីវការថែទាំសុខភាពនៃការបំពានលើភេទទៅលើអ្នកជំងឺនារី ភេទ ។

ឃ. ការអនុម័ត និងការអនុវត្តន៏ច្បាប់ប្រកបដោយប្រសិទ្ធិភាពដែលហាមឃាត់ដល់ការវះកាត់អង្គជាតិនារី និងអាពាហ៏ពិពាហ៏ក្មេងស្រី ។

១៦. រដ្ឋភាគីត្រូវធានាថាមានការការពារ និងសេវាសុខភាពគ្រប់គ្រាន់ រួមទាំងការព្យាបាលជំងឺនិងការពិគ្រោះរបួសស្នាម ដែលត្រូវផ្តល់ចំពោះនារីជាពិសេសនៅក្នុងកាលៈទេសលំបាក ដូចជាជាប់នៅក្នុងស្ថានភាពទំនាស់ប្រដាប់អាវុធ និងជនភៀសខ្លួននារីភេទ ។

១៧. ភារកិច្ចដើម្បីបំពេញសិទ្ធិបានដាក់ទៅលើរដ្ឋភាគីធ្វើការចាត់វិធានការនីតិបញ្ញត្តិ វិធានការតុលា ការរដ្ឋបាល ថវិកា សេដ្ឋកិច្ច និងវិធានការផ្សេងៗឱ្យបានសមស្របដល់នូវវិសាលភាពក៏រិតអតិបរិមានៃធនធានដែលមាន ដើម្បីធានាថានារីបានស្គាល់នូវសិទ្ធិរបស់ខ្លួន ចំពោះការថែទាំសុខភាព ។ ការសិក្សាបែបនោះបានសង្កត់ធ្ងន់ទៅលើអត្រាការស្លាប់នៃម្តាយ និងអត្រាការកើតជំងឺដែលមានក៏រិតនៅទូទាំង ពិភពលោកហើយមានគូរស្វាម៉ីមួយចំនួនធំដែលចង់កំនត់នូវទំហំគ្រួសាររបស់គេ ប៉ុន្តែខ្វះនៅការប្រើ ឬមិនប្រើនូវទម្រង់ណាមួយនៃការធ្វើ មិនឱ្យមានកូនដែលផ្តល់នូវសញ្ញាមួយដ៏សំខាន់ដល់រដ្ឋភាគីនៃការដែលអាចធ្វើឱ្យខូចនូវ ភារកិច្ចរបស់ គេចំពោះការធានាដល់នារីនូវការចូលទៅរកការថែទាំសុខភាព ។ គណៈកម្មាធិការបានស្នើឱ្យរដ្ឋភាគីធ្វើ

របាយការណ៍អំពីអ្វីដែលពួកគេបានធ្វើដើម្បីលើកឡើងនូវទំហំសុខភាពដែលឈឺ ជាពិសេសនៅពេលវាកើតឡើងក្នុងលក្ខខ័ណ្ឌដែលអាចទប់ស្កាត់បាន ដូចជាជំងឺរបេង និងហ៊ីវ/អេដស៍ ។ គណៈកម្មាធិការមានការព្រួយបារម្ភអំពីដែលរដ្ឋកំពុងធ្វើការបោះចោលនូវកាតព្វកិច្ចខ្លួនដោយពួកគេផ្ទេរមុខងារផ្នែកសុខាភិបាលទៅឱ្យភ្នាក់ងារឯកជន ។ រដ្ឋនិងគណបក្សមិនអាចបោះបង់ការទទួលខុសត្រូវនៅក្នុងវិស័យទាំងនេះដោយការប្រគល់សិទ្ធិ ឬការផ្ទេរនូវអំណាចទាំងនេះទៅឱ្យភ្នាក់ងារផ្នែកឯកជនឡើយ ។ ដូចនេះរដ្ឋភាគីគួរធ្វើរបាយការណ៍អំពីអ្វីដែលគេបានធ្វើរៀបចំដំណើរការរដ្ឋបាល និងគ្រប់រចនាសម្ព័ន្ធទាំងអស់តាមរយៈអំណាចសាធារណៈដែលត្រូវធ្វើការជំរុញ និងដើម្បីការពារសុខភាពនារី ។ ពួកគេគួរដាក់បញ្ចូលនូវពត៌ស្តីអំពីវិធានការវិជ្ជមានដែលបានចាត់ធ្វើឡើង ដើម្បីទប់ស្កាត់នូវការរំលោភលើសិទ្ធិនារីដោយភាគីទី៣ និងដើម្បីការពារនូវសុខភាពរបស់ពួកគេ និងវិធានការដែលពួកគេចាត់ធ្វើឡើង ដើម្បីធានានូវការផ្តល់នៃសេវាទាំងនោះ ។

១៨. បញ្ហាជំងឺហ៊ីវ/អេដស៍ និងជំងឺដែលឆ្លងតាមផ្លូវភេទផ្សេងៗទៀតគឺមានសារៈសំខាន់ដល់សិទ្ធិនារី និងនារីពេញវ័យចំពោះសុខភាពផ្លូវភេទ ។ នារីពេញវ័យ និងស្ត្រីនៅក្នុងប្រទេសជាច្រើនមិនបានទទួលនូវពត៌មានឱ្យបានគ្រប់គ្រាន់ និងសេវាចាំបាច់ដើម្បីធានាដល់សុខភាពផ្លូវភេទ ។ ហេតុនេះហើយការទំនាក់ទំនងដែលមានអំណាចមិនស្មើគ្នាអាស្រ័យលើភេទស្ត្រីនិងនារីពេញវ័យជារឿយៗមិនអាចបដិសេធនូវការរួមភេទ ឬក៏មិនអាចទទូចឱ្យមានការប្រតិបត្តិការរួមភេទដោយមានការទទួលខុសត្រូវ និងប្រកបដោយសុវត្ថិភាព ។ ការប្រតិបត្តិតាមប្រពៃណីយដ៏មានគ្រោះថ្នាក់ ដូចជាការវះកាត់អង្គជាតិនារីភេទ ការមានពហុពន្ធ ក៏ដូចជាការរំលោភរបស់ប្តី អាចធ្វើឱ្យក្មេងស្រីនិងស្ត្រីប្រថុយនឹងគ្រោះនៃការឆ្លងមេរោគហ៊ីវ/អេដស៍ និងជំងឺឆ្លងតាមផ្លូវភេទផ្សេងៗទៀត ។ នារីនៅក្នុងពេស្យាកម្មគឺទទួលរងនូវការគ្រោះថ្នាក់នៃជំងឺនេះផងដែរ ។ រដ្ឋភាគីគួរធ្វើការធានានូវសិទ្ធិទទួលពត៌មាន ការអប់រំ និងសេវាសុខភាពផ្លូវភេទចំពោះស្ត្រី និងក្មេងស្រីគ្រប់រូប ដោយមិនប្រកាន់ ឬការរើសអើង រួមទាំងអ្នកដែលត្រូវគេរត់ដួញដូរ ទោះបីជាពួកគេមិនជាប្រជាជនដែលរស់នៅក្នុងប្រទេសខ្លួនស្របច្បាប់ក៏ដោយ ។ ជាពិសេស រដ្ឋភាគីគួរធ្វើការធានាដល់សិទ្ធិនៃមនុស្សពេញវ័យទាំងពីរភេទ ចំពោះការអប់រំផ្លូវភេទ និងការអប់រំសុខភាពបន្តពូជ ដោយបុគ្គលិកដែលមានការបណ្តុះបណ្តាលត្រឹមត្រូវទៅតាមកម្មវិធីដែលមានការរៀបចំជាពិសេស ដែលមានការគោរពដល់សិទ្ធិឯកជន និង រក្សាការសំងាត់របស់ពួកគេ ។

១៩. នៅក្នុងរបាយការណ៍របស់គេ រដ្ឋភាគីគួរធ្វើការបង្ហាញនូវការធ្វើតេស្តដោយធ្វើការវាយតំលៃថាតើនារីបានទទួលការថែទាំសុខភាពដែលផ្អែកលើមូលដ្ឋានស្មើភាពគ្នារវាងបុរស និងនារីដើម្បីធ្វើការបង្ហាញនូវការគោរពតាមមាត្រា១២ ។ នៅក្នុងការអនុវត្តន៍ធ្វើតេស្តទាំងនេះ រដ្ឋភាគីត្រូវចងចាំនូវបទបញ្ញត្តិមាត្រា១របស់អនុសញ្ញា ។ ដូច្នេះរបាយការណ៍គួរធ្វើការដាក់បញ្ចូលនូវយោបល់ស្តីពីឥទ្ធិពល គោលនយោបាយ នីតិវិធី ច្បាប់ និងពិធីការសុខភាពមានចំពោះនារីដោយធៀបជាមួយបុរស ។

២០. នារីមានសិទ្ធិទទួលបាននូវពត៌មានយ៉ាងពេញលេញពីបុគ្គលិកដែលមានការបណ្តុះបណ្តាលត្រឹមត្រូវទៅតាមជំរើសរបស់គេ ដោយមានការយល់ព្រមចំពោះការព្យាបាល ឬការស្រាវជ្រាវ រួមទាំងដូចជាអត្ថប្រយោជន៍ និងផលអាក្រក់ខ្លាំងពីនីតិវិធីស្នើឡើង និងពីផ្លូវ ជំរើសដែលមានស្រាប់ ។

២១. រដ្ឋភាគីគួរធ្វើនូវរបាយការណ៍ស្តីពីវិធានការដែលបានចាត់ធ្វើឡើងដើម្បីលុបបំបាត់ចោលនូវ ឧបសគ្គដែលនារីប្រឈមមុខក្នុងការទទួលនូវសេវាសុខភាព និងវិធានការអ្វីខ្លះដែលគេបានចាត់ធ្វើឡើងដើម្បីធានាដល់នារីឱ្យបានទាន់ពេលវេលា និងគ្រប់គ្រាន់ចំពោះសេវាសុខភាព ។ របាំងរាំងស្ទះរួមទាំងការតំរូវឬលក្ខខ័ណ្ឌដែលប្រកាន់រើសអើងចំពោះការចូលទៅរកសេវាបំរើរបស់នារី ដូចជាតំលៃសេវាថែទាំ សុខភាពខ្ពស់ជាដើម តំរូវការសំរាប់ការឱ្យមានការយល់ព្រមដោយប្តី ឪពុកម្តាយ ឬអាជ្ញាធរសុខភាពជាបឋមដែលនៅឆ្ងាយពីកន្លែងសុខភាព និងការខ្វះនៅការដឹកជញ្ជូនមិនបានស្រួលបួល និងគ្រប់គ្រាន់ ។

២២. រដ្ឋភាគីគួរធ្វើរបាយការណ៍ផងដែរអំពីវិធានការដែលបានចាត់ធ្វើឡើង ដើម្បីធានាដល់ការទទួលបាននូវសេវាសុខភាពដោយស្មើគ្នា ឧទាហរណ៍ ការធ្វើឱ្យវាអាចទទួលបានចំពោះនារី ។ សេវាដែលអាចទទួលយកបានគឺជាសេវាដែលត្រូវបានគេផ្តល់ជូនតាមវិធីមួយ ដែលធានាថានារីបានផ្តល់ការយល់ព្រមយ៉ាងពេញ លេញហើយធ្វើការគោរពដល់ភាពថ្លៃថ្នូររបស់នាង និងធ្វើការធានាដល់ការរក្សានូវការសំងាត់របស់នាងនិងឆាប់ទទួលនូវតំរូវការព្រមទាំងទស្សនៈរបស់នាង ។ រដ្ឋភាគីមិនត្រូវផ្តល់ឱ្យមាននូវទម្រង់ការបង្ខិតបង្ខំ ដូចជាការធ្វើមិនឱ្យមានកូនដោយមិនមានការយល់ព្រម ការធ្វើតេស្តជាចាំបាច់ចំពោះជំងឺដែលឆ្លងតាមផ្លូវភេទ ឬការធ្វើតេស្តការមានគតិជាចាំបាច់ ដែលជាលក្ខខ័ណ្ឌអនុវត្តរំលោភទៅលើសិទ្ធិការយល់ព្រម និងភាពថ្លៃថ្នូរជានារី ។

២៣. នៅក្នុងរបាយការណ៍ រដ្ឋភាគីគួរធ្វើការបញ្ជាក់នូវអ្វីដែលជាវិធានការគេចាត់ធ្វើឡើងដើម្បីធានាការចូលទៅរកសេវាសុខ ភាពឱ្យទាន់ពេលវេលាដែលទាក់ទិនទៅនិងការរៀបចំផែនការគ្រួសារ ជាពិសេសសុខភាពផ្លូវភេទ និងសុខភាពបន្តពូជជាទូទៅ ។ ការយកចិត្តទុកដាក់ជាពិសេសគួរត្រូវតែធ្វើចំពោះការអប់រំសុខភាពនារីពេញវ័យ រួមទាំងពត៌មាន និងការពិគ្រោះទៅលើគ្រប់វិធីសាស្រ្តទាំងអស់នៅ ក្នុងការរៀបចំផែនការគ្រួសារ ។[២]

២៤. គណៈកម្មាធិការមានការព្រួយបារម្ភអំពីលក្ខខ័ណ្ឌសេវាថែទាំសុខភាពចំពោះនារីវ័យចំណាស់ ពីព្រោះនារីជារឿយៗមិនត្រឹមតែមានអាយុវែងជាងបុរស ហើយក៏ទំនងជាមានការទទួលរងគ្រោះដោយសារ ការពិការនិងដោយសារជំងឺរ៉ាំរ៉ៃធ្វើឱ្យចុះខ្សោយច្រើនជាង បុរសប៉ុណ្ណោះទេ ដូចជាជំងឺបាក់កំលាំង និងជំងឺវិកលចារិកជាដើម ប៉ុន្តែពួកគេជារឿយៗមានការទទួលខុសត្រូវចំពោះគ្រួសារវ័យចំណាស់របស់ខ្លួនថែមទៀត ។ ដូច្នេះរដ្ឋភាគីគួរធ្វើការចាត់វិធានការទាំងអស់ឱ្យបានសមស្របដើម្បីធានាដល់ការចូលទៅរកសេវាសុខភាព របស់ស្រ្តីចាស់ជរាដែលលើកឡើងអំពីការពិការ និងការអសមត្ថភាពដែលទាក់ទិននិងភាពវ័យចំណាស់ ។

២៥. នារីដែលអសមត្ថភាព គ្រប់សម័យទាំងអស់ ជារឿយៗមានការលំបាកជាមួយនិងការចូលទៅរកសេវាសុខភាព។ នារីដែលមានជំងឺផ្លូវចិត្តងាយទទួលរងគ្រោះថ្នាក់ជាពិសេស ទន្ទឹមនោះនៅមានការយល់ដឹងនៅមានកំរិតជាទូទៅអំពីទំហំការគ្រោះថ្នាក់ឱ្យបាន ទូលំទូលាយដល់សុខភាពផ្នែកខាងផ្លូវចិត្តដែលនារីទទួលមិនមានសមាមាត្រដោយហេតុមកពីការរើសអើងលើភេទ ពីអំពើហិង្សា ពីការក្រីក្រ ពីជំលោះប្រដាប់អាវុធពីការផ្លាស់ទីលំនៅ និងទម្រង់ផ្សេងៗនៃការរារាំងរបស់សង្គម។ រដ្ឋភាគីគួរធ្វើការចាត់វិធានការឱ្យបាន សមស្របដើម្បីធានាថាសេវាសុខភាពឆាប់ទទួលនូវតំរូវការរបស់នារីពិការ និងត្រូវធ្វើការគោរពពេញលេញចំពោះសិទ្ធិមនុស្ស និងភាពថ្លៃថ្នូររបស់មនុស្ស។

## មាត្រា១២

២៦. របាយការណ៍គួរធ្វើការដាក់បញ្ចូលនូវវិធានការណាខ្លះដែលរដ្ឋភាគីបានចាត់វិធានការដើម្បីធានាដល់នារីនូវសេវាដែលទាក់ទងទៅនិងការមានផ្ទៃពោះ ការកំនត់កំនើតកូន និងរយៈពេលក្រោយការកើត ឱ្យបានសមស្រប។ ជាពិសេសពត៌មានស្តីពីវិធានការទាំងនេះ ដែលបានធ្វើការកាត់បន្ថយជាទូទៅនូវអត្រាការ កើតជំងឺនិងអត្រាធ្វើឱ្យស្លាប់ដល់ម្តាយនៅក្នុងប្រទេសរបស់ខ្លួន និងនៅក្នុងក្រុមដែលងាយរងគ្រោះថ្នាក់នៅក្នុងតំបន់និងសហគមន៍ត្រូវដាក់បញ្ចូលផងដែរ។

២៧. រដ្ឋភាគីគួរធ្វើការដាក់បញ្ចូលនៅក្នុងរបាយការណ៍របស់គេនៅរបៀបពួកគេបានផ្តល់នូវសេវាមិនគិតថ្លៃ ដែលចាំបាច់ដើម្បីធានានូវការមានផ្ទៃពោះ ការផ្តល់កំនើត និងរយៈពេលក្រោយកើត ដោយមានសុវត្ថិភាពចំពោះស្ត្រី។ នារីជាច្រើនមានគ្រោះថ្នាក់បណ្តាលឱ្យស្លាប់ ឬ ពិការដោយសារការមានផ្ទៃពោះដែលទាក់ទិនទៅនឹងហេតុទាំងនេះពីព្រោះគេខ្វះនូវប្រាក់កាកដើម្បីទទួលសេវាចាំបាច់ ដែលរួមទាំងសេវា មុនពេលឆ្លងទន្លេសេវាសម្ភព និងសេវាក្រោយពេលឆ្លងទន្លេ។ គណៈកម្មាធិការបានកត់សំគាល់ឃើញថា វាគឺជាភារកិច្ចរបស់រដ្ឋភាគីដើម្បីធានានូវសិទ្ធិនារីចំពោះសេវាផ្តល់ឱ្យម្តាយ និងសេវាសំរាលកូនសង្គ្រោះបន្ទាន់ ដោយមានសុវត្ថិភាពហើយគេគួរកំនត់ចំពោះសេវាទាំងនេះឱ្យឈាន ដល់វិសាលភាពអតិបរមានៃធនធានដែលមានស្រាប់។

## មាត្រាផ្សេងៗដែលពាក់ព័ន្ធនៅក្នុងអនុសញ្ញា

២៨. នៅពេលធ្វើសេចក្តីរាយការណ៍អំពីវិធានការដែលបានចាត់ធ្វើដើម្បីគោរពទៅតាមមាត្រា១២ រដ្ឋភាគីត្រូវបានធ្វើការជំរុញ ឱ្យទទួលស្គាល់នូវអន្តរទំនាក់ទំនងរបស់ខ្លួនជាមួយនិងមាត្រាផ្សេងៗទៀតនៅក្នុងអនុសញ្ញាដែលមានដាក់នូវសុខភាពរបស់នារី។ មាត្រាទាំងនោះរួមទាំងមាត្រា៥(ខ) ដែលតំរូវឱ្យរដ្ឋភាគីធ្វើការ

ធានាថាការអប់រំគ្រួសាររួមមានការយល់ដឹងឱ្យបានត្រឹមត្រូវអំពីសម្ភព ដែលវាជាមុខងារមួយរបស់សង្គម ។ មាត្រា១០ដែលតំរូវឱ្យរដ្ឋភាគីធ្វើការធានាបានទទួលនូវការអប់រំស្មើភាពគ្នា ហេតុនេះផ្តល់លទ្ធភាពដល់នារីឱ្យទទួលការថែទាំសុខភាពកាន់តែឆាប់ និងកាត់បន្ថយអត្រាទំលាក់ថ្នាក់នៃកូនសិស្សស្រី ដែលវាជារឿយៗបណ្តាលមកពីការឆ្លងទន្លេមុនគ្រប់ខែ ។ មាត្រា១០ដែលតំរូវឱ្យរដ្ឋភាគីផ្តល់ដល់ស្ត្រី និងក្មេងស្រីទទួលបាននូវពត៌មានអប់រំជាក់លាក់ដើម្បីជួយធានាសុខភាព និងសុខមាលភាព នៃគ្រួសាររួមទាំងពត៌មាន និងដំបូន្មានស្តីពីការរៀបចំផែនការគ្រួសារ ។ មាត្រា១១ដែលផ្នែកខ្លះជាប់ទាក់ទង ជាមួយនិងការការពារសុខភាព និងសុវត្ថិភាពរបស់នារីនៅក្នុងលក្ខខ័ណ្ឌការងារ រួមទាំងការការពារមុខងារសុខភាពបន្តពូជ គឺការការពារពិសេសឱ្យផុតពីប្រភេទគ្រោះថ្នាក់នៃការងារនៅក្នុងអំឡុងពេលមានផ្ទៃពោះ ជាមួយបទបញ្ញត្តិនៃការឈប់សំរាកពេលសម្ភពដោយមានប្រាក់ខែ ។ មាត្រា ១៤ កថាខ័ណ្ឌ២ (ខ) ដែលតំរូវឱ្យរដ្ឋភាគីធ្វើការធានាឱ្យបានដល់នារីនៅជនបទទទួលបាននូវការថែទាំសុខភាពគ្រប់គ្រាន់ រួមទាំងពត៌មាន និងការពិគ្រោះយោបល់ និងសេវាផ្សេងៗនៅក្នុងការរៀបចំផែនការគ្រួសារ ហើយនៅកថាខ័ណ្ឌ (ជ) ដែលបង្គាប់ឱ្យរដ្ឋភាគីចាត់ វិធានការទាំងអស់ឱ្យបានត្រឹមត្រូវដើម្បីធានាលក្ខខ័ណ្ឌរស់នៅគ្រប់គ្រាន់ ជាពិសេសការរៀបចំផ្ទះសម្បែង ការរៀបចំអនាម័យ អគ្គិសនី ទឹកប្រើប្រាស់ ការដឹកជញ្ជូន និងការទំនាក់ទំនង ទាំងអស់នេះសុទ្ធតែមានសារៈសំខាន់ចំពោះការទប់ស្កាត់នៃជំងឺ និងការជំរុញដល់ការថែទាំសុខភាពឱ្យបានល្អ ។ មាត្រា៦ កថាខ័ណ្ឌ (ង) តំរូវឱ្យរដ្ឋភាគីធ្វើការធានាថា នារីមានសិទ្ធិស្មើគ្នា ដូចបុរសចំពោះការសំរេចចិត្តដោយ សេរី និងដោយមានការទទួលខុសត្រូវលើចំនួនកូន និងការពន្យាកំនើតកូនរបស់ខ្លួន និងដើម្បីទទួលបានពត៌មាន ការអប់រំ និងមធ្យោបាយ ដើម្បីផ្តល់លទ្ធភាពឱ្យពួកគេធ្វើការអនុវត្តនិងប្រើប្រាស់នូវសិទ្ធិទាំងនោះ ។ មាត្រា១៦ កថាខ័ណ្ឌ២ ធ្វើការដាក់អាយ័តលើការភ្ជាប់ពាក្យ ឬការរៀបការកូនចៅ ដែលជាកត្តាសំខាន់មួយនៅក្នុងការទប់ស្កាត់ការគ្រោះថ្នាក់លើរាងកាយ និងផ្លូវចិត្តដែលកើតឡើងបណ្តាលមក ពីការមានកូនមុនពេលកំនត់ ។

## អនុសាសន៍សំរាប់ការអនុវត្តន៍របស់រដ្ឋាភិបាល

២៩. រដ្ឋភាគីគួរធ្វើការអនុវត្តន៍នូវយុទ្ធសាស្រ្តជាតិឱ្យបានទូលំទូលាយដើម្បីលើកស្ទួយសុខភាពរបស់នារីពេញមួយអាយុកាលរបស់គេ ។ នេះរួមបញ្ចូលទាំងការធ្វើអន្តរាគមន៍ដែលសំដៅទៅលើ ទាំងលើការទប់ ស្កាត់ និងការព្យាបាលជំងឺ ព្រមទាំងលក្ខខ័ណ្ឌដែលធ្វើឱ្យ ប៉ះពាល់ដល់នារីក៏ដូចជាការឆ្លើយតបចំពោះអំពើហិង្សាប្រឆាំងនារី ហើយនិងធានាដល់ការទទួលយកបានជាសកលរបស់នារីគ្រប់រូប នូវក៏រិត គុណភាពថ្នាក់ខ្ពស់យ៉ាងពេញទំហឹង និងការថែទាំសុខភាពគ្រប់គ្រាន់រួមជាមួយសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ។

៣០. រដ្ឋភាគីគួរត្រូវធ្វើការកំនត់ថវិកា ធនធានមនុស្ស និងធនធានគ្រប់គ្រងឱ្យបានគ្រប់គ្រាន់ដើម្បីធានាថាសុខភាពនារីបានទទួល នូវភាគចំណែកនៃថវិកាសុខភាពទាំងមូលដែលអាចធ្វើការប្រៀបធៀប ជាមួយបុរសបាន ដែលគិតទៅដល់តំរូវការសុខភាពខុសគ្នារបស់ពួកគេផង ។

៣១. រដ្ឋភាគីគួរផងដែរ ជាពិសេសៈ

ក. ដាក់នូវទស្សនៈវិស័យផ្នែកភេទនៅចំនុចសំខាន់នៃគោលនយោបាយ និងកម្មវិធីទាំងអស់ដែលធ្វើឱ្យប៉ះពាល់សុខភាពនារី និងគួរដាក់ឱ្យនារីពាក់ព័ន្ធនៅក្នុងការរៀបចំផែនការ ការអនុវត្តន៍ និងការត្រួតពនិត្យនៃគោលនយោបាយ និងកម្មវិធីបែបនេះ និងនៅក្នុងបទបញ្ញត្តិនៃសេវាសុខភាពចំពោះនារីភេទ ។

ខ. ធានាដល់ការបំបាត់ចោលនូវរាល់ឧបសគ្គទាំងអស់ចំពោះការចូលទៅទទួលសេវាសុខភាព ការអប់រំ និងការចូលទៅ ទទួលពតិមានរបស់នារីរួមទាំងនៅក្នុងផ្នែកសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ហើយជាពិសេសកំនត់នូវធនធានសំរាប់កម្មវិធី ដែលតំរង់ទៅរកនារីពេញវ័យដើម្បីធ្វើការទប់ស្កាត់ និងការព្យាបាលចំពោះជំងឺឆ្លងតាមផ្លូវភេទរួមទាំងហ៊ីវ/អេដស៍ ។

គ. ផ្តល់អាទិភាពដល់ការទប់ស្កាត់នៃការមានផ្ទៃពោះមិនតាមបំណង តាមរយៈការរៀបចំធ្វើផែនការ និងការអប់រំ តាមផ្លូវភេទ ហើយនិងធ្វើការកាត់បន្ថយដល់អត្រាមរណៈម្តាយតាមរយៈសេវាសំរាប់សុវត្ថិភាពមាតា និងការជំនួយមុនពេលឆ្លងទន្លេ ។ នៅពេលដែលអាច នីតិកម្មដាក់ទោសឧក្រិដ្ឋដល់ការពន្លូតកូនគួរគេធ្វើវិសោធនកម្មដើម្បីដកនូវវិធានការទ័ណ្ឌកម្មដែលដាក់ លើនារីដែលធ្វើការពន្លូតកូន ។

ឃ. ត្រួតពិនិត្យលើបទបញ្ញត្តិសេវាសុខភាពចំពោះនារីដោយអង្គការសាធារណៈ អង្គការក្រៅរដ្ឋាភិបាល និងអង្គការឯក ជនដើម្បីចូលទៅទទួលការថែទាំ និងគុណភាពថែទាំស្មើគ្នា ។

ង. តំរូវឱ្យសេវាសុខភាពទាំងអស់ត្រូវស៊ីជាមួយនិងសិទ្ធិមនុស្សផ្នែកនារីរួមទាំងសិទ្ធិស្វ័យភាព សិទ្ធិឯកជន សិទ្ធិរក្សាការសំងាត់ សិទ្ធិយល់ព្រមតាមការផ្តល់ដំណឹង និងសិទ្ធិជ្រើសរើស ។

ច. ធានាថាកម្មវិធីបណ្តុះបណ្តាលសំរាប់អ្នកធ្វើការផ្នែកសុខភាពរួមមាន វគ្គបណ្តុះបណ្តាលចំណេះដឹងទូទៅ វគ្គចាំបាច់ វគ្គផ្នែកការងាយរងគ្រោះលើភេទស្តីពីសុខភាពនារី និងសិទ្ធិមនុស្ស ជាពិសេសអំពើហិង្សាវាងភេទ ។

## កំនត់សំគាល់

១. សូមមើលឯកសារផ្លូវការរបស់អង្គមហាសន្និបាត សម័យប្រជុំលើកទី៤៩ អត្ថបទបន្ថែមលេខ ៣៨ ( A/៤៩/៣៨) ជំពូក I section A យោបល់រួមលេខ២១ កថាខ័ណ្ឌ២៩

៣. ការអប់រំសុខភាពចំពោះនារីពេញវ័យគួរធ្វើការលើកឡើងបន្ថែមទៀត ជាពិសេសនូវគុណភាពភេទ អំពើហិង្សា ការទប់ស្កាត់ជំងឺដែលឆ្លងតាមផ្លូវភេទព្រមទាំងសិទ្ធិសុខភាពបន្តពូជ និងសិទ្ធិសុខភាពផ្លូវភេទ។

# អនុសាសន៍ទូទៅលេខ ២៥ មាត្រា៤ កថាខណ្ឌទី១ នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើស អើងប្រឆាំងនឹងនារីភេទ វិធានការពិសេសបណ្តោះអាសន្ន

## I. សេចក្តីផ្តើម

១. នៅក្នុងសម័យប្រជុំលើកទី២០ (ឆ្នាំ១៩៩៩) ដោយអនុលោមទៅតាមមាត្រា២១ នៃអនុសញ្ញា គណៈកម្មាធិការស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ បានសំរេចរៀបចំអនុសាសន៍លើមាត្រា៤ កថាខណ្ឌទី១ នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ។ អនុសាសន៏ទូទៅថ្មីនេះ គឺជាអនុសាសន៏បន្ថែមលើអនុសាសន៏ទូទៅដែលបានផ្តល់ជូនពីមុន រួមមានអនុសាសន៏ទូទៅលេខ៥ (សម័យប្រជុំលើកទី៧ ក្នុងឆ្នាំ១៩៨៨) ស្តីពីវិធានការពិសេសបណ្តោះ អាសន្ន អនុសាសន៏លេខ៨ (សម័យប្រជុំលើកទី៧ ឆ្នាំ១៩៨៨) ស្តីពីការអនុវត្តន៏មាត្រា៨ នៃអនុសញ្ញា និងអនុសាសន៏លេខ២៣ (សម័យប្រជុំលើកទី១៦ ឆ្នាំ១៩៩៧) ស្តីពីស្ត្រីក្នុងជីវិតសាធារណ ក៏ដូចជាអនុសាសន៏លើរបាយការណ៏របស់រដ្ឋភាគី ស្តីពីអនុសញ្ញា និងយោបល់រួមរបស់គណៈកម្មាធិការ ទៅលើរបាយការណ៏ទាំងនេះ។

២. ជាមួយនឹងអនុសាសន៏ទូទៅនាពេលបច្ចុប្បន្ននេះ គឺគណៈកម្មាធិការមានគោលបំណងដើម្បីបញ្ជាក់អំពីអត្ថន័យនៃមាត្រា៤ កថាខណ្ឌ១ ដើម្បីអោយជួយសំរបសំរួល និងដើម្បីធានាថារដ្ឋភាគី អនុវត្តអនុសញ្ញានេះ។ គណៈកម្មាធិការ បានជំរុញលើកទឹកចិត្តដល់រដ្ឋភាគី បកប្រែអនុសាសន៏ទូទៅនេះទៅជាភាសា ជាតិ និងភាសាតាមតំបន់ និងផ្សព្វផ្សាយអោយបានទូលំទូលាយទៅដល់អង្គការនីតិបញ្ញត្តិ នីតិប្រតិបត្តិ និង តុលាការ រួមទាំងថ្នាក់រដ្ឋបាល ក៏ដូចជាសង្គមស៊ីវិល រួមមានប្រពន្ធ័ផ្សព្វផ្សាយ ស្ថាប័នអប់រំ ស្ថាប័នសិទ្ធិ មនុស្ស និងសមាគមរបស់ស្ត្រី។

## II. ជីវប្រវត្តិ : គោលបំណងនៃអនុសញ្ញា :

៣. អនុសញ្ញា គឺជាឧបករណ៏ដ៏សំខាន់មួយ។ ចាប់តាំងពីមានការអនុម័តលើអនុសញ្ញាក្នុងឆ្នាំ ១៩៧៩មក គណៈកម្មាធិការ ក៏ដូចជាអ្នកពាក់ពន្ធ័ផ្សេងៗទៀត ទាំងនៅថ្នាក់ជាតិ និងអន្តរជាតិ បានចូលរួមផ្តល់ជាគំនិតដើម្បីបញ្ជាក់ និងបង្កើនការយល់ដឹងអំពីវិស័យសំខាន់ៗនៅក្នុងមាត្រានានា នៅក្នុង អនុសញ្ញា

និងរូបភាពជាក់ស្តែងនៃការរើសអើងប្រឆាំងនឹងស្ត្រី និងឧបករណ៍នានាសំរាប់ប្រយុទ្ធប្រឆាំងនឹងការរើសអើងទាំងនេះ ។

៤. វិសាលភាព និងអត្ថន័យនៃមាត្រា៤ កឋាខណ្ឌទី១ ត្រូវតែស្របទៅនឹងគោលបំណងទូទៅនៃ អនុសញ្ញា គឺការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ដើម្បីអោយស្ត្រីទទួលបាន សមភាពទាំងនៅក្នុងផ្នែកច្បាប់ និងការអនុវត្តន៍ជាក់ស្តែង ជាមួយនឹងបុរស ក្នុងការទទួលបានសិទ្ធិដែល ជាសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ។ រដ្ឋភាគីនៅក្នុងអនុសញ្ញានេះ ត្រូវមានកាតព្វកិច្ចគោរព ការពារ លើកកំពស់ និងបំពេញ ដើម្បីអោយស្ត្រីទទួលបាននូវសិទ្ធិ គ្មានការរើសអើង និងដើម្បីធានានូវការ អភិវឌ្ឍន៍ និងលើកកំពស់ដល់ស្ត្រី ដើម្បីធ្វើអោយឋានៈតួនាទីរបស់ស្ត្រី កាន់តែល្អប្រសើរឡើង ទាំងនៅ ក្នុងផ្នែកច្បាប់ និង ការអនុវត្តន៍ជាក់ស្តែង ដូចគ្នានឹងបុរសដែរ ។

៥. ទស្សនៈស្តីពីការរើសអើង ដែលចែងនៅក្នុងអនុសញ្ញា គឺខុសពីទស្សនៈដែលមាននៅក្នុង ស្តង់ដារ និងបទដ្ឋានផ្លូវច្បាប់ថ្នាក់ជាតិ និងអន្តរជាតិជាច្រើន ។ ស្តង់ដារ និងបទដ្ឋានផ្លូវច្បាប់ទាំងនោះ គឺហាមឃាត់ ពុំអោយមានការរើសអើង ដោយសារតែភេទ និងការពារទាំងបុរស និងស្ត្រី កុំអោយ មានការប្រតិបត្តិបំពាន ភាពខុសប្លែកគ្នាដោយអយុត្តិធម៌ និង/ឬដោយគ្មានហេតុផល ប៉ុន្តែអនុសញ្ញាផ្តោត លើការរើសអើងប្រឆាំងនឹងស្ត្រី ដោយសង្កត់ធ្ងន់ថាស្ត្រីបានទទួលការរងគ្រោះ និងនៅតែបន្តរងគ្រោះ ដោយសារការរើសអើងជាច្រើនរូបភាព ពីព្រោះដោយសារគាត់ ជាស្ត្រីភេទ ។

៦. មាត្រា១ ដល់មាត្រា៥ និងមាត្រា២៤ គឺជាមាត្រាសំខាន់ៗដែលអាចបកប្រែទៅជាក្របខណ្ឌ ការងារសំរាប់មាត្រាទាំងអស់នៅក្នុងអនុសញ្ញានេះ ហើយមាត្រាទាំងនេះ បញ្ជាក់យ៉ាងច្បាស់អំពី កាតព្វកិច្ចចំនួនបីសំរាប់រដ្ឋភាគី ក្នុងការលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី ។ រដ្ឋភាគីគួរតែអនុវត្ត កាតព្វកិច្ចទាំងនេះក្នុងរូបភាពរួមបញ្ចូលគ្នា និងអនុវត្តក្នុងរូបភាពផ្សេងៗទៀត ក្រៅពីកាតព្វកិច្ចផ្នែក ច្បាប់ជាផ្លូវការ ដើម្បីផ្តល់ជូនដល់ស្ត្រីនូវការប្រតិបត្តិស្មើភាពនឹងបុរសដែរ ។

៧. ជាដំបូង រដ្ឋភាគីមានកាតព្វកិច្ចធ្វើយ៉ាងណាកុំអោយមាន (ទោះដោយផ្ទាល់ ឬដោយមិន ផ្ទាល់) ១. ការរើសអើងប្រឆាំងនឹងស្ត្រី នៅក្នុងច្បាប់របស់រដ្ឋភាគី ហើយស្ត្រីទទួលបានការការពារ ប្រឆាំងនឹងការរើសអើងដែលប្រព្រឹត្តិដោយអាជ្ញាធរសាធារណ ប្រពន្ធ័ផ្លូវច្បាប់ អង្គការ សហគ្រាស ឬបុគ្គល - នៅក្នុង ជីវិតសាធារណ ក៏ដូចជាជីវិតឯកជន - ដោយរដ្ឋភាគីត្រូវដំណើរការកាត់ទោស ក៏ដូច ជាការដាក់ទណ្ឌកម្ម ដល់ជនល្មើស

និងផ្តល់ដល់ស្ត្រីនូវការសងជំងឺចិត្ត។ ទីពីរ កាតព្វកិច្ចរបស់រដ្ឋភាគី គឺត្រូវបង្កើនតួនាទីជាក់ ស្តែងរបស់ស្ត្រី តាមរយៈការរៀបចំគោលនយោបាយ និងកម្មវិធីម៉ត់ចត់ និងមានប្រសិទ្ធភាព។ ទីបី កាតព្វកិច្ចរបស់រដ្ឋភាគី គឺដោះស្រាយទំនាក់ទំនងយេនឌ័រដែលនៅតែមាន និងផ្នត់គំនិតយេនឌ័រ ដែលប៉ះ ពាល់ដល់ស្ត្រី ដែលកើតឡើងដោយបុគ្គល និងច្បាប់ រចនាសម្ពន្ធ័ផ្លូវច្បាប់ និងរចនាសម្ពន្ធ័សង្គម និង ស្ថាប័ន។

៨. អនុសាសន៍របស់គណៈកម្មាធិការ គឺថា យុទ្ធសាស្ត្រផ្លូវច្បាប់ជាផ្លូវការតែមួយ ឬការរៀបចំ កម្មវិធី គឺពុំទាន់គ្រប់គ្រាន់នោះទេ ក្នុងការធ្វើអោយស្ត្រីទទួលបាននូវសមភាពជាក់ស្តែងជាមួយនឹងបុរស - ដែលគណៈកម្មាធិការបកស្រាយសមភាពនេះ ថាជាសមភាពចាំបាច់យ៉ាងពិតប្រាកដ។ លើសពីនេះទៀត អនុសញ្ញាបានតម្រូវអោយមានការផ្តល់ដល់ស្ត្រីនូវការចាប់ផ្តើមស្មើនឹងបុរស ហើយស្ត្រីត្រូវទទទួល បាន នូវការបង្កើនភាពអង់អាចតាមរយៈការផ្តល់នូវបរិយាកាសបង្កើនលទ្ធភាព ដើម្បីសំរេចបាននូវ សមភាពនៃលទ្ធផល។ ការធានាអោយមានការប្រតិបត្តិចំពោះស្ត្រី ដូចគ្នានឹងការប្រតិបត្តិចំពោះបុរស គឺពុំទាន់គ្រប់ គ្រាន់នៅឡើយទេ។ ប៉ុន្តែលើសពីនេះ គឺត្រូវពិចារណាអំពីភាពខុសគ្នា ដែលជីវសាស្ត្រ សង្គម និងវប្បធម៌ បានកំណត់ចំពោះស្ត្រី និងបុរស។ នៅក្នុងកាលៈទេសៈមួយចំនួន ដើម្បីដោះស្រាយភាព ខុសគ្នាទាំងនេះ ទាមទារអោយមានការប្រតិបត្តិខុសគ្នា ចំពោះស្ត្រី និងបុរស។ ដើម្បីសំរេចគោលដៅ សមភាពចាំបាច់ គឺ ទាមទារនូវយុទ្ធសាស្ត្រប្រកដដោយប្រសិទ្ធភាព ក្នុងការដោះស្រាយបញ្ហាតំណាងរបស់ស្ត្រី (ដែលមានចំនួនតិចតួច) និងការបែងចែកឡើងវិញនូវធនធាន និងអំណាចរវាងបុរស និងស្ត្រី។

៩. សមភាពនៃលទ្ធផល គឺជាសមភាពជាក់ស្តែង ឬសមភាពចាំបាច់។ លទ្ធផលទាំងនេះ អាចជា ក្នុងលក្ខណៈជាបរិមាណ និង/ឬគុណភាព ដែលមានន័យថាស្ត្រី អនុវត្តសិទ្ធិរបស់ខ្លួននៅក្នុងវិស័យនានា ក្នុងនាមជាសមាជិកស្មើភាពនឹងបុរស ស្ត្រីទទួលបានប្រាក់ចំណូលស្មើគ្នាដូចបុរស ស្ត្រីទទួលបានសមភាព នៅក្នុងតួនាទីធ្វើសេចក្តីសំរេច និងវិស័យនយោបាយ ហើយស្ត្រីទទួលបាននូវសេរីភាព ចៀសផុតពីអំពើ ហិង្សា។

១០. តួនាទីរបស់ស្ត្រី នឹងពុំមានភាពល្អប្រសើរឡើយ ប្រសិនជាមូលហេតុនៃការរើសអើង ប្រឆាំងនឹងស្ត្រី និងវិសមភាព ពុំត្រូវបានដោះស្រាយប្រកបដោយប្រសិទ្ធភាពនោះទេ។ ការពិចារណាទៅ លើជីវិតរបស់ ស្ត្រី និងបុរស គឺត្រូវធ្វើឡើងទៅតាមកាលៈទេសៈ និងត្រូវមានវិធានការដើម្បីឆ្ពោះទៅរក ការផ្លាស់ប្តូរឱកាស ស្ថាប័ន និងប្រពន្ធ័យ៉ាងពិតប្រាកដ កុំអោយស្ថាប័ន និងប្រពន្ធ័ទាំងនោះប្រកាន់ យកតែទស្សនៈ របស់បុរសចំពោះអ្វីដែលហៅថាអំណាច និងអ្វីដែលជារូបភាពនៃជីវិត។

១១. តម្រូវការជាអចិន្ត្រៃយ៍ដែលកំណត់ដោយជីវសាស្ត្រ និងបទពិសោធន៍របស់ស្ត្រី គួរតែ ខុសពីតម្រូវការផ្សេងៗទៀត ពីព្រោះដោយសារតែលទ្ធផលនៃការរើសអើងប្រឆាំងនឹងស្ត្រី កាលពី អតីតកាល និងបច្ចុប្បន្នកាល ដែលប្រព្រឹត្តិដោយបុគ្គល ដោយទស្សនៈយេនឌ័រដែលមានលក្ខណៈ គ្រប ដណ្តប់ ឬដោយសារលទ្ធផលនៃការរើសអើងពីរចនាសម្ព័ន្ធ និងស្ថាប័នសង្គម និងវប្បធម៌។ នៅពេល ដែលកំពុងតែអនុវត្ត វិធានការជាជំហានៗ ដើម្បីលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី នៅពេលនោះ តម្រូវការរបស់ស្ត្រី អាចផ្លាស់ប្តូរ ឬលែងជាតម្រូវការរបស់ស្ត្រីទៀត ឬអាចក្លាយទៅជាតម្រូវការរបស់ ទាំងស្ត្រី និងបុរស។ ហេតុដូច្នេះ ការបន្តការត្រួតពិនិត្យតាមដានការអនុវត្តច្បាប់ កម្មវិធី និងការអនុវត្តន៍នានា ដែលមានគោលដៅបង្កើនសមភាពជាក់ស្តែង ឬសមភាពចាំបាច់ ដល់ស្ត្រី គឺត្រូវការជាចាំបាច់ ដើម្បីចៀសវាងនូវការប្រតិបត្តិ ខុសគ្នា ដែលលែងត្រូវការទៀតហើយនោះ។

១២. ក្រុមស្ត្រីជាក់ស្តែងមួយចំនួន ក្រៅពីការទទួលរងគ្រោះដោយសារការរើសអើងដោយសារ ពួកគាត់ជាស្ត្រី ពួកគាត់ថែមទាំងទទួលរងគ្រោះដោយសារការរើសអើងជាច្រើនទៀត ដូចជាពូជសាសន៍ សាសនា ពិការភាព អាយុ ឋានៈក្នុងសង្គម ឋានៈនៅក្នុងសាសនា ឬកត្តាផ្សេងៗទៀត។ ការរើសអើង បែបនេះអាចប៉ះពាល់ដល់ក្រុមស្ត្រីទាំងនេះ យ៉ាងខ្លាំង ឬក៏រឹត និងរូបភាពដែលស្ត្រីក្នុងក្រុមនេះ អាច ទទួលរងគ្រោះ អាចខុសពីបុរសនៅក្នុងក្រុមនេះដែរ។ រដ្ឋភាគី អាចត្រូវការវិធានការពិសេសជា បណ្តោះអាសន្ន ដើម្បីលុបបំបាត់ការរើសអើងទាំងនេះ និងលុបបំបាត់នូវផលប៉ះពាល់ជាអវិជ្ជមានទៅ លើស្ត្រី។

១៣. ក្រៅពីអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី នៅមានឧបករណ៍សិទ្ធិមនុស្សអន្តរជាតិ និងឯកសារគោលនយោបាយអន្តរជាតិផ្សេងៗទៀត ដែលត្រូវបានអនុម័ត នៅក្នុងប្រព័ន្ធសហប្រជាជាតិ ដែលមានចែងអំពីវិធានការពិសេសបណ្តោះអាសន្ន ដើម្បីគាំទ្រដល់ការ សំរេចអោយបាននូវសមភាព។ វិធានការនេះ គឺមានរូបភាព អត្ថន័យ និងការបកស្រាយខុសៗគ្នា។ ហេតុដូច្នេះ ហើយគណៈកម្មាធិការសង្ឃឹមថាអនុសាសន៍ទូទៅបច្ចុប្បន្ននេះ លើមាត្រា៤ កឋាខណ្ឌទី១ នឹងអាចបំភ្លឺ អំពីរូបភាព និងអត្ថន័យនៃវិធានការពិសេសជាបណ្តោះអាសន្ននេះ។

១៤. អនុសញ្ញាសំដៅដល់ការរើសអើងពីសង្គម និងវប្បធម៌កាលពីអតីត និងបច្ចុប្បន្ន ដែលរាំងស្ទះ ដល់ស្ត្រីក្នុងការទទួលបានសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន។ អនុសញ្ញាមានគោលដៅលុបបំបាត់រាល់ ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី រួមមានការលុបបំបាត់នូវមូលហេតុ និងផលវិបាកនៃវិសមភាពជាក់ ស្តែង ឬវិសមភាពចាំបាច់។ ហេតុដូច្នេះហើយ ការអនុវត្តន៍វិធានការពិសេសជាបណ្តោះអាសន្ន ស្របទៅ តាមអនុសញ្ញានេះ គឺជាមធ្យោបាយ

មួយ ក្នុងការទទួលស្គាល់នូវសមភាពជាក់ស្តែង ឬសមភាពចាំបាច់ សំរាប់ស្ត្រី ជាជាងការលើកលែងចំពោះបទដ្ឋាននៃភាពគ្មានការរើសអើង និងសមភាព។

## III. អត្ថន័យ និងវិសាលភាពនៃវិធានការពិសេសជាបណ្តោះអាសន្ននៅក្នុងអនុសញ្ញា ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រី

### មាត្រា៤ កថាខណ្ឌទី១

ការអនុម័តរបស់រដ្ឋភាគីលើវិធានការពិសេសជាបណ្តោះអាសន្ន ក្នុងគោលបំណងដើម្បីទទួលបាន សមភាពជាក់ស្តែងរវាងបុរស និងស្ត្រី ពុំគួរចាត់ទុកថាជាការរើសអើងនោះទេ (ដូចដែលបានចែងនៅក្នុង អនុសញ្ញានាពេលបច្ចុប្បន្ននេះ) ប៉ុន្តែវិធានការទាំងនេះនឹងពុំរក្សាទុកនូវវិសមភាព ឬស្តង់ដារដាច់ដោយ ឡែកឡើយ។ វិធានការទាំងនេះ នឹងត្រូវបញ្ឈប់វិញ នៅពេលដែលសំរេចបានតាមគោលបំណងសមភាព នៃឱកាស និងការប្រតិបត្តិ។

### មាត្រា ៤ កថាខណ្ឌទី២

ការអនុម័តរបស់រដ្ឋភាគី លើវិធានការពិសេស រួមមានវិធានការដែលមានចែងនៅក្នុងអនុសញ្ញា នាពេលបច្ចុប្បន្ននេះ ក្នុងគោលបំណងការពារសុខភាពមាតា គឺពុំត្រូវចាត់ទុកថាជាការរើសអើងឡើយ។

### ក. ទំនាក់ទំនងរវាងកថាខណ្ឌទី១ និងទី២ នៃមាត្រា៤

១៥. គោលបំណងនៃ "វិធានការពិសេស" នៅក្នុងមាត្រា៤ កថាខណ្ឌទី១ គឺខុសពីគោលបំណងនៅ ក្នុងកថាខណ្ឌទី២។ គោលបំណងនៃមាត្រា៤ កថាខណ្ឌទី១ គឺជំរុញការលើកកំពស់ឋានៈតួនាទីរបស់ស្ត្រី ដើម្បីអោយស្ត្រីទទួលបានសមភាពជាក់ស្តែង ឬសមភាពចាំបាច់ ជាមួយនឹងបុរស និងដើម្បីអោយមាន ការផ្លាស់ប្តូរនៅក្នុងរចនាសម្ព័ន្ធ សង្គម និងវប្បធម៌ ដែលចាំបាច់សំរាប់កែរលំអទម្រង់ និងផលប៉ះពាល់នៃ ការរើសអើងប្រឆាំងនឹងស្ត្រី ពីអតីតកាល និងបច្ចុប្បន្នកាល ក៏ដូចជាដើម្បីផ្តល់ដល់ស្ត្រីនូវការទូរទាត់សង។ វិធានការទាំងនេះគឺជាវិធានការបណ្តោះអាសន្នប៉ុណ្ណោះ។

១៦. មាត្រា៤ កថាខណ្ឌទី២ ចែងអំពីការប្រតិបត្តិខុសគ្នា សំរាប់ស្ត្រី និងបុរស ដោយសារតែភាពខុសគ្នានៃជីវសាស្ត្ររបស់ស្ត្រី និងបុរស។ វិធានការទាំងនេះ គឺជាវិធានការអចិន្ត្រៃយ៍ ដែលត្រូវអនុវត្ត យ៉ាងហោចណាស់រហូតដល់ពេលវេលាមួយដែលត្រូវពិនិត្យមើលឡើងវិញ នៅពេលដែលមានការរីក ចំរើនផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដូចចែងនៅក្នុងមាត្រា ១១ កថាខណ្ឌទី៣។

## ខ. ពាក្យបច្ចេកទេស

១៧. អនុសញ្ញា បានប្រើពាក្យបច្ចេកទេសខុសៗគ្នា ដើម្បីរៀបរាប់អំពី "វិធានការពិសេសជា បណ្តោះអាសន្ន" ដូចដែលមានចែងនៅក្នុងមាត្រា ៤ កឋាខណ្ឌទី១។ គណៈកម្មាធិការ ក៏បានប្រើពាក្យ ក្នុងទម្រង់ខុសៗគ្នា នៅក្នុងការផ្តល់អនុសាសន៍ទូទៅមុនៗ។ រដ្ឋភាគី ជាញឹកញាប់បកស្រាយពាក្យ "វិធានការពិសេស" ទៅជារូបភាព កែលំអរ ការទូទាត់សង និងការលើកស្ទួយ ដែលមានន័យថា "សកម្មភាពស្រប" "សកម្មភាពវិជ្ជមាន" "វិធានការវិជ្ជមាន" "ការរើសអើងត្រឡប់វិញ" និង "ការរើសអើងវិជ្ជមាន"។ ពាក្យទាំងនេះ ត្រូវបានលើកឡើងនៅក្នុងការពិភាក្សា និងការអនុវត្តន៍នៅក្នុងប្រទេសផ្សេងៗ។ អនុសាសន៍ទូទៅនាពេលបច្ចុប្បន្ននេះហើយ ដែលស្របទៅតាមការអនុវត្តន៍ ដែលមានចែងនៅក្នុងរបាយការណ៍របស់រដ្ឋភាគី គណៈកម្មាធិការសូមប្រើតែពាក្យ "វិធានការពិសេសជាបណ្តោះអាសន្ន" ដូចមាន ចែងនៅក្នុងមាត្រា ៤ កឋាខណ្ឌទី១។

## គ. ចំណុចសំខាន់ៗនៅក្នុងមាត្រា ៤ កឋាខណ្ឌទី១

១៨. វិធានការនៅក្នុងមាត្រា ៤ កឋាខណ្ឌទី១ ដែលអនុវត្តដោយរដ្ឋភាគី គួរតែមានគោលបំណង ដើម្បីពន្លឿនការចូលរួមស្មើភាពរបស់ស្ត្រីជាមួយបុរស នៅក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌ សង្គមស៊ីវិល ឬវិស័យផ្សេងៗទៀត។ គណៈកម្មាធិការ មានទស្សនៈថា ការអនុវត្តន៍វិធានការទាំងនេះ គឺ ពុំមែនជាករណីលើកលែង នៅក្នុងគោលការណ៍គ្មានការរើសអើងនោះឡើយ ប៉ុន្តែគណៈកម្មាធិការបាន សង្កត់ធ្ងន់ថា ការអនុវត្តន៍វិធានការពិសេសបណ្តោះអាសន្នទាំងនេះ គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រដ៏មាន សារៈសំខាន់របស់រដ្ឋភាគី ក្នុងការឆ្ពោះទៅសំរេចអោយបាននូវសមភាពជាក់ស្តែងឬសមភាពចាំបាច់សំរាប់ ស្ត្រី ស្មើភាពជាមួយបុរស នៅក្នុងការអនុវត្តន៍សិទ្ធិមនុស្ស និងទទួលបានសេរីភាពជាមូលដ្ឋាន។ ក្នុងខណៈដែលរដ្ឋភាគី កំពុងអនុវត្តវិធានការពិសេសជាបណ្តោះអាសន្ន ដើម្បីទូទាត់សងចំពោះផលប៉ះពាល់នៃការ រើសអើងពីអតីតកាលទៅលើស្ត្រី រដ្ឋភាគីនៅមានកាតព្វកិច្ច (ដូចដែលមានចែងនៅក្នុងអនុសញ្ញា) បង្កើន ឋានៈតួនាទីរបស់ស្ត្រី ដើម្បីទទួលបាននូវសមភាពជាក់ស្តែង ឬសមភាពសំចាំបាច់ ជាមួយនឹងបុរស ដោយពុំចាំបាច់មានភស្តុតាងបញ្ជាក់នូវការរើសអើងពីអតីតកាលនោះទេ។គណៈកម្មាធិការយល់ឃើញថា រដ្ឋភាគី ដែលអនុម័ត និងអនុវត្តវិធានការទាំងនេះ ដូចដែលមានចែងនៅក្នុងអនុសញ្ញា គឺពុំមែនជាការរើសអើង ប្រឆាំងនឹងបុរសឡើយ។

១៩. រដ្ឋភាគី គួរតែបញ្ជាក់អោយបានច្បាស់អំពីវិធានការពិសេសជាបណ្តោះអាសន្ន ដូចដែលមាន ចែងនៅក្នុងមាត្រា ៤ កឋាខណ្ឌទី១ ក្នុងការជំរុញអោយសំរេចបាននូវគោលដៅម៉ត់ចត់នៃសមភាពជាក់ ស្តែង ឬសមភាពចាំបាច់ សំរាប់ស្ត្រី និងអនុម័តលើគោលនយោបាយសង្គមទូទៅផ្សេងៗទៀត ដើម្បីធ្វើ អោយប្រសើរ

ឡើងនូវស្ថានភាពរបស់ស្ត្រី និងកុមារី។ ពុំមែនគ្រប់វិធានការទាំងអស់ ដែលផ្តោតលើស្ត្រី គឺជាវិធានការពិសេសជាបណ្តោះអាសន្ននោះទេ។ ការផ្តល់ជូននូវលក្ខខណ្ឌទូទៅ ដើម្បីធានាអោយបាននូវ សិទ្ធិស៊ីវិល នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ដល់ស្ត្រី និងកុមារី ក្នុងការធានានូវភាពថ្លៃថ្នូរ និងជីវិតដែលគ្មានអំពើហិង្សា គឺពុំមែនហៅថាវិធានការពិសេសជាបណ្តោះអាសន្ននោះទេ។

២០. មាត្រា ៤ កឋាខណ្ឌទី១ ចែងអំពីរូបភាព "បណ្តោះអាសន្ន" នៃវិធានការពិសេសនេះ។ ដូច្នេះ ហើយ វិធានការទាំងនេះ ពុំចាំបាច់ត្រូវអនុវត្តជារៀងរហូតនោះទេ ទោះបីជាការពិត អត្ថន័យនៃពាក្យ "បណ្តោះអាសន្ន" អាចមានន័យថាជាការអនុវត្តន៍រយៈពេលយូរក៏ដោយ។ រយៈពេលនៃការអនុវត្តន៍វិធាន ការពិសេសជាបណ្តោះអាសន្ន គួរតែកំណត់ទៅតាមលទ្ធផលនៃការឆ្លើយតបទៅនឹងបញ្ហា ពុំមែនទៅតាម រយៈពេលនៃពេលវេលានោះទេ។ វិធានការពិសេសជាបណ្តោះអាសន្ន នឹងត្រូវឈប់អនុវត្ត បន្ទាប់ពីសំរេច បាននូវលទ្ធផលដែលចង់បាន ហើយលទ្ធផលនោះមានលំនាំ មួយរយៈកាល។

២១. ពាក្យថា "ពិសេស" ទោះបីជាពាក្យនេះស្របទៅនឹងសិទ្ធិមនុស្សក៏ដោយ ប៉ុន្តែក៏ត្រូវការការពន្យល់យ៉ាងប្រុងប្រយត្ន័ផងដែរ។ ពេលខ្លះ ការប្រើពាក្យនេះ អាចធ្វើអោយស្ត្រី និងក្រុមផ្សេងៗទៀត ដែលជាប្រធានបទនៃការរើសអើង មានភាពទន់ខ្សោយ ងាយទទួលការរងគ្រោះ និងជាមនុស្សដែលត្រូវ ការវិធានការបន្ថែម ឬ "ពិសេស" ដើម្បីអាចចូលរួម ឬប្រកួតប្រជែងនៅក្នុងសង្គម។ ទោះបីជាយ៉ាងណា ក៏ដោយ អត្ថន័យពិតប្រាកដនៃពាក្យ "ពិសេស" នៅក្នុងមាត្រា ៤ កឋាខណ្ឌទី១ គឺសំដៅដល់វិធានការ ដែលរៀបចំឡើងដើម្បីគោលបំណងជាក់លាក់ណាមួយនោះ។

២២. ពាក្យ "វិធានការ" គឺសំដៅដល់ឧបករណ៍នីតិច្បាប់ ប្រតិបត្តិ រដ្ឋបាល និងបទបញ្ញត្តិផ្សេងៗ ទៀត គោលនយោបាយ និងការអនុវត្តន៍ ដូចជាកម្មវិធីផ្សព្វផ្សាយ ឬកម្មវិធីគាំទ្រ ការបែងចែក និង/ឬ ការបែងចែកឡើងវិញនូវធនធាន ការប្រតិបត្តិ ការជ្រើសរើសដោយដាក់គោលដៅ ការជួល និងការ តំឡើងឋានៈគោលដៅដែលមានពេលវេលាច្បាស់លាស់ និងប្រពន្ធ័កូតា។ ការជ្រើសរើស "វិធានការ" ជាពិសេស ត្រូវផ្អែកទៅលើបរិបទនៅក្នុងមាត្រា ៤ កឋាខណ្ឌទី១ ហើយនឹងត្រូវអនុវត្ត ដោយមានគោលដៅពិសេសដែលត្រូវ សំរេចអោយបាន។

២៣. ការអនុម័ត និងការអនុវត្តន៍វិធានការពិសេសជាបណ្តោះអាសន្ន អាចនាំទៅរកការពិភាក្សាអំពីគុណភាព និងគុណសម្បត្តិរបស់ក្រុម ឬបុគ្គល ដែលជាក្រុមគោលដៅ និងអាចនាំទៅរកការពិភាក្សា

តវ៉ាថាមានការយកចិត្តទុកដាក់ដល់ស្ត្រី ដែលមានគុណសម្បត្តិតិចជាងបុរស ដូចជានៅក្នុងវិស័យ នយោបាយ អប់រំ និងការងារ។ ពីព្រោះថាវិធានការពិសេសជាបណ្តោះអាសន្ន មានគោលបំណងពន្លឿន ការសំរេចអោយបាននូវសមភាពជាក់ស្តែង ឬសមភាពចាំបាច់ ដូច្នេះសំណួរពាក់ពន្ធ័នឹងសមត្ថភាព និង គុណសម្បត្តិជាពិសេសនៅក្នុងវិស័យការងារនៅក្នុងផ្នែកសាធារណ និងឯកជន ចាំបាច់ត្រូវពិនិត្យឡើង វិញដោយប្រុងប្រយត្ន័ ដើម្បីរកអោយឃើញនូវភាពលំអៀងយេនឌ័រ ពីព្រោះថាភាពលំអៀងទាំងនេះ បង្កើតឡើងដោយវប្បធម៌។ ចំពោះការតែងតាំង ការជ្រើសរើស ឬការបោះឆ្នោតនៅក្នុងផ្នែកសាធារណ និងនយោបាយ ក្រៅពីសមត្ថភាព និងគុណសម្បត្តិ រួមមានការអនុវត្តន៍គោលការណ៍ ប្រជាធិបតេយ្យ និងការជ្រើសរើសក្នុងការបោះឆ្នោត ក៏គួរតែពិចារណាចំពោះកត្តាផ្សេងៗទៀតផងដែរ។

២៤. មាត្រា ៤ កឋាខណ្ឌ័ទី១ ពាក់ពន្ធ័នឹងមាត្រា ១,២,៣,៥ និង ២៤ ចាំបាច់ត្រូវអនុវត្តជាមួយនឹង មាត្រា ៦ ដល់មាត្រា ១៦ ដែលចែងថា រដ្ឋភាគី "នឹងចាត់វាល់វិធានការសមស្រប"។ ដូច្នេះហើយ គណៈកម្មាធិការ យល់ឃើញថា រដ្ឋភាគី មានកាតព្វកិច្ចក្នុងការអនុម័ត និងអនុវត្តវិធានការពិសេសជា បណ្តោះអាសន្ន នៅក្នុងមាត្រាណាមួយក្នុងចំណោមមាត្រាទាំងនេះ បើសិនជាចាំបាច់ត្រូវការវិធានការទាំងនេះ និងមាន លក្ខណៈសមស្រប ដើម្បីពន្លឿនការសំរេចអោយបាននូវគោលដៅទូទៅ ឬគោលដៅពិសេស ដើម្បីអោយស្ត្រីទទួល បានសមភាពជាក់ស្តែង ឬសមភាពចាំបាច់។

IV. ***អនុសាសន៍ចំពោះរដ្ឋភាគី***

២៥. របាយការណ៍របស់រដ្ឋភាគី គួរតែបញ្ចូលពត៌មានអំពីការអនុម័ត ឬការខ្វះវិធានការពិសេសជា បណ្តោះអាសន្ន ដែលមានចែងនៅក្នុងមាត្រា ៤ កឋាខណ្ឌ័ទី១ នៃអនុសញ្ញា ហើយរដ្ឋភាគី គួរតែបញ្ជាក់ អោយបានច្បាស់អំពី "វិធានការពិសេសជាបណ្តោះអាសន្ន" ដើម្បីចៀសវាងការភាន់ច្រលំ។

២៦. រដ្ឋភាគីគួរតែបែងចែកអោយដាច់ពីគ្នារវាងវិធានការពិសេសជាបណ្តោះអាសន្នក្នុងគោល បំណងពន្លឿន ការសំរេចអោយបាននូវគោលដៅម៉ត់ចត់នៃសមភាពជាក់ស្តែង ឬសមភាពចាំបាច់សំរាប់ស្ត្រី ទៅនឹងគោល នយោបាយផ្នែកសង្គមកិច្ចទូទៅផ្សេងៗទៀត ដែលបានអនុម័ត និងអនុវត្ត ដើម្បីធ្វើអោយ ប្រសើរឡើងនូវស្ថាន ភាពរបស់ស្ត្រី និងកុមារី។ រដ្ឋភាគី គួរតែចងចាំថា ពុំមែនគ្រប់វិធានការទាំងអស់ ដែលផ្តោតលើស្ត្រី គឺជាវិធានការ ពិសេសជាបណ្តោះអាសន្ននោះទេ។

២៧. រដ្ឋភាគី គួរតែវិភាគស្ថានភាពរបស់ស្ត្រី នៅក្នុងគ្រប់ផ្នែកទាំងអស់នៃជីវិត ក៏ដូចជាផ្នែក គោលដៅ ជាក់លាក់ នៅពេលអនុវត្តវិធានការពិសេសជាបណ្តោះអាសន្ន ដើម្បីបង្កើនការសំរេចអោយបាន នូវសមភាព

ជាក់ស្តែង ឬសមភាពចាំបាច់សំរាប់ស្ត្រី។ រដ្ឋភាគី គួរតែវាយតំលៃផលប៉ះពាល់នៃវិធានការ ពិសេសជាបណ្តោះអាសន្ន ដោយផ្អែកលើគោលដៅជាពិសេសរបស់រដ្ឋភាគី និងអនុម័តលើវិធានការ ពិសេសជាបណ្តោះអាសន្នទាំងនោះ ទុកជាវិធានការដែលសមស្របបំផុត ដើម្បីពន្លឿនការសំរេចអោយ បាននូវសមភាពជាក់ស្តែង ឬសមភាពចាំបាច់សំរាប់ស្ត្រី។

២៨. រដ្ឋភាគី គួរតែពន្យល់អំពីមូលហេតុក្នុងការជ្រើសរើសយកប្រភេទនៃវិធានការណាមួយ ក្នុងចំណោមប្រភេទផ្សេងៗទៀត។ ការពន្យល់អំពីមូលហេតុដែលត្រូវអនុវត្តវិធានការពិសេសទាំងនោះ គួរតែបញ្ចូលអំពីស្ថានភាពជាក់ស្តែងរបស់ស្ត្រី រួមមានលក្ខខណ្ឌ និងឥទ្ធិពលដែលរៀបចំជីវិត និងឱកាសរបស់ ស្ត្រី - ឬស្ថានភាពរបស់ក្រុមស្ត្រីជាក់លាក់ផ្សេងៗទៀត ដែលរងគ្រោះដោយសាររើសអើងជាច្រើន និង ដែលរដ្ឋភាគីកំពុងតែពន្លឿនតួនាទីរបស់គាត់ អោយបានឆាប់រហ័ស តាមរយៈការអនុវត្តនូវិធានការ ពិសេសជាបណ្តោះអាសន្ន។ ពេលជាមួយគ្នានេះផងដែរ រដ្ឋភាគីគួរតែបញ្ជាក់អោយបានច្បាស់អំពីការពាក់ ពន្ធ័ត្មាវវាងវិធានការពិសេស ជាបណ្តោះអាសន្នទាំងនេះ និងវិធានការទូទៅ ដើម្បីបង្កើនឋានៈតួនាទីរបស់ ស្ត្រី។

២៩. រដ្ឋភាគី គួរតែពន្យល់អោយបានគ្រប់គ្រាន់អំពីការពុំបានអនុម័តលើវិធានការពិសេសជា បណ្តោះអាសន្នណាមួយនោះ។ រដ្ឋភាគីពុំគួរផ្តល់ហេតុផល ដូចជាការខ្វះអំណាច ឬដោយការពន្យល់អំពី ភាពអសកម្មដោយសារតែទីផ្សារដែលកើតមានហើយ ឬដោយសារកំលាំងនយោបាយ ដូចជានៅក្នុង វិស័យឯកជន អង្គការឯកជន ឬគណៈបក្សនយោបាយ ចំពោះការខកខានពុំបានអនុម័តនូវវិធានការ ពិសេសជាបណ្តោះអាសន្ននោះឡើយ។ រដ្ឋភាគី គួរចងចាំមាត្រា ២ នៃអនុសញ្ញា ដែលមាត្រានេះត្រូវ អនុវត្តជាមួយមាត្រាផ្សេងៗទៀតទាំងអស់ - មាត្រានេះចែងអំពីការទទួលខុសត្រូវរបស់រដ្ឋភាគី ចំពោះ ការប្រព្រឹត្តិរបស់អ្នកពាក់ពន្ធ័ទាំងនោះ។

៣០. រដ្ឋភាគី អាចរាយការណ៍អំពីការអនុវត្តនូវិធានការពិសេសជាបណ្តោះអាសន្ននៅក្នុងមាត្រាមួយចំនួន។ នៅក្នុងមាត្រា ២ រដ្ឋភាគី ត្រូវសរសេររបាយការណ៍អំពីវិធានការទាំងនេះដែលបានយកមក អនុវត្តដោយផ្អែកលើគោលការណ៍ច្បាប់ ឬដោយផ្អែកលើមូលដ្ឋានផ្សេងៗទៀត និងហេតុផលចំពោះ ការជ្រើសរើសយកយុទ្ធវិធីពិសេសណាមួយនោះ។ រដ្ឋភាគី ត្រូវរៀបរាប់អោយបានពិស្តារអំពីផ្អែកនីតិច្បាប់ ដែលពាក់ពន្ធ័នឹងវិធានការពិសេសជាបណ្តោះអាសន្ន និងជាពិសេស រៀបរាប់អំពីចំណុចដែលនីតិ ច្បាប់បានចែងអំពីអាណត្តិ ឬការស្មគ្រ័ចិត្តបង្កើតអោយមានវិធានការពិសេសជាបណ្តោះអាសន្ន។

៣១. រដ្ឋភាគី គួរតែរៀបរាប់អំពីស្ថាប័ន ឬនីតិច្បាប់ថ្នាក់ជាតិរបស់ខ្លួន ពាក់ពន្ធ័នឹងការអនុញ្ញាតិ អោយមានការអនុម័តលើវិធានការពិសេសជាបណ្តោះអាសន្ន។ គណៈកម្មាធិការ សុំអោយរដ្ឋភាគីចងចាំថានីតិច្បាប់ មានដូចជាច្បាប់គ្រប់ជ្រុងប្រឆាំងនឹងការរើសអើង ច្បាប់ស្តីពីឱកាសស្មើគ្នា ឬបទបញ្ជា ប្រតិបត្តិស្តីពីសមភាពសំរាប់ស្ត្រី អាចផ្តល់ជាគោលការណ៍ស្តីពីប្រភេទនៃវិធានការពិសេសជាបណ្តោះ អាសន្ន ដែលគួរតែអនុវត្ត ដើម្បីសំរេចគោលដៅដែលបានចែង នៅក្នុងវិស័យនានា។ គោលការណ៍ទាំងនេះ ក៏អាចចែងនៅក្នុងនីតិច្បាប់ជាក់លាក់ស្តីពីការងារ ឬការអប់រំ។ នីតិច្បាប់ពាក់ពន្ធ័ផ្សេងៗទៀតស្តីពី ភាពគ្មានការរើសអើង និងវិធានការពិសេសជាបណ្តោះអាសន្ន គួរតែគ្របដណ្តប់ដល់រដ្ឋាភិបាលដែលពាក់ ពន្ធ័ ក៏ដូចជាអង្គការ ឬសហគ្រាសឯកជន។

៣២. គណៈកម្មាធិការ បានសុំអោយរដ្ឋភាគីចាប់អារម្មណ៍ថា វិធានការពិសេសជាបណ្តោះអាសន្ន អាចយោងទៅលើក្រិត្យ បទបញ្ជាគោលនយោបាយ និង/ឬ គោលការណ៍រដ្ឋបាល ដែលបានរៀបចំឡើង និងអនុម័តដោយអង្គការប្រតិបត្តិថ្នាក់ជាតិ ថ្នាក់តំបន់ ឬថ្នាក់មូលដ្ឋានរបស់រដ្ឋាភិបាល ដើម្បីចែងអំពី ការងារសាធារណ និងវិស័យអប់រំ។ វិធានការពិសេសជាបណ្តោះអាសន្នទាំងនេះ អាចរួមបញ្ចូលទាំង ផ្នែកស៊ីវិល នយោបាយ វិស័យអប់រំឯកជន និងវិស័យការងារ។ គណៈកម្មាធិការ ក៏សុំអោយរដ្ឋភាគីចាប់ អារម្មណ៍ថាវិធានការពិសេសទាំងនេះ អាចយកទៅចរចារជាមួយដៃគូសង្គម នៅក្នុងវិស័យសាធារណ ឬ វិស័យការងារឯកជន ឬអាចយក ទៅអនុវត្តដោយស្មគ្រ័ចិត្ត ដោយសហគ្រាសសាធារណ ឬសហគ្រាស ឯកជន អង្គការ ស្ថាប័ន និងគណៈបក្សនយោបាយ។

៣៣. គណៈកម្មាធិការ រំលឹកឡើងវិញអំពីផែនការសកម្មភាពសំរាប់វិធានការពិសេសជាបណ្តោះ អាសន្ន ដែលចាំបាច់ត្រូវតែរៀបចំ អនុវត្ត និងវាយតំលៃ នៅក្នុងបរិបទថ្នាក់ជាតិជាក់លាក់ និងជីវប្រវត្តិ នៃរូបភាពជាក់លាក់របស់បញ្ហា ដែលរដ្ឋភាគី មានបំណងចង់ជំនះ។ គណៈកម្មាធិការ ផ្តល់អនុសាសន៍ថា រដ្ឋភាគី ត្រូវផ្តល់របាយការណ៍ពិស្តារស្តីពីផែនការសកម្មភាព ដែលមានគោលបំណងផ្តល់ដល់ស្ត្រីនូវឱកាស លទ្ធភាព និងមានគោលបំណងជំនះបញ្ហាដែលស្ត្រីមានតំណាងតិចតួច នៅក្នុងវិស័យជាក់លាក់មួយចំនួន ការបែងចែកធនធាន និងអំណាចឡើងវិញ នៅក្នុងវិស័យជាពិសេស និង/ឬការផ្លាស់ប្តូរនៅក្នុងស្ថាប័ន ដើម្បីជំនះលើការរើសអើងពីអតីតកាល ឬបច្ចុប្បន្នកាល និងដើម្បីពន្លឺនការសំរេចអោយបាននូវសមភាព យេនឌ័រជាក់ស្តែង។ របាយការណ៍ គួរតែពន្យល់ផងដែរ អំពីផែនការសកម្មភាព រួមទាំងផលប៉ះពាល់ដែល នឹងកើតឡើងដោយពុំបានគ្រោងទុក ពីវិធានការពិសេសទាំងនេះ ក៏ដូចជាសកម្មភាពដែលអាចធ្វើទៅបាន ដើម្បីការពារស្ត្រី អោយគេចផុតពីផលប៉ះពាល់ទាំងនេះ។ រដ្ឋភាគី គួរតែរៀបរាប់នៅក្នុងរបាយការណ៍ របស់ខ្លួននូវលទ្ធផលនៃវិធានការពិសេសជាបណ្តោះអាសន្ន និងការប៉ាន់ប្រមាណអំពីបុព្វហេតុដែលធ្វើ អោយការអនុវត្តវិធានការទាំងនេះ ពុំអាចសំរេចទៅបាន។

៣៤. នៅក្នុងមាត្រា ៣ រដ្ឋភាគីត្រូវសរសេររបាយការណ៍អំពីស្ថាប័នដែលមានតួនាទីទទួលខុសត្រូវក្នុងការរៀបចំ ការអនុវត្តន៍ ការត្រួតពិនិត្យ ការវាយតំលៃ និងការពង្រឹងការអនុវត្តន៍វិធានការពិសេសជាបណ្ដោះអាសន្នទាំងនេះ។ អាណត្តិស្ថាប័នថ្នាក់ជាតិដែលមានស្រាប់ ឬស្ថាប័នដែលនឹងបង្កើតឡើង ដូចជាក្រសួងនារី នាយកដ្ឋាននារី ដែលមាននៅក្នុងបណ្ដាក្រសួងនានា ឬការិយាល័យប្រធានាធិបតេយ្យ អ្នកអង្កេតរឿងក្ដីតុលាការ ឬស្ថាប័នសាធារណ ឬឯកជនផ្សេងៗទៀត មានតួនាទីរៀបចំកម្មវិធីជាក់លាក់ ត្រួតពិនិត្យការអនុវត្តន៍កម្មវិធីទាំងនោះ និងវាយតំលៃផលប៉ះពាល់ និងលទ្ធផលនៃកម្មវិធីទាំងនោះ។ គណៈកម្មាធិការ បានផ្ដល់អនុសាសន៍ថា រដ្ឋភាគី ត្រូវធានាថាស្ត្រីជាទូទៅ និងក្រុមស្ត្រីដែលរង គ្រោះជាពិសេស បានចូលរួមនៅក្នុងការរៀបចំការអនុវត្តន៍ និងការវាយតំលៃកម្មវិធីទាំងនេះ។ គណៈកម្មាធិការ បានសំណូមពរអោយមានការសហការនិងការពិគ្រោះយោបល់ជាពិសេសជាមួយសង្គម ស៊ីវិល និងអង្គការក្រៅរដ្ឋាភិបាល ដែលតំណាងអោយក្រុមស្ត្រីផ្សេងៗទៀត។

៣៥. គណៈកម្មាធិការ បានសុំអោយមានការចាប់អារម្មណ៍ និងរំលឹកឡើងវិញអំពីអនុសាសន៍ទូទៅ លេខ៩ ស្ដីពីទិន្នន័យស្ថិតិ ពាក់ពន្ធ័នឹងស្ថានភាពរបស់ស្ត្រី និងសំណូមពរអោយរដ្ឋភាគី ផ្ដល់ទិន្នន័យបែង ចែកតាមភេទ ដើម្បីវាយស្ទង់ការរីកចំរើនដែលទទួលបាន ឆ្ពោះទៅរកសមភាពជាក់ស្ដែង ឬសមភាព ចាំបាច់សំរាប់ស្ត្រី និងប្រសិទ្ធភាពនៃវិធានការពិសេសជាបណ្ដោះអាសន្ន។

៣៦. រដ្ឋភាគី គួរតែរាយការណ៍អំពីប្រភេទនៃវិធានការពិសេសជាបណ្ដោះអាសន្ន ដែលបានអនុវត្តនៅក្នុងវិស័យជាក់លាក់មួយចំនួន នៅក្នុងមាត្រាពាក់ពន្ធ័មួយចំនួននៅក្នុងអនុសញ្ញា។ ការរាយការណ៍នៅក្នុងមាត្រានីមួយៗ គួរតែរៀបរាប់អំពីទិសដៅ និងគោលដៅម៉ត់ចត់ ពេលវេលាច្បាស់លាស់ មូលហេតុ ក្នុងការជ្រើសរើសវិធានការពិសេសណាមួយ ឬជំហានដើម្បីអោយស្ត្រីមានលទ្ធភាពទទួលបានផលពីវិធានការពិសេសទាំងនេះ និងរៀបរាប់អំពីស្ថាប័នដែលមានតួនាទីទទួលខុសត្រូវក្នុងការត្រួតពិនិត្យការអនុវត្តន៍ និងការរីកចំរើន។ រដ្ឋភាគី ក៏ត្រូវរៀបរាប់ផងដែរ ថាតើស្ត្រីប៉ុន្មាននាក់ដែលទទួលការប៉ះពាល់ដោយសារ វិធានការទាំងនេះ តើស្ត្រីប៉ុន្មាននាក់នឹងអាចទទួលបានឱកាស និងចូលរួមនៅក្នុងវិស័យជាក់លាក់មួយ ចំនួន ដោយសារតែការអនុវត្តន៍វិធានការពិសេសទាំងនេះ ឬតើធនធាន និងអំណាចដែលវិធានការ ពិសេសទាំងនេះ នឹងធ្វើការបែងចែកឡើងវិញដល់ស្ត្រីចំនួនប៉ុន្មាននាក់ និងក្នុងរយៈពេលប៉ុន្មានដែរ។

៣៧. គណៈកម្មាធិការ បានរំលឹកឡើងវិញនូវអនុសាសន៍ទូទៅលេខ ៥, ៨ និង ២៣ ដែលក្នុងនោះមានការសំណូមពរអោយមានការអនុវត្តន៍វិធានការពិសេសជាបណ្តោះអាសន្ន នៅក្នុងវិស័យអប់រំ សេដ្ឋកិច្ច នយោបាយ និងការងារ នៅក្នុងវិស័យដែលស្ត្រីត្រូវទៅតំណាងអោយរដ្ឋាភិបាលនៅក្នុងកំរិតអន្តរជាតិ និងចូលរួមនៅក្នុងអង្គការអន្តរជាតិ និងនៅក្នុងវិស័យនយោបាយ និងសាធារណៈ។ រដ្ឋភាគីគួរ តែបញ្ជាក់អោយបានច្បាស់លាស់ - ដោយស្របទៅតាមបរិបទថ្នាក់ជាតិ - អំពីការខិតខំប្រឹងប្រែងជា ពិសេសវិស័យអប់រំនៅគ្រប់កំរិតក៏ដូចជាគ្រប់កំរិតនៃការបណ្តុះបណ្តាលការងារ និងការតំណាងនៅក្នុងវិស័យសាធារណៈ និងនយោបាយ។ គណៈកម្មាធិការ បានសំណូមពរថា នៅក្នុងគ្រប់កំរិតទាំងអស់ ជាពិសេសនៅក្នុងវិស័យសុខាភិបាល រដ្ឋភាគីគួរតែបែងចែកអោយបានដាច់ពីគ្នានៅក្នុងវិស័យនីមួយៗ រវាងវិធានការអចិន្ត្រៃយ៍ដែលកំពុងតែអនុវត្ត និងវិធានការពិសេសជាបណ្តោះអាសន្ន។

៣៨. រដ្ឋភាគី គួរតែចងចាំថា វិធានការពិសេសជាបណ្តោះអាសន្ន គួរតែអនុម័ត ដើម្បីពន្លឺនការ ផ្លាស់ប្តូរ និងការលុបបំបាត់ការអនុវត្តន៍ផ្នែកវប្បធម៌ ឥរិយាបថ និងអាកប្បកិរិយាខុសឆ្គងដែលរើសអើង ប្រឆាំងនឹងស្ត្រី ឬធ្វើអោយស្ត្រីបាត់បង់ផលប្រយោជន៍។ វិធានការពិសេសជាបណ្តោះអាសន្ន គួរតែអនុវត្ត នៅក្នុងផ្នែកឥណទាន និងប្រាក់កម្ចី កីឡា វប្បធម៌ និងសកម្មភាពកំសាន្ត និងការផ្សព្វផ្សាយផ្នែកច្បាប់។ នៅកន្លែងដែលចាំបាច់វិធានការទាំងនេះ ត្រូវដាក់គោលដៅទៅលើស្ត្រី ដែលទទួលរងការរើសអើងច្រើន រួមមានស្ត្រីនៅជនបទ ជាដើម។

៣៩. ទោះបីជាយ៉ាងណាក៏ដោយ ការអនុវត្តន៍វិធានការពិសេសជាបណ្តោះអាសន្ន ពុំអាចធ្វើទៅបាននៅក្នុងគ្រប់មាត្រាទាំងអស់នៅក្នុងអនុសញ្ញានោះឡើយ ប៉ុន្តែគណៈកម្មាធិការ បានផ្តល់អនុសាសន៍ថាការអនុម័តលើវិធានការពិសេសជាបណ្តោះអាសន្ន គួរតែពិចារណាដល់ការពន្លឺនឱកាសស្មើភាពក្នុងការ ចូលរួម និងម្យ៉ាងទៀតដើម្បីពន្លឺនដល់ដំណើរការការបែងចែកឡើងវិញនូវអំណាច និងធនធាន ក៏ដូចជា ត្រូវពិចារណាថាតើវិធានការទាំងនេះ ជាវិធានការចាំបាច់ និងសមស្របបំផុត នៅក្នុងកាលៈទេសៈនោះ ដែរឬទេ។

## កត់សំគាល់

១. ការរើសអើងដោយប្រយោលប្រឆាំងនឹងស្ត្រី អាចកើតមាននៅក្នុងច្បាប់ គោលនយោបាយ និងកម្មវិធីនានា ដែលផ្អែកលើលក្ខន្តិកអព្យាក្រិតយេនឌ័រ ហើយលក្ខន្តិកនេះប៉ះពាល់លើស្ត្រី។ ច្បាប់គោលនយោបាយ និងកម្មវិធីដែលប្រកាន់យកអព្យាក្រិតយេនឌ័រ អាចបន្តផ្តល់ដល់ស្ត្រីនូវផលវិបាកនៃ ការរើសអើងពីអតីតកាល (ទោះបីជាគ្មានបំណងក៏ដោយ)។ គោលនយោបាយ និងកម្មវិធីទាំងនេះ អាច នឹងត្រូវបានរៀបចំឡើង ទៅតាមបែបបទរបស់បុរស ដូច្នេះហើយពុំបានពិចារណាដល់រូបភាពនៃបទ ពិសោធន៍ជីវិតរបស់ស្ត្រី ដែលមានលក្ខណៈខុសពីបុរស។ ភាពខុសគ្នាទាំងនេះ អាចកើតមានឡើង ដោយ សារតែការរំពឹងទុកនៃផ្នត់គំនិតចាស់ ឥរិយាបថ

និងអាកប្បកិរិយា ដែលមានចំពោះស្ត្រី ដោយសារតែ ភាពខុសគ្នារវាងស្ត្រី និងបុរស។ ភាពខុសគ្នាទាំងនេះ អាចកើតមានឡើង ដោយសារតែភាពត្រួតត្រា (ដែលកើតមានរួចមកហើយ) របស់បុរសទៅលើស្ត្រី។

២. "យេនឌ័រ ត្រូវបានកំណត់ជាអត្ថន័យរបស់សង្គម ដែលផ្តល់ចំពោះភាពខុសគ្នានៃភេទ តាមផ្នែកជីវសាស្ត្រ។ យេនឌ័រ គឺកើតឡើងដោយមនោគមវិទ្យា និងវប្បធម៌ ប៉ុន្តែពាក្យយេនឌ័រ ក៏ត្រូវបានកំណត់ឡើងវិញក្នុងបរិបទនៃការអនុវត្តន៍ជាក់ស្តែង ហើយត្រឡប់មកវិញ គឺយេនឌ័រ ធ្វើអោយមានឥទ្ធិពលលើលទ្ធផលនៃការអនុវត្តន៍ទាំងនេះ។ យេនឌ័រ មានឥទ្ធិពលទៅលើការបែងចែកធនធាន ទ្រព្យ សម្បត្តិ ការងារ ការធ្វើសេចក្តីសំរេច និងអំណាចផ្នែកនយោបាយ និងការទទួលបានសិទ្ធិ និងសិទ្ធិនៅក្នុង គ្រួសារ ក៏ដូចជាជីវិតសាធារណ។ ទោះបីជាមានភាពខុសគ្នានៃវប្បធម៌ ឬពេលវេលា ប៉ុន្តែទំនាក់ទំនង យេនឌ័រ នៅទូទាំងពិភពលោក ទោះបីជាទៅដល់កន្លែងណាក៏ដោយ ក៏សំដៅដល់អំណាចរវាងបុរស និងស្ត្រី។ ដូច្នេះហើយ យេនឌ័រ គឺការកំណត់នៅក្នុងសង្គម ហើយក្នុងន័យនេះ យេនឌ័រ គឺប្រហាក់ប្រហែលទៅនឹង ការកំណត់ផ្សេងៗទៀត ដូចជាពូជសាសន៍ ឋានៈ ជនជាតិភាគតិច ភេទ និងអាយុ។ យេនឌ័រ ជួយយើងអោយយល់ អំពីការរៀបចំរបស់សង្គមចំពោះអត្តសញ្ញាណយេនឌ័រ និងរចនាសម្ព័ន្ធអំណាចតែមួយ ដែលនិយាយអំពី ទំនាក់ទំនងរវាងភេទ" ការអង្កេតពិភពលោកឆ្នាំ១៩៩៩ ស្តីពីតួនាទីរបស់ស្ត្រីនៅក្នុងកិច្ចអភិវឌ្ឍន៍ អង្គការសហប្រជាជាតិ ទីក្រុងញូយ៉ក ឆ្នាំ១៩៩៩ ទំព័រទី ix។

៣. ឧទាហរណ៍ សូមអានអនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជ សាសន៍ ដែលបានចែងអំពីវិធានការពិសេសជាបណ្តោះអាសន្ន។ ការបង្កើតសាប័នត្រួតពិនិត្យលើការ អនុវត្តន៍សន្ធិសញ្ញា មានដូចជាគណៈកម្មាធិការស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ គណៈកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងគណៈកម្មាធិការសិទ្ធិមនុស្ស បានបង្ហាញអោយឃើញថា គណៈកម្មាធិការទាំងនេះ បានចាត់ទុកការអនុវត្តន៍វិធានការពិសេសជាបណ្តោះអាសន្ន ទៅជាអាណត្តិ ដើម្បីសំរេចគោលបំណងរបស់សន្ធិសញ្ញានីមួយៗ។ អនុសញ្ញា ដែលត្រូវបានអនុម័តដោយមានការគាំទ្ររបស់អង្គការពលកម្មអន្តរជាតិ និងឯកសារផ្សេងៗទៀត របស់អង្គការសហប្រជាជាតិស្តីពី ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ ក៏បានបង្ហាញអំពីការអនុវត្តន៍វិធានការទាំងនេះផងដែរ។ អនុគណៈ-កម្មការស្តីពីការលើកកំពស់ និងការពារសិទ្ធិមនុស្ស មានការយកចិត្តទុកដាក់លើបញ្ហានេះ និងបានតែងតាំងអ្នករាយការណ៍ពិសេស១រូប ដើម្បីរៀបចំរបាយការណ៍សំរាប់ការពិចារណា និងធ្វើសកម្មភាព។ គណៈកម្មការស្តីពីស្ថានភាពស្ត្រី បានពិនិត្យមើលឡើងវិញនូវវិធានការពិសេសជាបណ្តោះអាសន្ន នៅក្នុងឆ្នាំ១៩៩២។ ឯកសារដែលជាលទ្ធផលនៃការពិនិត្យឡើងវិញនេះ ត្រូវបានអនុម័តនៅក្នុងសន្និបាតពិភព

លោកស្តីពីស្រ្តីរបស់អង្គការសហប្រជាជាតិ រួមទាំងផែនការសកម្មភាពនៅទីក្រុងប៉េកាំង នៅក្នុងសន្និបាតពិភពលោកលើកទី៤ ស្តីពីស្រ្តី ក្នុងឆ្នាំ១៩៩៥ និងសន្និបាតពិនិត្យឡើងវិញ ក្នុងឆ្នាំ២០០០ បានចែងអំពីសកម្មភាពវិជ្ជមាន ជាឧបករណ៍សំរាប់សំរេចអោយបាននូវសមភាពជាក់ស្តែង។ ការប្រើប្រាស់វិធានការពិសេសជាបណ្តោះអាសន្ន ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ គឺជាឧទាហរណ៍ជាក់ស្តែងនៅក្នុងវិស័យការងាររបស់ស្រ្តី រួមទាំងស្ថាប័នរដ្ឋបាលទទួលបន្ទុកក្នុងការជ្រើសរើសបុគ្គលិក ការលើក កំពស់ និងការតែងតាំងស្រ្តី នៅក្នុងលេខាធិការដ្ឋាន។ វិធានការទាំងនេះ មានគោលបំណងសំរេចអោយ បាននូវគោលដៅ ៥០/៥០ នៅក្នុងគ្រប់កំរិតទាំងអស់ ប៉ុន្តែជាពិសេសនៅកំរិតថ្នាក់ខ្ពស់។

៤. ពាក្យ "សកម្មភាពជាវិជ្ជមាន" ត្រូវបានប្រើប្រាស់នៅក្នុងសហរដ្ឋអាមេរិច និងនៅក្នុងឯកសាររបស់អង្គការសហប្រជាជាតិមួយចំនួន ប៉ុន្តែនៅកន្លែងខ្លះ ដូចជាអឺរ៉ុប ក៏ដូចជានៅក្នុងឯកសាររបស់អង្គការសហប្រជាជាតិជាច្រើនទៀត ជាទូទៅប្រើពាក្យ "សកម្មភាពវិជ្ជមាន"។ ទោះបីជាយ៉ាងណាក៏ ដោយពាក្យ "សកម្មភាពវិជ្ជមាន" នៅតែត្រូវបានយកទៅប្រើប្រាស់នៅក្នុងច្បាប់សិទ្ធិមនុស្ស ក្នុងន័យ "សកម្មភាពវិជ្ជមានរបស់រដ្ឋ" (កាតព្វកិច្ចរបស់រដ្ឋក្នុងការរៀបចំសកម្មភាពប្រឆាំងនឹងភាពអសកម្ម)។ ដូច្នេះពាក្យ "សកម្មភាពវិជ្ជមាន" មានអត្ថន័យច្រើន ព្រោះថាពាក្យនេះ ពុំទាន់ត្រូវបានកំណត់សំរាប់តែវិធានការពិសេសជាបណ្តោះអាសន្ន ដូចចែងនៅក្នុងមាត្រា ៤ កឋាខណ្ឌទី១ នៃអនុសញ្ញា នៅឡើយទេ។ ពាក្យ "ការរើសអើង" ឬ "ការរើសអើងជាវិជ្ជមាន" ត្រូវបានទទួលការរិះគន់ពីសំណាក់អ្នករិះគន់មួយ ចំនួនថាជាពាក្យពុំសមស្រប។

# អនុសាសន៍ទូទៅលេខ ២៦
# ស្តីពីស្ត្រីជាកម្មករចំណាកស្រុក

## សេចក្តីផ្តើម

១. ក្នុងកិច្ចប្រជុំលើកទី៣២ (ខែមករា ឆ្នាំ២០០៥) គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើនារីភេទ (គណៈកម្មាធិការ) បានសម្រេចដាក់ចេញនូវអនុសាសន៍ទូទៅសម្រាប់ក្រុមស្ត្រីជាកម្មករចំណាកស្រុក ដែលអាចប្រឈម នឹងការរំលោភ និងការរើសអើង ដោយបានលើកឡើងថា ស្ត្រីជាកម្មករចំណាកស្រុក ក៏ដូចជាស្ត្រីគ្រប់រូបដែរ មិនគួរទទួលរង ការរើសអើងក្នុងបរិយាកាសរស់នៅរបស់ខ្លួនឡើយ យោងតាមមាត្រា២១នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការ រើសអើងប្រឆាំងនឹងនារីភេទ (អនុសញ្ញា)។

២. អនុសាសន៍ទូទៅនេះ មានបំណងរួមចំណែកធ្វើឱ្យសម្រេចកាតព្វកិច្ចរបស់រដ្ឋជាភាគី ក្នុងការគោរព ការពារ និងឆ្លើយ តបទៅនឹងសិទ្ធិស្ត្រីជាកម្មករចំណាកស្រុក ព្រមទាំងកាតព្វកិច្ចស្របច្បាប់ដែលមានចែងក្នុងសន្ធិសញ្ញាផ្សេងទៀត ការតាំង ចិត្តចំពោះផែនការសកម្មភាពសម្រាប់សន្និសីទពិភពលោក និងការងារសំខាន់ៗរបស់ស្ថាប័នសន្ធិសញ្ញាផ្តោតលើការធ្វើ ចំណាកស្រុក ជាពិសេសគណៈកម្មាធិការទទួលបន្ទុកការការពារសិទ្ធិរបស់កម្មករចំណាកស្រុកទាំងអស់ និងសមាជិក គ្រួសារ របស់កម្មករចំណាកស្រុក។ តាមការកត់សម្គាល់ អនុសញ្ញាអន្តរជាតិស្តីពីការការពារសិទ្ធិរបស់កម្មករចំណាកស្រុកទាំង អស់ និងសមាជិកគ្រួសាររបស់កម្មករចំណាកស្រុក មិនត្រឹមតែការពារបុគ្គលម្នាក់ៗ រួមទាំងស្ត្រីជាកម្មករចំណាកស្រុក ដោយផ្អែកលើស្ថានភាពធ្វើចំណាកស្រុកប៉ុណ្ណោះទេ អនុសញ្ញានេះ ក៏ការពារស្ត្រីរួមទាំងស្ត្រីជាកម្មករចំណាកស្រុក ពីការរើសអើងទាក់ទងនឹងភេទ និងយេនឌ័រ។ ទោះបីជាការធ្វើចំណាកស្រុកផ្តល់ឱកាសថ្មីៗជាច្រើនដល់ស្ត្រី និងអាចជាមធ្យោបាយមួយ សម្រាប់ផ្តល់សិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីតាមរយៈការចូលរួមរបស់ស្ត្រីក៏ដោយ ប៉ុន្តែការធ្វើចំណាក ស្រុកក៏អាចនឹងធ្វើឱ្យសិទ្ធិស្ត្រី និងសន្តិសុខរបស់ស្ត្រី ស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ដែរ។ ដូច្នេះ អនុសាសន៍ទូទៅនេះមានគោលបំណងអធិប្បាយអំពីស្ថានភាពដែលធ្វើឱ្យស្ត្រីជាកម្មករចំណាកស្រុកទទួលរងគ្រោះថ្នាក់មួយចំនួន និងអំពីបទពិសោធន៍របស់ ស្ត្រីជាកម្មករដែលរងគ្រោះពីការរើសអើងទាក់ទងនឹងភេទ និងយេនឌ័រ ដែលនាំដល់ការរំលោភសិទ្ធិរបស់ស្ត្រី។

៣. ទោះបីរដ្ឋជាច្រើនមានសិទ្ធិត្រួតពិនិត្យតាមព្រំដែន និងគ្រប់គ្រងលើការធ្វើចំណាកស្រុកក៏ដោយ ប៉ុន្តែរដ្ឋទាំងនោះ ត្រូវអនុវត្ត ការត្រួតពិនិត្យ និងការគ្រប់គ្រង ស្របតាមកាតព្វកិច្ចរបស់ខ្លួនឱ្យបានពេញលេញ

ក្នុងនាមជាភាគីនៃសន្ធិសញ្ញាស្តីពីសិទ្ធិ មនុស្ស ដែលរដ្ឋទាំងនោះ បានផ្តល់សច្ចាប័ន ឬយល់ស្របអនុវត្តតាម។ សន្ធិសញ្ញានេះ រួមបញ្ចូលទាំងការផ្សព្វផ្សាយនីតិវិធី ធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងលើកកម្ពស់កាតព្វកិច្ចរបស់រដ្ឋជាភាគី ក្នុងការគោរព ការពារ និងឆ្លើយតបនឹង សិទ្ធិរបស់ស្ត្រីតាមរយៈ ខួបធ្វើចំណាកស្រុក។ កាតព្វកិច្ចទាំងនោះ ត្រូវអនុវត្តដោយទទួលស្គាល់ការរួមចំណែករបស់ស្ត្រីជាកម្មករចំណាកស្រុក ក្នុងសង្គម និងសេដ្ឋកិច្ច ដើម្បីជួយដល់ប្រទេសរបស់ខ្លួន និងប្រទេសគោលដៅ រួមបញ្ចូលទាំងការងារ ថែទាំ និងការងារបម្រើតាមផ្ទះ។

៤. គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ទទួលស្គាល់ថា ស្ត្រីជាកម្មករចំណាកស្រុកអាច បែងចែកជាច្រើនក្រុម អាស្រ័យលើកត្តាជំរុញឱ្យស្ត្រីធ្វើចំណាកស្រុក គោលបំណងនៃការធ្វើចំណាកស្រុក និងសិទ្ធិស្នាក់នៅរួមគ្នា ការប្រឈមនឹងគ្រោះថ្នាក់ និងការរំលោភ ឋានៈដែលស្ត្រីទទួលបាននៅប្រទេសដែលខ្លួនបានធ្វើចំណាកស្រុកទៅ ព្រមទាំងលទ្ធភាពនៃការទទួលបានសញ្ជាតិ។ ម្យ៉ាងវិញទៀត គណៈកម្មាធិការនេះ ក៏ទទួលស្គាល់ថា ការបែងចែក ក្រុមស្ត្រីជាកម្មករចំណាកស្រុកទាំងនេះ មិនមានភាពច្បាស់លាស់ និងមានលក្ខណៈដូចគ្នាច្រើន ដូច្នេះនាំឱ្យមាន ការលំបាកដល់ការញែកជាក្រុមឱ្យបានច្បាស់លាស់។ ដូចនេះ អនុសាសន៍ទូទៅនេះ មានវិសាលភាពផ្តោះបញ្ចាំងតែទៅលើ ស្ថានភាព របស់ក្រុមស្ត្រីជាកម្មករចំណាកស្រុក (កម្មករ) ដែលធ្វើការងារ ទទួលបានប្រាក់កម្រៃទាបហើយអាចប្រឈមនឹងគ្រោះ ថ្នាក់ខ្ពស់នៃការបំពាន និងការរើសអើស និងជាស្ត្រីកម្មករចំណាកស្រុកដែលអាចមិនទាមទារសិទ្ធិទទួលបានការស្នាក់នៅជា អចិន្ត្រៃយ៍ ឬទទួលបានសញ្ជាតិដែលបើកចំហសម្រាប់កម្មករ ចំណាកស្រុកដែលមានជំនាញវិជ្ជាជីវៈ នៅប្រទេសផ្តល់ការងារ ឡើយ។ ក្នុងករណីនេះ ស្ត្រីជាកម្មករ ចំណាកស្រុកទាំងនោះ អាចមិនទទួលបានការការពារពីច្បាប់របស់ ប្រទេសពាក់ព័ន្ធ ឡើយ ទាំង*តាមផ្លូវច្បាប់* ទាំង*តាមស្ថានភាពជាក់ស្តែង*។ ប្រភេទនៃក្រុមស្ត្រីជាកម្មករចំណាកស្រុក មានដូចខាង ក្រោម ៖

- ស្ត្រីជាកម្មករចំណាកស្រុក ដែលធ្វើចំណាកស្រុកដោយឯករាជ្យ
- ស្ត្រីជាកម្មករចំណាកស្រុក ដែលធ្វើចំណាកស្រុករួមជាមួយស្វាមីរបស់ខ្លួន ឬសមាជិកផ្សេងទៀតក្នុងគ្រួសាររបស់ខ្លួន ដែលអ្នកទាំងនោះក៏ជាកម្មករផងដែរ
- ស្ត្រីជាកម្មករចំណាកស្រុកដែលមិនមានឯកសារត្រឹមត្រូវ សម្រាប់បញ្ជាក់ពីការធ្វើចំណាកស្រុករបស់ខ្លួន ហើយអាចស្ថិតក្នុងក្រុមណាមួយក្នុងចំណោមក្រុមទាំងពីរខាងលើ។

ទោះជាយ៉ាងនេះក្តី គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ សង្កត់ធ្ងន់ថា ស្ត្រីជាកម្មករ ចំណាកស្រុកគ្រប់ប្រភេទទាំងអស់ ត្រូវរាប់បញ្ចូលក្នុងដែនកាតព្វកិច្ចរបស់រដ្ឋជាភាគីនៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ហើយស្ត្រីត្រូវទទួលបានការការពារពីរាល់ទម្រង់នៃការរើសអើងគ្រប់ប្រភេទពី អនុសញ្ញានេះ។

៥. ទោះបីការធ្វើចំណាកស្រុក មានទាំងបុរស ទាំងស្ត្រីក៏ដោយ ប៉ុន្តែការធ្វើចំណាកស្រុកនេះ មិនមែនជាបាតុភូតដែលមាន សមភាពយេនឌ័រឡើយ។ ស្ត្រីជាជនចំណាកស្រុក ស្ថិតក្នុងស្ថានភាពខុសពីបុរស បើគិតទៅលើមធ្យោបាយធ្វើចំណាកស្រុក ដោយស្របច្បាប់ វិស័យការងាររបស់ស្ត្រីធ្វើចំណាកស្រុក ទម្រង់នៃការបំពាន និងផលវិបាកបណ្តាលមកពីការធ្វើចំណាក ស្រុក។ ដើម្បីយល់ពីរបៀបជាក់លាក់នៃផលប៉ះពាល់ពីការធ្វើចំណាកស្រុក មកលើស្ត្រីជាជនចំណាកស្រុក ការសិក្សាអំពី ការធ្វើចំណាកស្រុករបស់ស្ត្រីគួរផ្តោតលើទិដ្ឋភាពវិសមភាពយេនឌ័រ តួនាទីរបស់ស្ត្រីតាំងពីបុរាណកាល ទីផ្សារការងារ បែងចែងតាមយេនឌ័រ ប្រេវ៉ាឡង់ជាសកលនៃអំពើហិង្សាផ្អែកលើយេនឌ័រ និងគោលនយោបាយជា សកលដោយផ្តោតការ យកចិត្តទុកដាក់ទៅលើការធ្វើចំណាកស្រុករបស់ស្ត្រី ដោយសារបញ្ហាភាពក្រីក្រ និងការងារ។ ដូច្នេះ ការរួមបញ្ចូលគ្នានូវ ទិដ្ឋភាពយេនឌ័រ គឺពិតជាសំខាន់ចាំបាច់ណាស់ សម្រាប់ការវិភាគអំពីស្ថានភាពរបស់ស្ត្រីជាជនចំណាកស្រុក និងការបង្កើត គោលនយោបាយ ដើម្បីប្រឆាំងនឹងការរើសអើង ការកេងប្រវ័ញ្ច និងការបំពានមកលើស្ត្រី។

**ការអនុវត្តគោលការណ៍ស្តីពីសិទ្ធិមនុស្ស និងសមភាពយេនឌ័រ**

៦. ស្ត្រីជាកម្មករចំណាកស្រុកទាំងអស់ ត្រូវទទួលបានការការពារសិទ្ធិរបស់ខ្លួន ដោយរាប់បញ្ចូលទាំងសិទ្ធិរស់រានមានជីវិត សិទ្ធិ ទទួលបានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន សិទ្ធិរួចផុតពីការធ្វើទារុណកម្ម សិទ្ធិរួចផុតពីការបង្ខូចកិត្តិយស និងអំពើ អមនុស្សធម៌ សិទ្ធិរួចផុតពីការរើសអើង ផ្អែកលើភេទ ពូជសាសន៍ ជាតិពន្ធុ លក្ខណៈពិសេសនៃវប្បធម៌ សញ្ជាតិ ភាសា សាសនា ឬលក្ខណៈផ្សេងៗទៀត សិទ្ធិរួចផុតពីភាពក្រីក្រ និងសិទ្ធិទទួលបានការរស់នៅសមស្រប និងសិទ្ធិស្មើគ្នានៅ ចំពោះមុខច្បាប់ និងសិទ្ធិទទួលបានអត្ថប្រយោជន៍ពីនីតិវិធីត្រឹមត្រូវស្របច្បាប់។ សិទ្ធិទាំងនេះ មានចែងក្នុងសេចក្តីប្រកាស ជាសកលស្តីពីសិទ្ធិមនុស្ស និងសន្ធិសញ្ញាស្តីពីសិទ្ធិមនុស្ស ដែលផ្តល់សច្ចាប័ន និងយល់ស្របអនុម័តតាមបណ្តារដ្ឋជាសមាជិករបស់អង្គការសហប្រជាជាតិ។

៧. ស្ត្រីជាកម្មករចំណាកស្រុក ក៏ទទួលសិទ្ធិការពារពីការរើសអើង ដោយផ្អែកលើសន្ធិសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទដែលតម្រូវឱ្យរដ្ឋជាភាគីចាត់វិធានការ សមស្របជាបន្ទាន់ ដើម្បីលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ និងធានាថា ស្ត្រីអាចប្រើប្រាស់

សិទ្ធិរបស់ខ្លួន និងទទួលបានសិទ្ធិស្មើគ្នាចំពោះបុរសដោយស្របច្បាប់ និងជាក់ស្តែងនៅគ្រប់ផ្នែកទាំងអស់។

**កត្តានានាដែលជះឥទ្ធិពលដល់ការធ្វើចំណាកស្រុករបស់ស្ត្រី**

៨. នាពេលបច្ចុប្បន្ននេះ ស្ត្រីមានចំនួនប្រហែលជាពាក់កណ្តាលនៃចំនួនជនចំណាកស្រុកនៅលើពិភពលោក។ កត្តានាំដល់ការធ្វើ ចំណាកស្រុកស្ត្រី មានដូចជា សកលភាវូបនីយកម្ម ការស្វែងរកឱកាសថ្មីៗ ភាពក្រីក្រ ទំនៀមទម្លាប់វប្បធម៌តាមយេនឌ័រ និងអំពើហិង្សា ទាក់ទងនឹងយេនឌ័រនៅប្រទេសដើមកំណើត គ្រោះមហន្តរាយធម្មជាតិ ឬសង្គ្រាម ព្រមទាំងជម្លោះផ្ទៃក្នុងជួរ កងទ័ព។ កត្តាទាំងនេះក៏រួមបញ្ចូលទាំងស្ថានភាពកាន់តែធ្ងន់ធ្ងរនៃការបែងចែកការងារជាក់លាក់ដោយកំណត់លើភេទ ក្នុងវិស័យកម្មន្តសាល និងសេវាផ្លូវការ និងក្រៅផ្លូវការ នៅប្រទេសគោលដៅ រួមទាំងវប្បធម៌បម្រើការកំសាន្តសប្បាយរបស់ បុរស ដែលវប្បធម៌នោះបង្កើតឱ្យមានតម្រូវការស្ត្រីសម្រាប់បម្រើការសប្បាយកាន់តែច្រើនឡើងៗ។ តាមការកត់សម្គាល់ បង្ហាញថា ការកើនឡើងយ៉ាងខ្លាំងនូវចំនួនស្ត្រីធ្វើចំណាកស្រុកតែម្នាក់ឯង ដើម្បីស្វែងរកប្រាក់កម្រៃ ជាផ្នែកមួយនៃនិន្នាការនេះ។

**កង្វល់ចំពោះសិទ្ធិមនុស្សផ្អែកតាមភេទ និងយេនឌ័រ ទាក់ទងនឹងស្ត្រីជាជនចំណាកស្រុក**

៩. ដោយសារការរំលោភសិទ្ធិរបស់ស្ត្រីជាកម្មករចំណាកស្រុក កើតមានឡើងនៅប្រទេសដើមកំណើតប្រទេសដែលស្ត្រីទាំង នោះឆ្លងកាត់ និងប្រទេសគោលដៅ អនុសាសន៍ទូទៅនេះ បង្ហាញរាល់បញ្ហាដែលកើតមានឡើងនៅត្រង់ចំណុចទាំងបីនេះ ដើម្បីសម្របសម្រួលដល់ការប្រើប្រាស់អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ និងដើម្បី បន្តលើកកម្ពស់សិទ្ធិរបស់ស្ត្រីជាកម្មករចំណាកស្រុក និងលើកកម្ពស់ភាពស្មើគ្នារវាងបុរស និងស្ត្រីដែលមានសារៈសំខាន់នៅ គ្រប់ផ្នែកនៃការរស់នៅរបស់ស្ត្រី។ តាមការរំលឹកឡើងវិញ ការធ្វើចំណាកស្រុក ជាបាតុភូតសកលដែលកើតឡើងតៗគ្នា ដែលតម្រូវឱ្យមានកិច្ចសហប្រតិបត្តិការក្នុងចំណោមរដ្ឋពហុភាគីទ្វេភាគី និងថ្នាក់តំបន់។

១០. <u>នៅប្រទេសដើមកំណើត មុនពេលធ្វើចំណាកស្រុក</u>

ទោះបីជាមុនពេលធ្វើចំណាកស្រុកក៏ដោយ ក៏ស្ត្រីជាកម្មករចំណាកស្រុក ប្រឈមនឹងក្តីកង្វល់ជាច្រើនទាក់ទងនឹងសិទ្ធិមនុស្ស រួមបញ្ចូលទាំងការហាមឃាត់ និងការដាក់កម្រិតសព្វបែបយ៉ាងទៅលើការធ្វើចំណាកស្រុករបស់ខ្លួន ផ្អែកលើភេទ ឬភេទ និងអាយុ ស្ថានភាពអាពាហ៍ពិពាហ៍ ឬការមានគភ៌ ឬស្ថានភាពមាតុភាព ការដាក់កម្រិត ជាក់លាក់លើមុខរបរ ឬលក្ខខណ្ឌ ដែលតម្រូវឱ្យ ស្ត្រីចាំបាច់ត្រូវសុំការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីបុរសជាសាច់ញាតិ ដើម្បីទទួលបានលិខិតឆ្លងដែនសម្រាប់ការធ្វើដំណើរ ឬធ្វើចំណាកស្រុក។ នៅពេលខ្លះ ស្ត្រីត្រូវឃាត់ទុកដោយភ្នាក់ងារ ជ្រើសរើសពលករ

ដើម្បីបណ្តុះបណ្តាលសម្រាប់ការត្រៀមខ្លួនមុនពេលចេញដំណើរដែលការធ្វើដូច្នេះ ស្ត្រីអាចប្រឈមនឹងជាការឆបោកថវិកា ការបំពាន លើរាងកាយ ផ្លូវភេទ ឬផ្លូវចិត្តរបស់ស្ត្រី។ ម្យ៉ាងវិញទៀត ស្ត្រីអាចទទួលរងគ្រោះពីផលវិបាកនៃការរឹតបន្តឹងមិនឱ្យទទួល បានការអប់រំ ការបណ្តុះបណ្តាល និងព័ត៌មានពេញលេញ និងអាចជឿទុកចិត្តបានអំពីការធ្វើចំណាកស្រុក ហើយផលវិបាក ទាំងនេះ អាចធ្វើឱ្យស្ត្រីកាន់តែទទួលរងគ្រោះដោយនិយោជករបស់ខ្លួន។ ភ្នាក់ងារស្វែងរកការងារឱ្យកម្មករធ្វើ អាចកេងប្រវ័ញ្ចប្រាក់ឈ្នួលពីកម្មករ ដែលនៅពេលខ្លះធ្វើឱ្យស្ត្រីដែលមានធនធានតិចជាងបុរស ជួបបញ្ហាថវិកា កាន់តែខ្លាំង និងធ្វើឱ្យស្ត្រីត្រូវការពឹងអាស្រ័យកាន់តែច្រើនទៅលើគ្រួសារ មិត្តភ័ក្តិ ឬអ្នកចងការប្រាក់ ដើម្បីខ្ចីប្រាក់ក្នុងអត្រាការប្រាក់ខ្ពស់។

១១. <u>នៅប្រទេសដើមកំណើត បន្ទាប់ពីត្រឡប់មកស្រុកដល់វិញ</u>

ស្ត្រីជាកម្មករចំណាកស្រុក អាចប្រឈមនឹងការរើសអើងទាក់ទងនឹងភេទ និងយេនឌ័រ រាប់បញ្ចូលទាំងការបង្ខំឱ្យពិនិត្យឈាម រកមេរោគអេដស៍ និងជំងឺអេដស៍ សម្រាប់ស្ត្រីដែលត្រឡប់មកស្រុកវិញ "ការស្តារ" សីលធម៌ឡើងវិញ សម្រាប់ស្ត្រីវ័យក្មេង ដែលត្រឡប់ស្រុកវិញ និងការចំណាយកាន់តែច្រើនលើបុគ្គលម្នាក់ៗ និងលើសង្គម បើប្រៀបធៀបទៅនឹងបុរស ដោយសារ កង្វះសេវាឆ្លើយតបទៅនឹងយេនឌ័រ។ ឧទាហរណ៍ បុរសអាចត្រឡប់មកកាន់គ្រួសារដែលមានស្ថានភាពគ្រួសារមានលំនឹង ចំណែកឯស្ត្រីអាចនឹងចែកផ្លូវគ្នា បន្ទាប់ពីត្រឡប់មកវិញ ហើយការចែកផ្លូវគ្នារវាងស្ត្រីជាកម្មករចំណាកស្រុកជាមួយនឹង គ្រួសាររបស់ខ្លួន អាចបណ្តាលមកពីអវត្តមានរបស់ស្ត្រីពីផ្ទះ។ ស្ត្រីជាកម្មករចំណាកស្រុកក៏អាចប្រឈមនឹងកង្វះការការពារប្រឆាំងនឹងការវាយដំពីសំណាក់ភ្នាក់ងារជ្រើសរើសពលករ ដែលមានគំនិតកេងប្រវ័ញ្ចលើកម្មករចំណាកស្រុក។

១២. <u>នៅប្រទេសដែលស្ត្រីជាកម្មករចំណាកស្រុកឆ្លងកាត់</u>

នៅពេលធ្វើចំណាកស្រុកឆ្លងកាត់ប្រទេសផ្សេងទៀត ស្ត្រីជាកម្មករចំណាកស្រុក អាចប្រឈមនឹងក្តីកង្វល់ជាច្រើនទាក់ទងនឹង សិទ្ធិមនុស្ស។ នៅពេលធ្វើដំណើរ ស្ត្រីជាកម្មករចំណាកស្រុក អាចត្រូវភ្នាក់ងារជ្រើសរើសពលករ ឬអ្នកជូនដំណើរបោះបង់ ចោល នៅពេលជួបបញ្ហានៅតាមប្រទេសដែលខ្លួនឆ្លងកាត់ ឬបន្ទាប់ពីមកដល់ប្រទេសគោលដៅ។ ម្យ៉ាងវិញទៀត ស្ត្រីអាច ទទួលរងគ្រោះដោយការបំពានផ្លូវភេទ និងរាងកាយពីសំណាក់ភ្នាក់ងារជ្រើសរើសពលករ និងអ្នកជូនដំណើរ នៅពេល ធ្វើដំណើរឆ្លងកាត់ប្រទេស។

១៣. <u>នៅប្រទេសគោលដៅ</u>

នៅពេលស្ត្រីជាកម្មករចំណាកស្រុកធ្វើដំណើរដល់គោលដៅស្ត្រីអាចប្រឈមនឹងទម្រង់ជាច្រើននៃការរើសអើង *តាមផ្លូវច្បាប់* និង*តាមស្ថានភាពជាក់ស្តែង*។ នៅពេលខ្លះ រដ្ឋាភិបាលប្រទេសមួយចំនួន ដាក់កម្រិត ឬបម្រាមលើការងាររបស់ស្ត្រីក្នុង វិស័យជាក់លាក់មួយចំនួន។ ទោះស្ថិតក្នុងស្ថានភាពបែបណាក៏ដោយ ស្ត្រីជាកម្មករចំណាកស្រុក ប្រឈមនឹងគ្រោះថ្នាក់កាន់ តែច្រើន បើប្រៀបធៀបទៅនឹងបុរស ដោយសារបរិយាកាសមិនឆ្លើយតបនឹងយេនឌ័រ ដែលមិនអនុញ្ញាតឱ្យស្ត្រីផ្លាស់ទីទៅ កន្លែងផ្សេង ហើយផ្តល់លទ្ធភាពតិចតួចដល់ស្ត្រីក្នុងការទទួលបានព័ត៌មានពាក់ព័ន្ធនឹងសិទ្ធិ និងការទទួលបានសិទ្ធិអំណាចរបស់ខ្លួន។ ទស្សនៈយេនឌ័រស្តីពីការងារសមស្របសម្រាប់ស្ត្រី ឆ្លុះបញ្ចាំងឱកាសការងារច្រើនទាក់ទង នឹងការងារក្នុងគ្រួសារ និងការងារផ្តល់សេវា ឬការងារផ្សេងៗទៀតក្នុងវិស័យមិនផ្លូវការ។ ស្ថិតក្នុងស្ថានភាពបែបនេះការងារដែលសម្បូរទៅដោយស្ត្រីគឺជាការងារបម្រើតាមផ្ទះឬការងារមួយចំនួនដែលបម្រើការសប្បាយ។

១៤. លើសពីនេះទៀត នៅប្រទេសគោលដៅ ការកំណត់និយមន័យការងារស្របច្បាប់ អាចមិនរាប់បញ្ចូលការងារទាំងនេះ ដែល នាំឱ្យស្ត្រីជាកម្មករចំណាកស្រុកមិនបានទទួលការការពារដោយស្របច្បាប់ឡើយ។ តាមរយៈការងារទាំងនោះ ស្ត្រីជាកម្មករ ចំណាកស្រុក មានបញ្ហាក្នុងការធ្វើកិច្ចសន្យាពាក់ព័ន្ធនឹងលក្ខខណ្ឌការងារ ដែលជួនកាលធ្វើឱ្យស្ត្រី ត្រូវធ្វើការច្រើនម៉ោង ដោយមិនទទួលបានប្រាក់ថែមម៉ោងឡើយ។ ជាងនេះទៀត ស្ត្រីជាកម្មករចំណាកស្រុកច្រើនជួបប្រទះទម្រង់ជាច្រើន នៃការរើសអើង ដែលមិនត្រឹមតែទទួលរងគ្រោះពីការរើសអើងទាក់ទងនឹងភេទ និងយេនឌ័រប៉ុណ្ណោះទេ ថែមទាំងធ្វើឱ្យស្ត្រីមាន អារម្មណ៍ស្អប់ខ្ពើមជនបរទេស និងទទួលរងគ្រោះពីការប្រកាន់ពូជសាសន៍ទៀតផង។ ការរើសអើងទាក់ទងនឹងជាតិ សាសន៍ ជាតិពន្ធុ លក្ខណៈពិសេសនៃវប្បធម៌ សញ្ជាតិ ភាសា សាសនា ឬលក្ខណៈផ្សេងៗទៀត អាចនឹងបង្ហាញឱ្យឃើញ តាមរយៈមធ្យោបាយជាក់លាក់ជាច្រើនទាក់ទងនឹងភេទ និងយេនឌ័រ។

១៥. ដោយសារការរើសអើងទាក់ទងនឹងភេទ និងយេនឌ័រ ស្ត្រីជាកម្មករចំណាកស្រុក អាចប្រឈមនឹងការទទួលបានប្រាក់ឈ្នួលទាប បើប្រៀបធៀបទៅនឹងបុរស ការមិនបើកប្រាក់កម្រៃ ភាពយឺតយ៉ាវក្នុងការទទួលបានប្រាក់កម្រៃ រហូតដល់ពេល ចេញដំណើរត្រឡប់មកស្រុកវិញ ឬការផ្ទេរប្រាក់ឈ្នួលទៅក្នុងគណនីដែលស្ត្រី មិនអាចដកប្រាក់បាន។ ឧទាហរណ៍ និយោជក របស់កម្មករបម្រើការងារតាមផ្ទះជាញឹកញាប់ ដាក់ប្រាក់ឈ្នួលរបស់កម្មករទៅក្នុងគណនីមួយ ដោយដាក់ឈ្មោះរបស់ខ្លួន។ ប្រសិនបើស្ត្រីម្នាក់និងស្វាមីរបស់ស្ត្រីនោះ មានឋានៈជាកម្មករ ប្រាក់ខែរបស់ស្ត្រីនោះ អាចនឹងបង់ចូលក្នុងគណនីមួយ ដែលដាក់ឈ្មោះស្វាមីនាង។ កម្មករធ្វើការងារក្នុងវិស័យដែលសម្បូរដោយស្ត្រី អាចមិនទទួលបាន

ប្រាក់ឈ្នួលសម្រាប់ថ្ងៃ ឈប់សម្រាប់ ឬថ្ងៃបុណ្យជាតិឡើយ។ ប្រសិនបើស្ត្រីជាកម្មករចំណាកស្រុកមានបន្ទុកធ្ងន់ធ្ងរដោយសារការជំពាក់បំណុល ភ្នាក់ងារជ្រើសរើសបុគ្គលិក ស្ត្រីនឹងមិនអាចចាកចេញពីស្ថានភាពដែលប្រឈមនឹងការរំលោភបំពានបានឡើយ ដោយសារ ស្ត្រីមិនមានមធ្យោបាយផ្សេងទៀតដើម្បីសងបំណុលដល់ភ្នាក់ងារទាំងនោះ។ ជាការពិត ស្ត្រីក្នុងស្រុក អាចប្រឈមនឹងការ រំលោភបំពានក្នុងការងារស្រដៀងៗគ្នាដែលសម្បូរដោយស្ត្រី។ ទោះបីជាយ៉ាងនេះក្តី ស្ត្រីក្នុងស្រុក មានលទ្ធភាពផ្លាស់ទីពី កន្លែងមួយទៅកន្លែងមួយទៀតដើម្បីស្វែងរកការងារធ្វើ បានប្រសើរជាងស្ត្រីជាកម្មករចំណាកស្រុក។ ស្ត្រីក្នុងស្រុកមាន ជម្រើសចាកចេញពីស្ថានភាពការងារដែលមានការសង្កត់សង្កិន និងទទួលបានការងារផ្សេងទៀត ចំណែកឯស្ត្រីជាកម្មករ ចំណាកស្រុកនៅប្រទេសមួយចំនួន អាចបាត់បង់ឯកសារត្រឹមត្រូវសម្រាប់បញ្ជាក់ពីការធ្វើចំណាកស្រុករបស់ខ្លួន នៅពេល ស្ត្រីត្រូវបោះបង់ការងាររបស់ខ្លួនភ្លាមៗ។ លើសពីនេះទៀត ស្ត្រីក្នុងស្រុក ទទួលបានការការពារផ្នែកសេដ្ឋកិច្ចមួយចំនួន តាមរយៈការឧបត្ថម្ភពីគ្រួសាររបស់ខ្លួន ប្រសិនបើស្ត្រីមិនមានការងារធ្វើ ប៉ុន្តែស្ត្រីជាកម្មករចំណាកស្រុក អាចមិនទទួល បានការការពារទាំងនោះឡើយ។ ដូច្នេះស្ត្រីជាកម្មករចំណាកស្រុក អាចប្រឈមនឹងគ្រោះថ្នាក់ដោយផ្អែកលើភេទ និង យេនឌ័រ រួមទាំងស្ថានភាពចំណាកស្រុករបស់ខ្លួន។

១៦. ស្ត្រីជាកម្មករចំណាកស្រុក មិនអាចសន្សំប្រាក់ ឬផ្ទេរប្រាក់សន្សំតាមមធ្យោបាយទៀងទាត់ប្រកបដោយសុវត្ថិភាពបានឡើយ ដោយសារការរស់នៅតែម្នាក់ឯង (សម្រាប់កម្មករបម្រើការងារតាមផ្ទះ) នីតិវិធីស្មុគស្មាញ ឧបសគ្គផ្នែកភាសា ឬថ្លៃ ប្រតិបត្តិការខ្ពស់។ ទាំងនេះជាបញ្ហាដ៏ធ្ងន់ធ្ងរសម្រាប់ស្ត្រីដោយសារស្ត្រីជាទូទៅរកប្រាក់ចំណូលបានតិចជាងបុរស។ ស្ត្រីអាចមានកាតព្វកិច្ចបន្ថែមទៀតក្នុងការផ្ញើប្រាក់ចំណូលដែលខ្លួនរកបានមកឱ្យគ្រួសារហើយបុរសមិនត្រូវបានរំពឹងថានឹងមាន កាតព្វកិច្ចនេះឡើយ។ ឧទាហរណ៍ សមាជិកគ្រួសារនៅឯផ្ទះ អាចរំពឹងទុកថានឹងទទួលបានការផ្តល់ការឧបត្ថម្ភផ្នែកហិរញ្ញ វត្ថុពីស្ត្រីនៅលីវ សូម្បីតែនៅក្នុងគ្រួសារដែលមានសមាជិកច្រើនក៏ដោយ។

១៧. ជាញឹកញាប់ ស្ត្រីជាកម្មករចំណាកស្រុក ទទួលរងគ្រោះពីវិសមភាពដែលគំរាមកំហែងដល់សុខភាពរបស់ខ្លួន។ ស្ត្រីអាចមិនទទួលបានសេវាសុខភាព រាប់បញ្ចូលទាំងសេវាសុខភាពបន្តពូជ ដោយសារស្ត្រីមិនអាចទទួលបានការធានារ៉ាប់រង ឬកម្មវិធី សុខភាពថ្នាក់ជាតិ ឬស្ត្រីមិនមានលទ្ធភាពបង់ថ្លៃសេវាទាំងនោះបាន។ ដោយសារស្ត្រីមានតម្រូវការផ្នែកសុខភាព ខុសពី តម្រូវការរបស់បុរស ដូច្នេះទិដ្ឋភាពនេះទាមទារឱ្យមានការយកចិត្តទុកដាក់ជាពិសេស។ ម្យ៉ាងវិញទៀត ស្ត្រីអាចទទួលរង គ្រោះដោយសារកង្វះការត្រៀមខ្លួន ដើម្បីការពារសុវត្ថិភាពរបស់ខ្លួននៅកន្លែងការងារ ឬការរៀបចំឱ្យមានសុវត្ថិភាពចំពោះការធ្វើដំណើរពីកន្លែងធ្វើការមកកន្លែងស្នាក់នៅ។ នៅកន្លែងធ្វើការដែលមានផ្តល់កន្លែងស្នាក់នៅ

ជាពិសេសការងារ ដែលសម្បូរដោយស្ត្រី រួមមានដូចជា ការងាររោងចក្រ ការងារកសិដ្ឋាន ឬការងារបម្រើតាមផ្ទះ ស្ថានភាពរស់នៅរបស់ កម្មករ កខ្វក់ និងទីកន្លែងរស់នៅចង្អៀត មិនមានទឹកម៉ាស៊ីន មិនមានសម្ភារបរិក្ខារដែលមានអនាម័យគ្រប់គ្រាន់ ឬខ្វះ សិទ្ធិផ្ទាល់ខ្លួន និងអនាម័យ។ ជួនកាល ស្ត្រីជាកម្មករចំណាកស្រុក អាចប្រឈមនឹងការជាប់កាតព្វកិច្ចធ្វើតែសរកមេរោគ អេដស៍/ជំងឺអេដស៍ ដោយមានការរើងអើងទាក់ទងនឹងភេទ ឬការធ្វើតែសរកជំងឺឆ្លងផ្សេងទៀត ដោយគ្មានការស្ម័គ្រចិត្តពីស្ត្រី ហើយលទ្ធផលធ្វើតែសរបស់ស្ត្រី ត្រូវបានផ្តល់ដល់ភ្នាក់ងារជ្រើសរើសពលករ និងនិយោជករបស់ស្ត្រី ប៉ុន្តែមិនបានផ្តល់ ដល់ស្ត្រីឡើយ។ ការធ្វើដូច្នេះ អាចនឹងធ្វើឱ្យស្ត្រីបាត់បង់ការងារ ឬការនិរទេសឱ្យត្រឡប់មកស្រុកកំណើតវិញ ប្រសិនបើស្ត្រី មានផ្ទុកមេរោគអេដស៍។

១៨. ជាពិសេស ការរើងអើង អាចនឹងធ្វើឱ្យស្ត្រីជាកម្មករចំណាកស្រុក ទទួលរងគ្រោះកាន់តែធ្ងន់ធ្ងរទាក់ទងនឹងការមានគភ៌។ ស្ត្រី អាចប្រឈមនឹងការបង្ខិតបង្ខំឱ្យធ្វើតែសរកមើលថានាងមាន ឬមិនមានគភ៌ ហើយប្រសិនបើនាងមានគភ៌មែននោះ នាងនឹងត្រូវនិរទេសចេញពីប្រទេសនោះ បង្ខំឱ្យរំលូតកូន ឬប្រឈមនឹងកង្វះខាតលទ្ធភាពទទួលបានសេវាពិនិត្យសុខភាព បន្តពូជ ឬសេវារំលូតកូនប្រកបដោយសុវត្ថិភាព នៅពេលសុខភាពរបស់ម្តាយស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ ឬប្រឈមនឹងការ បំពានផ្លូវភេទ ការទទួលបានច្បាប់លំហែមាតុភាព និងអត្ថប្រយោជន៍មិនគ្រប់គ្រាន់ ឬការមិនទទួលបានការថែទាំផ្ទៃសម្ភពដែលមានតម្លៃសមស្រប ជាលទ្ធផលនាំឱ្យស្ត្រីប្រឈមនឹងគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាព។ ស្ត្រីក៏អាចប្រឈមនឹងការ បណ្តេញចេញពីការងារ បន្ទាប់ពីរកឃើញថា នាងមានគភ៌ ដែលពេលខ្លះធ្វើឱ្យនាងប្រឈមនឹងបញ្ហាអន្តោប្រវេសន៍ខុស ច្បាប់ និងរងការបណ្តេញចេញពីប្រទេស។

១៩. ស្ត្រីជាកម្មករចំណាកស្រុក អាចប្រឈមនឹងការលំបាកជាច្រើន ទាក់ទងនឹងការស្នាក់នៅក្នុងប្រទេសមួយ។ នៅពេលខ្លះ ស្ត្រីជាកម្មករចំណាកស្រុក មិនអាចទទួលបានអត្ថប្រយោជន៍ពីកម្មវិធីជួបជុំគ្រួសារវិញឡើយ ដែលរាប់បញ្ចូលទាំងកម្មករធ្វើ ការងារក្នុងវិស័យសម្បូរដោយស្ត្រី ដូចជាកម្មករបម្រើការងារតាមផ្ទះ ឬកម្មករបម្រើការងារក្នុងវិស័យបម្រើការសប្បាយ។ ការអនុញ្ញាតឱ្យស្ត្រីកម្មករចំណាកស្រុកស្នាក់នៅក្នុងប្រទេសដែលស្ត្រីទៅធ្វើការ អាចមានការដាក់កម្រិតយ៉ាងខ្លាំង ជា ពិសេសសម្រាប់ស្ត្រីដែលបម្រើការងារតាមផ្ទះ នៅពេលកិច្ចសន្យាមានកំណត់ពេលវេលាជាក់លាក់ ត្រូវចប់ ឬត្រូវបញ្ចប់ ដោយនិយោជក។ ប្រសិនបើស្ត្រីជាកម្មករចំណាកស្រុកបាត់បង់ស្ថានភាពអន្តោប្រវេសន៍ ស្ត្រីអាចប្រឈមនឹងភាពងាយរង គ្រោះបន្ថែមទៀតទៅនឹងអំពើហិង្សាពីសំណាក់និយោជក ឬអ្នកដទៃដែលមានបំណងចង់រំលោភបំពានលើស្ថានភាពនេះ។ ប្រសិនបើស្ត្រីជាកម្មករចំណាកស្រុកត្រូវឃុំខ្លួន ស្ត្រីអាចប្រឈមនឹងអំពើហិង្សា ដែលប្រព្រឹត្តិដោយមន្ត្រីនៅមន្ទីរឃុំឃាំង។

២០. ស្ត្រីជាកម្មករចំណាកស្រុក កាន់តែងាយរងគ្រោះពីការរំលោភផ្លូវភេទ ការបៀតបៀនផ្លូវភេទ និង អំពើហិង្សាលើរាងកាយ ជាពិសេសក្នុងវិស័យដែលសម្បូរដោយស្ត្រី។ ជាពិសេស ស្ត្រីដែលបម្រើការងារ តាមផ្ទះ ងាយរងគ្រោះដោយការធ្វើបាបលើ រាងកាយ និងផ្លូវភេទ ញ៉ាំ និងគេងមិនគ្រប់គ្រាន់ ព្រមទាំងការធ្វើទុក្ខបុកម្នេញពីសំណាក់និយោជក។ ការបៀតបៀនផ្លូវ ភេទលើស្ត្រីជាកម្មករចំណាក ស្រុក នៅក្នុងបរិស្ថានការងារផ្សេងទៀត ដូចជាការងារកសិដ្ឋាន ឬវិស័យឧស្សាហកម្ម ជាបញ្ហា កើតមានឡើងនៅពាសពេញសកលលោក។ ស្ត្រីជាកម្មករចំណាកស្រុក ដែលធ្វើចំណាកស្រុកជាមួយ ស្វាមី ឬជាមួយ សមាជិកគ្រួសារ អាចប្រឈមនឹងគ្រោះថ្នាក់នៃការប្រព្រឹត្តិអំពើហិង្សាក្នុងគ្រួសារ បន្ថែមទៀតពីសំណាក់ស្វាមី ឬសាច់ញាតិ របស់ខ្លួន ដែលអ្នកទាំងនោះមានវប្បធម៌ផ្ដល់តម្លៃដល់តួនាទី របស់ស្ត្រីក្នុងគ្រួសារឱ្យចេះគោរពស្វាមី ឬសាច់ញាតិរបស់ខ្លួន។

២១. ស្ត្រីជាកម្មករចំណាកស្រុក អាចនឹងទទួលបានយុត្តិធម៌តិចតួច។ នៅប្រទេសមួយចំនួន ស្ត្រីជាកម្មករ ចំណាកស្រុក ត្រូវបានដាក់កម្រិតលើការប្រើប្រាស់ប្រព័ន្ធច្បាប់ ដើម្បីដោះស្រាយស្តង់ដាការងារ ដែលមានការរើសអើង ការរើសអើងការងារ ឬ អំពើហិង្សាទាក់ទងនឹងភេទ និងយេនឌ័រ។ លើសពីនេះ ទៀត ស្ត្រីជាកម្មករចំណាកស្រុក អាចគ្មានលទ្ធភាពទទួលបានជំនួយ ស្របច្បាប់ពីរដ្ឋាភិបាល ហើយអាច ប្រឈមនឹងឧបសគ្គផ្សេងទៀត ដូចជា ការមិនដោះស្រាយបញ្ហាហិង្សាដែលកើតឡើង និងភាព គ្រោតគ្រាតពីសំណាក់មន្ត្រីដែលបានឃុបឃិតជាមួយនឹងអ្នកប្រព្រឹត្តិអំពើហិង្សា។ ក្នុងករណីមួយចំនួន មន្ត្រីការទូត បានបំពាន ប្រើអំពើហឹង្សាលើផ្លូវភេទ ព្រមទាំងទម្រង់ផ្សេងទៀតនៃការរើសអើង ប្រឆាំងនឹងស្ត្រីជាកម្មករចំណាកស្រុក បម្រើការងារតាមផ្ទះ ទោះបីជាស្ត្រីទទួលបានការការពារផ្នែក ការទូតក៏ដោយ។ នៅប្រទេសមួយចំនួន ច្បាប់សម្រាប់ការពារ ស្ត្រីជាកម្មករចំណាកស្រុក នៅមានកង្វះ ខាតនៅឡើយ។ ឧទាហរណ៍ ស្ត្រីជាកម្មករចំណាកស្រុក អាចបាត់បង់លិខិតអនុញ្ញាត ឱ្យបម្រើការងារ នៅពេលស្ត្រីទៅរាយការណ៍អំពីការបំពាន ឬការរើសអើងដែលកើតឡើងចំពោះខ្លួន ហើយស្ត្រីមិនអាច បន្តស្នាក់នៅប្រទេសនោះបានទៀតឡើយ ក្នុងអំឡុងពេលកាត់ទោស។ ក្រៅពីឧបសគ្គជាផ្លូវការទាំងនេះ ឧបសគ្គជាក់ស្តែង អាចនឹងបង្អាក់ស្ត្រីជាកម្មករចំណាកស្រុក មិនឱ្យទទួលបានការដោះស្រាយបញ្ហាទាំង នោះឡើយ។ ស្ត្រីជាកម្មករចំណាកស្រុកជាច្រើន មិនចេះនិយាយភាសារបស់ប្រទេសគោលដៅ និងមិន យល់ដឹងពីសិទ្ធិរបស់ខ្លួន។ ស្ត្រីជាកម្មករចំណាកស្រុក អាចខ្វះ សិទ្ធិក្នុងការដើរហើរ ដោយសារ ស្ត្រីត្រូវបាននិយោជកដាក់កំហិតមិនឱ្យចាកចេញពីកន្លែងការងារ ឬកន្លែងស្នាក់នៅ មិន អនុញ្ញាតឱ្យ ប្រើទូរស័ព្ទ ដាក់បម្រាមមិនឱ្យទៅចូលរួមជាមួយក្រុម ឬសមាគមវប្បធម៌ឡើយ។ ជាញឹកញាប់ស្ត្រីជា កម្មករចំណាកស្រុក ច្រើនតែមិនសូវយល់ដឹងព័ត៌មានទាក់ទងនឹងស្ថានទូតរបស់ខ្លួន ឬសេវាផ្ដល់ដោយ

ស្ថានទូត ដោយសារស្ត្រី ភាគច្រើនពឹងផ្អែកទៅលើនិយោជក ឬស្វាមីរបស់ខ្លួន ដើម្បីទទួលបានព័ត៌មានទាក់ទងនឹងស្ថានទូត ឬសេវាទាំងនោះ។ ឧទាហរណ៍ ការលំបាកសម្រាប់ស្ត្រីជាកម្មករចំណាកស្រុកបម្រើការងារតាមផ្ទះ គឺថា ស្ត្រីកម្រនឹងគេចផុតពីក្រសែភ្នែករបស់ និយោជកខ្លួនណាស់ នៅពេលស្ត្រីមកធ្វើកំណត់ហេតុនានានៅស្ថានទូតរបស់ខ្លួន ឬមកដាក់ពាក្យបណ្តឹង។ ដោយសារស្ត្រីជា កម្មករចំណាកស្រុកមិនមានទំនាក់ទំនងជាមួយផ្នែកខាងក្រៅ និងមិនមានមធ្យោបាយសម្រាប់ធ្វើការប្តឹងផ្តល់ពីនិយោជករបស់ខ្លួន ស្ត្រីអាចនឹងទទួលរងគ្រោះពីអំពើហិង្សា និងការបំពានកាន់តែយូរ មុនពេលអំពើទាំងនោះ ត្រូវបានដឹងឮដល់អ្នកដទៃ។ ក្រៅពីនេះ ប្រសិនបើស្ត្រីធ្វើការក្នុងវិស័យទាក់ទងនឹងបណ្តាញបទល្មើស លិខិតឆ្លងដែនរបស់ស្ត្រីជាកម្មករចំណាក ស្រុកត្រូវបានដកហូតយកទៅរក្សាទុក ដោយនិយោជក ដើម្បីរារាំងមិនឱ្យស្ត្រីទៅរាយការណ៍ប្រាប់អ្នកដទៃបាន។

២២. ជាពិសេស ស្ត្រីជាកម្មករចំណាកស្រុក ដែលមិនមានឯកសារត្រឹមត្រូវសម្រាប់បញ្ជាក់ពីការធ្វើចំណាកស្រុករបស់ខ្លួន ងាយរង គ្រោះពីការកេងប្រវ័ញ្ច និងការបំពាន ដោយសារស្ថានភាពអន្តោប្រវេសន៍មិនទៀងទាត់របស់ខ្លួន នាំឱ្យស្ត្រីកាន់តែមិន ទទួលបានការយកចិត្តទុកដាក់ ហើយប្រឈមនឹងការកេងប្រវ័ញ្ចកាន់តែច្រើនថែមទៀត។ ស្ត្រីត្រូវបានកេងប្រវ័ញ្ចឱ្យធ្វើ ការងារដោយបង្ខំ ហើយធ្វើឱ្យស្ត្រីទទួលបានសិទ្ធិការងារតិចតួច ដោយសារតែការភ័យខ្លាចមិនហ៊ានប្រកាសឱ្យអ្នកដទៃបាន ដឹង។ ម្យ៉ាងវិញទៀត ស្ត្រីអាចប្រឈមនឹងការបៀតបៀនពីសំណាក់ប៉ូលីសផងដែរ។ ប្រសិនបើស្ត្រីជាកម្មករចំណាកស្រុក ត្រូវប៉ូលីសចាប់ខ្លួនបាន ស្ត្រីត្រូវកាត់ទោសលើការរំលោភច្បាប់អន្តោប្រវេសន៍ ហើយឃុំខ្លួនក្នុងមន្ទីរឃុំឃាំង ដែលនាំឱ្យស្ត្រី ត្រូវទទួលរងគ្រោះពីការរំលោភ និងនិរទេសចេញពីប្រទេសដែលខ្លួនធ្វើចំណាកស្រុកទៅនោះ។

## អនុសាសន៍សម្រាប់រដ្ឋជាភាគី

២៣. <u>ការទទួលខុសត្រូវរួមរបស់ប្រទេសដើម និងប្រទេសគោលដៅ</u>

*ក. គោលនយោបាយទូលំទូលាយផ្អែកលើវេន្ទ្រោចយេនឌ័រ និងសិទ្ធិមនុស្ស*

រដ្ឋជាភាគី គួរប្រើប្រាស់អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ និងអនុសាសន៍ទូទៅ ដើម្បីបង្កើតគោលនយោបាយផ្អែកលើការឆ្លើយតបនឹងយេនឌ័រ និងឈរលើមូលដ្ឋានសមភាព និងការមិនរើសអើង ដើម្បី ដាក់ចេញនូវបទប្បញ្ញត្តិ និងគ្រប់គ្រងលើទិដ្ឋភាពនិងដំណាក់កាលទាំងអស់នៃការធ្វើចំណាកស្រុក សម្របសម្រួលដល់ស្ត្រី ជាកម្មករចំណាកស្រុកឱ្យទទួលបានឱកាសការងារនៅបរទេស ដើម្បីលើកកម្ពស់ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងធានាថាសិទ្ធិរបស់ស្ត្រីជាកម្មករចំណាកស្រុកទទួលបានការការពារ (មាត្រា ២ក និង ៣)។

*ខ. ការចូលរួមយ៉ាងសកម្មពីស្ត្រីជាកម្មករចំណាកស្រុក និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ*

រដ្ឋជាភាគី គួរស្វែងរកការចូលរួមយ៉ាងសកម្មពីស្ត្រីជាកម្មករចំណាកស្រុក និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ ក្នុងការ បង្កើត ការអនុវត្ត ការពិនិត្យតាមដាន និងការវាយតម្លៃគោលនយោបាយនេះ ( មាត្រា ៧ខ) ។

*គ. ការស្រាវជ្រាវ ការប្រមូល និងការវិភាគទិន្នន័យ*

រដ្ឋជាភាគី គួរធ្វើការស្រាវជ្រាវ និងគាំទ្រការស្រាវជ្រាវតាមបែបបរិមាណវិស័យ និងគុណវិស័យ ប្រមូល និងវិភាគទិន្នន័យ ដើម្បីកំណត់បញ្ហា និងតម្រូវការរបស់ស្ត្រីជាកម្មករចំណាកស្រុក នៅគ្រប់ដំណាក់កាលនៃការធ្វើចំណាកស្រុក ដើម្បីលើក កម្ពស់សិទ្ធិរបស់ស្ត្រីជាកម្មករចំណាកស្រុក និងដើម្បីបង្កើតគោលនយោបាយពាក់ព័ន្ធនានា( មាត្រា ៣) ។

២៤. <u>ការទទួលខុសត្រូវជាក់លាក់របស់ប្រទេសដើម</u>

បណ្តាប្រទេសដើមទាំងអស់ ត្រូវគោរព ការពារ និងឆ្លើយតបសិទ្ធិរបស់ស្ត្រីជាពលរដ្ឋរបស់ខ្លួន ដែលធ្វើចំណាកស្រុកដោយ សារមូលហេតុការងារ ។ ខាងក្រោមនេះ ជាវិធានការដែលតម្រូវឱ្យមានជាចាំបាច់ ប៉ុន្តែមិនមែនមានត្រឹមតែវិធានការដូច បង្ហាញជូនខាងក្រោមឡើយ :

*ក. ការលុបចោលនូវបម្រាម ឬការដាក់កំហិតមិនឱ្យមានការរើសអើងចំពោះការធ្វើចំណាកស្រុក :*

រដ្ឋជាភាគី គួរលុបចោលនូវបម្រាមបញ្ជាក់យ៉ាងជាក់លាក់ទាក់ទងនឹងភេទ និងការដាក់កំហិតមិនឱ្យមានការរើសអើង ចំពោះការធ្វើចំណាកស្រុករបស់ស្ត្រីផ្អែកលើអាយុ ស្ថានភាពអាពាហ៍ពិពាហ៍ ការមានគភ៌ និងស្ថានភាពមាតុភាព។ រដ្ឋ ជាភាគីទាំងនោះ គួរលុបចោលបម្រាមដែលតម្រូវឱ្យស្ត្រីចាំបាច់ត្រូវសុំការអនុញ្ញាតពីស្វាមី ឬអាណាព្យាបាលជាបុរស ដើម្បីទទួលបានលិខិតឆ្លងដែន ឬការអនុញ្ញាតឱ្យធ្វើចំណាកស្រុក ( មាត្រា ២ច) ។

*ខ. ការអប់រំ ការលើកកម្ពស់ការយល់ដឹង និងការបណ្តុះបណ្តាលដែលមានខ្លឹមសារស្តង់ដា*

រដ្ឋជាភាគី គួរបង្កើតកម្មវិធីលើកកម្ពស់ការអប់រំ និងការយល់ដឹងសមស្រប ដោយមានការពិគ្រោះយោបល់យ៉ាង ជិតស្និទ្ធជាមួយអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ អ្នកជំនាញខាងយេនឌ័រ និងខាងការធ្វើចំណាកស្រុក ស្ត្រីជា កម្មករដែលធ្លាប់ធ្វើចំណាកស្រុក និងទីភ្នាក់ងារជ្រើសរើសពលករដែលអាចជឿទុកចិត្តបាន។ ក្នុងន័យនេះ រដ្ឋជាភាគី គួរ : ( មាត្រា ៣, ៥,១០ និង ១៤)

(i) ផ្សព្វផ្សាយ ឬសម្របសម្រួលកម្មវិធីផ្តល់ព័ត៌មាន និងការបណ្តុះបណ្តាលមុនពេលចេញដំណើរដោយឥតគិតថ្លៃនិងសមស្រមទាក់ទងនឹងយេនឌ័រ និងសិទ្ធិ ដើម្បីលើកកម្ពស់ការយល់ដឹងរបស់ស្ត្រីដែលនឹងធ្វើចំណាកស្រុកឱ្យយល់ដឹងអំពីការកេងប្រវ័ញ្ចដែលអាចកើតមាន រាប់

បញ្ចូលទាំង : ខ្លឹមសារជាអនុសាសន៍ស្ដីពីការធ្វើកិច្ចសន្យា ការងារ សិទ្ធិ និងការទទួលបានសិទ្ធិដោយស្របច្បាប់ នៅបណ្ដាប្រទេសដែលខ្លួនទៅធ្វើការ នីតិវិធីស្នើឱ្យមាន យន្តការដោះស្រាយតាមផ្លូវការ និងមិនផ្លូវការ ដំណើរការដើម្បីទទួលបានព័ត៌មានអំពីនិយោជក ស្ថានភាពវប្បធម៌នៅបណ្ដាប្រទេសគោលដៅ ការគ្រប់គ្រងភាពតានតឹង វិធានការផ្ដល់ជំនួយ និងការសង្គ្រោះបន្ទាន់ រាប់បញ្ចូលទាំងលេខទូរស័ព្ទ និងសេវាសង្គ្រោះបន្ទាន់របស់ស្ថានទូតប្រទេសខ្លួន ព័ត៌មានអំពីសុវត្ថិភាពនៅតំបន់ ឆ្លងកាត់ រួមមានដូចជា ព័ត៌មានទូទៅស្ដីពីព្រលានយន្តហោះ និងយន្តហោះ និងព័ត៌មានស្ដីពីសុខភាពទូទៅ និងសុខភាពបន្តពូជ រួមទាំងព័ត៌មានស្ដីពីការបង្ការមេរោគអេដស៍/ជំងឺអេដស៍ផងដែរ។ កម្មវិធីបណ្ដុះបណ្ដាល ទាំងនេះគួរផ្ដោតគោលដៅទៅលើស្ត្រីដែលនឹងធ្វើចំណាកស្រុក តាមរយៈកម្មវិធីផ្សព្វផ្សាយដែលមានប្រសិទ្ធ ភាព ហើយកម្មវិធីទាំងនេះ គួររៀបចំធ្វើនៅឡើងនៅកន្លែងបណ្ដុះបណ្ដាលនៅតាមបណ្ដាខេត្ត ដើម្បីឱ្យស្ត្រីទាំង នោះអាចចូលរួមបាន។

(ii) ផ្ដល់បញ្ជីឈ្មោះទីភ្នាក់ងារជ្រើសរើសពលករដែលពិតប្រាកដ អាចជឿទុកចិត្តបាន និងបង្កើតប្រព័ន្ធព័ត៌មានដែល មានឯកភាពគ្នាស្ដីពីការងារដែលអាចរកបាននៅបរទេស។

(iii) ផ្ដល់ព័ត៌មានស្ដីពីវិធីសាស្ត្រ និងនីតិវិធីសម្រាប់ការធ្វើចំណាកស្រុកទៅស្វែងរកការងារធ្វើ ប្រសិនបើស្ត្រីជា កម្មករចំណាកស្រុក មានបំណងចង់ធ្វើចំណាកស្រុកដោយឯករាជ្យតាម រយៈទីភ្នាក់ងារជ្រើសរើសពលករ។

(iv) តម្រូវឱ្យទីភ្នាក់ងារជ្រើសរើសពលករចូលរួមក្នុងកម្មវិធីលើកកម្ពស់ការយល់ដឹង និងការបណ្ដុះបណ្ដាល និងឱ្យ ទីភ្នាក់ងារទាំងនោះ ឆ្លើយតបទៅនឹងសិទ្ធិរបស់ស្ត្រីជាកម្មករចំណាកស្រុក និងទម្រង់នៃការរើសអើងទាក់ទងនឹង ភេទ និងយេនឌ័រ ការកេងប្រវ័ញ្ចដែលស្ត្រីអាចនឹងជួបប្រទះ ព្រមទាំងការទទួលខុសត្រូវរបស់ទី ភ្នាក់ងារទាំង នោះចំពោះស្ត្រីផងដែរ។

(v) លើកកម្ពស់ការយល់ដឹងរបស់សហគមន៍ទាក់ទងនឹងថ្លៃចំណាយ និងអត្ថប្រយោជន៍បានមកពីគ្រប់រូបភាពទាំង អស់នៃការធ្វើចំណាកស្រុករបស់ស្ត្រី និងរៀបចំសកម្មភាពលើកកម្ពស់ការយល់ដឹងឆ្លងវប្បធម៌ ដែលផ្ដោតលើ សាធារណៈជនទូទៅ ហើយសកម្មភាពទាំងនោះគួរលើកឡើងអំពីភាពប្រថុយប្រថាន គ្រោះថ្នាក់ និងឱកាស នានានៃការធ្វើចំណាកស្រុក ការទទួលបានសិទ្ធិរបស់ស្ត្រីក្នុងការរកប្រាក់ចំណូល ដើម្បីធានាឱ្យបានល្អនូវសុវត្ថិ ភាពថវិកា និងតម្រូវការរបស់ស្ត្រី ដើម្បីរក្សានូវតុល្យភាពរវាងការទទួលខុសត្រូវរបស់ស្ត្រីចំពោះគ្រួសារ

និង ការទទួលខុសត្រូវរបស់ស្ត្រីចំពោះខ្លួនឯង។ កម្មវិធីលើកកម្ពស់ការយល់ដឹងទាំងនោះ អាចនឹងអនុវត្តតាមរយៈ កម្មវិធីអប់រំផ្លូវការ និងមិនផ្លូវការ។

(vi) លើកទឹកចិត្តប្រព័ន្ធផ្សព្វផ្សាយ វិស័យព័ត៌មាន និងការប្រាស្រ័យទាក់ទង ឱ្យរួមចំណែកលើកកម្ពស់ការយល់ដឹង ស្ដីពីបញ្ហាធ្វើចំណាកស្រុក រួមបញ្ចូលទាំងការរួមចំណែករបស់ស្ត្រីជាកម្មករចំណាកស្រុកក្នុងវិស័យសេដ្ឋកិច្ច ភាពងាយរងគ្រោះរបស់ស្ត្រីដោយសារការកេងប្រវ័ញ្ច និងការរើសអើង ព្រមទាំងទីកន្លែងផ្សេងៗ ដែលមានអំពើ កេងប្រវ័ញ្ចកើតឡើង។

*គ. បទប្បញ្ញត្តិ និងប្រព័ន្ធពិនិត្យតាមដាន*

(i) រដ្ឋជាភាគី គួរអនុម័តបទប្បបញ្ញត្តិ និងរៀបចំប្រព័ន្ធពិនិត្យតាមដាន ដើម្បីធានាថា ភ្នាក់ងារជ្រើសរើសពលករ និងទីភ្នាក់ងារស្វែងរកការងារឱ្យពលករធ្វើ គោរពសិទ្ធិស្ត្រីជាកម្មករចំណាកស្រុក។ រដ្ឋជាភាគី គួរដាក់បញ្ចូល នូវនិយមន័យដ៏ទូលំទូលាយអំពីការជ្រើសរើសពលករមិនទៀងទាត់ និងបទប្បញ្ញត្តិនៃទោសប្បញ្ញត្តិដោយស្រប ច្បាប់ទៅក្នុងច្បាប់របស់ប្រទេសខ្លួនសម្រាប់ទីភ្នាក់ជ្រើសរើសពលករដែលរំលោភច្បាប់ ( មាត្រា ២ង) ។

(ii) រដ្ឋជាភាគី
គួរអនុវត្តកម្មវិធីទទួលស្គាល់ទីភ្នាក់ងារជ្រើសរើសពលករណាដែលអនុវត្តការងាររបស់ខ្លួនបានល្អ ក្នុង ចំណោមទីភ្នាក់ងារជ្រើសរើសពលករជាច្រើន ( មាត្រា ២ក) ។

*ឃ. សេវាសុខភាព*

រដ្ឋជាភាគី គួរធានាផ្ដល់លិខិតបញ្ជាក់សុខភាពដែលមានលក្ខណៈស្តង់ដា និងពិតប្រាកដដល់ស្ត្រីជាកម្មករចំណាកស្រុក ប្រសិនបើប្រទេសគោលដៅទាមទារឱ្យមាន ហើយគួរទារមទារឱ្យអនាគតនិយោជកស្ត្រីកម្មករចំណាកស្រុក ទិញការ ធានារ៉ាប់រងផ្នែកសុខភាពសម្រាប់ស្ត្រីផងដែរ។ ការធ្វើតែសរកមេរោគអេដស៍/ជំងឺអេដស៍មុនពេលចេញ ដំណើរ ឬ ការពិនិត្យសុខភាពមុនពេលចេញដំណើរ ចាំបាច់ត្រូវគោរពដល់សិទ្ធិមនុស្សរបស់ស្ត្រីជាកម្មករចំណាកស្រុក។ ការធ្វើតែសទាំងនោះ គួរផ្ដោតការយកចិត្តទុកដាក់ជាពិសេសលើការស្ម័គ្រចិត្ត ការផ្ដល់សេវាធ្វើតែស ឬពិនិត្យសុខ ភាពដោយឥតគិតថ្លៃ ឬមានតម្លៃថោក និងបញ្ហាដែលបង្កឱ្យមានភាពអាម៉ាស់ដលស្ត្រី ( មាត្រា ២ច និង១២) ។

*ង. ឯកសារសម្រាប់ការធ្វើដំណើរ*

រដ្ឋជាភាគី គួរធានាថា ស្ត្រីទាំងអស់ មានលទ្ធភាពទទួលបានឯកសារសម្រាប់ការធ្វើដំណើរ ដោយស្មើភាព និងដោយ ឯករាជ្យ ( មាត្រា ២ឃ) ។

*ខ. ជំនួយផ្នែកច្បាប់ និងរដ្ឋបាល :*

រដ្ឋជាភាគី គួរធានាផ្តល់ជំនួយផ្នែកច្បាប់ទាក់ទងនឹងការធ្វើចំណាកស្រុកស្វែងរកការងារធ្វើ ដល់ស្ត្រីជាកម្មករចំណាក ស្រុក។ ឧទាហរណ៍ ការពិនិត្យវាយតម្លៃផ្នែកច្បាប់ឡើងវិញ គួរតម្រូវឱ្យមាន ដើម្បីធានាថា កិច្ចសន្យាការងារមាន សុពលភាព និងការពារដល់សិទ្ធិរបស់ស្ត្រី ដោយឈរលើមូលដ្ឋានសមភាពរវាងបុរស និងស្ត្រី ( មាត្រា ៣ និង ១១) ។

*គ. ការការពារសុវត្ថិភាពនៃការផ្ញើប្រាក់ចំណូលមកគ្រួសារ*

រដ្ឋជាភាគី គួរបង្កើតវិធានការ ដើម្បីការពារសុវត្ថិភាពនៃការផ្ញើប្រាក់ចំណូលដែល ស្ត្រីជាកម្មករចំណាកស្រុករកបាន មកផ្ទះ និងផ្តល់ព័ត៌មាន ព្រមទាំងជំនួយដល់ស្ត្រី ឱ្យយល់ដឹងអំពីស្ថាប័នហិរញ្ញវត្ថុផ្លូវការសម្រាប់ផ្ញើប្រាក់ត្រឡប់មកផ្ទះ និងដើម្បីលើកទឹកចិត្តស្ត្រី ឱ្យចូលរួមក្នុងកម្មវិធីសន្សំប្រាក់ផងដែរ ( មាត្រា ៣ និង ១១) ។

*ឃ. ការសម្របសម្រួលដល់សិទ្ធិក្នុងពេលត្រឡប់មកប្រទេសដើមវិញ*

រដ្ឋជាភាគី គួរធានាថា ស្ត្រីជាកម្មករចំណាកស្រុក ដែលមានបំណងចង់ត្រឡប់មកប្រទេសដើមកំណើតរបស់ខ្លួនវិញ អាចរួចផុតពីការបង្ខិតបង្ខំ និងការបំពាននានា ( មាត្រា ៣) ។

*ង. សេវាសម្រាប់ស្ត្រីជាកម្មករចំណាកស្រុក ក្រោយពីត្រឡប់មកស្រុកកំណើតវិញ*

រដ្ឋជាភាគី គួររៀបចំ ឬត្រួតពិនិត្យមើលការផ្តល់សេវាផ្នែកសេដ្ឋកិច្ចសង្គមកិច្ច ផ្នែកចិត្តសាស្ត្រ និងផ្នែកច្បាប់ឱ្យបាន ទូលំទូលាយ ក្នុងគោលបំណងសម្របសម្រួលដល់ការជួបជុំគ្នាឡើងវិញរបស់ស្ត្រីជាកម្មករចំណាកស្រុកដែលបាន ត្រឡប់មកប្រទេសរបស់ខ្លួនវិញ។ រដ្ឋទាំងនោះ គួរពិនិត្យតាមដានអ្នកផ្តល់សេវា ដើម្បីធានាថាអ្នកទាំងនោះ មិន ទាញយកផលប្រយោជន៍ពីស្ថានភាពងាយរងគ្រោះរបស់ស្ត្រីដែលត្រឡប់មកពីធ្វើការនៅបរទេសវិញឡើយ ហើយ រដ្ឋទាំងនោះ គួររៀបចំឱ្យមានយន្តការប្តឹងតវ៉ា ដើម្បីការពារស្ត្រីជាកម្មករចំណាកស្រុក ពីការបង្ករបួសស្នាមដោយ ភ្នាក់ងារជ្រើសរើសពលករ និយោជក ឬអតីតស្វាមីរបស់ស្ត្រីជាកម្មករចំណាកស្រុក ( មាត្រា ៣ និង ២គ) ។

*ញ. ការការពារពីមន្ត្រីការទូត និងមន្ត្រីកុងស៊ុល*

រដ្ឋជាភាគី ត្រូវបណ្តុះបណ្តាល និងត្រួតពិនិត្យលើមន្ត្រីការទូត និងមន្ត្រីកុងស៊ុលរបស់ខ្លួនឱ្យបានសមស្រប ដើម្បីធានា ថាមន្ត្រីទាំងនោះ បានបំពេញតួនាទីរបស់ខ្លួន ក្នុងការការពារដល់សិទ្ធិរបស់ស្ត្រីជាកម្មករចំណាកស្រុកដែលធ្វើការនៅ បរទេស។ ការការពារទាំងនោះ គួររួមបញ្ចូលទាំងសេវាគាំទ្រប្រកបដោយគុណភាពសម្រាប់ស្ត្រីជាកម្មករចំណាក ស្រុក ដូចជា ការផ្តល់អ្នកបកប្រែផ្ទាល់ ការថែទាំសុខភាព និងការផ្តល់ប្រឹក្សាបានទាន់ពេលវេលា រួមទាំងជំនួយផ្នែក ច្បាប់ និងទីជម្រក

ផងដែរនៅពេលចាំបាច់។ ប្រសិនបើរដ្ឋជាភាគីមានកាតព្វកិច្ចជាក់លាក់ ដូចមានចែងក្នុងច្បាប់ ឬសន្ធិសញ្ញាអន្តរជាតិដែលយកមកអនុវត្តតាមទម្លាប់

ដូចជាអនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងរបស់មន្ត្រីកុងស៊ុល ជាដើម កាតព្វកិច្ចទាំងនោះ ត្រូវអនុវត្ត ដោយមានទំនាក់ទំនងផ្ទាល់ជាមួយស្ត្រីជាកម្មករចំណាកស្រុក (មាត្រា ៣)។

២៥. <u>ការទទួលខុសត្រូវជាក់លាក់របស់ប្រទេសដែលស្ត្រីជាកម្មករចំណាកស្រុកឆ្លងកាត់</u>

រដ្ឋជាភាគី គួរចាត់វិធានការជាជំហានៗ ដើម្បីធានាថា ដែនដីរបស់ខ្លួនដែលស្ត្រីជាកម្មករចំណាកស្រុកធ្វើដំណើរឆ្លងកាត់ មិនត្រូវប្រើសម្រាប់សម្របសម្រួលដល់ការរំលោភសិទ្ធិរបស់ស្ត្រីជាកម្មករចំណាកស្រុកឡើយ។ វិធានការចាំបាច់ដែលរដ្ឋ ទាំងនោះយកមកអនុវត្ត មានដូចខាងក្រោម ប៉ុន្តែមិនកំណត់តែទៅលើ :

*ក. ការបណ្តុះបណ្តាល ការពិនិត្យតាមដាន និងការគ្រប់គ្រងស្ថាប័នរដ្ឋាភិបាល*

រដ្ឋជាភាគី គួរធានាថា ប៉ូលីសការពារព្រំដែន និងមន្ត្រីអន្តោប្រវេសន៍របស់ប្រទេសខ្លួន បានទទួលការបណ្តុះបណ្តាល ការគ្រប់គ្រង និងពិនិត្យតាមដានបានសមរម្យ សម្រាប់ការអនុវត្តការងារទាក់ទងនឹងការឆ្លើយតបយេនឌ័រ និងមិនមានការរើសអើងចំពោះស្ត្រីជាកម្មករចំណាកស្រុកនៅពេលដោះស្រាយបញ្ហាដែលកើតមាន (មាត្រា ២ឃ)។

*ខ. ការការពារប្រឆាំងនឹងការរំលោភសិទ្ធិរបស់ស្ត្រីជាកម្មករចំណាកស្រុក ដែលកើតឡើងក្រោមដែនសមត្ថកិច្ចរបស់រដ្ឋ ទាំងនោះ :*

រដ្ឋជាភាគី គួរចាត់វិធានការយ៉ាងសកម្ម ដើម្បីបង្ការ កាត់ទោស និងដាក់ទណ្ឌកម្មដល់ការរំលោភសិទ្ធិមនុស្សពាក់ព័ន្ធ នឹងការធ្វើចំណាកស្រុកទាំងអស់ដែលកើតឡើងក្រោមដែនសមត្ថកិច្ចរបស់ខ្លួន មិនថាការរំលោភទាំងនោះ ធ្វើឡើង ដោយមន្ត្រីក្នុងស្ថាប័នសាធារណៈ ឬភាគីឯកជនឡើយ។ រដ្ឋជាភាគី គួរផ្តល់ ឬសម្របសម្រួលដល់ការផ្តល់សេវា និង ជំនួយនានា ក្នុងស្ថានភាពដែលស្ត្រីជាកម្មករចំណាកស្រុក ត្រូវភ្នាក់ងារជ្រើសរើសពលករ ឬអ្នករួមដំណើរ បោះបង់ចោល ហើយព្យាយាមស៊ើបអង្កេតរកមើលជនប្រព្រឹត្តិអំពើទាំងនោះ ព្រមទាំងចាត់វិធានការស្រប ច្បាប់ចំពោះជនទាំង នោះ (មាត្រា ២គ និង ២ង)។

២៦. <u>ការទទួលខុសត្រូវជាក់លាក់របស់ប្រទេសគោលដៅ</u>

រដ្ឋជាភាគី ក្នុងប្រទេសដែលស្ត្រីជាកម្មករចំណាកស្រុកទៅធ្វើការ គួរចាត់វិធានការសមស្រប ដើម្បីធានាមិនឱ្យមានការរើស អើងចំពោះស្ត្រីជាកម្មករចំណាកស្រុក និងធានានូវសិទ្ធិស្មើគ្នាចំពោះស្ត្រី រាប់បញ្ចូល

ទាំងនៅក្នុងសហគមន៍ផ្ទាល់របស់រដ្ឋទាំង នោះផងដែរ។ ខាងក្រោមនេះ ជាវិធានការចាំបាច់ដែលរដ្ឋទាំងនោះ យកមកអនុវត្ត ប៉ុន្តែមិនកំណត់តែទៅលើ :

*ក. ការលុបចោលនូវបម្រាម ឬការដាក់កំហិតមិនឱ្យមានការរើសអើងចំពោះការធ្វើអន្តោប្រវេសន៍ :*

រដ្ឋជាភាគី គួរលុបចោលនូវបម្រាម និងការដាក់កំហិតមិនឱ្យមានការរើសអើងចំពោះការធ្វើអន្តោប្រវេសន៍របស់ស្ត្រី ជាដាច់ខាត។ រដ្ឋជាភាគីទាំងនោះ គួរធានាថា កម្មវិធីផ្តល់ទិដ្ឋាការរបស់ខ្លួន មិនមានការរើសអើងដោយប្រយោល ចំពោះស្ត្រី ដោយដាក់កម្រិតមិនអនុញ្ញាតឱ្យស្ត្រីធ្វើការងារមួយចំនួន ដែលសម្បូរដោយបុរស ឬមិនដាក់បញ្ចូលការងារ មួយចំនួនដែលសម្បូរដោយស្ត្រី ទៅក្នុងកម្មវិធីផ្តល់ទិដ្ឋាការរបស់ខ្លួនឡើយ។ លើសពីនេះទៀត រដ្ឋទាំងនោះ គួរលុប ចោលនូវបម្រាមមិនឱ្យស្ត្រីជាកម្មករចំណាកស្រុករៀបការជាមួយជនជាតិរបស់ខ្លួន ឬប្រជាជនដែលរស់នៅអចិន្ត្រៃយ៍ ក្នុងប្រទេសរបស់ខ្លួន ដើម្បីទទួលបានសិទ្ធិរស់នៅអចិន្ត្រៃយ៍ ឬដើម្បីធានានូវការស្នាក់នៅដោយឯករាជ្យឡើយ (មាត្រា ២ច)។

*ខ. ការការពារស្របច្បាប់ដល់សិទ្ធិរបស់ស្ត្រីជាកម្មករចំណាកស្រុក*

រដ្ឋជាភាគី គួរធានាថា ច្បាប់រដ្ឋធម្មនុញ្ញ ច្បាប់រដ្ឋប្បវេណី និងច្បាប់ការងារ ផ្តល់សិទ្ធិដូចៗគ្នាក្នុងការរៀបចំ និងបង្កើត សមាគមដោយសេរីដល់ស្ត្រីជាកម្មករចំណាកស្រុក និងកម្មករទាំងអស់នៅប្រទេសរបស់ខ្លួន។ រដ្ឋទាំងនោះ គួរធានាថា កិច្ចសន្យាការងារ សម្រាប់ស្ត្រីជាកម្មករចំណាក់ស្រុក មានសុពលភាពដោយស្របច្បាប់។ ជាពិសេស រដ្ឋទាំងនោះ គួរធានាថា ច្បាប់ការងារ បទប្បញ្ញត្តិស្តីពីប្រាក់ឈ្នួល និងម៉ោងធ្វើការ ច្បាប់ការពារសុខភាព និងសុវត្ថិភាព និងបទប្បញ្ញត្តិផ្តល់ច្បាប់ឈប់សម្រាក និងថ្ងៃវិសម្សកាល ការពារដល់ការងារដែលភាគច្រើនធ្វើដោយស្ត្រីជាកម្មករចំណាកស្រុក ដូចជា ការងារបម្រើតាមផ្ទះ និងការងារបម្រើការសប្បាយមួយចំនួន។ ច្បាប់ទាំងនេះ គួរដាក់បញ្ចូលទាំង យន្តការសម្រាប់ពិនិត្យតាមដានស្ថានភាពកន្លែងធ្វើការរបស់ស្ត្រីជាកម្មករចំណាកស្រុក ជាពិសេសក្នុងប្រភេទការងារ ដែលភាគច្រើនធ្វើដោយស្ត្រី (មាត្រា ២ក, ២ច និង ១១)។

*គ. ការទទួលបានដំណោះស្រាយ*

រដ្ឋជាភាគី គួរធានាថា ស្ត្រីជាកម្មករចំណាកស្រុក មានលទ្ធភាពទទួលបានដំណោះស្រាយ នៅពេលសិទ្ធិរបស់ស្ត្រីទាំង នោះត្រូវបានគេរំលោភបំពាន។ ខាងក្រោមនេះ ជាវិធានការជាក់លាក់ដែលរដ្ឋជាភាគីយកមកអនុវត្ត ប៉ុន្តែមិនកំណត់ តែទោលើ : (មាត្រា២គ ២ច និង៣)

(i) ប្រកាសឱ្យប្រើប្រាស់ និងអនុវត្តច្បាប់ និងបទប្បញ្ញត្តិ ដែលរាប់បញ្ចូលទាំងដំណោះស្រាយតាមផ្លូវច្បាប់ និងយន្ត ការប្តឹងផ្តល់ ហើយដាក់យន្តការដោះស្រាយជម្លោះទាំងនោះ ឱ្យត្រូវចំកន្លែងដែលអាចឱ្យស្ត្រីជាកម្មករចំណាក ស្រុកងាយស្រួលទទួលបាន ដើម្បីការពារស្ត្រីជាកម្មករចំណាកស្រុកដែលមានឯកសារ និងមិនមានឯកសារ បញ្ជាក់ត្រឹមត្រូវ ពីការរើសអើង ឬការកេងប្រវ័ញ្ច និងការបំពានទាក់ទងនឹងភេទ។

(ii) លុបចោល ឬធ្វើវិសោធនកម្មច្បាប់ដែលរារាំងស្ត្រីជាកម្មករចំណាកស្រុកពីការប្រើប្រាស់ប្រព័ន្ធតុលាការ និង ប្រព័ន្ធផ្សេងទៀត ក្នុងការដោះស្រាយបញ្ហារបស់ស្ត្រី។ បញ្ហាទាំងនេះ រាប់បញ្ចូលទាំងការបាត់បង់លិខិតអនុញ្ញាត ឱ្យបម្រើការងារដែលធ្វើឱ្យស្ត្រី ត្រូវបាត់បង់ប្រាក់ចំណូល និងអាចត្រូវមន្ត្រីអន្តោប្រវេសន៍និរទេសចេញពីប្រទេស នៅពេលកម្មករម្នាក់ដាក់ពាក្យបណ្តឹងអំពី ការកេងប្រវ័ញ្ច ឬការបំពានមកលើខ្លួន ហើយដែលពាក្យបណ្តឹងនោះ កំពុងបន្តការតាមដានស៊ើបអង្កេត។ រដ្ឋជាភាគី គួរបង្ហាញពីភាពអាច់បត់បែនក្នុងដំណើរការផ្លាស់ប្តូរ និយោជក ឬអ្នកឧបត្ថម្ភ ដោយមិនមានការនិរទេសខ្លួន ក្នុងករណីដែលកម្មករប្តឹងអំពីការបំពានមកលើខ្លួន។

(iii) ធានាថា ស្ត្រីជាកម្មករចំណាកស្រុក ទទួលបានជំនួយផ្នែកច្បាប់ និងលទ្ធភាពប្រើប្រាស់ប្រព័ន្ធតុលាការ និងប្រព័ន្ធបទប្បញ្ញត្តិដែលទទួលបន្ទុកលើការពង្រឹងច្បាប់ការងារ រាប់បញ្ចូលទាំងជំនួយផ្នែកច្បាប់ ដោយឥតគិតថ្លៃ។

(iv) ផ្តល់ទីជម្រកបណ្តោះអាសន្នដល់ស្ត្រីជាកម្មករចំណាកស្រុក ដែលមានបំណងចង់ចាកចេញពីនិយោជក ស្វាមី ឬ សាច់ញាតិផ្សេងទៀត ដែលបំពានមកលើខ្លួន ព្រមទាំងផ្តល់អគារស្នាក់នៅប្រកបដោយសុវត្ថិភាពក្នុងអំឡុង ពេលកាត់ទោស។

ឃ. *ការការពារដោយស្របច្បាប់សម្រាប់សេរីភាពក្នុងការផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត*

រដ្ឋជាភាគី គួរធានាថា និយោជក និងភ្នាក់ងារជ្រើសរើសពលករ មិនត្រូវរឹបអូស ឬបំផ្លាញឯកសារសម្រាប់ធ្វើដំណើរ ឬឯកសារសម្រាប់បញ្ជាក់ពីអត្តសញ្ញាណរបស់ស្ត្រីជាកម្មករចំណាកស្រុកឡើយ។ រដ្ឋជាភាគី គួរចាត់វិធានការជា ជំហានៗ ដើម្បីបញ្ឈប់លែងឱ្យមានការបង្ខិតបង្ខំស្ត្រីជាកម្មករចំណាកស្រុក ជាពិសេស ស្ត្រីដែលបម្រើការងារតាមផ្ទះ ឱ្យស្ថិតនៅដាច់ពីគេ ឬចាក់សោទុកក្នុងផ្ទះឡើយ។ មន្ត្រីនគរបាល គួរទទួលបានការបណ្តុះបណ្តាល ដើម្បីការពារសិទ្ធិរបស់ស្ត្រីជាកម្មករចំណាកស្រុក ពីការបំពានទាំងនេះ ( មាត្រា ២ង)។

ង. *កម្មវិធីជួបជុំគ្រួសារឡើងវិញ ដោយមិនមានការរើសអើង*

រដ្ឋជាភាគី គួរធានាថា កម្មវិធីជួបជុំគ្រួសារឡើងវិញសម្រាប់កម្មករចំណាកស្រុក មិនមានការរើងអើងទាក់ទងនឹងភេទ ដោយផ្ទាល់ ឬដោយប្រយោលឡើយ ( មាត្រា ២ច) ។

ច. *បទប្បញ្ញត្តិស្នាក់នៅដោយមិនមានការរើសអើង*

ទោះបីជាលិខិតអនុញ្ញាតឱ្យស្នាក់នៅ មានបញ្ជាក់ថា ស្ត្រីជាកម្មករចំណាកស្រុក អាចស្នាក់នៅដោយមានការឧបត្ថម្ភ ពីនិយោជក ឬស្វាមីក៏ដោយ ប៉ុន្តែរដ្ឋជាភាគី គួរដាក់ចេញបទប្បបញ្ញត្តិទាក់ទងនឹងស្ថានភាពស្នាក់នៅដោយឯករាជ្យ របស់ស្ត្រីជាកម្មករចំណាកស្រុក។ បទប្បបញ្ញត្តិទាំងនោះ គួរអនុញ្ញាតឱ្យស្ត្រីដែលរត់គេចពីនិយោជក ឬស្វាមីដែល បំពានមកលើរូបខ្លួន ឬស្ត្រីដែលត្រូវបណ្តេញចេញពីផ្ទះ ដោយសារតែស្ត្រី ដាក់ពាក្យបណ្តឹងពីការបំពានពីសំណាក់ និយោជក ឬស្វាមីរបស់ស្ត្រី ស្នាក់នៅដោយស្របច្បាប់ ( មាត្រា ២ច) ។

ឆ. *ការបណ្តុះបណ្តាល និងការលើកកម្ពស់ការយល់ដឹង*

រដ្ឋជាភាគី គួរផ្តល់កម្មវិធីលើកកម្ពស់ការយល់ដឹងជាកាតព្វកិច្ច ទាក់ទងនឹងសិទ្ធិរបស់ស្ត្រីជាកម្មករចំណាកស្រុក និង ការបណ្តុះបណ្តាលស្តីពីរំញោចយេនឌ័រ ដល់ស្ថាប័នរដ្ឋ និងទីភ្នាក់ងារជ្រើសរើសពលករឯកជន រួមទាំងនិយោជក និង បុគ្គលិករដ្ឋពាក់ព័ន្ធនានា ដូចជា មន្ត្រីយុត្តិធម៌ព្រហ្មទណ្ឌ ប៉ូលីសការពារព្រំដែន មន្ត្រីអន្តោប្រវេសន៍ អ្នកផ្តល់សេវា សង្គម និងសេវាថែទាំសុខភាព ( មាត្រា ៣) ។

ជ. *ប្រព័ន្ធពិនិត្យតាមដាន*

រដ្ឋជាភាគី គួរអនុម័តបទប្បបញ្ញត្តិ និងរៀបចំប្រព័ន្ធពិនិត្យតាមដាន ដើម្បីធានាថា ភ្នាក់ងារជ្រើសរើសពលករ និង និយោជក គោរពដល់សិទ្ធិរបស់ស្ត្រីជាកម្មករចំណាកស្រុកទាំងអស់។ រដ្ឋជាភាគី គួរពិនិត្យតាមដានទីភ្នាក់ងារជ្រើស រើសពលករឱ្យបានជិតស្និទ្ធ និងដាក់ទោសទីភ្នាក់ងារទាំងនោះ ចំពោះការប្រព្រឹត្តិអំពើហិង្សា ការបង្ខិតបង្ខំ ការបោកបញ្ឆោត ឬការកេងប្រវ័ញ្ចដល់ស្ត្រីជាកម្មករចំណាកស្រុក ( មាត្រា ២ង) ។

ឈ. *ការទទួលបានសេវានានា*

រដ្ឋជាភាគីគួរធានាថា ស្ត្រីជាកម្មករចំណាកស្រុក អាចទទួលបានសេវារំញោចយេនឌ័រដែលសមស្របនឹងភាសា និង វប្បធម៌របស់ខ្លួន។ សេវាទាំងនោះ រាប់បញ្ចូលទាំងកម្មវិធីបណ្តុះបណ្តាលភាសា និងជំនាញ ទីជម្រកសម្រាប់កាលៈ ទេសៈបន្ទាន់ សេវាថែទាំសុខភាព សេវាយាមល្បាត កម្មវិធីដើរលំហែ និងកម្មវិធីដែលរៀបចំឡើងជាពិសេស សម្រាប់ស្ត្រីជាកម្មករចំណាកស្រុក

ដែលស្ថិតនៅដាច់ពីគេ ដូចជា កម្មករបម្រើការងារតាមផ្ទះ និងកម្មករដែលឃុំខ្លួន តែក្នុងផ្ទះមិនអាចទៅណាបាន រួមទាំងជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារផងដែរ។ ជនរងគ្រោះដោយការបំពាន ត្រូវទទួលបានការសង្គ្រោះបន្ទាន់ និងសេវាសង្គមដែលពាក់ព័ន្ធ ដោយមិនគិតទៅលើស្ថានភាពអន្តោប្រវេសន៍ របស់ខ្លួនឡើយ (មាត្រា ៣, ៥ និង ១២)។

៧. *សិទ្ធិរបស់ស្ត្រីជាកម្មករចំណាកស្រុកដែលត្រូវឃុំខ្លួន មិនថាស្ត្រីនោះមានឯកសារ ឬមិនមានឯកសារបញ្ជាក់ត្រឹមត្រូវ*

រដ្ឋជាភាគី គួរធានាថា ស្ត្រីជាកម្មករចំណាកស្រុក ដែលត្រូវឃុំខ្លួន មិនទទួលរងនូវការរើសអើង ឬអំពើហិង្សាទាក់ទង នឹងយេនឌ័រទេ ហើយម្តាយដែលកំពុងមានគភ៌ និងបំបៅកូនដោយទឹកដោះ រួមទាំងស្ត្រីដែលកំពុងមានជំងឺ ត្រូវទទួល បានសេវាសមស្រប។ រដ្ឋទាំងនោះ គួរពិនិត្យវាយតម្លៃ លុបបំបាត់ ឬធ្វើកំណែទម្រង់ច្បាប់ បទប្បញ្ញត្តិ ឬគោលនយោបាយ ដែលនាំឱ្យស្ត្រីជាប់ឃុំឃាំង ដោយសារហេតុផលទាក់ទងនឹងការធ្វើចំណាកស្រុក មានចំនួនមិនសមាមាត្រគ្នា (មាត្រា ២ឃ និង៥)។

៨. *ការចូលរួមរបស់ស្ត្រីជាកម្មករចំណាកស្រុកក្នុងសង្គម*

រដ្ឋជាភាគី គួរអនុម័តគោលនយោបាយ និងកម្មវិធី ដែលមានគោលបំណងអាចជំរុញឱ្យស្ត្រីជាកម្មករចំណាកស្រុកចូលរួមក្នុងសង្គមថ្មី។ ការខិតខំប្រឹងប្រែងទាំងនោះ គួរគោរពដល់អត្តសញ្ញាណវប្បធម៌របស់ស្ត្រីជាកម្មករចំណាកស្រុក និង ការពារដល់សិទ្ធិស្ត្រី ស្របតាមអនុសញ្ញាស្តីពីការលុបបំបាត់ការរើសអើងរាល់ទម្រង់នៃការរើស អើងប្រឆាំងនឹងនារី ភេទ (មាត្រា ៥)។

៩. *ការការពារស្ត្រីជាកម្មករចំណាកស្រុក ដែលមិនមានឯកសារបញ្ជាក់ត្រឹមត្រូវ*

ស្ថានភាពរបស់ស្ត្រីជាកម្មករចំណាកស្រុកដែលមានឯកសារបញ្ជាក់ត្រឹមត្រូវ ទាមទារឱ្យមានការយកចិត្តទុកដាក់ជាក់លាក់។ រដ្ឋជាភាគី ត្រូវមានកាតព្វកិច្ចការពារសិទ្ធិជាមូលដ្ឋាន របស់ស្ត្រីជាកម្មករចំណាកស្រុក ដោយមិនគិតពីកង្វះ ស្ថានភាពអន្តោប្រវេសន៍របស់ស្ត្រីឡើយ។ ស្ត្រីជាកម្មករចំណាកស្រុកដែលមិនមានឯកសារបញ្ជាក់ត្រឹមត្រូវ ត្រូវទទួលបានការដោះស្រាយដោយស្របច្បាប់ និងយុត្តិធម៌ ក្នុងករណីដែលស្ត្រី ត្រូវប្រឈមនឹងគ្រោះថ្នាក់ដល់ជីវិត ឬការធ្វើ ទុក្ខបុកម្នេញ និងការបង្ខូចកិត្តិយសរបស់ខ្លួន ឬក្នុងករណីដែលស្ត្រី ត្រូវបណ្តេញចេញ ពីការងារដោយបង្ខំ ទទួលបានតម្រូវការជាមូលដ្ឋានមិនបានគ្រប់គ្រាន់ រួមបញ្ចូលទាំងការសង្គ្រោះសុខភាពជាបន្ទាន់ ឬការមានគភ៌ និង មាតុភាពឱ្យបានទាន់ពេលវេលា ឬប្រសិនបើស្ត្រី ទទួលរងនូវការបំពានលើរាងកាយ និងផ្លូវភេទ ពីសំណាក់និយោជក ឬអ្នកដទៃ។ ប្រសិនបើស្ត្រីជាកម្មករ ចំណាកស្រុកដែលមិនមាន

ឯកសារបញ្ជាក់គ្រប់គ្រាន់ ត្រូវចាប់ខ្លួន ឬឃុំខ្លួន រដ្ឋជាភាគី ត្រូវធានាថា ស្ត្រីទទួលបានការយកចិត្តទុកដាក់ប្រកបដោយមនុស្សធម៌ និងទទួលបាននីតិវិធីត្រឹមត្រូវ ស្របច្បាប់ រាប់បញ្ចូលទាំងជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃផងដែរ។ ក្នុងន័យនេះ រដ្ឋជាភាគី គួរលុបចោល ឬធ្វើ វិសោធនកម្មច្បាប់ និងការអនុវត្តនានា ដែលរារាំងស្ត្រីជាកម្មករចំណាកស្រុកដែលមិនមាន ឯកសារបញ្ជាក់ត្រឹមត្រូវ មិនឱ្យទទួលបានការប្រើប្រាស់ប្រព័ន្ធតុលាការ ឬប្រព័ន្ធផ្សេងទៀតក្នុងការដោះស្រាយបញ្ហាដែលខ្លួនប្រឈម។ ប្រសិនបើស្ត្រី មិនអាចជៀសវាងពីការនិរទេសបាន រដ្ឋជាភាគីចាំបាច់ត្រូវចាត់ទុកករណីនីមួយៗ ដាច់ដោយឡែកពីគ្នា ដោយពិចារណាយ៉ាងយកចិត្តទុកដាក់លើកាលៈទេសៈទាក់ទងនឹងយេនឌ័រ និងការប្រឈមនឹង ការរំលោភបំពានសិទ្ធិ មនុស្សនៅប្រទេសដើមកំណើត( មាត្រា ២គ ២ច និង ២ង)។

២៧. <u>កិច្ចសហប្រតិបត្តិការទ្វេភាគី និងតាមតំបន់</u>

វិធានការដែលត្រូវយកមកអនុវត្តមានដូចខាងក្រោម ប៉ុន្តែមិនមែនកំណត់តែទៅលើ :

*ក. កិច្ចព្រមព្រៀងទ្វេភាគី និងតាមតំបន់*

រដ្ឋជាភាគី ដែលជាប្រទេសបញ្ជូន ប្រទេសទទួល និងប្រទេសឆ្លងកាត់ គួរអនុម័តកិច្ចព្រមព្រៀងទ្វេភាគី ឬតាមតំបន់ ឬ អនុស្សរណៈយោគយល់ ដើម្បីការពារដល់សិទ្ធិរបស់ស្ត្រីជាកម្មករចំណាកស្រុក ដូចមានពន្យល់ក្នុងអនុសាសន៍ទូទៅនេះ ( មាត្រា ៣)។

*ខ. ការអនុវត្តដ៏ប្រសើរបំផុត និងការចែករំលែកព័ត៌មាន*

(i) រដ្ឋជាភាគី ទទួលបានការលើកទឹកចិត្តឱ្យចែករំលែកបទពិសោធនៃការអនុវត្តដ៏ប្រសើរបំផុតរបស់ខ្លួន និងព័ត៌មានពាក់ព័ន្ធនានា ដើម្បីលើកកម្ពស់ការការពារសិទ្ធិរបស់ស្ត្រីជាកម្មករចំណាកស្រុកឱ្យបានពេញលេញ ( មាត្រា ៣)។

(ii) រដ្ឋជាភាគី

គួរសហការគ្នាផ្តល់ព័ត៌មានស្តីពីជនរំលោភបំពានសិទ្ធិរបស់ស្ត្រីជាកម្មករចំណាកស្រុក។ រដ្ឋជាភាគី គួរចាត់វិធានការស៊ើបអង្កេត កាត់ទោស និងដាក់ទណ្ឌកម្មជនរំលោភបំពានសិទ្ធិរបស់ស្ត្រីជាកម្មករចំណាកស្រុក នៅពេលរដ្ឋទាំងនោះទទួលបានព័ត៌មានទាក់ទងនឹងជនទាំងនោះនៅក្នុងទឹកដីរបស់ខ្លួនរួចហើយ។

២៨. <u>អនុសាសន៍ទាក់ទងនឹងការពិនិត្យតាមដាន និងការរាយការណ៍</u>

រដ្ឋជាភាគី គួរដាក់បញ្ចូលព័ត៌មានស្តីពីក្របខ័ណ្ឌច្បាប់ គោលនយោបាយ និងកម្មវិធីដែលរដ្ឋទាំងនោះបានអនុវត្ត ដើម្បីការពារសិទ្ធិរបស់ស្ត្រីជាកម្មករចំណាកស្រុក ទៅក្នុងរបាយការណ៍របស់ខ្លួន ដោយ

ពិចារណាទៅលើកង្វល់ស្តីពីសិទ្ធិមនុស្ស ទាក់ទងនឹងភេទ និងយេនឌ័រ ដូចមានចែងនៅក្នុងកថាខណ្ឌទី ១០-២២ និងការផ្តល់អនុសាសន៍ជាច្រើនលើកង្វល់ទាំងនោះ ដូចមានបង្ហាញនៅក្នុងកថាខណ្ឌទី ២៣-២៧ ក្នុងអនុសាសន៍ទូទៅនេះ។ ទិន្នន័យស្តីពីការពង្រឹង និងការអនុវត្តច្បាប់ គោល នយោបាយ និងកម្មវិធីជាច្រើន ព្រមទាំងស្ថានភាព*ជាក់ស្តែង*របស់ស្ត្រីជាកម្មករចំណាកស្រុក គួរប្រមូលឱ្យបាន គ្រប់គ្រាន់ ដើម្បីឱ្យព័ត៌មាននៅក្នុងរបាយការណ៍នានា មានខ្លឹមសារប្រកបដោយអត្ថន័យ។ ព័ត៌មានដែល ទទួលបាន គួរទាក់ទងនឹង មាត្រាភាគច្រើន ដែលសមស្របនឹងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ សម្រាប់ ការផ្តល់យោបល់ដល់អនុសាសន៍ទាំងអស់។

២៩. <u>ការផ្តល់សច្ចាប័ន ឬការទទួលបានសន្ធិសញ្ញានានាទាក់ទងនឹងសិទ្ធិមនុស្ស</u>

រដ្ឋជាភាគី ទទួលបានការលើកទឹកចិត្តឱ្យផ្តល់សច្ចាប័នលើលិខិតូបករណ៍អន្តរជាតិទាំងអស់ ដែលពាក់ព័ន្ធ នឹងការការពារសិទ្ធិ មនុស្សរបស់ស្ត្រីជាកម្មករចំណាកស្រុក ជាពិសេសអនុសញ្ញាអន្តរជាតិ ស្តីពីការ ការពារសិទ្ធិរបស់ជនចំណាកស្រុក និង សមាជិកគ្រួសាររបស់កម្មករចំណាកស្រុក។

---

[i] គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ទទួលស្គាល់នូវការរួមចំណែករបស់គណៈកម្មាធិការទទួលបន្ទុកសិទ្ធិរបស់កម្មករចំណាក ស្រុកទាំងអស់ និងសិទ្ធិសមាជិកគ្រួសារកម្មករចំណាកស្រុក ក្នុងអំឡុងពេលរៀបចំអនុសាសន៍ទូទៅនេះ។

[ii] គណៈកម្មាធិការ CEDAW ទទួលស្គាល់ និងព្យាយាមបង្កើតការងារសំខាន់ទាក់ទងនឹងសិទ្ធិរបស់ជនចំណាកស្រុក ដែលបានបញ្ចប់ដោយស្ថាប័នសន្ធិសញ្ញាសិទ្ធិ មនុស្សផ្សេងទៀត អ្នកសរសេររបាយការណ៍ពិសេសទាក់ទងនឹងសិទ្ធិមនុស្សរបស់ជនចំណាកស្រុក អង្គការមូលនិធិអភិវឌ្ឍន៍ដើម្បីស្ត្រីរបស់អង្គការសហប្រជាជាតិ អង្គភាពអភិវឌ្ឍន៍ស្ត្រី គណៈកម្មការទទួលបន្ទុកលើស្ថានភាពរបស់ស្ត្រី មហាសន្និបាត និងអនុគណៈកម្មការទទួលបន្ទុកលើការការពារ និងលើកកម្ពស់សិទ្ធិ មនុស្ស។ ម្យ៉ាងវិញទៀត គណៈកម្មាធិការ CEDAW សំដៅទៅលើអនុសាសន៍ដំបូងរបស់ខ្លួន រួមមានដូចជា អនុសាសន៍ទូទៅទី ៩ ស្តីពីការប្រមូលទិន្នន័យស្ថិតិ ទាក់ទងនឹងស្ថានភាពរបស់ស្ត្រី អនុសាសន៍ទូទៅ ជាពិសេសអនុសាសន៍ទូទៅទី ១២ ស្តីពីអំពើហិង្សាលើស្ត្រី អនុសាសន៍ទី ១៣ ស្តីពីការទទួលបានប្រាក់កម្រៃ ស្មើគ្នា ចំពោះការងារដែលមានតម្លៃស្មើគ្នា អនុសាសន៍ទូទៅទី ១៥ ស្តីពីការបញ្ចៀសការរើសអើងប្រឆាំងនឹងនារីភេទ នៅក្នុងយុទ្ធសាស្ត្រជាតិ សម្រាប់ការបង្ការ និងការគ្រប់គ្រងជំងឺអេដស៍ អនុសាសន៍ទូទៅទី ១៩ ស្តីពីអំពើហិង្សាលើស្ត្រី អនុសាសន៍ទូទៅទី ២៤ ស្តីពីលទ្ធភាពរបស់ស្ត្រី ក្នុងការទទួលបានការថែទាំសុខភាព រួមទាំងយោបល់រួមរបស់គណៈកម្មាធិការ CEDAW នៅពេលត្រួតពិនិត្យមើលរបាយការណ៍របស់រដ្ឋជាភាគី។

[iii] ក្រៅពីសន្ធិសញ្ញា និងអនុសញ្ញាជាច្រើន កម្មវិធី និងផែនការសកម្មភាពជាបន្តបន្ទាប់ ក៏មានលក្ខណៈសមស្របសម្រាប់យកមកអនុវត្តដែរ។ សេចក្តីថ្លែងការណ៍ និងកម្មវិធីសកម្មភាពរបស់អង្គការសហប្រជាជាតិនៅទីក្រុងវីយែន ត្រូវបានអនុម័តនៅក្នុងសន្និសីទពិភពលោកកាលពីឆ្នាំ១៩៩៣ ស្តីពីសិទ្ធិមនុស្ស និងកម្មវិធី សកម្មភាព (ផ្នែកទី២ កថាខណ្ឌទី ៣៣ ដល់ ៣៥)។ ផែនការសកម្មភាពនៃសន្និសីទអន្តរជាតិនៅទីក្រុងឡឺគែរ ស្តីពីប្រជាជន និងការអភិវឌ្ឍ (ជំពូកទី ១០)។ កម្មវិធីសកម្មភាពរបស់ជំនួបកំពូលពិភពលោកសម្រាប់ការអភិវឌ្ឍសង្គម (ជំពូកទី ៣)។ សេចក្តីថ្លែងការណ៍ និងគោលនយោបាយសកម្មភាពទីក្រុងប៉េកាំង សន្និសីទពិភពលោកលើកទី ៤ ស្តីពីសន្និសីទពិភពលោកសម្រាប់ស្ត្រី ដើម្បីប្រឆាំងនឹងការប្រកាន់ពូជសាសន៍ ការរើសអើង ការស្អប់ខ្ពើមជនបរទេស និង កង្វះភាពអត់ធ្មត់ដែលពាក់ព័ន្ធនានា កាលពីខែសីហា ឆ្នាំ២០០១។ ផែនការសកម្មភាពរបស់ ILO សម្រាប់កម្មករចំណាកស្រុក ឆ្នាំ២០០៤។

[iv] អនុសាសន៍ទូទៅនេះ ជាប់ទាក់ទងទៅនឹងការងារនានាដែលពាក់ព័ន្ធទៅនឹងស្ថានភាពរបស់ស្ត្រីជាកម្មករចំណាកស្រុក។ ទោះបីជាការពិតជាក់ស្តែងបង្ហាញថា ស្ត្រី កម្មករចំណាកស្រុក អាចក្លាយជាជនរងគ្រោះពីការជួញដូរ ដោយការប្រឈមនឹងភាពងាយរងគ្រោះក្នុងកម្រិតផ្សេងៗគ្នាក៏ដោយ ប៉ុន្តែអនុសាសន៍ទូទៅនេះ មិន បានដោះស្រាយស្ថានភាពទាក់ទងទៅនឹងការជួញដូរមនុស្សឡើយ។ បាតុភូតនៃការជួញដូរមនុស្ស ជាបញ្ហាធ្ងន់ធ្ងរ ហើយតម្រូវឱ្យមានការយកចិត្តទុកដាក់កាន់តែ ច្រើន។ គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ អាចមានជម្រើសសម្រាប់ដោះស្រាយបាតុភូតនេះ បានកាន់តែទូលំទូលាយ តាមរយៈមាត្រា ៦ នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ដែលដាក់កាតព្វកិច្ចដល់រដ្ឋជាភាគី "ឱ្យចាត់វិធានការសម ស្របទាំងអស់ រាប់បញ្ចូលទាំងច្បាប់ដើម្បីបង្ក្រាបរាល់ទម្រង់នៃការជួញដូរស្ត្រី និងការកេងប្រវ័ញ្ចស្ត្រីឱ្យធ្វើជាស្ត្រីរកស៊ីផ្លូវភេទ"។ ទោះបីជាយ៉ាងនេះក្តី គណៈ កម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹនារីភេទ សង្កត់ធ្ងន់ថា សមាសធាតុជាច្រើន នៅក្នុងអនុសាសន៍ទូទៅនាពេលបច្ចុប្បន្ននេះ ក៏មានជាប់ ទាក់ទងនឹងស្ថានភាពដែលស្ត្រីជាកម្មករចំណាកស្រុកក្លាយជាជនរងគ្រោះពីការជួញដូរផងដែរ។

[v] កម្មករដែលមិនមានឯកសារបញ្ជាក់ត្រឹមត្រូវ ជាកម្មករចំណាកស្រុកដែលមិនមានលិខិតអនុញ្ញាតឱ្យស្នាក់នៅ ឬបម្រើការងារដែលមានសុពលភាព។ កាលៈទេសៈ ជាច្រើនទាក់ទងនឹងកម្មករចំណាកស្រុកដែលមិនមានឯកសារបញ្ជាក់ត្រឹមត្រូវ កើតមានឡើងជាច្រើន។ ឧទាហរណ៍ កម្មករចំណាកស្រុក អាចនឹងទទួលបាន លិខិតក្លែងក្លាយពីភ្នាក់ងារអសីលធម៌ជាច្រើន ឬកម្មករទាំងនោះ អាចនឹងបានចូលទៅក្នុងប្រទេសមួយ ដោយមានលិខិតអនុញ្ញាតឱ្យបម្រើការងារដែលមាន សុពល ភាព ប៉ុន្តែអ្នកទាំងនោះ អាចនឹងបាត់បង់លិខិតទាំងនោះវិញ ដោយសារតែនិយោជករបស់កម្មករទាំងនោះ បានបញ្ចប់សេវារបស់ខ្លួន ឬកម្មករទាំងនោះ មិនមាន ឯកសារបញ្ជាក់ត្រឹមត្រូវ ដោយសារតែនិយោជក អាចនឹងរឹបអូសយកលិខិតឆ្លងដែនរបស់អ្នកទាំងនោះ។ ជួនកាល កម្មករចំណាកស្រុក អាចនឹងពន្យារ ពេលស្នាក់នៅរបស់ខ្លួន នៅក្នុងប្រទេសគោលដៅបន្តទៀត បន្ទាប់ពីលិខិតអនុញ្ញាតឱ្យបម្រើការងាររបស់ខ្លួន ផុតកំណត់ ឬដោយសារតែកម្មករទាំងនោះ ចូលទៅក្នុងប្រទេសគោលដៅ ដោយមិនមានឯកសារដែលមានសុពលភាព។

[vi] កថាខណ្ឌទី ១០ និង ១១ ពិពណ៌នាអំពីកង្វល់មួយចំនួន ក្នុងចំណោមកង្វល់នានាអំពីសិទ្ធិមនុស្សទាក់ទងនឹងភេទ និងយេនឌ័រ ដែលស្ត្រីជាច្រើនជួបប្រទះក្នុង ប្រទេសដើមរបស់ខ្លួន មុនពេលធ្វើចំណាកស្រុក និងក្រោយពេលត្រឡប់មកវិញ។ ក្តីកង្វល់ទាក់ទងនឹងប្រទេសដែលកម្មករចំណាកស្រុកឆ្លងកាត់ និងជីវិតនៅ

បរទេស មានពិភាក្សានៅក្នុងកថាខណ្ឌទី ១២-២២។ ផ្នែកទាំងនេះ ត្រូវបានលើកយកមកបង្ហាញ ប៉ុន្តែមិនបានបង្ហាញឱ្យបានលំអិតឡើយ។ តាមការកត់សម្គាល់ កង្វល់មួយចំនួនទាក់ទងនឹងសិទ្ធិមនុស្ស ដែលមានពិពណ៌នានៅទីនេះ អាចនឹងបង្ហាញពីការសម្រេចចិត្តរបស់ស្ត្រីក្នុងការធ្វើចំណាកស្រុកដោយការបង្ខិតបង្ខំ ក្រោមច្បាប់អន្តរជាតិដែលពាក់ព័ន្ធ ហើយក្នុងករណីនេះ ការវាយតម្លៃ គួរធ្វើឡើងចំពោះនិយាមទាំងនេះ។

vii គណៈកម្មការអង្គការសហប្រជាជាតិទទួលបន្ទុកលើសិទ្ធិមនុស្ស។ វិធានការដើម្បីលើកកម្ពស់ស្ថានភាព និងធានាបាននូវសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូររបស់កម្មករចំណាកស្រុកទាំងអស់។ របាយការណ៍របស់អគ្គលេខាធិការដ្ឋានស្តីពីអំពើហិង្សាលើស្ត្រីជាកម្មករចំណាកស្រុក។ E/C/N.4/1998/74/Add/1. ថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៨៨។

viii មាត្រាដែលមានចែងក្នុងអនុសាសន៍នីមួយៗ សំដៅលើមាត្រាក្នុងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ។